# ផ្កាភ្លើងស្នេហ៍

នាងជាក្មេងខ្សៀដែលគេមិនចូលចិត្ត ទើបបុរសមាត់ដាច មហាកំណាច ម្ចាស់ចម្ការតែល្បីឈ្មោះ
កាណែត ឈើរ៉សទិ ប្រើអំណាចរបស់ខ្លួនធ្វើបាបជំនួយការលេខាថ្មី វាប្រហែលគួរឲ្យធុញទ្រាន់
មិនសប្បាយលេង បើនាងស្ងប់ស្ងៀម មិនលេងជាមួយ តែព្រោះនាងមិនដូចអ្នកដទៃ
នាងស៊ូមិនរាថយ រកឱកាសសងសឹកគេគ្រប់វិធី នាងនេះហើយជាគូប្រកួតសមតិឡូគ្នា។
"អួក! លង់ខ្លួនឯង គិតថាមុខមាត់ល្អណាស់ឬក៏អី ពុកមាត់ស្រមូម
ខ្លួនសុទ្ធតែរោមដូចស្វាបែបនេះ គួរឲ្យស្រឡាញ់ត្រង់ណា ធ្វើឫកអន្ធពាលតែពាសដូចលោក
ខ្ញុំក៏មិនចង់បានដូចគ្នា"
ងឹត!
"នាងហ៊ានប្រៀបធៀបខ្ញុំនឹងស្វាផង!"
កាណែត បត់ចង្កូតឡានចូលចតអែបផ្លូវ និងជាន់ ហ្វ្រាំងគំហុកលាន់សំឡេងទ្រហឹង
ធ្វើឲ្យនាងផ្កាប់មុខ ហើយងាកមកធ្វើមុខកាចដាក់នាង។
"គិតខ្លួនឯងទៅ!"
"អឺ ហើយពេលត្រូវស្វាធាមស្រមូវថើបនេះ មានអារម្មណ៍យ៉ាងម៉េច ស្រៀវខ្លះអត់"
"អាឡប់ អាមាត់ផ្អែ"
"សាកបន្តិចក៏មិនខូចខាតអីដែរ ឲ្យវាដឹងថាមាត់ផ្អែមែនអត់"



Ls573

Come to join us
www.facebook.com/yuveakvey
Tel:010687767

ឈុតភ្លើងស្នេហា

រក្សាសិទ្ធិ ហាមថតចំលងគ្រប់រូបភាព

ផ្កាភ្លើងស្នេហ៍

S@rikA

Love Series

យុវវ័យ Publishing 18+



ផ្កាភ្លើងស្នេហ៍

តម្លៃ : ២៤០០០៛

Scanned with CamScanner

# ១

"ថាម៉េច ប៉ាឲ្យក្មេងនោះមកធ្វើជាជំនួយការលេខារបស់ខ្ញុំឬ ?"

កាណែត ឈើរសេទិ ស្មុះឈរភ្លាមពេលបានស្តាប់បញ្ហារបស់ឪពុកដែលតេរមករក តាំងពីថ្ងៃដំបូងដែលទើបតែត្រឡប់មកពីពិធីមង្គលការរបស់បងប្រុស តែហេតុអ្វីបានជានៅក្នុងពិធី មិនព្រមប្រាប់គេ។

( មែន ប៉ាឲ្យនាងទៅធ្វើការនៅចម្ការរបស់ឯង ស្អែកនេះ )

លោក អាហ្សា ញញឹមចុងមាត់ កែវភ្នែកមានពន្លឺផ្លេកៗ នៃការចូលចិត្ត ដែលសូម្បី គីម បេ ជាលេខាធិកាក៏លួចញញឹមតាម។ នេះបញ្ជាក់ថាចៅហ្វាយកំពុងដាក់ផែនការអ្វីហើយ សម្រាប់កូនប្រុសពៅ។

"ហេតុអីប៉ាធ្វើបែបនេះ ក៏ដឹងដែរ ថាខ្ញុំមិនសូវចូលចិត្តមុខនាងប៉ុន្មាន"

កាណែត ឡូឡាដោយសំឡេងគំរោះគំរើយ ទឹកមុខបង្ហាញឲ្យឃើញពីការមិនពេញចិត្ត ខណៈនោះក៏ឈរច្រត់ចង្កេះ មើលទៅក្រៅបង្អួចបន្ទប់ធ្វើការ មើលឃើញចម្ការតែ ដែលដាំដុះលើដីល្បាក់ កម្មករកំពុងបេះស្លឹកខ្ចី និងមានក្រុមទេសចរមកទស្សនាទេសភាព ថតរូប សិក្សាវិធីបេះស្លឹកតែពីកម្មករយ៉ាងសប្បាយរីករាយ។

( មិនចូលចិត្តមុខក៏មិនបាច់មើលមុខ ឯងធ្វើឲ្យនាងខូចខាត នាងមិនឃើញថាអីឯងមួយម៉ាត់ផង កាណែត ឬឯងបាត់បង់ការចងចាំ ន្ធាលប៉ាបញ្ជាក់ថាថ្ងៃនោះ ឯងប្រាប់ប៉ាថាម៉េចខ្លះ ប្រាប់ថាកំពុងសេពគប់មើលចិត្តនាង ដើម្បីគេចវេះការរៀបការ ប៉ាចាំបាន តែនេះពេលនេះ អាជ្រេ រៀបការហើយ សល់តែឯងម្នាក់ទៀតទេ ដែលមិនទាន់រៀបការ តែប៉ាមិនបង្ខំឲ្យឯងរៀបការជាមួយអ្នកណាទេ ឬគួរតែបង្ខំឲ្យឯងទទួលខុសត្រូវសម្តីរបស់ឯងដោយការរៀបការជាមួយ ស៊ុនស៊ូ ប៉ាថាបែបនេះក៏ល្អដែរ )

លោក អាហ្សា និយាយដោយសំឡេងកាច ដើម្បីកកាយការចងចាំរបស់កូនប្រុសពៅ ដែលប្រាប់កាលលើកមុន ពេល កាណែត ជូន អេដែន មកតាមរកប្រពន្ធកូន និងយកឈ្មោះរបស់ ស៊ុនស៊ូ មកស្រឡាប ធ្វើជាលេះ ដើម្បីគេចពីការទៅមើលគូ ដែលលោកក៏យល់ព្រម ព្រោះចង់ឲ្យ អាជ្រេ រៀបការមុនជាងហើយ អាជ្រេ ក៏រៀបការរួចដែរ អីចឹងដល់វេនកូនប្រុសពៅហើយ ព្រោះចង់បានចៅច្រើនពេលនេះ។

"ប៉ាកុំធ្វើបែបហ្នឹង គ្មានថ្ងៃខ្ញុំសេពគប់ក្មេងហ្នឹងដាច់ខាត ខ្ញុំមិនចូលចិត្ត"

កាណែត ធ្វើធីះនៅដើម.ក ព្រោះមិនចង់នៅជិត ស៊ុនស៊ូ ក្មេងមាត់ដាចនោះប៉ុន្មាន នាងចូលចិត្តធ្វើឫកធ្វើពារើសអើងគេ គេទេដែលរើសអើងនាង ទើបត្រូវ នាងជាកូនរបស់មនុស្សស្រីមុខក្រាស់ មុខលុយ គួរតែមិនខុសពីម្តាយ ប៉ុន្តែស៊ូអា គេលើកលែង ព្រោះនាងមិនដូចបងស្រី ប្រមាណខ្លួនប្រមាណប្រាណ

Scanned with CamScanner

សុភាពរាបសារ ទន់ភ្លន់ ថែមទាំងមានក្បាយគួរឲ្យស្រឡាញ់ឲ្យគេទៀត។

(អី តាមហ្នឹង បើឯងមិនសេពគប់ ឯងត្រូវឲ្យនាងធ្វើការជាមួយ តែបើឯងមិនព្រម ប៉ាអាចបង្ខំឲ្យឯងរៀបការជាមួយគេក៏ថាបាន)

លោក អាហ្សា បញ្ជាក់ ថែមទាំងគំរាមនៅចុងប្រយោគទៀត ព្រោះដឹងថាយ៉ាងណាក៏កូនត្រូវពៅត្រូវតែជ្រើសរើសសំណើដំបូង។

"ប៉ា"

កាណែត លើកដៃក្ដោបក្បាល ទឹកមុខតានតឹង សរសៃឈាមប៉ោងឲ្យឃើញត្រង់សៀតផ្កា ថ្ពាល់ត្រង់ថ្គាមឡើងប៉ោង និងរឹង។

(ឯងហៅប៉ាញឹកញាប់បែបនេះ ខ្លាចភ្លេចឬយ៉ាងម៉េច ហ៊ឹម!)

លោក អាហ្សា ប្រឹងទប់ស្នាមញញឹមអស់ពីសមត្ថភាព បើ កាណែត ឃើញ ច្បាស់ជាខឹងគាត់ច្រើនថ្ងៃឯនោះ។

"មិនមែនអីចឹងទេ តាមហ្នឹងទៅអីចឹង ឲ្យម៉ោធ្វើជាជំនួយការលេខារបស់ខ្ញុំ តែបើនាងធ្វើមិនត្រូវចិត្ត ខ្ញុំនឹងបណ្ដេញចេញ"

កាណែត ទ័លបញ្ញានឹងក្បាលរឹងចំពោះរឿងនេះ ព្រោះស្គាល់ចរិតរបស់ឪពុកច្បាស់ តែហ៊ានរឹង ដឹងតែគាត់ធ្វើអ្វីម្យ៉ាងមិនខាន អីចឹងចាក់បណ្ដោយសិនទៅ បើយ៉ាងណា ចាំចាត់ការតាមក្រោយ។

(បើបណ្ដេញចេញ ប៉ាត្រូវរកហេតុផល យ៉ាងណាក៏នាងជាមនុស្សរបស់ប៉ា មិនមែនរបស់ឯង)



លោក អាហ្សា ញាក់ស្មាតិចៗ ដោយមិនញញើត។

"យ៉ាងនេះ គឺហៅថាក្មេងខ្សៃហើយ"

(មែន ខ្សៃប៉ារបស់ឯងហ្នឹង យ៉ាងណាក៏ធំជាងឯង ឬឯងចង់ប្រាប់ថាមិនមែន)

លោក អាហ្សា ពើងទ្រូងអួតដោយមានមោទនភាព និងអស់សំណើចតិចៗ ដាក់ទូរសព្ទ។

"អ៊ូយ! ខ្ញុំមិនចង់ប្រកែកនឹងលោក អាហ្សា ទេ តាមហ្នឹងទៅ ឲ្យមកធ្វើការស្អែកនេះម៉ោ"

គេព្រមចាញ់ មិនចង់ប្រកែកនឹងឪពុកទៀត ព្រោះកាន់តែធ្វើឲ្យឈឺក្បាល ខ្លាចត្រូវបង្ខំឲ្យរៀបការជាមួយក្មេងនោះ នាំតែមានរឿងធំ។

គេដកដង្ហើមធំ លើកដៃទះអាកាសធាតុ ហើយលើកដៃជ្រងសក់។

(ល្អណាស់ អាកូនប្រុស ចាំប៉ាប្រាប់នាងឲ្យត្រៀមខ្លួនទៅធ្វើការជាមួយឯងស្អែកនេះ)

"បាទ"

កាណែត លាឪពុក ហើយក្ដាប់ទូរសព្ទណែនដៃ ចំណែកដៃម្ខាងទៀតគ្រវៃគ្រវាសដាក់អាកាសធាតុ បន្ទាប់មកដើរមកដាក់បង្អួយនៅតុធ្វើការលាន់ទិះ ទឹកមុខក្រមូវ និងដាក់ទូរសព្ទលើតុ ហើយលើកដៃលុបមុខ ដកដង្ហើមធំ។

គេគ្រវីក្បាលតិចៗ ព្យាយាមមិនយកចិត្តទុកដាក់ តែខួរក្បាលចេះតែគិត



Scanned with CamScanner

ដល់ក្មេងស្រីម្នាក់នោះជារឿយៗ។

"ធ្វើឯងក្មេងក្អាង ប្រយ័ត្នខ្លួនទៅ បើធ្វើការមិនកើតជាការ ខ្ញុំមិនទុកទេ ចាំមើលទៅ"

កាណែត អង្គុយសង្កៀតធ្មេញក្រតៗ តែម្នាក់ឯងក្នុងបន្ទប់ធ្វើការ ដោយអារម្មណ៍មិនស្រឡះល្អ។ តាំងពីជួបគ្នាលើកដំបូង ក៏ធ្វើមុខឱដាក់គេ គិតថាគេចាប់អារម្មណ៍ឬយ៉ាងម៉េច ច្រើនថ្ងៃមកនេះ តាំងពីមកនៅចម្ការ ជួយមើលថៃសួម គឺចេះតែដៀងភ្នែកមើលគេរហូត ស្អប់ណាស់ ស្អាតក៏មិនស្អាត នៅមកធ្វើមុខឱដាក់គេ។

អ្នកកំលោះអង្គុយធ្វើការដោយអារម្មណ៍មួម៉ៅ មួយសន្ទុះក្រោយមកក៏លើកដៃមើលនាឡិកា ហើយដកដង្ហើមធំ ពេលឃើញថាជិតដល់ម៉ោងចេញពីធ្វើការ ទើបពិនិត្យឯកសារម្តងមួយៗ បង្ការបញ្ហា បន្ទាប់ពីស៊ីញ៉េចរាល់ក៏រៀបចំទុកដាក់។

គេងើបឈរពេញកម្ពស់ ឲ្យឃើញរាងកាយមាំមួន ខ្ពស់ស្រឡះ សមនឹងខោខូវប៊យជើងវែង អាវយឺតពណ៌ខ្មៅ ស្បែកជើងស្បែកសុទ្ធពណ៌ត្នោត ហើយពត់ពេនខ្លួនប្រាណ បណ្តេញភាពចុករួយ ទើបដើរចេញពីបន្ទប់ធ្វើការ។

"សុងចូ ចាំឲ្យគេយកស្លាករើសជំនួយការលេខាចេញផង មិនបាច់រើសទេ ស្អែកមានមនុស្សមកធ្វើការហើយ"

"រើសបានលឿនម្ល៉េះ ទើបតែដាក់ស្លាកហ្នឹង"



"មនុស្សរបស់ប៉ាខ្ញុំ លេខាធ្លាប់ឃើញហើយ"

"អ្នកណាដែរ លោក កាណែត"

សុងចូ ធ្វើមុខមិងមាំង ថាតើអ្នកណាដែលខ្លួនធ្លាប់ឃើញ។

"កាំង ស៊ុនស៊ូ! ប៉ាខ្ញុំបញ្ជាឲ្យយកនាងមកធ្វើការនៅទីនេះ ស្អែកខ្ញុំឲ្យម៉ោធ្វើការហើយ"

"អ៎ូ! បាទ លោក កាណែត"

សុងចូ ញញឹមពព្រាយ ស្មានថាអ្នកណា គឺក្មួយស្រី អ្នកស្រីធំ ឬ ស៊ូអានោះឯង។ គេធ្លាប់ជួបហើយ នាងគួរឲ្យស្រឡាញ់ ជាអ្នកមើលថៃអ្នកប្រុស សួម កូនប្រុសរបស់លោក អេដែន តែឆ្ងល់ថាហេតុអីលោក អាហ្សា បញ្ជាឲ្យមកធ្វើការនៅទីនេះ។

"ឲ្យនាងមកធ្វើការ មិនមែនឲ្យមកអង្គុយញ៉ែ"

កាណែត ធ្វើមុខកាចដាក់លេខាធិការជំនិតរបស់ខ្លួន និយាយដល់មិនបានសោះហើយ ភ្នែកឲ្យគឃ្លើន។

"ហេះៗ មិនញ៉ែទេ អ្នកណាហ៊ានញ៉ែ សង្សារខ្ញុំវ៉ៃបែកក្បាលល្មម"

"ល្អហើយ កុំបែកពីសង្សារ ព្រោះតែស្រីម្នាក់នេះឲ្យសោះ មិនអីចឹងខ្ញុំអាចបណ្តេញឯងចេញក៏ថាបាន ហុង សុងចូ"

"មិនដាច់ខាត លោក កាណែត"

"អីចឹងថ្ងៃនេះទៅផឹកកំដរបន្តិច នៅក្នុងក្រុង គេរប្រាប់សង្សារទៅថាទៅ



Scanned with CamScanner

ជាមួយខ្ញុំ កុំឲ្យនាងពិបាកទៅតាម ខ្ញុំទៅចាំនៅខាងក្រៅ បានចម្លើយយ៉ាងណាទៅប្រាប់ផង"

កាណែត បញ្ជាកូនចៅ ហើយដើរចេញត្រង់នោះ។

"បាទៗ

សុងចូ ញញឹមពព្រាយ ប្រញាប់ប្រញាល់ចុចទូរសព្ទទៅសង្សារ ព្រោះមិនត្រូវការឲ្យនាងភ័យបារម្ភ ប្រចណ្ឌហួងហែងថាគេទៅជាមួយអ្នកណា តែបើទៅជាមួយចៅហ្វាយ ធានាថាសង្សារមិនថាអីទេ ហើយពេលសង្សារអនុញ្ញាតទើបរៀបចំទុកដាក់អីវ៉ាន់នៅលើតុធ្វើការ ដើរមករកចៅហ្វាយដែលកំពុងឈរនៅមិនឆ្ងាយពីឡានប៉ុន្មាន។

"ម៉េចដែរ?"

"រួចរាល់ហើយ ទៅឡានម្នាក់មួយក៏បាន កុំឲ្យលោកពិបាកជូនខ្ញុំទៅផ្ទះ"

"អូខេ ទៅហាងចាស់ អង្គុយផឹកបន្តិច"

កាណែត ញីបារីដែលជក់បានបន្តិចនិងធុងខ្សាច់ដែលនៅក្បែរនោះ។ យូរៗ គេជក់ម្តង បើមានអារម្មណ៍តានតឹង តែមួយរយៈនេះមិនសូវជក់ប៉ុន្មានទេ ព្រោះបងប្រុសមិនព្រមឲ្យចូលជិតក្មួយប្រុស បើជក់បារី ទើបគេផ្អាក។

"បាទ"

សុងចូ តាមមើលខ្នងរបស់ចៅហ្វាយដោយការសរសើរ។ កាណែត និងបងប្រុសទាំងពីរសុទ្ធតែសង្ហា មើលទៅថ្លៃថ្នូរ មុខមាត់ចេញពីពុម្ពតែមួយ ដូចគ្នា



បេះបិទ។

ចៅហ្វាយរបស់គេមានមុខមាំ ភ្នែកមុត សក់រួញអង្កាដី ថ្ងាសធំទូលាយ ចិញ្ចើមក្រាស់ ច្រមុះស្រួចសមបបូរមាត់ស្តើងរហៀរ ក្រហមព្រឿងៗ ចំណែកពុកមាត់ពុកចង្កាត្រូវតុបតែងមានរបៀប ស្មាបើកធំ មានសាច់ដុំកង់ៗ ស្អាតមានមាឌធំ រាងខ្ពស់ស្រឡះ រាងរៅបែបដែលស្រីៗ ឃើញហើយញ័របេះដូង។

កាណែត មើលខុសត្រូវចម្ការតែ និងរីសតនៅទីនេះជាចម្បង ថែមទាំងគ្រប់គ្រងបានល្អទៀតផង រួមទាំងផលិតតែ ដែលនៅសម័យនេះ ក្មេងៗមិនសូវមានការចាប់អារម្មណ៍នឹងរឿងប្រភេទនេះ តែចៅហ្វាយរបស់ សុងចូ ធ្វើបានល្អ និងអាចនាំផលិតផលតែទៅចែកចាយនៅបរទេស ប្រកួតប្រជែងនឹងតែល៉ំដាប់ពិភពលោក។ ចម្ការនៅទីនេះ ជាចម្ការតែមួយគត់ ដែលដាំតែបាវ៉ាំងបានច្រើនរាប់ពាន់ហិចតា និងដាំតែប្រភេទផ្សេងៗ ជាងពីរពាន់ហិចតា មានចម្ការ ស្ត្របឺរី ដែលដាំលើដីល្បាក់ដែរ កណ្តាលជ្រលងភ្នំ ដែលឡោមព័ទ្ធដោយអ័ព្ទស្អាត និងដាំកាការ ធ្វើឲ្យចម្ការតែរកកម្រៃបានច្រើន ក្រៅពីរីសតដែលត្រូវកក់ពេញៗពេញមួយឆ្នាំ។

កាណែត ឡើងឡានរបស់ខ្លួន ហើយបើកចេញទៅមុន សុងចូ ដែលបើកមកតាមពីក្រោយ។ ពួកគេមកដល់ហាងអាហារ ដែលខាងហាងស្វាគមន៍បានល្អ ព្រោះជាភ្ញៀវប្រចាំ ហើយថ្ងៃនេះមានភ្ញៀវមិនច្រើនប៉ុន្មាន ទើបមានទេសភាពល្អដូចទម្លាប់ ធ្វើឲ្យ កាណែត ពេញចិត្ត ព្រោះមិនបានកក់ជាមុន។





Scanned with CamScanner

គេកុម្ម៉ង់ស្រា មកជិបលេង មិនត្រូវការស្រវឹង ព្រោះត្រូវបើកឡានទៅផ្ទះវិញដោយខ្លួនឯង ខណៈនោះក៏និយាយរឿងនេះរឿងនោះ មានទាំងរឿងការងារដែរ ជាមួយ សុងចូ មួយសន្ទុះធំ ទើបត្រឡប់ទៅវិញ ហើយដូចការគិត ត្រូវឲ្យបុគ្គលិករបស់ហាងជូន សុងចូ ដែលស្រវឹង ទោះតិចតួចក៏ដោយ ទៅផ្ទះ ព្រោះគេបារម្ភ និងគិតដល់សុវត្ថិភាពជាចម្បង។

កាណែត បើកឡានមកដល់ផ្ទះ ជិតអាធ្រាត្រទៅហើយ ព្រោះគេទៅអង្គុយផឹកស្រានៅហាងក្នុងក្រុង មិនបានផឹកទាល់តែស្រវឹង ព្រោះត្រូវបើកបរ តែត្រូវការផ្លាស់ប្ដូរបរិយាកាស ដោយសារស្ត្រេសរឿងដែលឪពុកបញ្ជា។

គេចុះពីឡាន ចាក់សោទ្វាររួចរាល់ ក៏លូកដៃចូលហោប៉ៅខោ ហួចឲ្យគ្រលួច ដើរមកឈរមុខផ្ទះ តែពេលចាប់ប្រដាប់បិទបើក ឃើញថាត្រូវចាក់សោ ទើបទាញកូនសោមកចាក់ ពេលចូលទៅខាងក្នុងហើយ ក៏បិទ ចាក់សោវិញ ហើយបែរខ្នង ប្រុងដើរឡើងទៅជាន់លើ តែក៏ទចង់ដំណើរ ពេលបានឮសំឡេងដូចរបស់ធ្លាក់នៅក្នុងផ្ទះបាយ។

ប្រាវ!

គេបង្វែរទិសដៅទៅផ្ទះបាយភ្លាម ដោយដើរសម្រាលជើងបំផុត ដៃក៏ក្ដាប់ជាប់ ត្រៀមរួចជាស្រេច ក្រែងលជាចោរ ឃើញភ្លើងបើកនៅក្នុងនោះ ទើបទៅឈរកៀនទ្វារ អើតមើលទៅខាងក្នុង ហើយធូរទ្រូង ពេលឃើញថាមិនមែន



ចោរដូចការគិត។

គេឱបដៃ ផ្អែកស្មានឹងទ្វារ មើលអ្នកដែលកំពុងតែមមាញឹកនឹងការផឹកទឹកដោះគោ មិនដាក់ភ្នែក រង់ចាំថាពេលណាទើបនាងងាកមក។

ស៊ុនស៊ូ ផឹកទឹកដោះគោទាល់តែអស់ យកកែវទៅលាងទុកដាក់រួចរាល់ ក៏បែរមករកទ្វារ លើកដៃជូតមាត់ ហើយភ្ញាក់ព្រើត ពេលឃើញថាមានអ្នកឈរផ្អែកនឹងទ្វារមើលមកខ្លួន។

"អុំ! លោក កាណែត ម៉ោឈរមិនឲ្យសូរឲ្យសៀងបែបនេះ លស់ព្រលឹងអស់"

"បានឮសំឡេង ស្មានថាចោរ"

គេញាក់ស្មាបន្តិច សម្លឹងអ្នកនៅចំពោះមុខមិនដាក់ភ្នែក ស្រីមាឌល្អិតដែលចូលចិត្តឃើញនាងចងសក់សឹងតែគ្រប់ពេល តែពេលនេះទម្លាក់វា ឲ្យរាយពេញខ្នង ឯមួយចំនួនប៉ើងលើមុខ ធ្វើឲ្យគេចង់លូកដៃទៅប៉ះ ថាវាទន់ទេ ហើយប្រញាប់រលាស់គំនិតនោះចោល ពេលបានឮសំឡេងគំរោះគំរើយរបស់នាង ព្រមទាំងធ្វើមុខក្រមូវ ឲ្យគេខាំធ្មេញក្រតៗ ដោយការមិនចូលចិត្ត។

"លោកក៏ឃើញ ថាមិនមែនចោរ ហើយម៉េចមិនឡើងបន្ទប់ទៅ"

ស៊ុនស៊ូ ត្បុកសួរដោយសំឡេងគំរោះគំរើយ ព្រមទាំងលើកដៃឱបទ្រូង សំណាងដែលពាក់អាវយឺត ស្លៀកខោកីឡា មិនមែនឈុតដេកពណ៌ស្រស់ដូចស្រីៗភាគច្រើនចូលចិត្តពាក់។ នាងមើលគេដោយមិនសូវទុកចិត្តប៉ុន្មាន មើល



Scanned with CamScanner

ទៅគេដូចស្រវឹងឬអត់ ក៏មិនសូវច្បាស់ ព្រោះឃើញភ្នែកក្រហមតិចៗ។

"មិនទាន់ចង់ឡើង គ្មានស្អីទេ លួចម៉ោចាប់ចោរបន្តិច មានឯណា ឆ្មាញី នេះឯង"

អ្នកកំលោះដើរចូលផ្ទះបាយ ហើយប្រើខ្សែភ្នែកមុតស្រួចមើលនាងតាំងពីក្បាលដល់ចុងជើង ព្រមទាំងធ្វើទឹកមុខ និងសំឡេងឡកឡឺយដាក់។

"ខ្ញុំមិនបានលួច ខ្ញុំគ្រាន់តែម៉ោផឹកទឹកដោះគោប៉ុណ្ណោះ លោកស្រវឹងហើយ ទៅដេកទៅ"

នាងក្ដាប់ដៃណែន ប្រកែកច្រែតៗ ទាំងមុខក្ដៅភាយៗដោយសារភ្នែករបស់គេដែលមើលមក បែបនេះ ចង់តែយកឆ្នាំងវាយក្បាលគេទេ។

"ម៉េចក៏ដឹងថាខ្ញុំស្រវឹង បើស្រវឹង ខ្ញុំបើកឡានមកផ្ទះមិនដល់ទេ ស៊ុនស៊ូ"

គេញាក់ស្មាតិចៗ ញញឹមចុងមាត់ ព្រមទាំងវាយចិញ្ចើមដាក់ ពេលឮអ្នកនៅចំពោះមុខថាគេស្រវឹង។

"អីចឹងវាជារឿងរបស់លោក ខ្ញុំសុំទៅសិនហើយ ងងុយដេកហើយ"

ស៊ុនស៊ូ ធ្វើឆើយដាក់ ហើយដើរចេញពីផ្ទះបាយ ព្រោះមើលទៅគេមិនគួរឲ្យទុកចិត្តប៉ុន្មាន។ ស្អប់ណាស់ មនុស្សមាត់ដាច ចូលចិត្តរករឿងនាងគ្រប់ពេលវេលា។

"កុំអាលទៅ ខ្ញុំមានរឿងនិយាយជាមួយនាងបន្តិច គិតថានាងប្រហែលដឹងហើយ"



គេដើរតាម មកស្ទាក់មុខនៅមុខផ្ទះបាយ លើកដៃទ្រាននឹងទ្វារ មិនឲ្យនាងដើរទៅណារួច។

"រឿងអី ?"

បេះដូងរបស់នាងក្រមុំលោតញាប់ដោយការភិតភ័យ និងឈានជើងថយក្រោយពីរជំហាន នៅឲ្យឆ្ងាយពីគេ ពេលសួរនាំ។

"ហ៊ឺ! ធ្វើឯងមិនដឹងរឿងអីផង នេះប្រហែលទៅម្ញិកម៉ូក់ប៉ាខ្ញុំ ដើម្បីបានមកធ្វើការនៅចម្ការតែរបស់ខ្ញុំ មែនទេ"

គេសើចហ៊ឹៗ ពេលនិយាយ តែគ្មានការលេងសើចនៅក្នុងសំឡេងសើចនោះ តែសម្ដីរបស់គេ ធ្វើឲ្យនាងឆួលចុងច្រមុះ។

"កុំម៉ោចោទខ្ញុំ ខ្ញុំមិនបានទៅម្ញិកម៉ូក់លោកម្ចាស់ទេ"

នាងខាំធ្មេញក្រតៗដាក់ ព្រោះគេមកចោទប្រកាន់នាងបែបនេះមិនបានទេ ព្រោះនាងទើបតែទទួលបញ្ជាពីលោក អាហ្វា នៅថ្ងៃនេះដែរ និងមិនអាចបដិសេធបាន។

"កុំម៉ោបដិសេធឲ្យហត់ ខ្ញុំមិនជឿទេ ធ្វើឯងមីះៗ តែជាតុពិត មនុស្សដូចនាងសាហាវណាស់"

"លោក កាណែត បើមកររករឿងបែបនេះ គួរតែរកព័ត៌មានឲ្យបានច្បាស់សិន ខ្ញុំមើលថែប្អូនខ្ញុំសុខៗ ហើយលោកម្ចាស់ក៏ប្រាប់ឲ្យខ្ញុំទៅធ្វើការជាមួយលោក ស្មានថាខ្ញុំចង់ទៅធ្វើការជាមួយលោកណាស់ក៏អី កុំគិតស្អីវែងពេក"





Scanned with CamScanner

ស៊ុនស៊ូ ក្តាប់មាត់ណែន សម្លក់សម្លឹងគេដោយខ្សែភ្នែកឆ្មាសឆ្មើម។

ប្រុសម្នាក់នេះលង់ខ្លួនឯងណាស់ គិតថានាងចង់ទៅធ្វើការជាមួយគេឬយ៉ាងម៉េច បើមិនមែនជាបញ្ហារបស់លោក អាហ្សា កុំសង្ឃឹមថានាងព្រមទៅងាយៗ នោះ មនុស្សលង់ខ្លួនឯង ស្អប់ណាស់។

"ហើយគិតថាចង់ឲ្យមកធ្វើការជាមួយណាស់ក៏អី មិនបានចង់ឲ្យម៉ោទេ បើប៉ាមិនបង្ខំ កូនរបស់ស្រីម្នាក់នោះ គឺមិនខុសពីម្តាយទេ"

គេខាំធ្មេញក្រតៗ គ្រហឹមដាក់នាង និងសម្លឹងមុខមិនដាក់ភ្នែក។

តមាត់ឲ្យប៉ប៉េះតែម្តង ក្មេងនេះ!

"លោកធំហើយតើ លោកម្ចាស់ម៉េចបង្គាប់បង្ខំបានទៅ វាជារឿងរបស់លោក ពេលលោកម្ចាស់បញ្ជាឲ្យខ្ញុំទៅធ្វើការជាមួយលោក ខ្ញុំក៏ធ្វើ ទាំងដែលមិនចង់ធ្វើការជាមួយចៅហ្វាយមាត់ដាចបែបនេះ"

នាងក្តាប់មាត់ ហើយត្បកវិញ តែក្តាប់ដៃណែន ទាំងខឹង ទាំងខ្លាចអារម្មណ៍ពីរនេះ វាច្របល់គ្នាអស់ទៅហើយ ទើបទប់ចិត្តឲ្យសំឡេងស្មើ ពេលនិយាយ កុំឲ្យវាញ័រ និងជ្រឹមភ្នែកដាក់គេជាការប្រមាថ។

"នេះនាងហ៊ានថាឲ្យខ្ញុំ?"

កាណែត លើកដៃចង្អុលមុខនាងដោយការមួម៉ៅ មិនធ្លាប់មានស្រីណាហ៊ានតមាត់នឹងគេមួយម៉ាត់ធ្លាក់ដល់ដីបែបនេះទេ ស្រីម្នាក់នេះជាអ្នកណាបានជាថ្លើមធំបែបនេះ។

"ហេតុអីថាមិនបាន លោកក៏ជាមនុស្ស ខ្ញុំក៏ជាមនុស្ស"

បេះដូងរបស់ក្រមុំតូចលោតឌុកឌាក់ ខ្លាចគេលូកដៃធំៗនោះមកច្របាច់កនាង ទើបថយក្រោយមួយជំហានទៀត និងលេបទឹកមាត់ក្អឹកៗ។

"របល់យក៏!"

"និយាយឲ្យស្រួលបួលបន្តិចទៅ ម៉េចចាំបាច់ជេរ នេះជាកូនលោកម្ចាស់មែនឬអត់ ឬជាក្មេងដែលលោកម្ចាស់រើសពីធុងសំរាមមកចិញ្ចឹម និយាយស្តីអសុរោះ មាត់ក៏ដាច មួយម៉ាត់ក៏គំហក ពីរម៉ាត់ក៏គំហកជេរ កើតអីណាស់ណាឬអត់ លោកនេះ"

និយាយបណ្តើរ បេះដូងលោតឌីបៗ បណ្តើរ តែខំធ្វើចិត្តឲ្យរឹងមាំ មិនឲ្យគេដឹងថានាងខ្លាច កុំឲ្យអាមនុស្សប្រុសឆ្កួតឡប់នៅចំពោះមុខគំរាមនាង។

"ខ្ញុំនេះកូនបង្កើត កុំពត្លើនិយាយបែបនេះ តិចត្រូវ"

អ្នកកំលោះខាំធ្មេញក្រតៗ មុខក្រមូវឡើងក្រហមង៉ាំង ផ្សែងចេញតាមត្រចៀកតែម្តង ពេលបានឮសម្តីស៊កសៀតរបស់នាង។ មានពីអង្កាល់មកថាគេជាកូនដែលប៉ារើសពីធុងសំរាមមកចិញ្ចឹម។

"ហើយយ៉ាងម៉េច ត្រង់លោកចេះថាឲ្យខ្ញុំបាន ហេតុអីពេលខ្ញុំថាលោកវិញម្តង លោកមិនពេញចិត្ត បែបនេះមិនមែនប្រុសពិតទេ"

ស្អប់ណាស់ មនុស្សអន្ធពាល ពូកែតែថាឲ្យគេប្រេតៗ ពេលត្រូវជេរវិញក៏ធ្វើមុខយក្សដាក់គេ!



Scanned with CamScanner

"ចង់សាកប្រុសពិតមើលទេ"

គេលើកចិញ្ចើម ញញឹមចុងមាត់ យកអណ្ដាតរុញថ្ពាល់ ជ្រីមភ្នែកមើលស្រីសម្ដីហំ ខណៈនោះក៏លើកដៃប្រឡេះឡេវអាវមួយគ្រាប់ខាងលើ និងដើរមករកដោយកាយវិការដាក់សម្ពាធ ទើប ស៊ុនស៊ូ ឈានជើងថយក្រោយ។

"ថយចេញទៅ លោកចង់ធ្វើអី!"

នាងមើលគេទាំងបេះដូងលោតឌុកឌាក់ ថយក្រោយទាល់តែបុកនឹងតុនៅកណ្ដាលផ្ទះបាយ ទើបងាកចេញ តែគេលឿនជាង ស្ទុះមកជិត ស្រវាចាប់តុដោយដៃទាំងពីរ ទ្រាបទៅលើខ្លួននាង ឃុំឃាំង មិនឲ្យទៅណារួច។

"ធ្វើឲ្យនាងមើលហ្នឹងអីថាខ្ញុំសមជាប្រុសពិត កុំឲ្យនាងថាខ្ញុំមិនមែនជាប្រុសពិត"

"ថយចេញទៅ"

ស៊ុនស៊ូ ស្រែកគំហកដោយសំឡេងញ័រតិចៗ ភ្នែកក៏ក្រឡេបក្រឡាប់ និងបញ្ជាគេឲ្យថយចេញ ខណៈនោះក៏ប្រឹងងាកមុខចេញ មិនមើលគេ។

"ម៉េច! មិនបាច់ខ្លាចទេថាមានអ្នកណាម៉ោឃើញ ពេលនេះដេកលក់អស់ហើយ"

គេធ្វើជាខ្សឹបខ្សៀវដាក់ដោយសំឡេងស្អកៗ ព្រោះអ្នកនៅក្នុងរង្វង់ដៃ។ ស្អប់គេណាស់មែនទេ ល្អ គេក៏ចង់ដឹងដែរ ថាបើគេនៅជិតជាងនេះ នាងនឹងធ្វើយ៉ាងម៉េច។



"ថយចេញទៅ ស្អុយស្រាណាស់ ចេញឲ្យឆ្ងាយទៅ!"

នាងក្រមុំធ្វើជាលើកដៃម្ខាងបិទមាត់ បិទច្រមុះ ចំណែកដៃម្ខាងទៀតរុញដើមទ្រូងរបស់គេចេញ។ នាងធុំក្លិនស្រាយភាយចេញពីខ្យល់ដង្ហើមរបស់គេមិនប៉ុន្មានទេ តែខ្លាចអ្វីផ្សេងជាង។

"ខ្លាចអ្ហ៎! មិញឃើញប្រែតៗតើ ខ្លាចមែនឬអត់បែបនេះ ឬធ្វើពុត គិតថាខ្ញុំចើបមែនទេ ហ៊ឹៗ"

"មិនបានខ្លាចទេ តែខ្ពើម បើចង់បោកឲ្យខ្លាច ប្រាប់ឲ្យដឹងទៅថាមិនខ្លាចទេ ថយចេញទៅ អ៊ូយ!"

"ខ្ពើមខ្លាំងឬ ស៊ុនស៊ូ ការពិតខ្ញុំទេដែលត្រូវខ្ពើមនាង ខ្ញុំនៅចាំក្មេងស្រីស្រមេកស្រមកដែលធ្វើភ្នែកម៉ក់ៗ មើលខ្ញុំ ពេលប៉ាខ្ញុំនាំម៉ាក់នាងចូលផ្ទះ តែតាំងពីពេលនោះមកក៏មិនដែលជួបទៀត មិនស្មានថាបានជួបគ្នាទៀតសោះ"

កាណែត ស្រវាទាញនាង មកឱបណែនដៃ ខាំធ្មេញក្រតៗ និយាយពីអតីត ទោះអ្នកនៅចំពោះមុខចាំមិនបាន តែគេចាំបានច្បាស់។

"ហើយចង់យ៉ាងម៉េច ពេលនេះខ្ញុំមិនមែនក្មេងស្រីស្រមេកស្រមកដូចកាលមុនទេ ម្យ៉ាងទៀត មីង ស៊ូអា រៀបការជាមួយបងប្រុសរបស់លោកហើយ ខ្ញុំមានសិទ្ធិនៅទីនេះ លោកគ្មានសិទ្ធិមកធ្វើខ្លួនអន្ធពាលបែបនេះដាក់ខ្ញុំទេ"

នាងខ្មាសមុខឡើងក្រហមង៉ាំង ពេលឮសម្ដីឡកឡឺយរបស់គេដែលនិយាយពីនាងកាលនៅតូចក្រូចឆ្មារ ដែលនាងចាំមិនបានថាធ្លាប់ជួបគេ ព្រោះ



Scanned with CamScanner

ពេលនោះនាងនៅតូចណាស់ និងពេលដឹងក្តី គេក៏លែងនៅកូរ៉េខាងត្បូងទៅហើយ ចំណែកនាង និងម្តាយមីងបានរៀនបានសូត្រ ដោយឪពុករបស់គេជួយឧបត្ថម្ភ។ នាងដឹងគុណលោក អាហ្សា ដែលមិនបោះបង់ឲ្យនាង និងម្តាយមីងប្រឈមនឹងជតាយោរយៅតែពីរនាក់។

នាងរៀននៅសាលាប្រចាំ និងមហាវិទ្យាល័យនៅសេអ៊ូល យូរៗម្តងទើបមកទីនេះ ភាគច្រើនម្តាយមីងទៅលេង តែកាលពីឆ្នាំមុន នាងត្រូវប្រឹងរៀនព្រោះជិតចប់ឆ្នាំ ទើបនិយាយលេងជាមួយម្តាយមីងតាមទូរសព្ទ ហើយដឹងរឿងគឺពេលម្តាយមីងនាំកូនទៅរេក និងនាំគ្នាមីទៅនៅកន្លែងផ្សេង សំណាងល្អដែលនាងរៀនចប់ និងទើបតែរកការងារបានធ្វើ។

ពេលនេះនាងជួយម្តាយមីងមើលថៃ ស្ងម ដែលជាកូនប្រុសនៅចម្ការអេដែន ក៏ចិត្តល្អឲ្យថ្លៃចាយវាយ ទាំងដែលនាងទើបតែមកជួយការងារ ខុសពីប្អូនប្រុសពៅរបស់ពូថ្លៃ ហេតុអីគេអន្ធពាលយ៉ាងនេះ។

"សម្តីហំណាស់ តមាត់ច្រៃតៗ"

"ខ្ញុំហំដាក់តែអ្នកខ្លះប៉ុណ្ណោះ លែង!"

"មិនលែង!"

"នេះនែ៎!"

ស៊ុនស៊ូ ឈោងយកក្រូចឆ្មុងជាសមកក្តាប់ បន្ទាប់មកក៏យកមកគោកក្បាលរបស់គេខ្លាំងៗ។ កាណែត ដែលមិនបានប្រយ័ត្នខ្លួន ទៅជាភ្ញាក់ព្រើត

តែមិនព្រមពន្លែងដៃ ទើបនាងឱនខាំដៃរបស់គេកប់ចង្កូមតែម្តង។

"អ៊ុយ!"

គេស្រែក ព្រោះឈឺផង អាម៉ាស់មុខផង ទើបពន្លែងដៃម្ខាង មកចាប់ចង្ការបស់នាង ច្របាច់ខ្លាំងៗ ទើបនាងព្រមហាមាត់។

ផាច់!

"មនុស្សថោកទាបដូចលោក សមតែត្រូវបែបនេះ"

នាងខឹង ច្រាល់ឈាមពេញមុខ ទើបយារដៃទះកំផ្លៀងគេមួយទំហឹងទោះឈឺដៃ តែឈឺចិត្តជាង ហើយងាកខ្លួន ដើរចេញ តែដើរបានបីជំហាន ក៏ត្រូវគេទាញទៅឱបរឹតវិញ និងរុញទៅពិតនឹងគុឈើ ដែលម្តងនេះគេចាប់ដៃទាំងពីររបស់នាង ច្របាច់ខ្លាំងៗ ឲ្យនាងឈឺដៃ និងរើមិនរួចផង។

"យកក្រូចគោកក្បាលខាំដៃទះកំផ្លៀងហើយគិតថាដើរគេចបានងាយៗអីចឹងឬ បើមិនធ្វើអីជាការប្រដៅនាងខ្លះ មិនសមជាខ្ញុំទេ ស៊ុនស៊ូ"

កាណែត ខាំធ្មេញក្រតៗ កែវភ្នែកមុតស្រួចក្រហមគួរឲ្យខ្លាច មុខសង្ហាឡើងក្រមូវ សំឡេងដែលបន្លឺឡើងក៏បញ្ជាក់ថាគេប្រឹងអត់ធ្មត់ ដើម្បីមិនឲ្យជះកំហឹងដាក់អ្នកនៅចំពោះមុខ ដែលច្របាច់តែបន្តិច ក៏អាចខ្ទេចដោយសារដៃរបស់គេទៅហើយ។

"ខ្ញុំនឹងស្រែកឲ្យបែកផ្ទះ"

"អញ្ជើញ ស្រែកទៅ ន្លាលខ្ញុំបានប្រាប់មនុស្សពេញមួយផ្ទះថា នាងបុះ



Scanned with CamScanner

មកស្ទួចខ្ញុំដល់ខាងក្រោម ពេលខ្ញុំមិនលេងជាមួយ ក៏ធ្វើជាឯងស្រែកឲ្យមនុស្សឆោឡោ ថាខ្ញុំរំលោភ"

"មនុស្សថោកទាប"

"ខ្ញុំថោកទាបដាក់តែអ្នកខ្លះប៉ុណ្ណោះ ហើយពេលនេះត្រូវការថោកទាបហើយ"

គេនិយាយ ព្រមទាំងញញឹមចុងមាត់ ហើយលើកដៃម្ខាងចាប់កញ្ចឹង.ករបស់នាងជាប់ និងឱនទៅថើបមាត់ បឺតជញ្ជក់ខ្លាំងៗ ជាការដាក់ទោស មិនឲ្យខ្លាំងទៀត ចំណែកដៃម្ខាងទៀតក៏ឱបរឹតណែន ដោយមានចេតនា មិនឲ្យនាងរួចខ្លួនពីការដាក់ទោសរបស់គេ។

"អឺ..."

ស៊ុនស៊ូ ឈឺទាំងមាត់ ទាំងថ្ពាល់ ព្រោះមាត់ក្តៅ និងពុកមាត់ពុកចង្កាហើយពេលនេះត្រូវគេប្របាច់ចង្កាខ្លាំងៗ ដើម្បីឲ្យនាងហាមាត់ដែលប្រឹងខ្ទប់ឲ្យនាងឈឺ និងអត់ដង្ហើមលែងបាន ទើបហាមាត់ ដកដង្ហើមចូលឲ្យជ្រៅៗដែលវាជាឱកាសឲ្យគេជ្រែកអណ្តាតចូលមកពិនិត្យប្រអប់មាត់របស់នាង កេរអណ្តាត រឹតរួតខ្លាំងៗ ឲ្យនាងហត់ ចង់អស់កម្លាំង។

នាងប្រឹងរុញច្រានគេផង គក់ផង ក្តិចខ្លាំផង ដើម្បីឲ្យគេពន្លែង និងងើបចេញ តែមិនបានសម្រេច គេខាំមាត់នាង និងកាន់តែឱបរឹត ឲ្យរាងកាយប៉ះគ្នាធ្វើឲ្យនាងមានអារម្មណ៍ប្លែកផង ភ័យខ្លាចផង កម្លាំងកំហែងក៏ខ្សោះបន្តិចម្តងៗសឹងតែទប់ខ្លួនមិននឹង ដកដង្ហើមព្ធខ្លាំងៗ។

"ជុំប! ម៉េចដែរ ទន់ជង្គង់ឬ ហ៊ឺៗ អុំ! ចង់ត្រូវមែនទេ.បាន"

កាណែត ដកបបូរមាត់ចេញ និងមុខក្រហមង៉ាំងរបស់នាង ព្រមទាំងនិយាយស្តីបេះបួយដាក់ ទើបត្រូវនាងក្រញោមុខ តែសំណាងល្អដែលគេគេចទាន់ ទើបត្រូវតែបន្តិច។ គេខាំធ្មេញក្រតៗ សម្លក់នាងថ្មៃ ហើយផ្តួលនាងឲ្យដេកលើគុ និងតាមទៅទ្រោបពីលើ ត្រសុលចូលប្រឡោះជើង ហើយថើបដាក់ទោសម្តងទៀត។

នាងប្រឹងងាកមុខចេញ តែមិនបានសម្រេច សក់វែងទៅជាសើងមម៉ើងមុខឡើងក្រហមង៉ាំង ញើសផុសពេញថ្ងាស។ នាងប្រឹងមួល.កដៃ ដើម្បីឲ្យរបូតពីដៃរបស់គេ តែមិនបានដូចគ្នា និងឈឺលើសដើម ហើយកាយវិការបែបនេះធ្វើឲ្យនាង និងគេនែបនិត្យជិតគ្នា និងរាងកាយក៏ឡើងកម្តៅ។ ទាំងដែលនាងប្រឹងតតាំង រសថើបរបស់គេទាំងកាច ទាំងទាមទារ ធ្វើឲ្យនាងភ្លើតភ្លើនតាម តែស្នាមថើបដំបូងត្រូវប្លន់យ៉ាងព្រៃផ្សៃ។

"ស្រើបស្រាលទេ ការថើបរបស់ខ្ញុំ"

កាណែត ដកបបូរមាត់ចេញ ពេលដឹងកម្លាំងតតាំងរបស់អ្នកនៅក្រោមរាងកាយចុះខ្សោយ ហើយនិយាយ ដោយសំឡេងស្អកៗ ជិតបបូរមាត់ក្រពុំបន្ទាប់មកក៏ងើបចេញ ដោយទាញនាងឲ្យមកជាមួយ។

"ហ៊ឹក! មនុស្សថោកទាប ខ្ញុំស្អប់លោក"

Scanned with CamScanner

ទឹកភ្នែករបស់នាងហូរសស្រាក់ដោយការឈឺចិត្ត។ នាងខាំមាត់ ព្រោះស្ពឹកទាំងមាត់ ទាំងរាងកាយ ហើយជេរគេដោយសំឡេងខ្សឹបៗ ញ័រខ្លួនទទ្រើតដោយការភ័យខ្លាច ខណៈនោះក៏មានអារម្មណ៍ប្លែកៗ លាយឡំគ្នា។

"ផុំៗ ពូកែមិនអីចឹង យំធ្វើអី តែទឹកដោះគោនិងស្រា ពេលលាយគ្នា វាឲ្យអារម្មណ៍ប្លែកៗ ដែរតើ នេះជាលទ្ធផលដែលក្មេងក្លាងដាក់ខ្ញុំ ស្មានថាចង់នៅជិតណាស់ក៏អី ហ៊ឺ!"

គេគ្រហឹមដាក់រួច ទើបរលាស់ដៃទាំងពីររបស់នាងមួយទំហឹង និងថយចេញបន្តិច សម្លឹងមើលរាងកាយញ័រទទ្រើតរបស់នាងដោយការចំអក។

ធ្វើឯងយំ គិតថាគួរឲ្យអាណិត ដេកចាំទៅ!

"ខ្ញុំក៏មិនចង់នៅជិតលោកដែរ លោកឯងគួរឲ្យខ្ពើម!"

ស៊ុនស៊ូ ដៀងមើលគេ ដោយខ្សែភ្នែកដែលបង្ហាញពីការខ្ពើមរអើមផងភ័យខ្លាចផង ហើយលើកដៃជូតទឹកភ្នែកដូចកូនក្មេង ជូតទាំងស្លាកស្នាមរបស់គេចោល។

"ថ្ងៃមួយនឹងបានប្ដីបែបស្អប់ៗ ខ្ពើមៗ អាំៗ បើទះទៀត ធានាថាបានប្ដីក្នុងផ្ទះបាយដោយមិនបាច់សង្ស័យ មិនជឿ សាកមើលទៅ"

គេញញឹមចុងមាត់ លើកដៃចង្អុលមុខនាង ព្រមទាំងគំរាម ពេលនាងយារដៃ។

"ចេញឲ្យផុតពីមុខខ្ញុំទៅ"



នាងបង្ខំចិត្តទម្លាក់ដៃចុះ និងបណ្ដេញគេដោយសំឡេងញ័រៗ។

"ហ៊ឺ! ស្អែកកុំភ្លេចទៅធ្វើការ មិនមែនធ្វើអណ្ដើករួញក្បាល"

អ្នកកំលោះញាក់ស្មាដាក់ លូកដៃទាំងពីរចូលហោប៉ៅ ញញឹមចំអកហើយបែរខ្នង ដើរចេញពីផ្ទះបាយដោយមានអារម្មណ៍ល្អ ទុកឲ្យនាងលើកដៃឱបខ្លួនយំខ្សឹបៗ។

"អាមនុស្សអន្ធពាល ចោកទាប ខ្ញុំស្អប់លោក ស្អប់ៗ"

ស៊ុនស៊ូ លើកដៃត្រដុសមាត់ខ្លាំងៗ និងនៅតែយំ មួយសន្ទុះក្រោយមកទើបរើសរបស់ដែលធ្លាក់រាយប៉ាយ ដាក់ឲ្យត្រូវទីត្រូវកន្លែងរបស់វា ហើយដើរចេញពីផ្ទះបាយ ទៅបន្ទប់ដេករបស់ខ្លួនដែលនៅខាងលើ ដោយមិនទាន់ចូលភ្លាមៗ ឆ្លៀតងាកឆ្វេងងាកស្ដាំ មើលសិនថា កាណែត នៅម្ដុំនេះឬអត់ ពេលមិនឃើញ ទើបចូលបន្ទប់ភ្លាម ដោយមិនដឹងទេថាត្រូវគេលួចមើលរហូត។

កាណែត ដើរចូលបន្ទប់ដេករបស់ខ្លួន ដោយអារម្មណ៍ប្លែកៗ ដែលសូម្បីគេក៏រកចម្លើយមិនបាន។

"ក្មេងជើងល្អ ចាំមើល ខ្ញុំនឹងចាត់ការនាងឲ្យចាស់ដៃ"

គេនិយាយរអ៊ូៗ លើកដៃចាប់ក្បាល ដែលមានទឹកនិងកំពឹសក្រួចជាប់សក់ បន្តដោយការស្ទាបថ្ពាល់ដែលឈឺតិចៗ ដោយសារបាតដៃតូច តែមានកម្លាំងមិនតូច ហើយបែរខ្លួន ដើរចូលបន្ទប់ទឹក ងូតទឹក សម្អាតខ្លួនប្រាណឲ្យស្រឡះល្អ ឲ្យសាយភាពតានតឹង ព្រោះស្អែកត្រូវប្រឈមនឹង ស៊ុនស៊ូ ទៀត។



Scanned with CamScanner

# ២

ព្រឹកថ្ងៃបន្ទាប់

"គិតឬ ថាខ្ញុំព្រមឲ្យមនុស្សអន្ធពាលដូចលោកមករករឿងខ្ញុំបានងាយៗ ចាំមើល បើធ្វើអីខ្ញុំទៀត ខ្ញុំនឹងលេងឲ្យចេញឈាម"

ស៊ិនស៊ី តែងខ្លួននៅមុខកញ្ចក់ធំ សម្លឹងមើលខ្លួនឯងនៅក្នុងនោះហើយក៏សង្កៀតធ្មេញ ដោយកំហឹង ព្រោះនៅចាំទង្វើដែល កាណែត ធ្វើដាក់នាងកាលពីយប់បានច្បាស់។

ស្អប់អាប្រុសមាត់ឆ្កែ ចាំមើល មួយមកដឹងតែពីរទៅ នាងមិនព្រមចាញ់គេដាច់ខាត!

"អាមនុស្សគួរឲ្យខ្ពើម"

នាងនិយាយរអ៊ូៗ ដាក់ខ្លួនឯងនៅក្នុងកញ្ចក់ ហើយខាំមាត់ និងលើកដៃត្រដុសខ្លាំងៗ មុខឡើងក្រហម ដោយការមិនពេញចិត្ត ដែលនៅចងចាំរសជាតិរបស់គេ។ នាងត្រដុសទាល់តែបបូរមាត់ចង់ជាំ ទើបដកដង្ហើមធំ ហើយដើរចេញពីបន្ទប់តែងខ្លួន។

កាំង ស៊ិនស៊ី ក្រមុំមុខស្រស់ អាយុម្ភៃបីឆ្នាំ ជាក្មួយស្រីរបស់ ស៊ូអា



ភរិយាជាទីស្រឡាញ់របស់ អេដែន បងប្រុសច្បងរបស់ កាណែត តែអ្នកមិនដឹងគិតថានាងជាប្អូន ព្រោះម្ដាយរបស់នាងមានកូនតាំងពីអាយុដប់បួនឆ្នាំ ចំណែក ស៊ូអា ជាកូនប៉ូច ទើបក្មួយ និងម្ដាយមីងមានអាយុបងប្អូនគ្នាមិនប៉ុន្មាន។ នាងរៀនចប់ មកជួយមើលថែប្អូនប្រុសជីដូនមួយ ដែលជាកូនរបស់ ស៊ូអា។ អេដែន ឲ្យប្រាក់ខែច្រើន ធ្វើឲ្យនាងក្រែងចិត្ត តែពូថ្លៃប្រាប់ថាមិនបាច់គិតច្រើនទេ ព្រោះត្រូវការឲ្យនាងជួយ ល្អជាងជួលអ្នកដទៃ ដែលនាងក៏រីករាយជួយ សួម កាន់តែគួរឲ្យស្រឡាញ់ មានការវិវឌ្ឍជារៀងរាល់ថ្ងៃ ហើយពេលនេះនាងទទួលបញ្ជាពីលោក អាហ្សា ឲ្យទៅធ្វើការជាមួយ កាណែត។

រឿងនេះ អេដែន ប្រាប់បន្ទាប់ទទួលទានអាហារល្ងាចរួច ដែលធ្វើឲ្យនាងស្រឡាំងកាំងតែម្ដង តែក៏ព្រមធ្វើតាមបញ្ជា ព្រោះលោក អាហ្សា មានគុណចំពោះនាង និងម្ដាយមីង ចំណែករឿង សួម ពូថ្លៃប្រាប់ថាមិនបាច់គិតច្រើនទេ ពេលនេះ សួម ធំហើយ អាចនាំទៅខាងក្រៅជាមួយបាន ម្យ៉ាងទៀតមានមេផ្ទះ ជិន និង អ៊ិននីម ជួយមើលថែ តែភាគច្រើនលោកប៉ាតែងតែនាំកូនប្រុស និងភរិយាជាទីស្រឡាញ់ទៅជាមួយ ទើបនាងធូរចិត្ត។

"ស៊ីៗ កាំង ស៊ិនស៊ី កុំទៅខ្លាចពួកអស់នោះ"

នាងក្រមុំលើកទឹកចិត្តខ្លួនឯង ហើយយកកាបូបមកស្ពាយ ដើរចេញពីបន្ទប់ដេក តែពេលចុះជណ្ដើរ ក៏ទប់ជើង ពេលឃើញ កាណែត កំពុងដើរសំដៅមកដោយដំណើរឲ្យរំភើយ ទើបដៀងមើលគេដោយកន្ទុយភ្នែក ព្រោះតែមិន

ចូលចិត្ត ពេលឃើញគេញញឹមចុងមាត់។ នាងចង់តែយកស្អីចាក់ភ្នែកគេឲ្យខ្វាក់ទេ ព្រោះវាមានពន្លឺផ្លេកៗ មើលទៅពោរពេញដោយល្បិច។

"វ៉ាវ! តែងខ្លួនរួចរាល់ ទៅធ្វើការនៅចម្ការហើយនេះ"

កាណែត លើកដៃអង្អែលចង្កា ញញឹមចុងមាត់ សម្លឹងមើលនាងដែលស្លៀកពាក់មានរបៀប អាវកខុបដៃខុបពណ៌ខៀវ ទីនុយនឹងខោខូវប៊ិយសាច់រឹងសមរូបរាង លើកសក់វែងចងជាកន្ទុយសេះ បង្ហួតមុខស្រស់ស្អាត ធ្វើឲ្យនាងកាន់តែគួរមើល ដល់ថ្នាក់គេអត់សរសើរមិនបាន តាមធម្មតា គេមិនសូវយកភ្នែកមើលនាងប៉ុន្មាន។

"តាមធម្មតា ខ្ញុំក៏តែងខ្លួនបែបនេះ លោកគ្មានភ្នែកមើលឃើញទេក៏អី"

នាងនិយាយទ្រគោះបោះបោកដាក់គេ ថែមដោយការសម្លក់សម្លឹង។ មិនចូលចិត្តទេដែលគេនិយាយឡកឡឺយដាក់ ទាំងដែលនាងតែងខ្លួនបែបនេះជារឿងធម្មតា។

"ហ៊ឺ! នៅសម្ដីហំដដែល យប់មិញបែបមិនទាន់មានអារម្មណ៍អី អីចឹងត្រូវខាំមាត់ញឹកញាប់ហើយបែបនេះ"

"សាកមើលមើល៍! តែហ៊ានធ្វើទៀត ខ្ញុំនឹងរកស្អីវ៉ៃក្បាលលោកឲ្យចេញឈាម"

"អ៊ូយ! គួរឲ្យខ្លាចដល់ហើយ តែខ្លាចអ្នកខ្លះជាប់ចិត្ត ទន់ដៃទន់ជើងគ្មានកម្លាំង ញ័រខ្លួនចំប្រប់ សំណាងដែលមិនថ្ងូរឲ្យឮ មិនអីចឹង ខ្ញុំប្រហែលគិតថានាងចូលចិត្ត"



កាណែត នៅតែញញឹមចុងមាត់ ហើយជ្រឹមភ្នែកមើលអ្នកនៅចំពោះមុខដោយការឡកឡឺយ។

*ឆ្កឹងឯងសម្ដីហំ ក៏ចង់ដឹងដែរ ថាហំបានប៉ុន្មានតឹក!*

"មាត់ដាច"

នាងក្ដាប់ដៃ ខាំធ្មេញក្រតៗ សម្លឹងគេមិនដាក់ភ្នែក។

"មិនឃើញដាច នៅល្អស្អាត ក្រអូបទៀត មែនទេ ហ៊ឺៗ"

គេញាក់ស្មាតិចៗ ដោយមិនញញើត ហើយធ្វើជាលើកដៃខ្ទប់មាត់ និងព្រួសខ្យល់ដង្ហើមមកហិត បន្ទាប់មកក៏ដើរមកជិត ដកដង្ហើមខ្លាំងៗ ដាក់។

"អ៊ី! ចេញឲ្យឆ្ងាយទៅ មនុស្សឡប់"

នាងរុញគេចេញ និងជេរដោយសំឡេងញ័រៗ ហើយប្រញាប់ដើរចុះទៅខាងក្រោម មានគេដើរតាមពីក្រោយ ដោយមានអារម្មណ៍ល្អ ដែលបានញ៉េះនាងឲ្យខ្លាច។

នាងដើរលឿនស្ទើរចូលបន្ទប់ទទួលទានអាហារ ដែលពេលនេះមិនទាន់មានអ្នកណាចុះមក មានតែនាង និង កាណែត ទើបជួរថ្ងូង។

"អ្នកនាង ស៊ិនស៊ី លោក កាណែត ចុះមកល្មម ខ្ញុំរៀបស្ងួចល្មម"

មេផ្ទះ ជិន ងាកមកញញឹមដាក់កំលោះក្រមុំដែលចូលមកបន្តកន្ទុយគ្នាដោយទឹកមុខខុសគ្នា ម្នាក់មុខក្រមូវ តែពេលត្រូវរាក់ទាក់ក៏ញញឹមដាក់វិញ



Scanned with CamScanner

ចំណែកម្នាក់ទៀតញញឹមញញែម ហើយពេលដាក់បង្អុយចុះក៏វាយចិញ្ចើមដាក់ឲ្យអ្នកនៅទល់មុខងាកមុខចេញជាបន្ទាន់។

"មកមិនទាន់ជួយអីទេ"

ស៊ុនស៊ូ ងាកទៅប្រាប់មេផ្ទះដោយការក្រែងរអែងចិត្ត ព្រោះព្រឹកនេះមិនបានជួយធ្វើអាហារពេលព្រឹក។

"មិនអីទេ ខ្ញុំ និង អ៊ុននីម ធ្វើតែមួយភ្លែតទេ យប់មិញសង្ស័យលោកៗឃ្លាន ខ្ញុំឃើញក្រូចរាយប៉ាយក្នុងផ្ទះបាយ និងធុងសំរាម តែក្រូចទាំងនោះផ្អែមខ្ញុំភ្លក្សហើយមិនជូរទេ តែហេតុអីបោះចោលទាំងនៅល្អក៏មិនដឹង"

មេផ្ទះប្រាប់ដោយទឹកមុខញញឹម តែពេលនិយាយដល់ក្រូចដែលភ្លក្សសាកមើលកាលពីព្រលឹម ព្រោះចង់ដឹងថាវាជូរឬអត់ ក៏ចងចិញ្ចើម ព្រោះឆ្ងល់ដែលធ្វើឲ្យ កាណែត ទប់សំណើចមិនចង់ជាប់ ចំណែក ស៊ុនស៊ូ ក្រហមមុខធ្វើភ្នែកឡេមឡាម។

"អឺ...កាលពីយប់មិញ ខ្ញុំចុះមកផឹកទឹក ធ្វើឲ្យកញ្ច្រែងផ្លែឈើធ្លាក់ អាខ្លះវាបែក អំ ទើបខ្ញុំរើសវាទៅចោល អាចរើសមិនអស់"

ស៊ុនស៊ូ ប្រញាប់ចេញមុខប្រាប់មេផ្ទះ មិនចង់ឲ្យស្ត្រីវ័យចាស់និយាយអីឬសួរអ្នកណារឿងក្រូចទៀត។

"អូ៎ៗ ខ្ញុំស្មានថាក្រូចមិនឆ្ងាញ់តើ"

"មែនហ្នឹង ឃើញបែបហ្នឹង អ្នកណាក៏គិតថាក្រូចមិនឆ្ងាញ់ដែរ លើកមុខ



លើកក្រោយ ធ្វើអីឲ្យវាស្រួលបួលបន្តិច កុំស្លាក់ស្លើត"

កាណែត ប្រឹងទប់សំណើច ធ្វើឫកបេះបួយដាក់នាង ពេលនិយាយដល់ហេតុការណ៍កាលពីយប់មិញ។

"វាជារឿងរបស់ខ្ញុំ ឬថាខ្ញុំយកក្រូចបោកក្បាលលោក!"

នាងពេបមាត់ សម្លក់សម្លឹងគេ ហើយឡកឡឺយដាក់វិញ។

"សម្ដីហំណាស់"

គេបាញ់ខ្សែភ្នែកកាច និងញេញចង្អូមដាក់ និយាយខ្សឹបៗ ដាក់នាងដែលតមាត់ប៉ប៉ែះ។

"ហ៊ឺ!"

ស៊ុនស៊ូ ធ្វើសំឡេងងឺះដាក់ ហើយយកចិត្តទុកដាក់ចំពោះអាហារនៅចំពោះមុខវិញ រង់ចាំម្ដាយមីង និងពូថ្លៃចុះមក ដើម្បីទទួលទានជុំគ្នា ម្យ៉ាងទៀតនាងក៏មិនសូវឃ្លានប៉ុន្មានដែរ តែក្លិនអាហារ វាធ្វើឲ្យលេបទឹកមាត់។

"ញ៉ាំមុនហើយ ន្ទាលចូលចម្ការ នាំកម្មករទៅបង្រៀនការងារបន្តិច"

"ចាំ លោក កាណែត លោក អេដែន និងអ្នកស្រី ចុះម៉ោល្មម អ៊ុននីមទៅយកអ្នកប្រុសតូចឲ្យឆាប់ឡើង ចាំខ្ញុំជួសបាយ"

មេផ្ទះ ជិន ងក់ក្បាលដាក់ កាណែត ហើយងាកទៅមើលទ្វារ ឃើញចៅហ្វាយបីនាក់ទៀតដើរចូលមកល្មម ទើបបញ្ជា អ៊ុននីម ឲ្យទៅជួយយកអ្នកប្រុស ស្លូម មកអង្គុយលើកៅអីសម្រាប់ក្មេងនៅជិតក្បាលតុ ដែលជាកៅអី



Scanned with CamScanner

របស់លោក អេដែន នោះឯង។

ពេលដាក់អ្នកប្រុសអង្គុយហើយ អ៊ុននីម ក៏យករបស់លេងមកដាក់ឲ្យ ចំណែក ស៊ូអា ពេលដាក់បង្គុយចុះ ដោយមានស្វាមីទាញកៅអីឲ្យហើយក៏ងាកទៅញញឹមដាក់ក្មួយស្រី និងប្អូនថ្លៃពៅ។

"មិនបាច់ញញឹមដាក់វាទេ អាជើងល្អហ្នឹង"

អេដែន ប្រាប់ភរិយាខ្សឹបៗ បង្កប់ដោយការហួងហែង។

"អេដែន"

ស៊ូអា ងាកទៅធ្វើមុខខ្វះដាក់ស្វាមី គ្រាន់តែញញឹមដាក់ប្អូនប្រុសរបស់គេក៏មិនបានដែរ ប្រុសឆ្កួតនេះមិនដឹងជាហួងហែងស្អីណាស់ណា ចាំមើលទៅនាងនឹងញញឹមដាក់កម្មករពេញមួយចម្ការ។

"ហួងហែងហ្នឹងណ៎ា"

អេដែន និយាយដោយទឹកមុខប្រាកដប្រជា តែឮខ្សឹបៗ ខ្លាចប្រពន្ធខឹង ធ្វើឲ្យអ្នករួមតុលួចញញឹម ហើយនាំគ្នាទទួលទានអាហារពេលព្រឹក។

"លោក កាណែត សុំផ្ញើ ស៊ុនស៊ូ ផង បើមានអីខុសឆ្គង ប្រាប់បាន"

ស៊ូអា បារម្ភពីក្មួយស្រី ព្រោះពីរនាក់នេះមិនសូវចូលចិត្តគ្នាប៉ុន្មាន ទើបខ្លាចមានការប៉ះទង្គិចកើតឡើង។

"បាទ ខ្ញុំជាអ្នកបង្រៀនការងារដល់នាង តែប្រហែលមិនពិបាក នាងក៏ធ្លាប់ធ្វើការក្រុមហ៊ុន គិតថាធ្វើបាន ការងារនៅចម្ការស្រួលៗ ទេ មិនពិបាក



នាងធ្វើការ"

កាណែត ប្រាប់បងថ្លៃ ហើយលើកកាហ្វេផឹក ទាល់តែអស់ពីពែង តាមដោយទឹកសុទ្ធ រួចរាល់ក៏ជូតមាត់ ងាកមកមើលមុខ ស៊ុនស៊ូ មិនដាក់ភ្នែក។

"មិនច្បាស់ដែរ"

នាងក៏ទទួលទានផ្លែតដែរ ទើបងាកទៅនិយាយដាក់គេដោយសំឡេងដូចក្រូចឆ្មារអត់ទឹក ធ្វើឲ្យម្ដាយមីងដកដង្ហើមធំ ហើយងាកទៅមើលស្វាមីដូចសុំយោបល់ តែ អេដែន មិននិយាយអី គិតតែមើលកំលោះក្រមុំជាការវាយតម្លៃថាត្រឹមថ្ងៃដំបូងក៏មិនចុះសម្រុងនឹងគ្នាទៅហើយ ហើយថ្ងៃបន្តបន្ទាប់នឹងទៅជាយ៉ាងណា។

"អីចឹងសុំទៅសិនហើយ នាំទៅមើលការងារ ន្ទាលឲ្យជួយធ្វើនេះធ្វើនោះជាការរៀនសូត្រ"

"អ្ហឹម"

អេដែន ងក់ក្បាល និងតាមមើលប្អូនប្រុសដែលដើរចេញទៅ ចំណែកក្មួយប្រសាក៏ងើបចេញពីតុ ខិនគំនាប់ជាការលាពួកគេ។

"ត្រូវចេះអត់ធ្មត់ ស៊ុនស៊ូ"

"ចាំ មីង ខ្ញុំនឹងអត់ធ្មត់"

ស៊ុនស៊ូ សន្យាចំពោះម្ដាយមីង ហើយងាកទៅមើលពូថ្លៃបន្តិច ព្រមទាំងដកដង្ហើមធំ បន្ទាប់មកទើបដើរទៅតាមប្រុសមាត់ដាច ដែលពេលនេះចាំនៅ



Scanned with CamScanner

លើឡាន បញ្ឆេះម៉ាស៊ីនរួចរាល់ហើយ និងមើលមកនាង ដោយខ្សែភ្នែកកាច ថែមទាំងចុចស៊ីហ្វ្លេតម្លង់ពីរបីដងទៀត។

"អែនអននៅហ្នឹងហើយ ឲ្យវារហ័រហួនបន្តិចបានទេ"

កាណែត ស្តីឲ្យ ដោយអារម្មណ៍មិនសូវល្អ។ មុននេះស្មានថានាងដើរតាមតើ តែមានឯណា គិតតែពីស្តីកស្រពន់នៅហ្នឹងហើយ។

ស៊ុនស៊ូ ខាំមាត់ ប្រឹងដើរញាប់ជើង មកឡើងឡានរបស់គេទាំងបង្ខំចិត្ត ហើយពេលចូលអង្គុយហើយ ត្រូវចាប់ប្រដាប់ចាប់នៅលើក្បាល ព្រោះបិទទ្វាររួច គេក៏បញ្ជាឡានចេញទៅទាំងកញ្ឆក់កញ្ឆេង ដោយមិនខ្វល់ពីអ្វីទាំងអស់។

"បើកឡានម៉ាកស្អីហ្នឹង!"

នាងគំហកដាក់ដោយការមិនពេញចិត្ត ព្រោះអម្បាញ់មិញធ្វើឲ្យបេះដូងរបស់នាងធ្លាក់ទៅនៅនឹងភ្នែកគោ សំណាងដែលនាងចាប់កៅអីជាប់។

"បើកម៉ាកខ្ញុំហ្នឹង ចង់យ៉ាងម៉េច"

កាណែត ងាកមកវាយចិញ្ចើមដាក់ អ្នកដែលធ្វើភ្នែកឆ្មាសដាក់គេ ដោយមិនញញើតញញើម។ គេបើកឡានតាមអារម្មណ៍ផ្ទាល់ខ្លួន និងលួចជៀងមើលអ្នកនៅក្បែរខ្លះៗដែរ ឃើញនាងស្រវេស្រវាទាញខ្សែក្រវាត់ការពារមកពាក់ មុខឡើងក្រមូវរហូតដល់ចម្ការតែ ហើយធ្វើបាបដោយការជាន់ហ្វ្រ៊ាំងទាំងគំហុក រំះធ្វើឲ្យនាងផ្កាប់មុខ សំណាងល្អដែលពាក់ខ្សែក្រវាត់ការពារ។

"បើកម៉ាកអន់ៗ នេះឯង ពួកបង្អោះម៉ូតូ បើកល្អជាងទៅទៀត អន់មែន"

ស៊ុនស៊ូ ដោះខ្សែក្រវាត់ការពារ ហើយងាកទៅធ្វើមុខឡូកឡឺយ ព្រមទាំងព្រួសខ្យល់ដង្ហើមដាក់ខ្លាំងៗ ទៀត មុនពេលចុះពីឡាន ធ្វើឲ្យគេមួម៉ៅ ប្រញាប់ចុះពីឡាន បិទទ្វារលាន់ប៉ុង ដើរលឿនស្លេវមករក ជាការរករឿង។

"ម៉េច! ចង់ធ្វើអីខ្ញុំ កូនចៅរបស់លោកកំពុងមើលម៉ោពីនុះ ម៉ោ ចូលម៉ោ បើខ្លាំង"

នាងលើកដៃឱបទ្រូង ធ្វើឫកខ្លាំងដាក់ជាការផ្ចាញ់ផ្ចាល ព្រោះពេលនេះកូនចៅរបស់គេកំពុងអើត.កមកមើលច្រើននាក់ ដែលធ្វើនាងកក់ក្ដៅចិត្ត។

"សម្តីហំណាស់ តិចទៀតគង់តែដឹងទេថា ហំដូចមាត់អត់ តាមម៉ោ"

កាណែត ខាំធ្មេញក្រតៗ ជាលើកទីប៉ុន្មានហើយក៏មិនដឹង តាំងពីព្រឹកមក លើកដៃម្ខាងច្រត់ចង្កេះ ម្ខាងទៀតលើកចង្អុលមុខនាង។ គេចង់ប្រដៅឲ្យរាងចាល តែទាស់ត្រង់ថាកូនចៅកំពុងតែមើលមកនេះឯង។

*ផ្ញើទុកសិនចុះ តិចទៀតនឹងគិតទាំងដើមទាំងការ ក្មេងជើងល្អ!*

គេគិតនៅក្នុងចិត្តដោយការចងអាឃាត ហើយបែរខ្លួន ដើរមុខក្រមូវសំដៅការិយាល័យ។

"ខ្លាចងាប់ហើយ ធ្វើដូចខ្លាឃ្មុំត្រូវឃ្មុំទិច សមមុខ"

ស៊ុនស៊ូ ជ្រួញច្រមុះ ពេបមាត់ដាក់ និងធ្វើភ្នែកឡេមឡាម ពេលដើរតាមចូលការិយាល័យ។ ពេលចូលទៅដល់ ឃើញគេឈរបញ្ជាការងារបុរសមុខមាត់សង្ហាម្នាក់ ទើបដើរមកឈររាងឆ្ងាយបន្តិច។



Scanned with CamScanner

"នេះជំនួយការលេខារបស់ឯង សុងចូ... កាំង ស៊ុនស៊ូ នាងជាក្មួយស្រីរបស់ ស៊ូអា"

"សួស្តី"

នាងឱនគំនាប់ និងញញឹមដាក់ សុងចូ តែធ្វើឲ្យអ្នកណែនាំមានការមិនពេញចិត្ត ដោយគ្មានហេតុផល។

"ហុង សុងចូ ជាលេខារបស់ខ្ញុំ ម្យ៉ាងទៀត គេមានសង្សារហើយ"

"ខ្ញុំដឹងហើយ លោក កាណែត"

"ល្អ ដឹងហើយក៏ល្អ កុំឲ្យពិបាកតាមដាន ចាប់ផ្តើមការងារថ្ងៃនេះ"

"អ៊ុំ! តើឲ្យអ្នកនាង កាំង ធ្វើឯកសារអីមុន ន្ទាលខ្ញុំត្រៀម"

"មិនបាច់ទេ ខ្ញុំឲ្យនាងទៅធ្វើការនៅចម្ការសិន ព្រឹកនេះទៅជួយកម្មករបេះស្លឹកតែ មុនថ្ងៃត្រង់ ទៅជួយការងារចុងភៅ ធ្វើម្ហូបឲ្យកម្មករ ឯងនាំនាងទៅ ហើយឲ្យមេការរាយការណ៍ផង ថាបេះស្លឹកតែបានច្រើនទេ មេចុងភៅផង ថាការងារក្នុងផ្ទះបាយយ៉ាងម៉េចយ៉ាងម៉ា"

"បេះស្លឹកតែឬ?"

"មែន ម៉េច លេខា ហុង មិនដឹងទេក៏អី អ្នកនាង កាំង ពូកែចង់ងាប់រឿងប៉ុណ្ណឹង តូចតាចណាស់ ឯងមិនបាច់បារម្ភទេ"

"មិនអីទេ លេខា ហុង ខ្ញុំធ្វើបាន គ្រាន់តែបេះស្លឹកតែ និងធ្វើម្ហូបហ្នឹង ការងារស្រួលៗ ល្អជាងអង្គុយធ្វើឯកសារ សម្ងំនៅតែក្នុងបន្ទប់ ដែលប្រហែលថប់ដង្ហើមស្លាប់ហើយ ខូចបរិយាកាសការងារអស់ល្មម តោះ ទៅ ជ្រេញមុខ"

នាងខ្ជិលស្តាប់គេដុកដាន់ទៀត ទើបលូកមាន់ ហើយសម្រេចចិត្តឲ្យ សុងចូ នាំទៅធ្វើការ តែសម្តីរបស់នាង ធ្វើឲ្យ កាណែត មុខក្រមូវ។

"អី...ខ្ញុំសុំទៅសិនហើយ"

"ឆាប់ទៅ ឆាប់ម៉ោវិញ ខ្ញុំមានការងារច្រើនណាស់ឲ្យឯងធ្វើ"

កាណែត ប្រាប់លេខាធិការរបស់ខ្លួន ហើយដើរចូលបន្ទប់ធ្វើការ ធ្វើឲ្យ សុងចូ លួចព្រួសខ្យល់ដង្ហើមតាមមាត់ ព្រោះធូរទ្រូង ដោយមិនស្មានទេថាមានអ្នកណាហ៊ានតមាត់នឹងចៅហ្វាយប៉ប៉េះបែបនេះទេ ថែមទាំងពូកែជៀមដាមទៀត ធ្វើឲ្យចៅហ្វាយខាំធ្មេញក្រតៗ តែម្តង។

គេដើររលេះរលាំង មកតាម ស៊ុនស៊ូ នាំនាងចូលចម្ការតែ ដែលពេលនេះកម្មករកំពុងបេះស្លឹកតែយ៉ាងសស្រាក់សស្រាំ។

"មេការ ចូ លោក កាណែត ឲ្យអ្នកនាង កាំង មកជួយបេះស្លឹកតែ ពឹងមេកាជួយបង្រៀនផង ពេលបេះរួច ឲ្យទៅជួយចុងភៅធ្វើម្ហូប លោក កាណែត បញ្ជាម៉ោ"

សុងចូ ប្រាប់មេការកម្មករសម្បុរស្រគាំ មាឌដំបង មុខកាច តែចិត្តល្អ ទើបមេការងក់ក្បាល និងហុចកន្ត្រកសម្រាប់ដាក់ស្លឹកតែឲ្យ និងបង្រៀននាង ដោយគេឈរមើលមួយភ្លែត ទើបត្រឡប់មកការិយាល័យវិញ ដើម្បីរាយការណ៍ជូនចៅហ្វាយ។



Scanned with CamScanner

...

បន្ទាប់ពីបេះស្លឹកតែបានមួយសន្ទុះធំ ស៊ុនស៊ូ ក៏លើកដៃជូតញើស និង មើលស្លឹកតែក្នុងកន្ត្រកដែលស្ពាយជាប់ខ្នង ពេលឃើញតិចពេក ទើបបេះបន្ត ដោយមិនរអ៊ូរទាំ ព្រោះអ្នកដទៃធ្វើបាន ហេតុអីនាងធ្វើមិនបាន ការងារប៉ុណ្ណឹង សោះ។

"អ្នកនាង កាំង ប៉ុណ្ណឹងបានហើយ ខ្ញុំនាំទៅជួយការងារនៅផ្ទះបាយ នេះ មួយសន្ទុះទៀត ផ្អាកបេះហើយ"

"អូខេ មេការ ចូ តែខ្ញុំបេះបានបន្តិចទេ"

នាងហុចកន្ត្រកឲ្យមេការ ដោយទឹកមុខស្រពោន ព្រោះខ្លួនឯងបេះបាន តិចពេក។

"មិនអីទេ ដំបូងៗ គឺអីចឹងហើយ ពេលបេះយូរៗទៅ នឹងស្ទាត់ដូចគេដូច ឯងហើយ តែអ្នកនាង កាំង ប្រហែលមិនមកញឹកញាប់ទេ"

"តាមពិតខ្ញុំត្រូវជាជំនួយការលេខា តែលោក កាណែត ឲ្យមកបេះស្លឹកតែ សាកល្បងសិន"

"អីចឹងឬ ខ្ញុំមិនដឹងសោះ ខ្ញុំក៏គិតដែរ មិនគួរណាឲ្យមកធ្វើការក្នុងចម្ការ ហើយហេតុអីលោក កាណែត មិននាំទៅបង្រៀនការងារក្នុងការិយាល័យ"

"គេចង់ឲ្យរៀនការងារសិន មេការ ចូ នាំខ្ញុំទៅរោងអាហារទៅ"

"បាទ"



បុរសវ័យចាស់ញញឹមដាក់ ហើយនាំនាងទៅរោងអាហារដែលពេលនេះ មានចុងភៅពីរនាក់កំពុងធ្វើការ។

"យាយ អាន ខ្ញុំនាំ អ្នកនាង កាំង ឲ្យមកជួយការងារ នាងជាជំនួយការ លេខាថ្មី តែលោក កាណែត ឲ្យមកសាកល្បងការងារនៅទីនេះសិន"

ស៊ុនស៊ូ ញញឹមពព្រាយ ព្រមទាំងឱនគំនាប់មេចុងភៅវាងជាត់ មុខមិន ស្រស់ ដែលមើលមកនាងបន្តិច ងើយងក់ក្បាលដាក់។

"អីចឹងជួយហាន់សាច់ជ្រូកទៅ កំពុងវល់"

"ចាំ"

នាងយកអាវការពារប្រឡាក់ពីកន្លែងព្យួរមកចងនឹងចង្កេះ ហើយដើរទៅ កាន់កាំបិត ហាន់សាច់ជ្រូកដោយកាយវិការរៀសរវ៉ៃ ដែលធ្វើឲ្យមេចុងភៅ មាន ការពេញចិត្ត។

"អ្នកនាង កាំង កាប់ឆ្អឹងជំនីរឲ្យផង ខ្ញុំស្ងោរជ្រក់តីមឈី ខ្ញុំនិងពីរនាក់ នោះទៅយកបន្លែ និងសាច់សត្វដែលគេយកមកឲ្យមួយភ្លែត បើទឹកពីរឆ្នាំងនេះ ពុះហើយ ជួយបន្ថយភ្លើងផង កុំឲ្យវាពុះគគ្រុក"

"ចាំ មេចុងភៅ អាន អីចឹងខ្ញុំធ្វើឲ្យក៏បាន ស្ងោរជ្រក់តីមឈីឆ្អឹងជំនីរ ខ្ញុំ ចេះស្ល ចំណែកសាច់ជ្រូកចិញ្ច្រាំឆាបន្លែ និងបំពងត្រី ខ្ញុំធ្វើបាន"

"ចេះធ្វើឬ ល្អដល់ហើយ អីចឹងអ្នកនាងធ្វើ ខ្ញុំអស់បារម្ភហើយ ព្រោះត្រូវ ពិនិត្យមើលអីវ៉ាន់ដែលគេដឹកម៉ោឲ្យ និងជួយលើកទៅទុកដាក់ ន្ទាលឆាប់បាន

Scanned with CamScanner

ម៉ោវិញ"

"ចាំ មេចុងភៅ មិនបាច់ប្រញាប់ទេ ធ្វើការតាមសម្រួលចុះ ចាំខ្ញុំស្ល"

នាងញញឹមប្រាប់ ព្រោះឃើញថាបន្លែសាច់រៀបចំរួចហើយ នៅឡើយតែដាក់ស្លប៉ុណ្ណោះ ទើបមេចុងភៅ ងាកទៅហៅក្មេងៗ ពីរនាក់ឲ្យដើរតាម។

ស៊ុនស៊ូ ធ្វើម្ហូបឆ្អិនពីរមុខហើយ ទើបចិញ្ច្រាំសាច់ជ្រូក ដើម្បីធ្វើមួយមុខទៀត តែចិញ្ច្រាំបានមួយសន្ទុះ ក៏មានអ្នកដើរមកឈរចំអកនៅទល់មុខ។

"ម៉េចដែរ ការងារស្រួលៗ ខ្ញុំប្រាប់ហើយថាធ្វើបាន"

កាណែត លើកដៃឱបទ្រូង មើលអ្នកនៅចំពោះមុខ ដែលពេលនេះថ្ពាល់ទាំងពីរក្រហមឆ្អាំងគួរឲ្យមើល ដើងសក់សើមដោយញើសតិចៗ ទើបនាងលើកដៃអារជូត។

"ធ្វើបាន មិនឃើញទេក៏អីថាកំពុងធ្វើ"

"មានថាអីឯណា នេះទៅណាអស់ហើយ ?"

"ទៅយកសាច់បន្លែដែលគេដឹកម៉ោ លោកម៉ោរញ៉េរញ៉ៃអីនៅទីនេះ"

"ម៉ោឆែកការងារនាងបន្តិច ថាធ្វើបានល្អប៉ុណ្ណា"

"ឃើញហើយ ក៏ទៅវិញទៅ ន្ទាលខ្ញុំធ្វើបន្ត ទើសទែង"

"នាងថាអ្នកណាទើសទែង ?"

គេដើរមកជិត ស្រវាចាប់ដៃរបស់នាង ទាញឲ្យងាកមកមើលមុខចំៗ។

"អុំ !"



ស៊ុនស៊ូ ឧទាន ក្តាប់កាំបិតជាប់ ព្រោះគេទាញលឿនពេក។

"ប៉ុណ្ណឹងធ្វើឯងភ្ញាក់ បើខ្ញុំថើបនៅត្រង់នេះនឹងភ្ញាក់ជាងនេះទេ"

"សាកមើល បើលោកមិនខ្លាចអានេះ"

"ហ៊ំ !"

នាងលើកចិញ្ចើម និងលើកកាំបិតបង្ហាញ ទើប កាណែត ពន្លែងដៃនាងភ្លាម និងថយឲ្យឆ្ងាយ លើកដៃស្ទាបទ្រូងខាងឆ្វេង ព្រោះស្រៀវនឹងមុខកាំបិតសស្ងាចដែលបែរមុខមករកគេ។

"នាងលេងឆ្លូតស្អីហ្នឹង ស៊ុនស៊ូ"

"គឺឆ្លូតដូចដែលលោកចង់ឆ្លូតហ្នឹង"

"ហ៊ានអ្ហុំ ! មិនខ្លាចឈឺខ្លួនទេក៏អី ខ្ញុំនឹងចាត់ការនាងវិញឲ្យចាស់ដៃ ហ៊ានតែធ្វើមើល៍ បើមុខសង្ហារបស់ខ្ញុំមានស្នាម នាងត្រូវតែទទួលខុសត្រូវ ចង់សាកទេ ?"

គេធ្វើជាដំឡើងសំឡេង ជាការដាស់តឿន ដើម្បីឲ្យនាងខ្លាច ដែលត្រឹមប៉ុណ្ណឹងនាងក៏ខ្លាចនៅក្នុងចិត្តបាត់ទៅហើយ ព្រោះគិតថាគេមិនបានគំរាមលេងតែខាងក្រៅនៅតែខ្លាំង។

"ចូលម៉ោមើល៍ ចូលម៉ោ ខ្ញុំនឹងយកប៉ុងតោនេះចិញ្ច្រាំ មិនជឿ ចង់សាកក៏ចូលម៉ោ !"

ស៊ុនស៊ូ យារកាំបិត ដោយចាប់វាជាប់ ព្រោះខ្លាចរបូត ទាំងបែកញើស



Scanned with CamScanner

ដោកខ្នង បាតដៃត្រជាក់ស្រេង មុខម្ដងស្លេកម្ដងក្រហម មាត់ម្ដងខ្ចីបម្ដងលា ខ្យល់ដង្ហើមក៏ដកមិនពេញពោះ ញ័រទ្រូងតិចៗ ពេលគេមិនព្រមថយ។

"គិតថាខ្ញុំខ្លាចក៏អី កាំបិតប៉ុណ្ណឹង បើនាងខ្លាំងមែន ម្ល៉េះណោះវាដោតជាប់ក្បាលរបស់ខ្ញុំទៅហើយ ហ៊ឺ! ធ្វើឯងហំ"

"សាកមើលទេ"

នាងព្រិចភ្នែកញាប់ស្លេក មិនស្មានថាគេកំណាចបែបនេះ ធ្វើឯងមកឈរឱបដៃ ញញឹមពេបជ្រាយ បែបនេះសមតែកាប់ចោលមែនទេ។

"ហ៊ឺ! ខ្លាចថាកាំបិតឆាសតែបន្តិច ឃើញឈាម ក៏ស្រែកចាចទេដឹង ដាក់ចុះទៅ មិនចុកដៃទេក៏អី ដៃញ័រហើយនុ៎ះ"

កាណែត ធ្វើជាមិនញញើត ទាំងចិត្តកំពុងស្រៀវៗ កាំបិតមិនមែនរបស់លេង បើនាងគប់មកមែន មិនច្បាស់ទេថាគេគេចទាន់ឬអត់។

"មិនបាច់ម៉ោចេះដឹងរឿងខ្ញុំទេ ចេញឲ្យផុតទៅ"

នាងធ្វើចិត្តខ្លាំងដាក់ យារដៃ តែមិនទាន់គប់ភ្លាមៗ និងដើរទៅរក ដើម្បីគំរាមគេ។

"មិនឃើញអីប្រាកដប្រជាទេ គិតថាខ្លាចក៏អី ញ័រដូចខ្មោចចូលបែបនេះ ស្ទួរតាមត្រង់ ធ្លាប់សម្លាប់អីខ្លះទេនេះ អាំៗ មិនបាច់ឆ្លើយក៏បាន ចាំខ្ញុំរកនឹកឲ្យអ្ហៃៗ ប្រហែលមូសស្អីអស់នោះឯង"

ខ្ទាប់!



ប៉ឹក!

សំឡេងកាំបិតត្រូវយារកាប់គុ ធ្វើឲ្យមនុស្សប៉ប៉ាច់ប៉ប៉ោចភ្ញាក់ព្រើត ស្ទុះថយក្រោយមួយជំហាន កែវភ្នែកមុតស្រួចក៏កន្ទ្រាក់ បេះដូងលោតញាប់ លើកដៃឱបទ្រូង ហើយដកដង្ហើមខ្លាំងៗ សម្លឹងមើលនាងមិនដាក់ភ្នែក។

"ខ្ញុំប្រាប់ថាឲ្យចេញទៅ!"

មុខរបស់ ស៊ុនស៊ូ ឡើងក្រហមង៉ាំងដោយសារកំហឹង ពេលគេនៅតែនិយាយបេះបួយមិនឈប់។

"និយាយប៉ុណ្ណឹងសោះ ធ្វើឯងខឹង ទៅក៏បាន"

កាណែត ប្រឹងលេបទឹកមាត់ ធ្វើជាញញឹមបេះបួយ និងត្រដាងដៃដាក់ញាក់ស្មាតិចៗ ហើយព្រមដើរចេញពីត្រង់នោះ ត្រឡប់ទៅការិយាល័យវិញដោយដំណើរស្វាហាប់ ដើម្បីមិនឲ្យអាម៉ាស់មុខពេក។

"អាំ!"

នាងកម្ចាយកំហឹងដោយការចិញ្ច្រាំសាច់ជ្រូកញាប់ដៃ។

"អាមនុស្សបេះបួយ អាមនុស្សល្បិចកល អា..."

"មិញខ្ញុំឃើញ លោក កាណែត ស្មានថាម៉ោកុម្ម៉ង់អីតើ"

"គ្មានអីទេ មេចុងភៅ គេគ្រាន់តែម៉ោមើលថា បញ្ជាការងារខ្ញុំគ្រប់ហើយនៅ តែប៉ុណ្ណោះ"

"អ៊ីចឹងឬ តែប្លែក ក្រែងថាជាជំនួយការលេខា ហេតុអីមកជួយធ្វើអាហារ

នៅផ្ទះបាយ"

"ប្រហែលចង់ដឹងថា ខ្ញុំចេះធ្វើអីឬអត់ទេដឹង កុំទៅខ្វល់ពីគេអី ឆាប់ធ្វើការវិញ ខ្លាចមិនទាន់ថ្ងៃត្រង់"

ស៊ុនស៊ូ សើចញឹមៗ ដាក់ស្ត្រីវ័យចាស់។ សំណាងដែលអម្បាញ់មិញគ្មានអ្នកណាឃើញ ព្រោះកំពុងជួយលើកត្រីសាច់ទៅទុកដាក់ មិនអីចឹង នាងមុខជាខ្មាសគេមិនខាន។

ពេលចម្អិនម្ហូបអាហាររួចរាល់ នាងក៏ជួយដួសឲ្យកម្មករដែលតម្រង់ជួរចូលមកទទួលទាន។

"ម្ហូបឆ្ងាញ់គ្រប់មុខ ខ្ញុំចូលចិត្ត អ្នកនាង កាំង ពូកែដល់ហើយ"

មេចុងភៅសរសើរ ញញឹមចង់រហែកមាត់តែម្តង។

"មីង ស៊ូអា បង្រៀនខ្ញុំ"

"មីង ស៊ូអា? អ្នកស្រី ដែលជាភរិយារបស់លោក អេដែន ឬ?"

"ចាំ"

"អូ! អីចឹងតើបានជាមើលមុខទៅប្រហែលៗ តាមពិតជាក្មួយស្រីរបស់អ្នកស្រីនេះឯង ខ្ញុំថាមុខប្រហែលៗ ដូចធ្លាប់ឃើញនៅឯណា សុទ្ធតែជាគ្នាឯង"

ស្ត្រីវ័យចាស់ទះជង្គង់មួយដៃ ធ្វើឲ្យកូនកាំបិតពីរនាក់សើចញឹមៗ។

"កម្មករចូលម៉ោហើយ ដួសម្ហូបៗ"

នាងលើកដៃខ្ទប់មាត់សើចតិចៗ ហើយជួយដួលម្ហូបអាហារឲ្យកម្មករ



កាណែត និង សុងចូ ក៏ដើរមកអង្គុយនៅតុនៅមិនឆ្ងាយប៉ុន្មាន មានកម្មករលើកចាយម្ហូបយកទៅឲ្យ ទើបលួចដៀងមើលគេបន្តិច និងមិនចូលចិត្តទេដែលគេចាញ់ខ្សែភ្នែកមើលមកខាងណេះរហូត ដូចចង់ចាប់កំហុសយ៉ាងអីចឹង។

"ថ្ងៃនេះម្ហូបឆ្ងាញ់គ្រប់មុខ អ៊ំ អាន រសជាតិឆ្ងាញ់"

កាណែត ដើរមកនិយាយជាមួយមេចុងភៅ អាន តែកន្ទុយភ្នែកដៀងមើលអ្នកនៅក្បែរនោះញឹកញាប់។

"អូ្ហ! មែនឬ បញ្ជាក់ថាថ្ងៃមុនៗ ខ្ញុំធ្វើមិនឆ្ងាញ់ទេមើលទៅ"

"មិនមែនអីចឹងទេ អ៊ំ អាន អ៊ំធ្វើឆ្ងាញ់ តែថ្ងៃនេះរសជាតិរាងចាស់បន្តិចតែចាស់ឆ្ងាញ់"

"ថ្ងៃនេះ ខ្ញុំធ្វើតែអាហារបំពងប៉ុណ្ណោះ ចំណែកសម្ល អ្នកនាង កាំង ជាអ្នកធ្វើ ឆ្ងាញ់បែបនេះ ត្រូវឲ្យមកជួយផ្សំគ្រឿងញឹកញាប់ហើយ"

មេចុងភៅសើចញឹមៗ ឃើញទឹកមុខរបស់កំលោះក្រមុំហើយ ដូចគូស្នេហ៍កំពុងងរង៉ក់គ្នា។

"អូ្ហ! អីចឹងទេឬ អាចទទួលយកបាន"

កាណែត ក្រឡាស់សម្តីភ្លាម តែក៏លួចស្រឡាំងកាំង ដែល ស៊ុនស៊ូ ធ្វើម្ហូបបានឆ្ងាញ់យ៉ាងនេះ។

"តាមម៉ោ ពេលរសៀលឲ្យ សុងចូ បង្រៀនការងារនៅការិយាល័យ"

"តិចទៀត ខ្ញុំទៅ នៅជួយលាងចានឆ្នាំងសិន មិនទាន់ដល់ម៉ោងធ្វើការផង

មិនបាច់ប្រញាប់ទេ"

"ស៊ុនស៊ូ"

អ្នកកំលោះខាំធ្មេញក្រតៗ ដាក់ខ្នងរបស់អ្នកដែលនិយាយចប់ក៏ធ្វើធើយ ដោយការដើរចូលផ្ទះបាយ បោសសម្អាតនៅក្នុងនោះ មិនខ្វល់ពីគេទៀត ដែលវាធ្វើឲ្យគេក្តៅឆេវ ក្តាប់ដៃណែន បែរខ្នង ដើរចេញទៅរោងអាហារ ត្រឡប់ទៅការិយាល័យវិញ ក្រោមការភ្ញាក់ផ្អើលរបស់គ្រប់គ្នា ខណៈនោះមេចុងភៅ អានដែលលើកដៃស្ទាបទ្រូង មិនស្មានទេថាមានអ្នកហ៊ានតមាត់នឹងចៅហ្វាយនាយ ដោយមិនត្រូវចៅហ្វាយធ្វើអី បានតែធ្វើមុខក្រមូវ ដើរចេញទៅបាត់។

ស៊ុនស៊ូ មិនចាប់អារម្មណ៍អ្វីទាំងអស់ ក្រៅពីធ្វើការក្នុងផ្ទះបាយទាល់តែដល់ម៉ោង ទើបដើរទៅការិយាល័យ សុងចូ ក៏យកការងារដែលចៅហ្វាយបញ្ជាមកដាក់លើតុ ដែលរៀបចំទុកឲ្យនាងមុននេះ និងជួយបង្រៀនការងារខ្លះៗ ដែលពេលខ្លះគេឃើញនាងដកដង្ហើម តែមិនអ៊ូរទាំឲ្យឮ។

ពេលល្ងាច

កាណែត បិទឯកសារដែលខ្លួនឯងត្រួតពិនិត្យរួចរាល់ ក៏ងើបចេញពីកៅអី ពត់ខ្លួនពត់ប្រាណ ហើយដើរចេញពីបន្ទប់ ដោយកាន់ឯកសារមកឲ្យលេខាធិការ ដែលអង្គុយនៅមុខបន្ទប់។

"ខ្ញុំពិនិត្យការងាររួចហើយ ស្អែកយកទៅបើកខ្ទង់ចំណាយបាន តាម



ការកុម្ម៉ង់ លេខា ហុង"

"បាទ លោក"

សុងចូ យកឯកសារទៅទុកដាក់ក្នុងទូឲ្យមានរបៀប ដោយនឹកឆ្ងល់ថាតាមធម្មតា ចៅហ្វាយមិនធ្លាប់ពិនិត្យឯកសារលម្អិតយ៉ាងនេះទេ មិនដឹងថាមើលគ្រប់តួអក្សរឬអត់ បើយកចូលទៅយូរម្លឹងៗ ថែមទាំងឲ្យជំនួយការធ្វើការច្រើនទៀត ទាំងដែលជាថ្ងៃដំបូងសោះ និងប្រាប់ថាឲ្យរៀនធ្វើការសិន សំណាងដែលគេជួយខ្លះៗ កុំអីធ្ងន់ករហើយ ហើយពេលនេះនាងបិទកុំព្យូរ ផ្អាកការងារហើយ ដោយមិនខ្វល់ពីចៅហ្វាយនាយ។

"ឯងទៅផ្ទះចុះ ស៊ុនស៊ូ ទៅជាមួយខ្ញុំ"

"អឺ...តែ..."

"ខ្ញុំប្រាប់លេខា ហុង ថាឲ្យគេជូនទៅ លោកទៅចុះ"

ស៊ុនស៊ូ ងើបមុខមកប្រាប់ភ្លាម ព្រោះមុននេះនាងសុំពឹងពាក់ សុងចូរួចហើយ។

"មិនបាន នាងត្រូវទៅជាមួយខ្ញុំ ស៊ុនស៊ូ ចំណែក សុងចូ ឯងទៅចុះ ឬចង់មានបញ្ហានឹងសង្សារ?"

"មិនចង់ទេ មិនចង់មានបញ្ហានឹងលោក កាណែត"

"អីចឹងចេញទៅ មិនបាច់ចារម្តខាងណោះទេ"

"លោក កាណែត ម៉េចចាំបាច់គំរាម"

Scanned with CamScanner

នាងក្តាប់មាត់ដាក់គេដោយការមិនពេញចិត្ត ដែលគេចូលចិត្តគំរាមឲ្យកូនចៅខ្លាច ឃើញទេ សុងចូ មុខស្លេកអស់ទៅហើយ។

"មិនបានគំរាម មែនទេ សុងចូ?"

"បាទ មែន ហេះៗ ខ្ញុំសុំទៅមុនហើយ ជំនួយការ កាំង"

សុងចូ ម្ទីម្ទាដើរចេញទៅភ្លាម មិនឲ្យចៅហ្វាយម្ចូម៉ៅទាន់ និងមិនចាំឲ្យស៊ុនស៊ូ ស្រែកហៅទាន់។

"លេខា ហុង"

នាងស្រែកហៅ តែម្ចាស់ឈ្មោះដើរលឿនស្លេវចេញទៅ ដោយមិនងាកក្រោយ ទើបនាងបានត្រឹមខាំមាត់ ងាកមកសម្លឹងមុខ កាណែត ដោយកំហឹង។

"មើលធ្វើអី ទៅផ្ទះ គ្មានឡានទេ ឬចង់ដើរ?"

កាណែត ញាក់ស្មាបន្តិចដាក់ លើកដៃមើលនាឡិកា នេះលើសម៉ោងចេញពីធ្វើការមួយម៉ោងហើយ មេឃចង់ងងឹតហើយ។

"ទៅ ហត់ចង់ងាប់ទៅហើយ ចង់ងូតទឹកត្រជាក់ឲ្យស្រួលខ្លួន"

និយាយចប់ នាងក៏ដើរចេញ ដោយធ្វើអីគេមិនបាន ក្រៅពីធ្វើមុខក្រម្ញូវឡើងឡាន ដាក់ខ្សែក្រវាត់ការពារបង្ការគេចេញឡានទាំងកញ្ចក់កញ្ចេង តែម្តងនេះគេចិត្តល្អ បើកឡានស្រួលបួល ទាស់ត្រង់ថាពេលមកដល់មុខចង្ការ គេបែរជាបង្វែរទិសដៅ។

"លោកចង់ទៅណា នេះមិនមែនជាផ្លូវទៅផ្ទះទេ"



"ទៅលេងក្នុងក្រុងបន្តិច ចូលផាប់ ធ្លាប់ចូលទេ ហ៊ឹម?"

"ខ្ញុំមិនចង់ទៅ ជូនខ្ញុំទៅផ្ទះសិន"

"មិនជូន ខ្ជិលបើកទៅបើកមោ បើមិនចង់ចូល ក៏អង្គុយចាំក្នុងឡានទៅ ខ្ញុំផឹកស្ងួចនឹងចេញមោវិញ តែបើហ៊ានតែមោផ្ទះមុន ដឹងតែមានរឿង មិនជឿក៏សាកមើលទៅ តែបើឲ្យអ្នកណានាំមោចង្ការក៏គួរឲ្យខ្លាចបន្តិច ស្រួលមិនស្រួលមិនដល់ចង្ការ ត្រូវនាំចូលតាមផ្លូវ មិនដឹងទេណា៎"

កាណែត កម្លាឲ្យខ្លាច មុខមាត់ កាយវិការបែបនេះ ធ្វើឲ្យគេចង់បេះបួយទើបនាំមកដើរលេងឲ្យសប្បាយចិត្ត ចង់ងូតទឹកឬ ចាំសិនទៅ។

គេបើកឡានមកដល់ផាប់ល្បីឈ្មោះ ចតឡានហើយងាកទៅមើលនាងដែលអង្គុយឱបដៃ ធ្វើមុខក្រម្ញូវ មិនព្រមមើលមុខគេ ហើយញញឹមចុងមាត់ដោយការចូលចិត្ត។

"ចាំខ្ញុំចុចកញ្ចក់ឲ្យ ក្តៅក៏រកអីបក់ទៅ តែកុំបិទកញ្ចក់អស់ អាចស្លាប់ក្នុងឡានបាន តិចខ្ញុំលក់ឡានមិនចេញ"

កាណែត ដោះសោទ្វារ ចុចកញ្ចក់ចុះ និងពន្លត់ម៉ាស៊ីនឡាន ដោយមិនភ្លេចងាកទៅជៀមដាម។

"ចង់ទៅផឹកស៊ីក៏ឆាប់ចូលទៅ ទៅឲ្យផុតពីមុខទៅ"

នាងនិយាយគំរោះគំរើយដាក់ ដោយការមិនពេញចិត្ត។

"អីចឹងចាំនៅក្នុងនេះហើយ បើទៅផ្ទះមុន ដឹងតែមានរឿងមិខាន បើចង់

Scanned with CamScanner

ផ្ទាញ់ផ្ទាលក៏សាកមើលទៅ"

គេខាំធ្មេញក្រតៗ គំរាមឲ្យខ្លាច ហើយចុះពីឡាន បិទទ្វារលាន់ក្ទាំង ធ្វើឲ្យនាងភ្ញាក់ព្រើត ប្រញាប់ប្រញាល់ចុចទ្វារ ចាក់សោ ខ្លាចមានអ្នកណាមក បើក នាំឲ្យរឿងធំ ហើយតាមមើលអ្នកដែលដើរចូលទៅក្នុងផាប់។

នាងប្រញាប់ទាញទូរសព្ទមកមើល តែវាអស់ថ្ម តាំងពីពេលណាក៏មិន ដឹង ទើបទុកវានៅកន្លែងដើមវិញ ហើយសម្រួលកៅអី ទម្រេតខ្លួនចាំ កាណែត ចេញមកវិញ ដែលមិនដឹងថាយូរទៀតប៉ុណ្ណា។



# ៣

"លោក កាណែត ម៉ោម្នាក់ឯងទេឬ មិនឃើញបងប្រុសរបស់លោកមក ជាមួយ ?"

ស្រីស្អាតដើរមកនៃបនិត្យ ព្រមទាំងរាំតាមចង្វាក់ភ្លេង ឲ្យរាងកាយប៉ះគ្នា ជាការទាក់ទាញ ហើយដាក់ដៃលើរាងកាយមាំមួន ស្ទាបអង្អែលថ្នមៗ តាម ដោយការបាញ់ខ្សែភ្នែកសិចស៊ីដាក់។

"បងប្រុសខ្ញុំមិនទំនេរ ថ្ងៃនេះខ្ញុំម៉ោម្នាក់ឯង អ្នកនាងអាចផឹកកំដរខ្ញុំបាន ទេ ?"

កាណែត ញញឹមចុងមាត់ ជ្រឹមភ្នែកមើលមនុស្សស្រីម្នាក់នៅចំពោះមុខ ក៏មានការពេញចិត្ត ស ស្អាត សិចស៊ី ក្តៅគគុក ធ្លាប់ៗ...ឆ្នាម្តងហើយ ហើយ ថ្ងៃនេះគេចង់នាំនាងទៅឱបនៅចម្ការតែមួយយប់ ស្អែកសឹមបញ្ជូនមកផ្ទះវិញ រឿងទំនាក់ទំនងមួយរាត្រី គេអូរខេស្រាប់ហើយ ដោយភ្លេចទៅថាទុកអ្នកណា ចោលនៅក្នុងឡាន។

"អ៊ូហ៎ុ! និយាយបែបនេះ ខ្ញុំហ៊ានបដិសេធឬលោក កាណែត"

ស្រីស្អាតញញឹមពព្រាយ ដាក់កែវស្រាទៅលើតុ និងផ្តួលខ្លួនទៅឱបគេ



Scanned with CamScanner

ណែនដៃ ចំណែកគេក៏មិនបដិសេធ លើកដៃឱបនាងវិញ ថែមទាំងឱនថើបអ្នកដែលចំទើតជើងមកធ្វើមាត់ស្រួចដាក់។

"អឺ...លោក កាណៃត"

នាងថ្ងូរនៅដើម.ក ហៅឈ្មោះរបស់គេ ប្រណាំងនឹងសំឡេងតន្ត្រី ដោយរាងកាយសឹងតែឆេះដូចភ្លើង ត្រឹមគេតបស្នង។

"នៅទីនេះមួយសន្ទុះសិន ហើយចាំចេញទៅ"

គេខ្សឹបដាក់ត្រចៀកស្រីស្អាត ហើយឱបចង្កេះរបស់នាងរាំតាមភ្លេង។

"អូខេ"

ស្រីស្អាតញញឹមទទួល និងបបោលអង្អែល មិនព្រមទៅណាឆ្ងាយ ខ្លាចមានស្រីផ្សេងមកឆក់យកគេ ដែលយូរៗ ទម្រាំបានស្និទ្ធស្នាលម្តង អ្នកណាទៅព្រមពន្លែងដៃងាយៗ ទៅ។

ពេលផឹកស្រា និងរាំរែកបានមួយសន្ទុះ កាណៃត ក៏ឱបចង្កេះនាងនាំចេញពីផាប់ សំដៅរថយន្ត ដែលស្រីស្អាតក៏ធ្វើពុតជាស្រវឹង សើចកក្អិច ឱបថើបគេ ដើម្បីឲ្យគេមានអារម្មណ៍ភ្លើតភ្លើនតាមការប៉ះពាល់របស់នាង។

"ស្រវឹងហើយ ពេលណាដល់បន្ទប់ ខ្ញុំទ្រាំលែងបានហើយ"

"មួយភ្លែតទៀត ដល់ហើយ"

កាណៃត ញញឹមចុងមាត់ ដឹងថាអ្នកដែលកំពុងឱបថើបខ្លួន មិនបានស្រវឹងដូចកាយវិការបង្ហាញឲ្យឃើញ តែនាងកំពុងទាក់ទាញគេ។

"អូខេ ដល់ហើយលោក កាណៃត ដោះអាវឲ្យផង ខ្ញុំចង់ក្តៅគគុកជាមួយលោកហើយ"

នាងលើកដៃឱប.ករបស់គេ និងត្រសុលមកបៀត ជ្រឹមភ្នែកមើលមក និងខាំមាត់ដោយកាយវិការសិចស៊ី និយាយខ្សឹបៗដាក់។

"អួក! អួក! ចង់ក្អួត បូរាណណាស់ លោក កាណៃត លោក កាណៃត ខ្ញុំក្តៅគគុកណាស់ អុំ! ខ្ញុំមិនបានលួចស្តាប់ ចៃដន្យបានឮទៅវិញទេ"

ស៊ុនស៊ូ ដែលចាំនៅលើឡានជាងបីម៉ោងទៅហើយ ក៏បើកទ្វារចេញមក លើកដៃឱបទ្រូង មើលស្រីស្រស់ប្រុសស្អាត ដោយខ្សែភ្នែកមើលងាយ ដែលកាណៃត ចូលចិត្តធ្វើ ហើយពេបមាត់ និយាយត្រាប់តាម ដែលធ្វើឲ្យអ្នកដែលកំពុងឱបគ្នាស្អិតល្មួត ខ្ទាតចេញពីគ្នាភ្លាម។

"ឯងជាអ្នកណា ម៉េចក៏និយាយបែបនេះ!"

ស្រីស្អាតក្រហមមុខង៉ាំងដោយការខ្មាសអៀន ភ្លេចខ្លួនថាអម្បាញ់មិញនៅក្នុងរង្វង់ដៃរបស់មនុស្សប្រុស ងាកទៅចង្អុលមុខ ស៊ុនស៊ូ និងស្រែកគំហកដាក់ដោយកំហឹង។

កាណៃត សម្លក់ ស៊ុនស៊ូ ថ្មេ កែវភ្នែកមុតស្រួចជះពន្លឺខឹងសម្បា ខាំធ្មេញក្រតៗ លូកដៃចូលហោប៉ៅខោ និងឈរស្ងៀម ចាំមើលថានាងចង់ធ្វើអ្វី។

"គឺជាខ្ញុំនេះឯង ម៉ោជាមួយមនុស្សប្រុសម្នាក់នេះ ចាំយូរហើយ ងងុយដេកចង់ងាប់ ស្មានថាធ្វើអី ម៉ោស្ងួចបានត្រីស្អុយនេះឯង ចំណង់ចំណូលចិត្ត

Scanned with CamScanner

អន់ណាស់ លោក កាណែត អ៊ូយ! ងាប់ហើយៗ បែបនេះ យកទៅនិយាយឲ្យកម្មករនៅចម្ការស្ដាប់ដឹងតែសប្បាយសើច ហាសហា"

ស៊ុនស៊ូ សម្លឹងមើលស្រីស្អាតតាំងពីក្បាលដល់ចុងជើង ស្រីស្អាតមុខមាត់ល្អ សម្បុរស សក់ពណ៌ប្រផេះ កៀបទឹករលកបបោលអង្អែលស្មា និងមុខ ពាក់រ៉ូបចោមពុងពណ៌ខ្មៅ សមនឹងរូបរាង ឲ្យមើលទៅកាន់តែល្អតល្អន់ តែពេលធ្វើឫកពាមាយាដកខ្ញី វាធ្វើឲ្យនាងជ្រេញ។

"ឯងហ៊ានថាខ្ញុំជាត្រីស្អុយអ្ហុស មីចង្រៃ ឯងជាអ្នកណា ម៉េចក៏ហ៊ានមកនិយាយបែបនេះដាក់ខ្ញុំ"

ស្រីស្អាតតន្រ្តំជើងសិងតែធ្វើឲ្យរ៉ូបចោមពុងរបូតពីទ្រូង ក្ដាប់មាត់ដោយការឈឺចិត្ត ពេលត្រូវប្រៀបធៀបនឹងត្រីស្អុយ។

ស៊ុនស៊ូ ញាក់ស្មាតិចៗ ដោយមិនអើពើ ហើយងាកទៅមើលគេដែលសម្លក់នាងថ្មៃ ព្រោះត្រូវគេធ្វើបាបឲ្យរង់ចាំនៅក្នុងឡានបែបនេះ។

"ខ្ញុំងងុយដេកហើយ ចង់ទៅផ្ទះ ហើយបើមិនចង់ឲ្យខ្ញុំយករឿងនេះទៅនិយាយឲ្យផ្អើលចម្ការ ថាលោក កាណែត ពាលវាលប៉ុណ្ណា នាំស្រីណាក៏មិនដឹងចេញពីបារ៍ ក៏នាំខ្ញុំទៅផ្ទះវិញទៅ ស្អែកត្រូវធ្វើការបន្ត ខាតពេលដេកមែនក្រោមភ្នែកខ្ញុំខ្មៅ លោកត្រូវទិញឡេឲ្យខ្ញុំផង ព្រោះត្រូវមកអង្គុយចាំលោកស៊ីបុកត្រីស្អុយ"

នាងនិយាយដាក់ កាណែត ដោយកំហឹង។ តើមិនឲ្យខឹងម្ដេចបាន បង្ខំ



ឲ្យនាងមកទីនេះ ហើយឲ្យចាំនៅក្នុងឡានបែបនេះ ក្ដៅក៏ក្ដៅ ចង់ចុះពីឡានមកឈរនៅក្រៅក៏មិនហ៊ាន ព្រោះមានតែមនុស្សស្រវឹង។

"ស៊ុនស៊ូ!"

គេសម្លឹងនាងចង់ជ្រុះគ្រាប់ភ្នែក គ្រហឹមនៅដើម.ហៅស្រីក្មេងក្លាងនៅចំពោះមុខ ចង់ចប់នាងអង្រួនឲ្យញ័រក្បាល មាត់នេះឃើពីដាច។

"លោកចង់ធ្វើអីខ្ញុំ ខ្ញុំនឹងប្រាប់លោកម្ចាស់ សាកមើលទៅ"

នាងបូញមាត់បូញ.កនិយាយដោយការផ្ចាញ់ផ្ចាល ដោយមិនព្រមចាញ់នាងងងុយដេក និងចង់ងូតទឹក តែត្រូវមនុស្សឆ្កួតអំណាចនាំមកអង្គុយយាមឡាននៅទីនេះយ៉ាងយូរ ចំណែកខ្លួនឯងបែរជាទៅសើយសុខនៅខាងក្នុង ថែមទាំងចេញមកវិញ នាំស្រីមកឱបរឹតគ្នា មិនបេះខ្មាសមេឃខ្មាសដីទៀត។

"ហ៊ានយកប៉ាខ្ញុំមកគំរាមផង គិតថាខ្ញុំខ្លាចមែនទេ!"

កាណែត ដើរទៅជិត ស្រវាចាប់ដើមដៃរបស់នាងច្របាច់ខ្លាំងៗ ខាំធ្មេញនិយាយខ្សឹបៗដាក់។

"គឺស្រេចតែលោក តែបើពេលនេះលោកមិននាំខ្ញុំទៅផ្ទះ ខ្ញុំនឹងទូលពិត"

នាងសម្លឹងមុខគេជាការផ្ចាញ់ផ្ចាល ពេលនេះមិនព្រមចាញ់ទេ។

"លោក កាណែត ចុះខ្ញុំ?"

ស្រីស្អាតដើរមកចាប់ដើមដៃរបស់គេ ធ្វើឫកម៉ិកម៉ូក់ដាក់ ដែលធ្វើឲ្យស៊ុនស៊ូ អត់ជ្រេញមិនបាន។

Scanned with CamScanner

"ម៉ាខ្លួនឯង ទៅខ្លួនឯងទៅ ពេលម៉ោ គ្មានដើងទេក៏អី ទើបពេលទៅត្រូវមកម៉ិកម៉ូក់ឲ្យមនុស្សប្រុសជូនទៅ លែងស្រវឹងហើយអ្ហ៎! ឬមាយា ពូកែស្ទូចមនុស្សប្រុសដែរតើ ជុំៗ មិនអន់ទេយើងនេះ"

ស៊ុនស៊ូ ងាកទៅដៀមដាមស្រីស្អាត ដែលប្រសប់ធ្វើខ្លួនគួរឲ្យជ្រេញៗ

"ឯង!"

ស្រីស្អាតស្រែកចាស ស្ទុះមករក បំណងប្រទូស្តរ៉ាយរាងកាយ តែនាងគេចទាន់ ហើយលើកដៃច្រានខ្នងស្រីស្អាត ឲ្យជ្រមិលទៅបុកនឹងឡាន។

"អ៊ុយ! ខ្ញុំការពារខ្លួនឯងប៉ុណ្ណោះ"

នាងធ្វើជាលើកដៃ ត្រវែក្បាល ធ្វើមុខមោយៗ ដាក់ដោយការបេះបួយ។

"ឯងច្រានខ្ញុំ មីមុខគ្មានជាតិ ឯងមិនបាច់ម៉ោធ្វើមុខមោយទេ ចង់ទះឯងមួយកំផ្លៀងពីរ"

ស្រីស្អាតខាំមាត់ដោយការគុំកួន សំណាងដែល កាណែត ត្រកងជាប់មិនឲ្យដួលឲ្យខ្មាសគេ ហើយពេលលើកដៃយារ ស៊ុនស៊ូ ក៏យារដៃដែរ។

"អា៎! អ្នកណាប្រើឲ្យធ្វើបាបខ្ញុំមុន នាងជាអ្នកខុស ហើយចង់មកទះខ្ញុំទៀត គិតថាចេះទះតែម្នាក់ឯងក៏អី ខ្ញុំក៏ចេះទះដែរ មុខគ្មានជាតិដូចខ្ញុំមិនបាច់បារម្ភ តែមុខស្អាតៗដូចនាង តែរយះ ដឹងតែអស់លុយច្រើន ប្រាប់ឲ្យដឹង"

ស៊ុនស៊ូ យារដៃ មិនព្រមទម្លាក់ សម្លឹងស្រីស្អាតដោយមិនញញើត។

"បានហើយ ស៊ុនស៊ូ!"



កាណែត គំហកនាង គេអស់អារម្មណ៍ក្តៅគគុកហើយពេលនេះ។

"ចាត់ការទៅលោក កាណែត បានសម្តីណាស់"

ស្រីស្អាតអង្រួនដៃគេឲ្យចាត់ការ ស៊ុនស៊ូ ព្រមទាំងញញឹមញញែមដោយការពេញចិត្ត។

"មិនខ្វល់"

ស៊ុនស៊ូ ញាក់ស្មាដាក់ ហើយឡើងឡាន បិទទ្វារលាន់ប៉ុង សម្លឹងកាត់ភាពងងឹត មើលមកខាងក្រៅ និងរង់ចាំគេជម្រះនឹងស្រីរបស់គេឲ្យរួចរាល់។

"អ្នកនាងទៅវិញសិនទៅ ថ្ងៃក្រោយចាំខ្ញុំទាក់ទងទៅ"

កាណែត ងាកទៅប្រាប់ខ្សឹបៗ ស្រីស្អាត ព្រមទាំងបេះដៃនាងចេញពីដៃរបស់ខ្លួន ដោយទឹកមុខកាច។

"លោក កាណែត"

ស្រីស្អាតថ្ងូរតិចៗ ធ្វើមុខក្រមូវដាក់គេ។

"សង្ឃឹមថាអ្នកនាងយល់ ខ្ញុំទៅសិនហើយ"

កាណែត មួម៉ៅ អស់អារម្មណ៍ទៅណាបន្ត ហើយពេលនិយាយចប់ ក៏ឡើងឡាន ទុកស្រីស្អាតឲ្យឈរឆ្កឹងនៅត្រង់នោះ ឈឺចិត្តតែម្នាក់ឯង តាមមើលគូទឡានដែលរត់ចេញទៅ។



"ក្រែងងងុយខ្លាំង បើងងុយក៏ដេកទៅ អង្គុយត្រង់ខ្លួនស្លុកធ្វើអី មិញនៅ

Scanned with CamScanner

សម្តីហំតើ"

កាណែត ងាកមកគ្រហឹមដាក់អ្នកអង្គុយក្បែរ ទាំងដែលកំពុងបើកឡានក្នុងល្បឿនលឿន ធ្វើឲ្យនាងខ្ទាំពូកឡានជាប់ ខ្លាចគេនាំឲ្យធ្លាក់ផ្លូវ សំណាងល្អដែលយប់ស្ងាត់ មិនសូវមានចរាចរ យូរៗមានឡានបើកកាត់មួយគ្រឿង។

"បើលោកបើកឡានដូចហោះបែបនេះ ខ្ញុំដេកមិនលក់ទេ"

នាងខាំមាត់ ងាកមកសម្លក់សម្លឹងគេ តែពេលនិយាយ សម្តីឡើងញ័រ។

"ខ្លាចអ្វី មិនបាច់ខ្លាចទេ នុះ! ផ្លូវចូលចម្ការ"

គេខាំធ្មេញក្រតៗ បត់ឡានចូលចម្ការ ធ្វើឲ្យ ស៊ុនស៊ូ ជ្រមិលទៅបៀតនឹងទ្វារ។ នាងប្រឹងអត់ដង្ហើម សុំឲ្យដល់ផ្ទះឆាប់ៗ ដោយសុវត្ថិភាព ហើយពេលគ្មានគ្រោះថ្នាក់ក៏ធូរទ្រូង។

ងឹត!

"ចតធ្វើអី?"

នាងងាកមកមើលមុខគេដោយខ្សែភ្នែកឡេមឡាម ព្រោះសុខៗ គេក៏ចតឡានអែបផ្លូវ មានតែចម្ការក្រូចងងឹតៗ បែបនេះ វាស្ងាត់គួរឲ្យខ្លាច។

"ចុះពីឡានខ្ញុំ ហើយដើរទៅខ្លួនឯងទៅ!" គេងាកមកបណ្តេញ។

"លោកឆ្កួតទេក៏អី!"

នាងក្រមុំចំហមាត់ឆ្ងង មើលមុខគេដោយមិនចង់ជឿថាគេបណ្តេញនាងចុះពីឡានត្រង់នេះ គេកើតឆ្កួតស្អីនេះ។



"ចុះភ្លាម!"

គេបណ្តេញម្តងទៀត ហើយដោះសោទ្វារ និងដោះខ្សែក្រវាត់ការពារចេញពីខ្លួន។

"ខ្ញុំមិនចុះ"

នាងគ្រវីក្បាលញាប់ស្អេក ចាប់កៅអីជាប់។

"មិនចុះមែនទេ!"

អ្នកដែលកំពុងខឹង ពន្លត់ម៉ាស៊ីនឡាន ទាញកូនសោចេញ ហើយចុះពីឡាន ដើរវាងខាងមុខមករកខាងដែល ស៊ុនស៊ូ អង្គុយ បើកទ្វារ និងទាញនាងទម្លាក់។

"លែងខ្ញុំ"

ស៊ុនស៊ូ ខ្លាចហើយពេលនេះ នៅតាមដងផ្លូវងងឹតក៏ងងឹត ស្ងាត់ក៏ស្ងាត់ គេបែរជាមកទម្លាក់នាងនៅត្រង់នេះនេះ តែគេបែរជាមិនខ្វល់ ទាញនាងចុះពីឡានបានសម្រេច និងរុញមួយទំហឹងឲ្យជ្រមិលដួល ហើយដើរឡើងឡាន បើកចេញទៅបាត់ ទុកឲ្យនាងដួលអុកគូទនៅត្រង់នោះតែម្នាក់ឯង។

"អាមនុស្សចិត្តអាក្រក់ អាមនុស្សចិត្តខ្មៅ ខ្ញុំស្អប់លោក អាមនុស្សឆ្កួត កុំឲ្យដល់វេនខ្ញុំឲ្យសោះ ខ្ញុំនឹងឲ្យលោកដើរអូសជើង អាមនុស្សពាល!"

នាងឈឺទាំងគូទ ឈឺទាំងចិត្ត ប្រឹងងើបឈរ ទឹកភ្នែកហូររហាម ទើបលើកដៃជូតចោល ហើយមើលទៅជុំវិញខ្លួន ដែលឲ្យអារម្មណ៍គួរឲ្យខ្លាច និង

Scanned with CamScanner

ដើរអូសជើងចេញទៅ។

ព្រិន...ព្រិន...

សំឡេងឡានដែលរត់មកពីចម្ងាយ ធ្វើឲ្យនាងកាន់តែខ្លាច ទើបប្រញាប់រត់ចូលគុម្ពោតក្រូចនៅតាមដងផ្លូវ លួចមើលជាឡានអីដែលរត់មក ប៉ុន្តែមិនហ៊ានចេញទៅហៅ ទាំងដែលវាបើកទៅផុត ក៏មិនហ៊ានចេញពីត្រង់នោះ ទើបដើរអូសជើងយឺតៗ តាមក្រោមដើមក្រូច ដែលពេលខ្លះដើរធ្លាក់ជង្ហុកតូចៗ ធ្វើឲ្យដួលអុកគូទជាច្រើនដង។

"អ៊ូយ!"

នាងជ្រមិលដួល ពេលដើរធ្លាក់ជង្ហុក ដែលម្តងនេះក៏ខ្ចិលងើប ទើបអង្គុយឱ្យឡោមក្បាលជង្គង់ សម្រក់ទឹកភ្នែក យំដោយមិនបញ្ចេញសំឡេង ហើយមួយសន្ទុះក្រោយមក ទើបប្រឹងងើប ដើរយឺតៗ កាត់អាកាសធាតុរងា ដោយមិនប្រញាប់ប្រញាល់ដូចកាលពីដំបូង។

"អ្នកនាង ស៊ុនស៊ូ...អ្នកនាង ស៊ុនស៊ូ នៅម្តុំនេះឬអត់?"

សំឡេងហៅដែលឮពីចម្ងាយ ធ្វើឲ្យនាងទប់ដំណើរ តែមិនហ៊ានចេញទៅតាមសំឡេងនៅ។ នាងឈរមើលពន្លឺភ្លើងដែលបញ្ចាំងមក វាដូចភ្លើងពិលនិងសំឡេងហៅនោះឮកាន់តែជិតទៅៗ ដឹងថានោះជាសំឡេងរបស់អ្នកណា ទើបញញឹមពព្រាយ ជូតទឹកភ្នែកចេញពីមុខ ហឹតសម្បោរឮខ្សឹតខ្សូត។

"លោក ជេមីន ខ្ញុំនៅទីនេះ លោក ជេមីន"



ស៊ុនស៊ូ ប្រញាប់ប្រញាល់ដើរចេញមកស្រែកហៅ ជេមីន ដែលជិះកង់ហួសកន្លែងដែលនាងពួន ទើបគេប្រញាប់បង្វែរក្បាលកង់មកវិញ និងបញ្ចាំងពិលមករក។

"ឡើងកង់មោ"

ជេមីន សើចហេះៗ ពេលឃើញស្ថានភាពរបស់នាង ភ្នែកហើមក្រហមប្រហែលយំនោះឯង តែនាងនៅញញឹមដាក់គេទៀត ឃើញហើយអត់អាណិតមិនបាន។ លោក កាណែត ចេះឲ្យដើរម្នាក់ឯងលើផ្លូវស្ងាត់ ពេលយប់ងងឹតបែបនេះ វាគ្រោះថ្នាក់ណាស់។

"អរគុណ លោក ជេមីន ហើយនេះម៉េចក៏លោកដឹងថាខ្ញុំនៅម្តុំនេះ?"

នាងក្រមុំសួរដោយការសប្បាយចិត្ត។

"លោក អេដែន ឲ្យខ្ញុំមកមើល គាត់ប្រាប់ថាអ្នកនាងគួរតែនៅម្តុំនេះ"

"អឺចឹងឬ"

នាងដកដង្ហើមធំ ហើយឡើងអង្គុយលើរនកង់ ទើប ជេមីន ជិះកង់នាំសំដៅផ្ទះធំភ្លាម តាមបញ្ជារបស់ចៅហ្វាយ ដែលគេរមកដាស់ឲ្យគេប្រញាប់ចេញមកតាម ស៊ុនស៊ូ។

"ដល់ហើយ អ្នកនាង ស៊ុនស៊ូ"



ជេមីន ចាប់ហ្វ្រាំងកង់ ហើយប្រាប់អ្នកនៅពីក្រោយដោយទឹកមុខញញឹម ដើម្បីមិនឲ្យនាងតានតឹង។

Scanned with CamScanner

"អរគុណលោក ជេមីន"

ស៊ុនស៊ូ ចុះពីកង់ ឱនគំនាប់ជាការអរគុណ ហើយត្រដុសបាតដៃ ព្រោះរងា។

"មិនអីទេ ត្រូវអរគុណលោក អេដែន ដែលតរមកដាស់ខ្ញុំឲ្យមកយកអ្នកនាង ខ្ញុំយកកង់ទៅទុកសិន"

ជេមីន នៅតែញញឹមពព្រាយ និងដឹកកង់ទៅទុកនៅក្នុងរោងឡាន ន្លាលបានចូលដេកចូលពួន។

"ចាំ"

នាងតាមមើលខ្នងរបស់គេ ហើយដើរចូលក្នុងផ្ទះ បិទទ្វារ ចាក់សោ គិតថា អេដែន ចំជាដឹងចិត្តប្អូនប្រុសមែន និងគិតថានាងនឹងត្រូវទុកចោលនៅតាមផ្លូវឲ្យដើរមកផ្ទះវិញម្នាក់ឯង សំណាងល្អដែលពូថ្លៃមិនប្រាប់ភរិយា មិនអីចឹងម្ដាយមិងនឹងបារម្ភ ដេកមិនលក់មិនខាន តែក៏ល្អដែរ កុំឲ្យនាងពិបាកនិយាយវែងឆ្ងាយ។

ពេលនេះនាងឈឺចុកឈួយពេញខ្លួនអស់ទៅហើយ ទើបប្រញាប់ដើរចូលបន្ទប់ដេករបស់ខ្លួន បិទទ្វារ ចាក់សោ និងបើកភ្លើងឲ្យភ្លឺ។

"អុំ!"

"លស់ព្រលឹងអ្ហ៎ ដែលឃើញខ្ញុំនៅក្នុងនេះ ពូកែដែរតើ ដើរមកវិញបានថ្ងៃក្រោយ ត្រូវឲ្យដើរញឹកញាប់ហើយ"



កាណែត ដែលលួចចូលមកក្នុងបន្ទប់ដេករបស់នាង ស្ទុះងើបពីគ្រែ មកឈរច្រត់ចង្កេះ មើលម្ចាស់បន្ទប់ ដោយការត្រួតពិនិត្យតាំងពីក្បាលដល់ចុងជើង ពេលឃើញខ្លួនប្រាណស្រមេកស្រមកហើយក៏ពេបមាត់ចំអក ដោយមិនដឹងទេថាបងប្រុសច្បងជាអ្នកឲ្យ ជេមីន ទៅយកនាងពីតាមផ្លូវស្ងាត់មក។

"ចេញពីបន្ទប់ខ្ញុំភ្លាម ចេញភ្លាម!"

ស៊ុនស៊ូ ស្រែកគំហកខ្លាំងៗដាក់បុរសនៅចំពោះមុខដោយការភ័យខ្លាចឆ្ងល់ថាគេលួចចូលមកក្នុងបន្ទប់របស់នាងធ្វើអី។ នាងធ្វើភ្នែកឡេមឡាម ហើយប្រញាប់បែរខ្លួនដើរសំដៅទ្វារ បំណងចេញពីបន្ទប់វិញ តែមិនទាន់បានចាប់ទ្វារផង ក៏ត្រូវ កាណែត ដើរលឿងស្លេវមកពាំងមុខ និងទាញនាងឱបណែនដៃ។

"លែងខ្ញុំ អាមនុស្សថោកទាប ខ្ញុំស្អប់លោក"

នាងប្រឹងរើបម្រះ ដើម្បីឲ្យរបូតពីរង្វង់ដៃរបស់គេឲ្យបាន ហើយក្ដាប់ដៃគក់ តែធ្វើមិនស្រួល។

"សម្ដីហំណាស់"

គេអត់ជ្រេញមិនបាន ទើបខ្សឹបៗដោយសំឡេងកាច នាំដើរទៅកណ្ដាលបន្ទប់។

"លោកចង់ធ្វើអី លែងខ្ញុំភ្លាម"

ស៊ុនស៊ូ ភ័យទៅជាស្លេកមុខ ប្រឹងក្រាញ តែមិនបានសម្រេច។

"ខ្លាចអ្ហ៎! ល្អ ខ្លាចៗ បែបនេះ ខ្ញុំចូលចិត្ត"

Scanned with CamScanner

"អាមនុស្សថោកទាប"

នាងនិយាយបានតែប៉ុណ្ណឹង ក៏ស្រែកលែងចេញ ពេលត្រូវគេឱនមកបើបបិទមាត់ដែលកំពុងហា និងត្រសុលមកបៀត ដែលធ្វើឲ្យនាងឈឺខ្លួន ទាំងដែលកំពុងឈឺចុករួយស្រាប់ហើយ។ នាងផ្អៀងមុខចេញ តែត្រូវ កាណែត ចាប់កញ្ចឹង.កជាប់ ទើបប្រឹងខ្ទឹបមាត់ តែត្រូវគេប្រើពុកមាត់ពុកចង្កា និងមាត់របស់គេធ្វើឲ្យនាងទាំងឈឺ ទាំងផ្សាមុខមាត់។

កាណែត ញញឹមញញែម ហើយដកដៃពីកញ្ចឹង.ករបស់នាង មកចាប់ថ្ពាល់ ច្របាច់ខ្លាំងៗ ដើម្បីឲ្យនាងហាមាត់ ន្ទាលគេបានជ្រែកអណ្ដាតចូលទៅក្នុងប្រអប់មាត់។

"កុំ អី!"

នាងក្រមុំប្រឹងរុញផង ក្ដាប់ដៃគក់ស្មារបស់គេផង ចាប់ទាញសក់របស់គេត្រង់កញ្ចឹង.កផង ដើម្បីឲ្យគេងើបមុខចេញ តែមនុស្សឆ្អួតកម្លាំងច្រើននេះមិនព្រមថយទៅណា។ នាងញ័រខ្លួនទទ្រើត ពេលគេជ្រែកអណ្ដាតក្ដៅចូលមកក្នុងមាត់ កេរផង រឹតរួតអណ្ដាតរបស់នាងផង ដែលវាឲ្យអារម្មណ៍ស្រៀវសព្វសាច់ឲ្យកម្លាំងតតាំងទៅជាចុះខ្សោយ ជើងក៏ទន់ ឈរមិននឹង។

កាណែត ត្រវាសអណ្ដាត ជន្លជន្លេញ បិតជញ្ជក់ដោយចិត្តញៀនញ៉ាមរសជាតិក្រអូបផ្អែមដែលទទួលបាន ធ្វើឲ្យគេមិនដកថយ គិតថាក្មេងម្នាក់នេះក៏មានគុណសម្បត្តិដែរតើ ស្មានថាស្គមមានតែស្បែកដណ្ដប់ឆ្អឹង តែមានឯណា



ទ្រលុកទ្រលន់ពេញខ្លួនតែម្ដង។

"អុំ!"

គេស្រែកបាច ពេលច្រឡំពន្លែងដៃ ទើបត្រូវនាងខាំមាត់ចង់ដាច់។

"ហ៊ានខាំខ្ញុំផង ស៊ុនស៊ូ"

គេខាំធ្មេញក្រតៗ សម្លឹងនាងមិនដាក់ភ្នែក។

"ចង់ខាំឲ្យដាច់ផង"

នាងតមាត់ដោយសំឡេងញ័រៗ ព្រមទាំងដកដង្ហើមមិនពេញពោះ។

"សម្ដីហំណាស់"

គេគ្រហឹមនៅដើម.ក ជ្រឹមភ្នែកមើលមកជាការដាក់ទោស។

"លែងខ្ញុំ"

នាងស្រវាចាប់ដៃដែលកំពុងតែច្របាច់ថ្ពាល់របស់នាង តែដៃរបស់គេរឹងដូចដង្កៀបដែក ទើបមិនអាចធ្វើអីគេបាន។ នាងប្រឹងស្រូបខ្យល់ដង្ហើមចូលឲ្យពេញសួត និងថយកែងដៃអុក បំណងឲ្យត្រូវចុងចង្ការបស់គេមួយទំហឹង តែវាឆាសប៉ុណ្ណោះ និងបានឮសំឡេងធ្មេញរបស់គេទង្គិចគ្នាខ្លាំងៗ ហើយគេភ្ញាក់ថយក្រោយ ព្រមពន្លែងដៃពីរាងកាយរបស់នាងភ្លាម។

ផូស!

"អូយ!"

កាណែត ដែលត្រៀមខ្លួនមិនទាន់ ស្រែកបាច និងញ័រខ្លួន ពេលធ្មេញ



Scanned with CamScanner

របស់ខ្លួនទង្គិចខ្លាំង លេងឲ្យបែកអំពិលអំពែក។

ផាច់! ផាច់!

នាងទះគេពីរកំផ្លៀង ដោយមិនប្រណីកម្លាំង ព្រមទាំងដកដង្ហើមដង្ហក់។ នាងឈរឡើងស្លឹកបាតដៃទៅហើយ មុខម្តងស្លេក ម្តងក្រហម លើកដៃ ឱបខ្លួនឯងជាការការពារ ព្រមទាំងឈានជើងថយក្រោយ នៅឲ្យឆ្ងាយពីគេ។

"ហ៊ឺយ"

អ្នកកំលោះខឹងឡើងមុខក្រហមង៉ាំង កែវភ្នែកមុតស្រួចដះពន្លឺក្តៅគគុកដូចមានអណ្តាតភ្លើងនៅក្នុងនោះ ថ្ពាល់ត្រង់ថ្គាមឡើងរឹងកំព្រឹស ហើយពេលលើកដៃប្រចាច់ចង្ការបស់ខ្លួនតិចៗ ក៏ដើរមករកនាងយ៉ាងលឿន ស្រវាចាប់ដៃនិងគ្រវែងឲ្យដួលទៅលើគ្រែ និងតាមទៅទ្រាបពីលើ។

"អា! អុំ!"

នាងស្រែកបានតែប៉ុណ្ណឹង ព្រោះចុក និងភ័យខ្លាច ពេលត្រូវគេទ្រាបពីលើបែបនេះ ប្រឹងលើកដៃរុញច្រានគេចេញ តែត្រូវគេចាប់ដៃទាំងពីរសង្កត់នឹងពូក លោមុខមកជិត ញញួចង្អមគួរឲ្យខ្លាចដាក់នាង បេះដូងលោតខុកខាក់លើកនេះនាងខ្លាចជាងមុនមួយរយដង។

"សង្ស័យចូលចិត្តបែបព្រៃផ្សៃ ទះថើបមែនទេ ស៊ុនស៊ូ បាន ចាំចាត់ចែងឲ្យ រឿងស្អាត់ស្រាប់"

គេខ្សឹបប្រាប់ដោយសំឡេងស្អកៗ តែស្តាប់ហើយ វាធ្វើឲ្យនាងព្រឺសម្បុរ



ខ្យល់ដង្ហើមក្តៅៗរបស់គេក៏ស្រោចលើថ្ពាល់ ទើបនាងប្រញាប់ងាកចេញ។

"កុំ អាមនុស្សឆ្កួត កុំធ្វើអីខ្ញុំ"

ស៊ុនស៊ូ ស្រែកហាមដោយសំឡេងញ័រៗ។

"មិនបាច់ខ្លាចទេ ជានាថានាងច្បាស់ជាចូលចិត្ត"

ពេលឃើញកាយវិការភ័យខ្លាចរបស់នាងហើយ គេក៏ញញឹមពេញចិត្ត ...ស្មានថាខ្លាំងតើ ល្អ ខ្លាចណាស់មែនទេ គេនឹងធ្វើលើសពីនេះទៅទៀត។

គេលោមុខសង្ហាមកជិត អូសចុងច្រមុះស្រួចលើថ្ពាល់ថ្នមៗ ឲ្យនាងប្រឹងអត់ដង្ហើម ប្រឹងបិទភ្នែក ប្រឹងទាញដៃចេញ តែមិនបានសម្រេច រើបម្រះមិនបានទៀត ព្រោះត្រូវគេច្រកកៀរពីលើ ថែមទាំងអូសចុងច្រមុះមករកចង្កា ថើបច្បិចមាត់របស់នាងតិចៗ ហើយបង្អួសទៅរកប្រឡោះក។

គេឃើញសរសៃ.ករបស់នាងកន្ត្រាក់ ក៏ញញឹមចុងមាត់ ទើបបឺតខ្លាំងៗឲ្យសាច់ត្រង់នោះមានស្នាមក្រហមពីរបី ព្រោះត្រូវការឲ្យនាងខ្មាស បន្ទាប់មកក៏អូសមករកដើមទ្រូង ដែលបិទបាំងដោយសាច់អាវ។

"កុំ លោក កាណែត"

នាងស្រែកហាមដោយសំឡេងញ័រ ការភ័យខ្លាចកើនកម្រិតកាន់តែខ្លាំងដែលវាសឹងតែធ្វើឲ្យនាងគាំងបេះដូង លាយឡំដោយអារម្មណ៍ប្លែកៗ ស្រៀវៗពេលត្រូវគេប៉ះពាល់ខ្លួនប្រាណ ហើយពេលនេះមុខរបស់នាង និងបបូរមាត់របស់គេនៅជិតគ្នាពេកហើយ។

កាណែត មិនអើពើ ខិនទៅរកគល់ទ្រូងដែលប្រាល់ចេញពី.កអាវ ថើបដោយច្រមុះផង បិតដោយមាត់ផង ឲ្យក្តៅខ្លួន។

"កុំ! ឈប់!"

នាងស្រែកហាមម្តងទៀត ប៉ុន្តែដូចកាន់តែហាម កាន់តែពន្លះ គេខាំសាច់ទ្រូងរបស់នាងខ្លាំងៗ ហើយក្រសោប.កដៃទាំងពីររបស់នាងទៅសង្កត់លើក្បាលដោយដៃម្ខាង ចំណែកដៃម្ខាងទៀតប្រឡេះឡេវអាវនោះពីរបីគ្រាប់ ឲ្យឃើញដើមទ្រូងណែនក្បុំ ដែលក្រសោបដោយអាវក្នុងពណ៌ខ្មៅរូបផ្កា ហើយការដង្ហើមដង្ហក់របស់នាង ធ្វើឲ្យវាលោតដូចរ៉ឺស័រ មកទាក់ទាញភ្នែក។ កាណែត ញញឹមដូចបិសាច ហើយខិនទៅឈ្មុលជ្រលងរបស់វា ដោយមុខសង្ហា ដែលវាធ្វើឲ្យនាងប្រឹងកញ្ជ្រមស្មា ព្រោះស្រៀវ។

"កុំអី កុំ ហ៊ឹក!"

នាងស្រែកហាមដោយទឹកភ្នែករលីងរលោង ហើយយំមួយរំពេច ព្រោះទាំងខ្លាច ទាំងភ័យនៅក្នុងពេលតែមួយ តែគេមិនប្រណីដដែល ថែមទាំងលើកដៃម្ខាង បំណងទាញអាវក្នុងនោះចេញ តែមានសំឡេងគោះទ្វារបន្លឺឡើងល្មម។

គុក...គុក...គុក...

"ជួយផង...អី"

"ស៊ុនស៊ូ ស៊ុនស៊ូ ទើបមកដល់មែនទេ ស៊ុនស៊ូ"

សំឡេងហៅរបស់បងថ្លៃ ធ្វើឲ្យ កាណែត ប្រញាប់លើកដៃបិទមាត់របស់



ស៊ុនស៊ូ និងធ្វើមុខកាចដាក់ ពេលនាងប្រើរើបម្រះ។

"បើនាងស្រែកឲ្យមីងនាងជួយ ធានាថាស្អែកនេះនាងបានធ្វើជាប្រពន្ធរបស់ខ្ញុំដោយមិនបាច់សង្ស័យ បើអ្នកផ្សេងដឹង ប៉ាខ្ញុំក៏ត្រូវតែដឹង បើមិនចង់ធ្វើជាប្រពន្ធរបស់ខ្ញុំបែបបង្ខំចិត្ត កុំឲ្យ ស៊ូអា ដឹង ឬនាងចង់ធ្វើជាប្រពន្ធរបស់ខ្ញុំ"

ពេលនាងគ្រវីក្បាលញាប់ស្អេក ទើបគេព្រមពន្លែងដៃពីមាត់ តែនៅតែធ្វើមុខកាច និងសម្លឹងមុខនាងជាការគំរាម។

"ងើបចេញទៅ"

នាងលើកដៃរុញដើមទ្រូងរបស់គេឲ្យជ្រមិលបន្តិច ទើបគេលើកដៃទ្រានពូក ព្រមងើបចេញពីខ្លួនរបស់នាង និងចុះទៅឈរក្បែរ ញញឹមចុងមាត់ចំអកដាក់អ្នកដែលងើបអង្គុយ លើកដៃជូតទឹកភ្នែកចេញពីមុខ ហើយប្រញាប់ដាក់ឡេវអាវដោយដៃញ័រទទ្រើត ពេលរួចរាល់ក៏ស្ទុះចុះពីគ្រែម្ខាងទៀត ខាំមាត់ដាក់អ្នកដែលដើរទៅពួននៅបន្ទប់តែងខ្លួន តែសម្លឹងនាងមិនដាក់ភ្នែកដដែលជាការគំរាម ទើបនាងដកដង្ហើមចូលឲ្យជ្រៅៗ ពេលដើរទៅរកទ្វារ។

"ស៊ុនស៊ូ កើតអី ស៊ុនស៊ូ បើមិនបើក មីងឲ្យពូថ្លៃទម្លាយចូលទៅហើយ"

ស៊ូអា មិនស្រួលចិត្ត ព្រោះលួចបានឮស្វាមីគេប្រាប់ ដេមីន ឲ្យទៅយកស៊ុនស៊ូ នៅតាមផ្លូវ។ នាងរង់ចាំទាល់តែឃើញក្មួយស្រីចូលផ្ទះ ព្រោះស្វាមីលួចទៅឈរមើលក្រោយភាំងនន ទើបលោមសួរ ទាល់តែគេព្រមនិយាយការពិតឲ្យស្តាប់ ដែលធ្វើឲ្យនាងងរស្វាមី ទើបត្រូវគេលួង និងព្រមនាំនាងមករកក្មួយស្រី

Scanned with CamScanner

ដល់មុខបន្ទប់ដេកនៅពេលនេះ ទាស់ត្រង់ម្ចាស់បន្ទប់មិនព្រមបើកទ្វារ នេះ ហើយដែលធ្វើឲ្យនាងអន្ទះសា។

ឃ្លិក!

ទ្វារបន្ទប់ត្រូវបើក ដោយ ស៊ុនស៊ូ ឱនមុខជ្រប់ មិនហ៊ានប្រសព្វភ្នែកនឹងម្ដាយមីង និងពូថ្លៃ ខ្លាចត្រូវចាប់បានថាមានមនុស្សនៅក្នុងបន្ទប់របស់នាង។

"ស៊ុនស៊ូ មីងចារម្ដ ម៉ោវិញយប់ជ្រៅ ញ៉ាំបាយហើយនៅ?"

ពេលឃើញស្ថានភាពរបស់ក្មួយស្រី ទោះស្រមេកស្រមក តែមិនបានសង្ស័យអី គិតថាប្រហែលមកពីរត់ដួល ហើយម្ដាយមីងក៏ជួរថ្ងូរ។

"នៅទេ ខ្ញុំក៏ឃ្លានដែរ មីងធ្វើអីឲ្យញ៉ាំបន្តិចបានទេ?"

នាងខាំមាត់ប្រាប់ ព្រោះមិនចង់ឲ្យម្ដាយមីងចូលបន្ទប់ដេករបស់ខ្លួន ព្រោះតែចូលនឹងមានរឿងធំ ដោយសារពេលនេះ កាណែត នៅក្នុងនេះដែរ។

"ល្អ ចាំមីងធ្វើឲ្យ អូនចុះទៅធ្វើម្ហូបឲ្យ ស៊ុនស៊ូ សិន បងសម្លាញ់"

ស៊ូអា ញញឹមដាក់ និងលូកដៃទៅចាប់សក់ក្មួយស្រី រៀបឲ្យមានរបៀប ហើយងាកទៅសុំអនុញ្ញាតពីស្វាមី។

"បាទ"

អេដែន ងក់ក្បាល ព្រមទាំងលើកដៃឱបថ្ងូរ ឱនមកថើបថ្ពាល់របស់ភរិយា ខណៈនោះក៏មើលក្មួយប្រសាដោយនឹកអាណិត ហើយពេលតាមមើលក្រមុំទាំងពីរបណ្ដើរគ្នាចុះទៅខាងក្រោមផុតពីភ្នែកហើយ ទើបប្លុកគ្រហែម។



"បងថាឯងនៅក្នុងនេះ កាណែត"

បងប្រុសគ្រហែមហៅ តែមិនបានដើរចូលទៅខាងក្នុង រង់ចាំឲ្យមនុស្សមានខ្លួនចេញមកដោយខ្លួនឯង។

"ដឹងហើយ ចង់ធ្វើអីខ្ញុំ ខ្ញុំមិនទាន់បានធ្វើស្អីនាងទេ គ្រាន់តែម៉ោមើលមុខប៉ុណ្ណោះឯងថាដើរម៉ោហត់ទេ"

កាណែត លើកដៃអង្អែលចង្កា ពេលដើរយ៉ាងរំភើយចេញមក ធ្វើមុខដូចគ្មានអ្វីកើតឡើង ទាំងដែលលួចចូលបន្ទប់មនុស្សស្រីទាំងយប់អធ្រាត្រ។

"ឯងនេះអាក្រក់ កាណែត ទុកគេចោលកណ្ដាលផ្លូវស្ងាត់ ថែមទាំងលួចចូលបន្ទប់របស់គេបែបនេះទៀត បើឯងចូលទៀត បងនឹងរាយការណ៍ប្រាប់លោក អាហ្វា ឲ្យចាត់ការឯងហើយ"

អេដែន គ្រវីក្បាលហួសចិត្តដាក់ប្អូនប្រុសពៅ និងធ្វើជាកាចដាក់ មិនហ៊ានថាពេញមាត់ ព្រោះខ្លួនឯងក៏ធ្លាប់មានប្រវត្តិធ្វើរឿងបែបនេះឲ្យវាចាប់បានយល់ល្អឲ្យលោក អាហ្វា ចាត់ការ។

"រ៉ូៗ ស្អីគេហ្នឹងបងធំ ខ្ញុំមិនទាន់បានធ្វើអីផង ម៉េចទូលពិតបានទៅ"

កាណែត ញញឹមចុងមាត់ លើកចិញ្ចើមដាក់ និងធ្វើពុតជាខ្លាចញញើត ព្រោះដឹងថាយ៉ាងណាក៏បងប្រុសមិនទូលពិតឪពុកដែរ គ្រាន់តែគំរាមប៉ុណ្ណោះ។

"អឺ! ហើយស្នាមនឹង.ករបស់ ស៊ុនស៊ូ នោះស្រមោចខាំទេដឹង អេះឡើងក្រហម មិនចូលចិត្តគេមិនអីចឹង ហើយថើបគេធ្វើអី!"

Scanned with CamScanner

អេដែន គ្រវីក្បាលម្តងទៀត ដោយការអារចិត្ត ហើយនិយាយដល់ស្នាមក្រហមដែលប្អូនប្រុសពៅបន្សល់ទុកនឹង.ករបស់ ស៊ុនស៊ី។ ខ្សែភ្នែកដូចស្ទាំងរបស់គេក្រឡេកតែមួយខ្ទាច់ក៏ដឹងទៅហើយថាជាថ្វីដៃរបស់អ្នកណា។

"គឺគ្រាន់តែ...ទៅដេកហើយ ធុញមនុស្សដឹងច្រើន"

កាណែត និយាយមិនចេញ មិនស្មានថាបងប្រុសភ្នែករៀសយ៉ាងនេះ ពេលមានភស្តុតាងនៅនឹងមុខបែបនេះ គេក៏មិនបដិសេធ។

"ធុញហ្នឹងល្អហើយ បើឯងហ៊ានតែធ្វើបាបនាងឥតល្ហែ បងជានាថាដឹងដល់ត្រចៀលោក អាហ្សា មិនខាន"

"បាទ"

អេដែន ធ្វើជារអ៊ូរទាំឲ្យឮ តែសាមីខ្លួនបែរជាធ្វើព្រងើយ ដើរយ៉ាងរំភើយទៅបន្ទប់ដេករបស់ខ្លួន។

"ហ៊ឺ! ធ្វើឯងសម្តីហាំទៅអាក្អូន"

អេដែន គ្រវីក្បាលរអាចិត្ត ហើយដើរចូលបន្ទប់ដេករបស់ខ្លួន ដេកចាំប្រពន្ធល្អជាង ដោយមិនចុះទៅក្រោម ព្រោះមិនចង់ឲ្យក្មួយប្រសាទើសទ័ល។



# ៤

"មានបញ្ហានឹងលោក កាណែត មែនទេ ឲ្យមីងប្រាប់លោកម្ចាស់ល្អទេថាមិនបាច់ទៅធ្វើការជាមួយលោក កាណែត មីងបារម្ភ ខ្លាចថា..."

ស៊ូអា កំពុងកម្តៅម្ហូប ចំណែក ស៊ុនស៊ី ដួសបាយដាក់ចានក្រឡុងធំរង់ចាំម្ហូប ដើម្បីលាយ។

"មិនអីទេ មីង ខ្ញុំធ្វើបាន រឿងប៉ុណ្ណឹង គ្មានបញ្ហាទេ គេមានសមត្ថភាពធ្វើអីខ្ញុំបាន ចាំមើលខ្ញុំនឹងចាត់ការវិញ ពូកែធ្វើបាបខ្ញុំណាស់ ខ្ញុំនឹងលេងវិញ"

ស៊ុនស៊ី គ្រវីក្បាលបដិសេធសំណើនេះ ព្រោះមិនចង់ឲ្យម្តាយមីងមកអំពល់ទុក្ខដោយសារខ្លួន ពេលនេះអាចទ្រាំបាន នាងទ្រាំសិនទៅ ចាំពេលណាទ្រាំលែងបាន ចាំឈប់ទ្រាំ។ នាងយកចានម្ហូបចុងក្រោយចាក់ចូលចានធំ និងច្របល់ឲ្យសព្វ ភ្លក្សវា ឃើញថាឆ្ងាញ់ហើយ ទើបទទួលទាន ដែលពេលបានមួយម៉ាត់ ក៏ឃ្លានមួយរំពេច ទាំងដែលមុននេះគ្មានអារម្មណ៍ថាឃ្លាន ព្រោះទាំងខឹង ទាំងខ្លាច ដែលត្រូវប្រុសកំណាចធ្វើបាប ហើយថ្ពាល់ឡើងក្តៅ ពេលនឹកដល់ការប៉ះពាល់របស់គេ វាឲ្យអារម្មណ៍ប្លែកៗ។

"កុំធ្វើបែបហ្នឹង ស៊ុនស៊ី មីងស្គាល់ច្បាស់ថាលោក កាណែត ជាមនុស្ស

Scanned with CamScanner

បែបណា គេមានចរិតដូច អេដែន ហ្នឹងឯង តែមើលទៅគេយូរៗទៅដូចខូចជាងគេជាងឯង កុំទៅញ៉ោះឲ្យគេខឹង ឯងមិនសូវស្គាល់គេ មីងបារម្ភ ខ្លាចឯងឈឺខ្លួន មើលចុះ ថ្ងៃនេះធ្វើការថ្ងៃដំបូងនៅត្រូវធ្វើបាប ហ៊ានទុកចោលកណ្ដាលផ្លូវបែបនោះ តើថ្ងៃបន្តបន្ទាប់នឹងប៉ុណ្ណា"

"មីងមិនបាច់បារម្ភទេ ខ្ញុំមិនសងសឹកក៏បាន ខ្ញុំនឹងអត់ធ្មត់ មិនឲ្យគេមកជេរមកថាឲ្យយើងបានទេ តិចគេថាយើងមកតោងគ្រួសារគេស៊ី យ៉ាងណាក៏លោកម្ចាស់មេត្តាយើង រឿងប៉ុណ្ណឹងតូចតាចណាស់ ខ្ញុំមិនខ្លាចទេ"

"អីចឹងតាមចិត្តឯង តែបើទ្រាំមិនបាន ត្រូវប្រាប់"

"ចាំ បើទ្រាំមិនបាន ខ្ញុំអាចវ៉ៃគេបែកក្បាល ហើយប្រញាប់រត់មកឲ្យមីងជួយ"

ស៊ុនស៊ូ អស់សំណើច តែនាងនិយាយដូចការគិតមែន។

"និយាយឆ្កួតៗ បើគេបែកក្បាលមែន ឯងបានស្លាប់នៅនឹងកន្លែងនោះដោយមិនបាច់សង្ស័យ មីងជួយមិនទាន់ទេ"

ស៊ូអា ស្ដីឲ្យ ដោយមិនបានលេងសើច ព្រោះដឹងថា កាណែត ជាមនុស្សមួយមកមួយទៅ មិនឲ្យអ្នកមានមានប្រៀបលើខ្លួនទេ។

"ខ្ញុំនិយាយលេងទេ ហេះៗ"

ក្មួយស្រីសើចលួងចិត្តម្ដាយមីង។

"ឆាប់ញ៉ាំទៅ ន្ទាលងូតទឹកក្ដៅ មើលចុះ ស្រមេកស្រមកអស់ហើយ"



ស៊ូអា ជួយជ្រងសក់ក្មួយស្រីឲ្យម្ដងទៀត ហើយពិនិត្យមើលខ្លួនប្រាណ។

"មិនឲ្យស្រមេកស្រមកយ៉ាងម៉េច ថ្ងៃនេះពេលចូលចម្ការ ក៏ឲ្យខ្ញុំចូលបេះស្លឹកតែ មុនថ្ងៃត្រង់ឲ្យទៅជួយការងារនៅផ្ទះបាយ ពេលរសៀលឲ្យជួយការងារលេខា ហុង គេធ្វើបាបខ្ញុំឡើងគរគោក ពេលចេញពីធ្វើការ មិនព្រមឲ្យខ្ញុំម៉ោផ្ទះមុន ទាំងដែលខ្ញុំប្រាប់ថាឲ្យលេខា ហុង ជូនម៉ោ គេបណ្ដេញលេខា ហុង ទៅផ្ទះ និងឲ្យខ្ញុំឡើងឡាននាំទៅផាប់ ខ្ញុំខឹងណាស់ គេទុកឲ្យខ្ញុំចាំក្នុងឡានបីបួនម៉ោង ខ្ញុំតេរម៉ោផ្ទះមិនបាន ទូរសព្ទវាអស់ថ្ម តែសមមុខហើយ ពេលគេយួរស្រីចេញម៉ោ ខ្ញុំក៏ចាត់ការ ទាល់តែស្រីរបស់គេផាសក្រញាំ ហ៊ីៗ"

"ធ្វើឲ្យគេខឹងអីចឹងតើ ទើបត្រូវទុកចោលកណ្ដាលផ្លូវ ឲ្យដើរម៉ោផ្ទះទាំងយប់ស្ងាត់បែបនេះ"

"គេវាអន្ធពាល ខ្ញុំស្អប់!"

នាងនិយាយដោយការងរង៉ក់ និងចង់តែរត់ឡើងទៅខាងលើ រកស្អីវាយក្បាលរបស់គេឲ្យខ្លាំងៗ ឲ្យបាត់បង់ការចងចាំ កុំឲ្យមកអុកឡុកនាងទៀត។

"កុំនិយាយ មានធ្លាប់ឮគេថាស្អប់អី បានហ្នឹងទេ កាំង ស៊ុនស៊ូ"

"ដូចមីងនិងពូថ្លៃមែនទេ តែខ្ញុំមិនអាចទេ"

នាងញញឹមបង្អាប់ម្ដាយមីងរួបស្រស់ តែពេលនឹកដល់ កាណែត ក៏ធ្វើមុខក្រមូវវិញ។ គេជាមនុស្សប្រុសមាត់ដាច កំណាច អន្ធពាល នាងមិនព្រមចុះញ៉មគេងាយៗ ទេ នាងស្អប់គេខ្លាំងណាស់។

Scanned with CamScanner

"ឆ្អែតហើយ អរគុណមីង ដែលតែងតែបារម្ភពីខ្ញុំ"

ស៊ុនស៊ូ ដាក់ស្លាបព្រា ទាញទឹកមកផឹក ហើយងើបឈរ អង្អែលពោះ និងញញឹមពព្រាយដាក់ម្ដាយមីង។

"យើងមានគ្នាតែពីរនាក់ មិនបារម្ភពីឯង តើឲ្យបារម្ភពីអ្នកណា"

ពីរនាក់ម្ដាយមីងក្មួយញញឹមដាក់គ្នា។ ពួកនាងឆ្លងកាត់រឿងលំបាកមកច្រើនណាស់ នាងតែងតែស្រឡាញ់ និងបារម្ភពីក្មួយស្រីជានិច្ច ហើយទោះនាងរៀបការ មានកូនម្នាក់ហើយក៏ដោយ ក៏គ្មានគំនិតថាបោះបង់ក្មួយស្រីឲ្យឯកា។

"ខ្ញុំស្រឡាញ់មីងជាងគេ"

ពេលប្រាប់ហើយ ស៊ុនស៊ូ ក៏លើកចានទៅលាង ដោយមានម្ដាយមីងតាមមើលដោយស្នាមញញឹម តែពេលនាងប្រមក់លាងចានរួច ជូតដៃនឹងអាវក៏ស្ដីឲ្យ។

"ជូតអាវទៀតហើយ"

"មិនអីទេ វាប្រឡាក់ស្រាប់ហើយ"

ស៊ុនស៊ូ សើចហេះៗដាក់ ពេលត្រូវស្ដីឲ្យ ម្ដាយមីងក៏គ្រវីក្បាលអោចិត្តដាក់ ហើយដើរមកជិត តែពេលឃើញកន្ទួលក្រហមនិង.ករបស់ក្មួយស្រីក៏ចងចិញ្ចើម សម្លឹងមើលមិនដាក់ភ្នែក។

"មានអីឬ?"

មនុស្សមានខ្លួនភ្ញាក់ព្រើត លេបទឹកមាត់ក្អឹកៗ ប្រឹងរឹងខ្លួន ឡើងយ៉ាង



សរសៃ.ក ពេលឃើញម្ដាយមីងសម្លឹង.ករបស់នាងមិនដាក់ភ្នែក។ សង្ឃឹមថាមិនមែនស្នាម ដែលមនុស្សឆ្កួតនោះបន្សល់ទុកទៅចុះ ព្រោះនាងមិនបានគិតដល់ចំណុចនេះ ពេលចេញពីបន្ទប់ដេក។

"ស្នាមក្រហមៗនេះ ត្រូវស្អីខាំឬអត់ ហ៊ឹម?"

"អឺ...ពេលដើរម៉ោ ខ្ញុំត្រូវមូស ស្រមោចខាំ ទើបអេះ ក្រហមខ្លាំងទេ?"

"មិនខ្លាំងទេ តិចតួចទេ ងូតទឹកហើយរកថ្នាំលាបផង កុំឲ្យស្នាម ក្រែងលសត្វល្អិតមានពិស បើមិនជា ន្ទាលទៅរកពេទ្យ"

"អឺ...ចាំ មីង យើងទៅគេងទៅ ខ្ញុំងងុយហើយ ថ្មើរណេះពូថ្លៃអើត.កចាំហើយទេដឹង ជឿទេ បើដប់នាទីទៀត មីងមិនព្រមឡើងទៅ ច្បាស់ជាចុះមកតាមហើយ"

ស៊ុនស៊ូ នាំនិយាយរឿងផ្សេង បង្វែរចំណាប់អារម្មណ៍ម្ដាយមីង។

"អឺ! ឡើងគេងក៏បាន"

ម្ដាយមីងដែលមានអាយុមិនច្រើនជាងគ្នាប៉ុន្មាន អៀនឡើងក្រហមមុខ ដើរនាំមុខក្មួយស្រីឡើងទៅជាន់លើ ហើយពេលមកដល់មុខបន្ទប់ អេដែន បើកទ្វារចេញមកល្មម។

"ឃើញទេ ថាអីចេះខុស ខ្ញុំចូលបន្ទប់ហើយ ខ្ជិលមើលកុនផ្អែមល្ហែម រាត្រីសួស្ដី"

ស៊ុនស៊ូ មិចភ្នែកដាក់ម្ដាយមីង ហើយចូលបន្ទប់ដេករបស់ខ្លួនភ្លាម មិន

Scanned with CamScanner

រង់ចាំឲ្យម្ដាយមីងនិយាយអីទៀត។

"កាំង ស៊ុនស៊ូ"

ស៊ូអា និយាយបានតែប៉ុណ្ណឹង ក៏ញញឹម ដើរទៅរកស្វាមីដែលឈរឱបដៃមើលមកមិនដាក់ភ្នែក មុខសង្ហាឡើងកាចតែម្ដង។

"យឺតតែបន្តិចហ្នឹងឯង"

ពេលដើរទៅដល់ នាងក៏លើកដៃបះដើមទ្រូង និងស្ទាជំទូលាយរបស់ស្វាមី ហើយចំទើតជើងថើបបបូរមាត់របស់គេថ្នមៗ ដោយមុខក្រហមង៉ាំង។

"ចាំឡើងយូរ កំពុងតែចុះទៅតាម ទើបប្ដូរខោទឹកនោមឲ្យកូន និងបញ្ចុកទឹកដោះគោ ដេកលក់មិញហ្នឹង និយាយស្ដីយូរម៉េះ"

អេដែន សើចញឹមៗ ពេលត្រូវប្រពន្ធយកចិត្ត តែធ្វើជាកាច មិនព្រមស្រាយទឹកមុខ។

"ស្នួម ភ្ញាក់ ម៉េចមិនចុះទៅតាម អូនឲ្យកូនបៅដោះ"

"មិនបាច់ទេ ប្ដីបញ្ចុករួចរាល់ហើយ ដល់ពេលរបស់ប៉ាម៉ាក់ម្ដងហើយ"

"បងនេះ អូនបារម្ភពីក្មួយ ទើបនិយាយគ្នាយូរបន្តិច ហើយខ្លួនត្រូវស្នីខាំក៏មិនដឹង ឡើងកន្ទួលក្រហម ខ្លាចវាមានពិស តែនាងថាមិនអីទេ"

"ស្នីខាំនៅឯណា ?"

"ខាំក ឡើងកន្ទួលក្រហម នាងអេះឡើងស្នាមអស់ តែមិនក្រហមពេកទេ ដូចសាកពណ៌ហើយ បើស្អែកមិនជា គិតថានាំទៅពេទ្យ"



"ហ៊ឺៗ គង់តែជាទេ បើមានពិស ប្រហែលផ្សា រមាស់ មិនបាច់បង្វែររឿងទេ សុំដាក់ទោស ដែលក្រឡើងម៉ោ"

អេដែន សើចនៅដើម.ក កែវភ្នែកមុតស្រួចជះពន្លឺផ្លេកៗ ពេលភរិយាលើកដៃប៉ះកខ្លួនឯង អធិប្បាយឲ្យគេឃើញរូបភាព និងដឹងភ្លាមថាជាស្នាមអ្វី តែមិនប្រាប់ទេ ព្រោះបើប្រាប់ នាងនឹងឡូឡា រករឿង កាណែត មិនខាន អីចឹងហើយបណ្ដោយសិនទៅ ចាំមើលចរិតប្អូនប្រុសជើងល្អសិន បើវានៅតែមិនកែចរិត ជានាថាឆាប់ៗនេះ លោក អាហ្សា បានកូនប្រសាមួយទៀតមិនខាន។

គិតហើយ គេក៏អស់សំណើច ហើយឱនថើបបបូរមាត់ក្រពុំរបស់ភរិយានាំចូលបន្ទប់ដេក បង្កាត់ភ្លើងស្នេហាឲ្យឆេះសន្ធោសន្ធៅ ហើយទម្រាំតែរលត់ក៏ធ្វើឲ្យ ស៊ូអា អស់កម្លាំង ទើបព្រមឲ្យនាងសម្ងំដេកក្នុងលង្វែកទ្រូង និងលង់លក់ជាមួយគ្នារហូតដល់ព្រឹកថ្ងៃថ្មី។

**ថ្ងៃបន្ទាប់**

( បេះស្លឹកតែរួច ទៅជួយ សុងចូ មើលឯកសារនៅការិយាល័យផង )

កាណែត តេរមកប្រាប់អ្នកដែលកំពុងបេះស្លឹកតែ ឲ្យត្រឡប់ទៅធ្វើការឯកសារ បន្ទាប់ពីបេះស្លឹកតែរួច។

"មិនទៅធ្វើការនៅរោងអាហារទេក៏អី ?"

នាងធ្វើភ្នែកឡេមឡាម ពេបមាត់ដោយការពុញទ្រាន់។ មនុស្សឆ្កួតស្នី



Scanned with CamScanner

បញ្ហានេះបញ្ហានោះ មួយថ្ងៃច្រើនមុខ។

(ហើយខ្ញុំប្រាប់ឬអត់ថាឲ្យទៅធ្វើ មិនបានបញ្ហាគឺមិនបាច់)

"ចាំ ចៅហ្វាយ ពេលបេះស្លឹកតែរួច ខ្ញុំនឹងចូលទៅ ប៉ុណ្ណឹងចុះ ខាតពេលច្រើនណាស់ តិចបេះមិនទាន់គេឯង បេះបានតែស្លឹកតែចាស់ៗ ធ្វើឲ្យចម្ការតែរបស់លោកខូចរសជាតិទទេៗ"

នាងត្បុកដាក់ ហើយដាក់ទូរសព្ទចុះ មិនចង់ខាតពេលនិយាយជាមួយគេទៀត ហើយទោះវាញ័រនៅក្នុងហោប៉ៅ ព្រោះមានការគេរចូល ក៏មិនខ្វល់ពីវា។ ចង់តេរក៏តេរឲ្យបែកមេដៃទៅ នាងមិនរវល់ទេ។

"តេរឲ្យរឹងម្រាមទៅ មនុស្សឆ្កួតអំណាច គិតតែបញ្ហាៗ ពាលៗ ហ៊ឹយ!"

នាងកញ្ឆក់ស្លឹកតែចាស់ចេញពីដើម ញីហើយចោល បន្ទាប់មកទើបសម្រួលអារម្មណ៍ ធ្វើការបន្ត មិនចង់ឲ្យបរិយាកាសល្អៗបែបនេះ ត្រូវមួម៉ៅតាមអារម្មណ៍របស់នាង តែបេះចុះបេះឡើង អារម្មណ៍នៅតែខឹង ពេលនឹកដល់រឿងកាលពីយប់មិញ រឿងដែលគេចូលបន្ទប់ដេករបស់នាង និងរឿងកាលពីព្រឹកពេលជិះឡានមកធ្វើការជាមួយគ្នា ដែលគេដៀមដាមឌឺដងនាងមិនឈប់។

'ម៉េចដែរ យប់មិញដេកលក់ស្រួលទេ'

'ស្រួលមិនស្រួល ជារឿងរបស់ខ្ញុំ ខ្ញុំគ្មានតួនាទីអីឆ្លើយសំណួរលោកទេ'

'អ្ហ៎! នៅសម្ដីហាំដដែល សង្ស័យយប់មិញនៅតិចពេក មាត់បានបែបនេះខ្ញុំចូលចិត្ត'

គេសើចចំអក និងលើកដៃត្រដុសមាត់ខ្លួនឯងជាការដាស់តឿនដោយប្រយោល។

'ខ្ញុំមិនចូលចិត្តជាមួយទេ'

នាងងាកមុខចេញ ព្យាយាមមិនគិតដល់រឿងយប់មិញឲ្យមួម៉ៅ។

'មែនក៏អី កុំប្ដូរចិត្តមកចូលចិត្តខ្ញុំឲ្យសោះ'

'អួក! លង់ខ្លួនឯង គិតថាមុខមាត់ល្អណាស់ឬក៏អី ពុកមាត់ស្រមូម ខ្លួនសុទ្ធតែរោមដូចស្វាបែបនេះ គួរឲ្យស្រឡាញ់ត្រង់ណា ធ្វើប្ញកអន្ធពាលតែពាសដូចលោក ខ្ញុំក៏មិនចង់បានដូចគ្នា'

ឆឹត!

'នាងហ៊ានប្រៀបធៀបខ្ញុំនឹងស្វាផង!'

កាណែត បត់ចង្កូតឡានចូលចតអែបផ្លូវ និងជាន់ហ្វ្រាំងទាំងគំហុក លាន់សំឡេងទ្រហឹង ធ្វើឲ្យនាងផ្កាប់មុខ ហើយងាកមកធ្វើមុខកាចដាក់នាង។

'គិតខ្លួនឯងទៅ!'

'អី ហើយពេលត្រូវស្វារោមស្រមូវថើបនេះ មានអារម្មណ៍យ៉ាងម៉េច ស្រៀវខ្លះអត់'

'អាឡប់ អាមាត់ឆ្កែ'

'សាកបន្តិចក៏មិនខូចខាតអីដែរ ឲ្យវាដឹងថាមាត់ឆ្កែមែនអត់'

គេខាំធ្មេញក្រតៗ ស្រវាទាញនាងមកជិតបាន ដោយនាងមិនបានជា

Scanned with CamScanner

ប្រយ័ត្នខ្លួន ព្រោះរវល់តែតមាត់។

'អាមនុស្សឆ្កួត លែងខ្ញុំ អឺ!'

នាងហាមាត់ដេរ ហើយដកដង្ហើមដង្ហក់ ពេលត្រូវគេថើបមាត់ខ្លាំងៗ ជាការដាក់ទោស និងរុញទៅពិតនឹងទ្វារឡាននៅខាងក្រោយ បន្ទាប់មកក៏បន្ធូយកម្រិត មកទន់ភ្លន់ ថើបឲ្យថ្ងូរ ព្រោះអារម្មណ៍ស្រៀវស្រើប ពេលនាងអស់កម្លាំងរើបម្រះ។

'ហ៊ឹ! ប៉ុណ្ណឹងក៏ដឹងទៅហើយថាមាត់ខ្ញុំឆ្អែឬអត់ តែវាធ្វើឲ្យនាងថ្ងូរបានទៅចុះ ស៊ុនស៊ូ'

កាណែត និយាយខ្សឹបៗ ដាក់បបូរមាត់ក្រពុំ ដោយសំឡេងសិចស៊ី និងសម្លឹងមុខក្រហមង៉ាំងរបស់អ្នកដែលធ្វើភ្នែកព្រឹមៗ ដូចមនុស្សស្រវឹង ហើយប្រឹងទប់ចិត្ត នាងច្រមក់នេះសាហាវណាស់ មិនត្រូវលង់នាងជាដាច់ខាត។

'អា!'

ស៊ុនស៊ូ បើកភ្នែក ពេលបានឮសម្ដីកំណាចរបស់គេ ប្រឹងរុញគេចេញនិងចង់ដេរ តែត្រូវគេឱនមកថើបមាត់ម្ដងទៀត ដែលម្ដងនេះថើបជញ្ជក់ខ្លាំងៗ ជ្រែកអណ្ដាតមកជួសជងយករសជ្អែមល្ហែមពីក្នុងប្រអប់មាត់ ដោយនាងមិនអាចរើបម្រះ ឬជួយខ្លួនឯងបាន។

នាងស្ទឹកពេញខ្លួន ដកដង្ហើមដង្ហក់ បេះដូងលោតញាប់ ខ្លាំផង ក្ដិចផង រុញច្រានផង តែគេមិនព្រមថយចេញ ទាល់តែគេជួសជងឆ្អែតឆ្អោះឯង ទើបព្រមងើបចេញយឺតៗ ថយទៅផ្អែកនឹងកៅអី។

'ហ៊ឺយ! រាងគ្រាន់បន្តិច បែបនេះ ទើបស្វាត់ត្រចៀក'

និយាយហើយ គេក៏ញាក់ស្មាដាក់ និងបញ្ឆេះឡាន បើកចេញទៅយឺតៗ ដោយភ្នែកចេះតែដៀងមើលអ្នកអង្គុយក្បែរ ដែលក្លាយជាមនុស្សគមួយខណៈ កំពុងយកដៃជូតមាត់ខ្លួនឯងខ្លាំងៗ ដូចខ្លាចមិនជ្រះ។

'ជុំៗ មាត់ហើមជាំអស់ហើយ បែបនេះគេដឹងមិនខានថាទៅធ្វើស្អីម៉ោម៉េចដែរ ពុកមាត់ពុកចង្កាស្រមូមរបស់ខ្ញុំ វាឲ្យនាងស្រើបស្រាលទេ ស៊ុនស៊ូ សាកម្ដងទៀតទេ ហ៊ឹម?'

'បញ្ឈប់គំនិតឆ្កួតៗរបស់លោកទៅ អាមនុស្សថោកទាប'

នាងក្រមុំក្ដាប់មាត់ ក្ដាប់ដៃណែន សម្លឹងមុខគេ ហើយដោះខ្សែក្រវាត់ចុះពីឡាន ពេលមកដល់ការិយាល័យ។

'ទៅបេះស្លឹកតែដូចកាលពីម្សិល នៅកន្លែងចាស់'

នាងប្រុងដើរចូលការិយាល័យ តែពេលត្រូវគេចេញបញ្ជាបែបនេះ ក៏បង្វែរទិសដៅ ដោយមុនពេលទៅ មិនភ្លេចងាកទៅសម្លក់គេចង់ជ្រុះគ្រាប់ភ្នែក មាត់ក៏រអ៊ូមិនដាច់សូរ។

'មនុស្សឆ្កួត មនុស្សថោកទាប ខ្ញុំស្អប់លោក ស្អប់ ស្អប់ ស្អប់!'



"អ្នកនាង កាំង លោក កាណែត គេរមក ឲ្យអ្នកនាងទៅការិយាល័យ



Scanned with CamScanner

បានហើយ"

ស៊ុនស៊ូ ភ្ញាក់ព្រើត ដែលកំពុងបេះស្លឹកតែសុខៗ មេការ ចូ ក៏ដើរមកប្រាប់ ដោយមិនឲ្យសូរឲ្យសៀង ហើយញញឹមដាក់បុរសវ័យចាស់។

"ចាំតិចទៀតក៏បាន មេការ ចូ ឲ្យខ្ញុំបេះឲ្យរួចសិន កន្លះម៉ោងទៀត"

*ពេលនាងមិនលើកទូរសព្ទ ក៏តែរមករំខានអ្នកដទៃ ឲ្យមកតាម ធី:! ឲ្យចាំសិនទៅ នាងមិនព្រមទៅពេលនេះទេ!*

"ចង់បានអីចឹងឬ តែខ្ញុំខ្លាចលោក កាណែត ខឹង"

"មិនអីទេ មេការ លោក កាណែត របស់មេការខឹងខ្ញុំជាប្រពៃណីស្រាប់ហើយ បណ្តោយឲ្យខឹងផ្ទុះសរសៃឈាមបានកាន់តែល្អ"

"អូ! អ្នកនាង កាំង កុំទៅកាច់កុងលោក កាណែត អី"

បុរសវ័យចាស់ ធ្វើមុខ ធ្វើសំឡេងអង្វរករ សុំការយោគយល់ពីក្រមុំតូច ព្រោះស្គាល់ចរិតរបស់ចៅហ្វាយច្បាស់ កុំឲ្យខឹងឲ្យសោះ លោក កាណែត ខឹងអាក្រក់អាក្រីណាស់។

"មួយភ្លែតទៀតទេ មេការ ចូ គេប្រហែលមិនថាអីទេ ចាំខ្ញុំប្រាប់គេ មេការកុំបារម្ភអី"

ពេលឃើញទឹកមុខរបស់មេការ នាងក៏លើកដៃមើលនាឡិកា ហើយញញឹមដាក់។

"អូខេ រួចរាល់ហើយ ប្រញាប់ទៅផង"

មេការ ចូ ព្រមចាញ់ តែមិនភ្លេចបញ្ជាក់ ព្រោះបារម្ភ ខ្លាចចៅហ្វាយឡូឡា ដោយសារសំឡេងដែលបញ្ជាតាមទូរសព្ទកាចណាស់។

ស៊ុនស៊ូ តាមមើលបុរសវ័យចាស់ដែលបែរខ្នង ដើរចេញទៅ ហើយខាំមាត់ដោយការពិចារណា បន្ទាប់មកក៏សម្រេចចិត្តបេះស្លឹកតែបន្ត។ ពេលដល់ម៉ោង យកស្លឹកតែដែលបេះបានឲ្យអ្នកប្រមូលហើយ ទើបនាងដើរទៅលាងដៃលុបលាងមុខមាត់ ហើយដកដង្ហើមចូលឲ្យពេញសួត ពេលដើរទៅការិយាល័យដែលពេលទៅដល់ សុងចូ ក៏ងើបមុខមកញញឹមដាក់។

"ម៉ោយឺតតិចតួច សង្ឃឹមថាចៅហ្វាយរបស់លេខា ហុង មិនឡូឡាទេ"

"មិនច្បាស់ទេ ជំនួយការ កាំង ត្រៀមខ្លួនទៅ ខ្ញុំមិនចង់បាត់បង់ជីវិតនៅពេលនេះទេ"

សុងចូ ខ្សឹបខ្សៀវ ខ្លាចចៅហ្វាយចេញមកឮ ព្រោះពេលនេះ កាណែត មានទឹកមុខគួរឲ្យខ្លាចណាស់។

"ដល់ម្លឹងផង!"

នាងក្រមុំលេបទឹកមាត់ក្អឹកៗ បុកពោះតិចៗ។

"តិចតួច"

"ស៊ុនស៊ូ ម៉ោហើយនៅ?"

កាណែត បើកទ្វារបន្ទប់ធ្វើការរបស់ខ្លួនចេញមក ព្រមទាំងគំហកសួរ ហើយពេលឃើញអ្នកដែលខ្លួនសួររក ក៏បាញ់ខ្សែភ្នែកកាចដាក់។

Scanned with CamScanner

"ម៉ោ...ម៉ោហើយ លោក កាណែត"

"ចូលបន្ទប់ធ្វើការ!"

ពេលប្រាប់ហើយ គេក៏ចូលទៅក្នុងវិញ ទុកឲ្យមនុស្សពីរនាក់មើលមុខគ្នាឡើងឡង់ៗ។

"សំណាងល្អ ជំនួយការ កាំង"

"សំណាងល្អអី បែបនេះ សំណាងអាក្រក់ច្បាស់ណាស់"

នាងខ្សឹបប្រាប់ សុងចូ ហើយដកដង្ហើមធំ ដើរចូលបន្ទប់ធ្វើការរបស់ចៅហ្វាយ ដោយបេះដូងលោតរាងញាប់ គិតថាថ្ងៃមួយ នាងអាចស្លាប់ ព្រោះគាំងបេះដូង។

"បិទទ្វារផង!"

សំឡេងគំហកេរបស់គេ ធ្វើឲ្យអ្នកកំពុងគិត ទៅជាភ្ញាក់ព្រើត ឆ្លោយរុញទ្វារបិទ លាន់សំឡេងប៉ុងប៉ុង ហើយឈរធ្មឹង មិនកម្រើក។

"មិនមែនចង់ឲ្យខ្ញុំជំទាលនិយាយជាមួយនាងទេ ស៊ុនស៊ូ"

នាងក្រមុំខាំមាត់ ដើរទៅជិតតុ មើលគេដោយការប្រុងប្រយ័ត្ន។

"ខ្ញុំប្រាប់ឲ្យនាងម៉ោពេលណា ហើយម៉េចមិនម៉ោ!

"ខ្ញុំកំពុងបេះស្លឹកតែ បេះជិតរួចហើយ ទើបចាតិចទៀតចាំម៉ោក៏បាន តែមួយភ្លែតទៀតទេ"

នាងលេបទឹកមាត់ឡើមបំពង់.ក និងសម្របសំឡេងមិនឲ្យញ័រ ពេលឲ្យ



ហេតុផលគេ។

"ខ្ញុំបញ្ជាគឺបញ្ជាឲ្យម៉ោ មិនមែនមិនព្រមម៉ោ ហើយមិនព្រមលើកទូរសព្ទខ្ញុំទៀត បែបនេះមានន័យថាម៉េច!"

"មិនបានមានន័យថាម៉េចទេ គ្មានអីដោះសាទេ"

ប៉ឹក!

"ស៊ុនស៊ូ!"

កាណែត ទម្លាក់សំណុំឯកសារលើតុមួយទំហឹង និងគំហកហៅ ឲ្យនាងភ្ញាក់ព្រើត។

"លោកហៅឈ្មោះខ្ញុំញឹកយ៉ាងនេះ ខ្លាចភ្លេចឬយ៉ាងម៉េច!"

ថ្វីត្បិតខ្លាចមែន តែមិនឲ្យគេដឹងដាច់ខាតថានាងខ្លាច។

"ពូកែសៀតស៊កណាស់ អីចឹងម៉ោណេះ"

គេស្ទុះងើបចេញពីតុ ដើរមករកលឿនស្លេវ ខុសពីរាងកាយមាំមួន ដែលមិនសមធ្វើសកម្មភាពហ័សរហួនយ៉ាងនេះ ធ្វើឲ្យនាងគេចមិនទាន់។ ពេលមកដល់ គេចាប់ដើមដៃទាំងពីររបស់នាង ច្របាច់ខ្លាំងៗឲ្យឈឺ សម្លឹងមុខដោយខ្សែភ្នែកកាច ចុងច្រមុះក៏រីក ព្រោះខឹង។

"លោកចង់ធ្វើអី!"

"ប្រដៅឲ្យរាងចាល"

គេខាំធ្មេញ និយាយខ្សឹបៗ ហើយទាញនាងឲ្យដើរតាម ឬហៅថាអូសក៏

បាន ព្រោះនាងប្រឹងក្រាញ។

"មិនទៅ អាំ!"

នាងប្រឹងរើបម្រះយ៉ាងងាប់យករស់នៅក្នុងរង្វង់ដៃរបស់គេ។

"មិនឃើញមានអីឲ្យខ្លាច មិញនៅហាំតើ"

គេប្រើកម្លាំងដែលមានច្រើនជាង អូសនាងទៅដល់សាឡុងសម្រាប់ទទួលភ្ញៀវ ដែលនៅមិនឆ្ងាយប៉ុន្មាន ហើយរុញឲ្យដួលទៅលើនោះ។

"អ៊ូយ!"

នាងស្រែក ទោះពូកទន់ក៏ដោយ តែគេរុញមួយទំហឹងដោយមិនឲ្យដឹងខ្លួនបែបនេះ វាតែងតែឈឺហើយ ហើយប្រញាប់ប្រែខ្លួន តែគេចមិនទាន់ ព្រោះត្រូវទ្រាបពីលើ ចាប់ដៃទាំងពីរសង្កត់នឹងបង្អែកសាឡុង មិនកម្រើករួច។

"លោកចង់ធ្វើឆ្កួតស្អី!"

"ធ្វើស្អីទៅណាំ"

គេនិយាយខ្សឹបៗ ដោយការបេះបួយឲ្យនាងភ័យលេង។

"លែងខ្ញុំ លោកម៉ោធ្វើបែបនេះដាក់ខ្ញុំមិនបានទេ"

នាងពើងទ្រូង ធ្វើជាមិនខ្លាច ទាំងដែលខ្លួនប្រាណញ័រទទ្រើត ខ្លាចអ្វីដែលនឹងកើតឡើងបន្ទាប់ពីនេះ ព្រមទាំងប្រឹងមូល.កដៃឲ្យរបូតពីដៃរបស់គេ តែមិនងាយនោះទេ ដៃរបស់គេដូចដង្កាប់ កម្លាំងក៏ច្រើន សង្កត់មិនឲ្យរើបម្រះរួច ថែមទាំងព្រួសខ្យល់ដង្ហើមក្ដៅៗដាក់ទៀត។



កាណែត មិននិយាយអីទៀត ក្រៅពីឱនមកថើបមាត់ តែនាងគេចទាន់ ទើបបបូរមាត់ក្ដៅសង្កត់លើថ្ពាល់រលោង គេគ្រហឹមដោយការឃ្នើសចិត្ត ខាំធ្មេញក្រតៗ ខឹងកាន់តែខ្លាំង ពេលឃើញកាយវិការរើសអើងរបស់នាងដែលមានចំពោះគេបែបនេះ ទើបសង្កត់បបូរមាត់នឹងថ្ពាល់រលោងខ្លាំងៗ បន្ទាប់មកអូសចុះក្រោម បំណងមករកបបូរមាត់ក្រពុំដើម្បីត្លក្សរសជាតិដូចកាលពីព្រឹក ឬធ្វើអ្វីលើសពីនោះ តែសំឡេងចេញពីទូរសព្ទទំនើបក៏បន្លឺឡើង ធ្វើឲ្យគេដកដង្ហើមធំ បិទភ្នែក ខាំធ្មេញក្រតៗ ម្ដងទៀត ថ្ពាល់ឡើងរឹងកំព្រឹស ហើយបើកភ្នែកសម្លឹងមុខនាងមិនដាក់ភ្នែក ដោយរង់ចាំថាអ្នកតេរមកលះបង់ការព្យាយាមទេ តែសំឡេងនោះនៅតែរោទ៍ ទើបគេសម្រេចចិត្ត ងើបចេញពីខ្លួននាង លើកដៃជ្រងសក់។

"ហាមចេញពីបន្ទប់នេះដាច់ខាត!"

គេបញ្ជានាងដោយទឹកមុខកាច ហើយដើរទៅរកទូរសព្ទ។

ស៊ុនស៊ី ធូរទ្រូងខ្សាក លើកដៃជូតថ្ពាល់ និងចាប់កដៃរបស់ខ្លួនរលាស់។ ពេលប្រាកដប្រជានេះ កាណែត គួរឲ្យខ្លាចណាស់ គួរឲ្យខ្លាចដូចមេការ ចុ ថា មែនហ្នឹង ធ្វើឲ្យនាងភ័យចង់រាកនោម ទើបមិនហ៊ានចេញពីបន្ទប់នេះ រង់ចាំឲ្យគេនិយាយទូរសព្ទចប់ ទាល់តែដល់ថ្ងៃត្រង់ សុងចូ ក៏ចូលមកតាមទៅរកបាយទឹក ទើបនាងអាចយោងអាត្មាបានម្ដងទៀតប៉ុន្តែពេលរសៀល គឺត្រូវប្រឈមមុខនឹងគេដដែល។

Scanned with CamScanner

# ៥

កាណែត មកជួបភ្ញៀវបរទេស នៅសណ្ឋាគារទំនើបក្នុងក្រុង ដោយនាំលេខាធិការនិងជំនួយការមកជាមួយ ហើយពេលនេះគេកំពុងនិយាយពីទំនិញនិងផលិតផល ដែលភ្ញៀវម្នាក់នេះចាប់អារម្មណ៍ ព្រោះធ្លាប់កុម្ម៉ង់ឈុតធំៗច្រើនដងហើយ និងកុម្ម៉ង់ជាបន្តបន្ទាប់ តែលើកនេះមកចរចាដោយផ្ទាល់ ព្រោះត្រូវការនាំចូលផ្តាច់មុខ ធ្វើជាតំណាងតែម្នាក់គត់នៅទីផ្សារក្នុងប្រទេសបារាំង។ អ្នកកំលោះមិនទាន់សម្រេចចិត្តភ្លាម ព្រោះមានភ្ញៀវជាច្រើនចង់ធ្វើជាតំណាងទំនិញនេះដែរ ដូច្នេះហើយ ទើបគេត្រូវការពិចារណាឲ្យម៉ត់ចត់។

"អរគុណច្រើន លោក កាណែត ដែលព្រមមកចរចាជាមួយខ្ញុំបែបនេះ ស្អែកនេះខ្ញុំទៅមើលទំនិញនៅចម្ការរបស់លោក និងអាចធ្វើការសាកល្បងដែរ"

ភ្ញៀវជនជាតិបារាំង ញញឹមពព្រាយដោយការពេញចិត្ត និងលូកដៃមកសុំចាប់ដៃ កាណែត បន្ទាប់ពីការចរចានេះបញ្ចប់យ៉ាងរលូន។

"រីករាយ លោក អាល់បឺត ចម្ការតែ ឈើរីសេទិ ស្វាគមន៍ជានិច្ច"

កាណែត ចាប់ដៃជាមួយភ្ញៀវ ដោយទឹកមុខញញឹមដូចគ្នា។

"អ៊ីចឹង ខ្ញុំនិងកូនចៅសុំលាសិនហើយ ឲ្យលោក អាល់បឺត បានសម្រាក



ស្អែកនេះបានទៅមើលចម្ការតាំងពីព្រឹក ដើម្បីបានទស្សនាវិធីប្រមូលផល និងផលិត ខ្ញុំឲ្យអ្នកនៅចម្ការមកទទួល សេចក្តីលម្អិត ខ្ញុំឲ្យលេខារបស់លោកហើយបើត្រូវការកែប្រែយ៉ាងណា ជួយប្រាប់ផង"

កាណែត សុំលា បន្ទាប់ពីរៀបចំឯកសារ ហុចឲ្យលេខាធិការរួចរាល់។

"អូខេ"

អាល់បឺត ងក់ក្បាល ហើយដើរចេញពីបន្ទប់ប្រជុំ ចំណែក កាណែត ក៏ងៀងមើលកូនចៅរបស់ សុងចូ ដែលនៅក្នុងបន្ទប់នេះដែរ ឃើញនាងធ្វើក្រទើដាក់ ទើបគេព្យាយាមធ្វើជាមិនចាប់អារម្មណ៍។

"ទៅញ៉ាំបាយនៅហាងក្នុងក្រុងសិន ល្ងាចណាស់ហើយ"

អ្នកកំលោះលើកដៃមើលនាឡិកាទំនើប ហើយងាកទៅប្រាប់កូនចៅ ព្រោះកុំឲ្យខាតពេលទៅណាឆ្ងាយ ថ្មើរណេះល្ងាចណាស់ទៅហើយ បើចាំទៅទទួលទានផ្ទះ យប់ល្មម។

"បាទ លោក កាណែត"

សុងចូ ទទួលបញ្ជា ខណៈនោះក៏ងៀងមើល ស៊ុនស៊ូ ដែលធ្វើជាមិនចាប់អារម្មណ៍អ្នកណាទាំងអស់ ទើបសើចញឹមៗ ដាក់ចៅហ្វាយ ដែលបាញ់ខ្សែភ្នែកកាចមករក។

ស៊ុនស៊ូ នៅតែស្ងប់ស្ងាត់បន្ត មិនចង់តមាត់ត.ក គេសម្រេចយ៉ាងណាក៏ត្រូវតែធ្វើតាមនោះ ព្រោះនាងមកឡានជាមួយ សុងចូ។



Scanned with CamScanner

កាណែត លើកដៃ សម្រួលដៃអាវ ហើយដើរយ៉ាងសង្ហាចេញទៅ ដែលធ្វើឲ្យនាងអត់ជ្រេញមិនបាន ទើបលៀនអណ្តាតនិងជ្រួញច្រមុះតាមពីក្រោយ។

"ហ៊ឺ! មិនសួរយោបល់អីមួយម៉ាត់ ពូកែតែបញ្ជាៗ ស្អប់ណាស់"

"ហាសហា អ្នកនាង ស៊ុនស៊ូ កំប្លែងមែន កាយវិការបែបនេះ កុំឲ្យលោក កាណែត ឃើញឲ្យសោះ ជានាថានឹងមានរឿង"

"បើលេខា ហុង មិនប្រាប់ គេក៏មិនដឹងដែរ"

"អូខេ តែឆាប់តាមទៅ មុនពេលត្រូវទាំងមួយទាំងពីរ"

សុងចូ ញញឹម ហើយដុកនាងឲ្យប្រញាប់ដើរទៅតាមចៅហ្វាយ ព្រោះបើយឺតយ៉ាវ នឹងត្រូវឡូឡាមិនខាន។

"ចាំ"

ស៊ុនស៊ូ ងក់ក្បាល ហើយដើរតាមមកដល់មុខសណ្ឋាគារ ដែលពេលនេះបុគ្គលិកយកឡានមកចតឲ្យហើយ ដោយមានចៅហ្វាយឈរឱបដៃចាំ មុខឡើងក្រមូវ។

"រវល់ធ្វើស្អី ម៉េចក៏ស្ពឹកម្លេះ"

"មិនបានរវល់ធ្វើអីទេ លោក កាណែត ជូនអី ខ្ញុំឆែកថាមានឯកសារអីដាក់ចូលមិនទាន់អស់ឬអត់ ខ្លាចធ្វើឲ្យជ្រុះបាត់"

សុងចូ ប្រញាប់ដោះសា ចំណែក ស៊ុនស៊ូ មិនចង់មើលមុខមនុស្សដែលចូលចិត្តរករឿងអ្នកដទៃ ទើបធ្វើជាមើលនេះមើលនោះ កំដរភ្នែក។

"អីចឹងឡើនឡានទៅ ខ្ញុំឃ្លានបាយ"

កាណែត បញ្ជា ហើយឡើងឡានខាងអ្នកបើក បើកបិទទ្វារលាន់ប៉ុងប៉ុង សុងចូ ក៏ប្រញាប់ឡើងមកអង្គុយក្បែរ ចំណែក ស៊ុនស៊ូ ឡើងចាំងក្រោយ បិទទ្វារបណ្តើរ រអ៊ូរទាំបណ្តើរ។

"កាលពីថ្ងៃ ញាំបាយចង់អស់មួយបេអង្ករ នៅមករអ៊ូថាឃ្លានទៀត ក្រៅពីជាស្វាហើយ នៅជាខ្លាឃ្មុំស៊ីច្រើនទៀត"

"កុំស្មានថាខ្ញុំមិនឮ ស៊ុនស៊ូ"

អ្នកកំលោះគ្រហឹមនៅដើម.ក ទាំងដែលកំពុងបើកឡាន ទើបមិនងាកទៅមើលនាង។

*មានត្រចៀកទិព្វឬយ៉ាងម៉េច និយាយខ្សឹបៗ សោះ មនុស្សឆ្កួតនេះ ត្រចៀករវៀសម្លេះ!*

នាងរអ៊ូរទាំនៅក្នុងចិត្ត ព្រមទាំងធ្វើភ្នែកឡេមឡាមមើលលើ។

"សុំទោស ខ្ញុំប្រហែលរអ៊ូរាងឮបន្តិច"

នាងមិនបដិសេធ ថែមទាំងធ្វើមុខធ្វើមាត់ព្រមទទួលទៀត ហើយពេលនិយាយរួច ក៏លើកដៃឱបទ្រូង ងាកទៅមើលក្រៅឡាន។

សុងចូ លួចលេបទឹកមាត់ក្អឹកៗ សំណាងដែលគេអង្គុយបាំងមុខ មិនអីចឹង ចៅហ្វាយមុខជាចាប់កាច់កនាងមិនខាន។

កាណែត ខាំធ្មេញក្រតៗ មិននិយាយអីទៀត តែបញ្ជាឡានមកដល់

Scanned with CamScanner

ហាងអាហារល្បីឈ្មោះនៅក្នុងក្រុង ដែលតែងតែមកជាមួយបងប្រុស។ ហាងតុបតែងស្អាត មានបរិយាកាសល្អដូចផ្ទះចម្ការនៅបរទេស បន្ទប់អាហារមានទីធ្លានៅខាងក្រៅ និងខាងក្នុង ដែលជាកញ្ចាំងកញ្ចក់ និងមានជាន់លើដំបូលមានតន្ត្រីករប្រគុំបទភ្លេងពីរោះៗ ឲ្យស្តាប់នៅខាងលើ ដែលប្រគុំចាប់ពីម៉ោងប្រាំបីយប់។

"សួស្តី លោក កាណែត ទៅខាងលើ ឬនៅខាងក្រោម?"

អ្នកចាត់ការចេញមកស្វាគមន៍ ដោយទឹកមុខញញឹម។

"នៅខាងក្រោម ថ្ងៃនេះនាំកូនចៅមកញាំបាយ មិននៅយូរទេ"

កាណែត បួញមាត់ទៅតុខាងក្រោម ដែលមានតុទំនេរច្រើន។

"បាទ អ៊ីចឹងយកតុនៅវានហាល មាត់អាង ឃើញទេសភាពស្អាត"

"អរគុណ"

គេងក់ក្បាល ហើយដើរតាមអ្នកចាត់ការសំដៅតុដែលត្រូវណែនាំ មើលឃើញទេសភាពស្អាតដូចដែលបានប្រាប់។

"មេនុយ"

អ្នកចាត់ការយកមេនុយពីកូនចៅមកដាក់ឲ្យភ្ញៀវ។

"ខ្ញុំសុំបៀរត្រជាក់ៗ មួយកែវ ចំណែកអាហារចាំឲ្យពីរនាក់នេះរើស ឯងយកបៀរទេ សុងចូ?"

ពេលកុម្ម៉ង់បៀរឲ្យខ្លួនឯងរួច គេក៏ងាកទៅសួរកូនចៅដែលអង្គុយក្បែរ



ចំណែកម្នាក់ទៀតអង្គុយទល់មុខ កុម្ម៉ង់ទឹកសុទ្ធឲ្យខ្លួនឯង។

"បាទ បានមួយកែវក៏ល្អដែរ"

សុងចូ សើចញឹមៗ ដាក់ចៅហ្វាយ។

"បាទ ចំណែកអាហារ បន្តិចទៀតនឹងមកសួរនាំ"

អ្នកចាត់ការប្រាប់ ហើយនាំកូនចៅដើរចេញឆ្ងាយបន្តិច ទុកពេលឲ្យភ្ញៀវរើសមុខម្ហូបដែលត្រូវការ។

"អ្នកទាំងពីរផឹកបែបនេះ បើកឡានរួចទេ?"

នាងបាញ់ខ្សែភ្នែកស្តីបន្ទោសដាក់ចៅហ្វាយ ទើបត្រូវគេសម្លឹងមុខវិញ។

"ត្រឹមបៀរមួយកែវ មិនធ្វើឲ្យខ្ញុំស្រវឹងទេ ស៊ុនស៊ូ កុម្ម៉ង់អាហារទៅ ន្ទាលញ៉ាំ កុំឲ្យខ្ញុំថែមកែវទីបី ទីបួនទាន់ មិនអ៊ីចឹងទៅផ្ទះវិញ វាលំបាក អ៊ឹម! តែថ្ងៃមុនខ្ញុំក៏នាំនាងទៅផ្ទះបានតើ ឬនាងភ្លេចទៅហើយ ហ៊ឹ?"

កាណែត ញញឹមចុងមាត់ ពេលនឹកឃើញរឿងមួយ ហើយលើកបៀរជិបខណៈនោះក៏ស្រឹមភ្នែកមើលអ្នកអង្គុយទល់មុខ ដោយខ្សែភ្នែកលាក់កំណួច។

"លោក កាណែត"

នាងខ្ទឹបមាត់ ក្តាប់ដៃណែន សម្លក់សម្លឹងគេ ក្នុងចិត្តក៏ចង់រកស្តីចាក់មាត់គេមែនទែន។

"ហេឡូ! សុំកុម្ម៉ង់អាហារ"

អ្នកកំលោះញាក់ស្មាដាក់ ហើយបក់ដៃហៅបុគ្គលិកមកកុម្ម៉ង់អាហារ



Scanned with CamScanner

ដោយ សុងចូ កុម្ម៉ង់បានបន្តិច ចំណែក ស៊ុនស៊ូ គិតតែអង្គុយស្ងៀម ព្រោះឮបុរសៗ កុម្ម៉ង់ច្រើនហើយ។

ពេលអាហារមកដល់ កាណែត ទទួលទានបណ្ដើរ ផឹកបៀរបណ្ដើរ និងលួចមើលអ្នកនៅទល់មុខដោយខ្សែភ្នែកមានពន្លឺផ្លេកៗ ដែលគេមិនដឹងខ្លួន តែពេលនាងងើយមុខ ក៏ធ្វើជាមើលទៅផ្សេង ហើយខាំធ្មេញក្រតៗ ពេលឃើញថានរណាកំពុងដើរសំដៅមក។

"មានអីឬលោក ?"

សុងចូ ខ្សឹបសួរ ពេលឃើញកាយវិការរបស់ចៅហ្វាយ ហើយពេលមើលតាមខ្សែភ្នែកកាចនោះ ទើបយល់។

"សួស្ដី លោក កាណែត ខានជួបយូរហើយ ខ្ញុំក៏ចាំមិនបានដែរនេះ"

បុរសរាងខ្ពស់ស្រឡះ មុខមាត់សង្ហា ចរិតផ្លេបិយ ដើរមករាក់ទាក់ដោយទឹកមុខញញឹម និងមើលគ្រប់គ្នា ហើយក៏ជំទប់ភ្នែកនឹងស្រីស្អាត។

"សួស្ដី ម្ចាស់ចម្ការ សាន"

កាណែត សម្លឹងមុខអ្នកដែលមករាក់ទាក់ខ្លួន ហើយញោចចុងមាត់ពេលឃើញម្ចាស់ចម្ការ សាន ឬ សាន ដុងវ៉ុក មើល ស៊ុនស៊ូ មិនដាក់ភ្នែក ទើបមើលនាងម្ដង ចង់ដឹងថានាងមានប្រតិកម្មបែបណាចំពោះបុរសរាងឈើចាក់ធ្មេញ។

"រីករាយដែលលោក កាណែត ចាំខ្ញុំបាន អីចឹងខ្ញុំសុំអញ្ជើញលោកផឹកបៀរមួយជុំ"

ដុងវ៉ុក ឆ្លៀតឱកាសនេះដាក់បង្អួយក្បែរស្រីស្អាត ព្រមទាំងមានចេតនាឲ្យស្មារបស់ខ្លួនប៉ះស្មារបស់នាង ដែលធ្វើឲ្យនាងភ្ញាក់ព្រើត ខិតចេញបន្តិច។

"ឃើញថាមិនបានទេ ខ្ញុំត្រូវបើកឡាន ហើយខ្ញុំក៏កុម្ម៉ង់រួចដែរ មិនរំខានម្ចាស់ចម្ការ សាន ទេ"

កាណែត ខាំធ្មេញក្រតៗ ពេលឃើញកាយវិការដាក់សម្ពាធរបស់ ដុងវ៉ុក ដែលមានចំពោះ ស៊ុនស៊ូ ពេលនោះបុគ្គលិកលើកបៀរដែលគេកុម្ម៉ង់មកដាក់ឲ្យល្មម។

"មិនអីទេ អីចឹងខ្ញុំសុំជល់កែវមួយទៅចុះ សួស្ដី យកបៀរមួយកែវ ជូនលោក កាណែត"

"បាទ"

បុគ្គលិកងក់ក្បាល ហើយលើកបៀរត្រជាក់មកដាក់ឲ្យភ្លាម។

"ខ្ញុំសុំជល់កែវ លោក កាណែត លេខា ហុង និងអ្នកនាងស្អាត"

ដុងវ៉ុក លើកកែវបៀរ និងញញឹមដាក់ តែកែវភ្នែកលាក់កំណួចមើលទៅគ្រប់គ្នា តែពេលមកដល់ ស៊ុនស៊ូ បែរជាមិចភ្នែកដាក់នាង ដែលពេលនេះខិតទៅជិតដល់រនាំងឈើទៅហើយ។

"ខ្ញុំមិនផឹកបៀរទេ"

នាងគ្រវីក្បាលបដិសេធ និងមិនព្រមមើលមុខគេចំ ព្រោះខ្សែភ្នែករបស់គេដែលមើលមកនាង គួរឲ្យស្អប់ខ្លាំងណាស់។

Scanned with CamScanner

"អ៊ីចិងឬ សុំជល់ទឹកសុទ្ធទៅចុះ"

ម្ចាស់ចម្ការ សាន ញាក់ស្មាបន្តិចដាក់ ហើយយកកែវបៀររបស់ខ្លួនទៅជល់និងកែវទឹកសុទ្ធរបស់នាង ហើយពេលងាកមកញញឹមដាក់ កាណែត និង សុងចូ រួច ទើបលើកបៀរផឹកអស់ពីកែវ ខណៈដែលពីរនាក់ទៀតជិបតិចៗ។

"អាំ! បៀរត្រជាក់ៗ នេះឲ្យអារម្មណ៍ស្រស់ស្រាយណាំះ សមនឹងអង្គុយគយគន់ទេសភាព មើលរបស់ស្អាតៗ"

ដុងវ៉ុក ដាក់កែវទទេចុះ លើកដៃត្រដុស លើកចិញ្ចើមម្ខាង និយាយស្ដីឌិដងអ្នកអង្គុយក្បែរ ដោយ កាណែត មើលមិនដាក់ភ្នែក។

"ប្រហែលអ៊ីចឹងទេដឹង ខ្ញុំនិងកូនចៅឆ្អែតហើយ បើម្ចាស់ចម្ការ សាន មិនប្រកាន់ ខ្ញុំសុំទៅមុនហើយ ហេឡូ! គិតលុយ"

កាណែត ញញឹមចុងមាត់ ពេលនិយាយ ព្រោះមិនចូលចិត្តបុរសមុខខូចម្នាក់នេះ មិនចង់ជ្រលក់មាត់។

"អ៊ឹម! អ៊ីចឹង ខ្ញុំក៏សុំទៅដែរ សង្ឃឹមថាបានជួបគ្នាទៀត មិនច្បាស់ទេ ខ្ញុំអាចទៅកម្មវិធីប៉ុឡូក៏ថាបាន"

ម្ចាស់ចម្ការ សាន ញញឹម និយាយពីកម្មវិធីប៉ូឡូសប្បុរសដែលនឹងរៀបចំនៅមិនប៉ុន្មានអាទិត្យទៀត គេក៏ជាសមាជិក និងបានលិខិតអញ្ជើញហើយដែរ ដំបូងថាមិនទៅ តែពេលនេះមានរបស់គួរឲ្យចាប់អារម្មណ៍ទាក់ទាញអារម្មណ៍ឲ្យគេចង់ទៅហើយ។



"ដោយក្ដីរីករាយ ខ្ញុំជឿថាម្ចាស់ចម្ការ សាន បានលិខិតអញ្ជើញ ដើម្បីយកលុយ ដែលប្រមូលបានជួយទៅជួយមូលនិធិ"

"ចាស អ៊ីចឹងចាំជួបគ្នានៅកម្មវិធី លោក កាណែត លេខា ហុង និង អ្នកនាងស្អាត ខ្ញុំមិនទាន់ស្គាល់ទេ ថាអ្នកនាងឈ្មោះអី"

"កាំង ស៊ុនស៊ូ"

កាណែត ប្រាប់ឲ្យ ចំណែកម្ចាស់ឈ្មោះក៏ខ្ទឹបមាត់ មើលមកគេ ដោយការឃ្នើសចិត្ត។

"ឈ្មោះពីរោះដល់ហើយ អ្នកនាង កាំង សង្ឃឹមថាជួបគ្នានៅកម្មវិធី"

ដុងវ៉ុក ធ្វើមុខធ្វើមាត់ប្រឡឺមដាក់ស្រីស្អាត ដោយមិនខ្វល់ពីខ្សែភ្នែករបស់អ្នកណាដែលមើលមក។

"ចាំ"

នាងសើចញឹមៗដាក់គេដោយចៀសមិនខាន ហើយងាកទៅសម្លឹងមុខអ្នកអង្គុយទល់មុខ ដែលពេលនេះធ្វើប៉ើយ ឲ្យនាងចង់ខ្វាចមុខសង្ហានោះ។

*ស្អប់ណាស់ ចេះដឹងមិនទំនង!*

សុងចូ មើលម្ចាស់ចម្ការ សាន ដោយការមិនពេញចិត្ត ព្រោះមិនចូលចិត្តស្រាប់ហើយ ដែលធ្វើឫកព្រាននារីដាក់ ស៊ុនស៊ូ ចេញមុខមាត់ ដោយមិនទុកមុខឲ្យចៅហ្វាយ និងគេ ទាំងដែល ស៊ុនស៊ូ មកជាមួយពួកគេ នេះបើនាងមកម្នាក់ឯង ជានាថាមិនរួចពីដៃអាព្រាននេះទេ។





Scanned with CamScanner

"រួចរាល់ហើយ លោក កាណែត"

សុងចូ ប្រាប់ចៅហ្វាយ ពេលបុគ្គលិកយកលុយអាប់មកឲ្យ ហើយពួកគេក៏ងើបឈរ ដើរចេញពីតុ ដែលពេលនោះ ដុងវ៉ុក ក៏លួចស្រង់ក្លិនក្រអូបដែលភាយចេញពីខ្លួនរបស់ ស៊ុនស៊ូ ដោយម្ចាស់ខ្លួនមិនដឹង តែ កាណែត និង សុងចូ មើលឃើញ។

ស៊ុនស៊ូ ដើរចេញទៅ តាមដោយ សុងចូ ចំណែក កាណែត បន្ទាប់ពីដើរបានប៉ុន្មានជំហាន ក៏ងាកមករកអ្នកដែលមិនទាន់ដើរទៅណា។

"ស៊ុនស៊ូ ជាក្មួយស្រីរបស់ភរិយាបង អេដែន បើចង់ធ្វើអី ត្រូវចាំទុកថាត្រកូល ឈើរ៉សេទិ ការពារនាងដូចការពារមនុស្សរបស់ ឈើរ៉សេទិ គ្រប់គ្នា"

កាណែត និយាយដោយទឹកមុខស្មើក៏ពិតមែន តែឲ្យអារម្មណ៍ព្រឺសម្បុរដល់អ្នកស្ដាប់។

"ខ្ញុំមិនបានធ្វើអីឯណា លោក កាណែត អ៊ូហ៊ូ! មិនស្មានថាជាក្មួយស្រីរបស់ភរិយាលោក អេដែន សោះ ស្អាតដូចម្ដាយមីង ណ៎ះ អ៊្ហ៎! ខ្ញុំធ្លាប់ឮថាបងស្រីរបស់ភរិយាលោក អេដែន ធ្លាប់ជាភរិយាចាស់របស់លោក អឺចឹងអ្នកនាងស៊ុនស៊ូ ជាកូនស្រីរបស់បងស្រីរបស់ភរិយាលោក អេដែន"

ទោះបុកពោះនឹងទឹកមុខ ពន្លឺភ្នែកកាចរបស់ កាណែត យ៉ាងណា ក៏នៅតែចង់និយាយឆ្កឹះឆ្កៀល។

"មែន ហើយសង្ឃឹមថាម្ចាស់ចម្ការ សាន ផ្ដល់កិត្តិយសឲ្យនាងដូចដែលពួកខ្ញុំផ្ដល់កិត្តិយសឲ្យលោក"

កាណែត ដាស់តឿនដោយប្រយោលម្ដងទៀត។

"បាទ ធានាបានថាខ្ញុំមិនធ្វើអីឲ្យខូចខាតទេ"

"បើលោកនិយាយបែបនេះ ខ្ញុំក៏សប្បាយចិត្ត យើងមិនបាច់មានរឿងអីប៉ះពាល់គ្នា តែបើមាន ខាង ឈើរ៉សេទិ ត្រៀមរួចជានិច្ច សុំទៅសិនហើយ"

កាណែត ព្រឹមភ្នែកមើលគូសន្ទនា និយាយខ្សឹបៗឲ្យបានឮតែពីរនាក់ និងធ្វើជាមួរដៃអាវ ដែលកាយវិការនេះជាការគំរាម ហើយដើរចេញទៅ ទុកឲ្យអ្នកឈរមួយកន្លែង ខាំធ្មេញក្រតៗ ខឹងគុំគួនតែម្នាក់ឯង។

"ឡើងឡាន"

ពេលដើរមកដល់ ដោះសោទ្វារឡានរួចរាល់ កាណែត ក៏បញ្ជា និងពេលឡើងឡានគ្រប់គ្នាហើយ ក៏បញ្ជាចេញទៅ ដោយគេនៅតែខឹង ដុងវ៉ុក មិនទាន់បាត់ ដោយមិនដឹងមូលហេតុ ទើបមិនមាត់មិន.ក។

"ម៉ោអង្គុយខាងមុខម៉ោ ស៊ុនស៊ូ"

ពេលជូន សុងចូ មកដាក់នៅមុខផ្ទះហើយ គេមិនព្រមចេញឡានភ្លាមៗ តែងាកទៅបញ្ជាអ្នកនៅអង្គុយនៅចាំងក្រោយសិន។

"សាំញ៉ាំ"



នាងអឺរទាំ តែក៏ព្រមចុះពីចាំងក្រោយ មកអង្គុយនៅចាំងមុខ ដែលធ្វើឲ្យអ្នកបញ្ជាមានការពេញចិត្ត ទើបព្រមបញ្ជាឡានចេញពីមុខផ្ទះ សុងចូ។

Scanned with CamScanner

"ម៉េចដែរ ថ្ងៃនេះជួបម្ចាស់ចម្ការ សាន មើលទៅគេចូលចិត្តនាង"

"ខ្ញុំមិនស្គាល់ ហើយក៏មិនចង់ដឹងដែរ"

"អ៊ុំ! តែមើលទៅគេចូលចិត្តនាង ឃើញបាញ់ខ្សែភ្នែកគឃ្លើនដាក់"

"លោកគាំទ្រខ្ញុំឬ និយាយច្រើនដល់ហើយ"

ដំបូងខឹងដែលគេនិយាយច្រើន តែពេលនេះចាក់បណ្ដោយតែម្ដងទៅ។

"អត់ទេ តែបើនាងចង់រស់សុខស្រួល គឺគ្មានអ្នកណាថាទេ អាចនៅក្នុងឈាមរបស់នាងក៏ថាបាន អ៊ុំ! តែប្រាប់ឲ្យដឹងមុន ម្ចាស់ចម្ការ សាន គេមានប្រពន្ធច្រើនណាស់ មានក្នុងមានក្រៅ មានធំមានតូច បើចង់ធ្វើប្រពន្ធគេ ត្រូវលំបាកបន្តិចហើយ ឆ្លងវគ្គច្រើនណាស់ តែបើបែបបណ្ដោះអាសន្ន អាចទៅរួចបានស្រួលៗ តែបើនាងបានធ្វើជាប្រពន្ធ ឬជាស្រី ដឹងតែទឹកភ្នែកជូតក្បាលជង្គង់ លេបទឹកភ្នែកជំនួសបាយ"

ស៊ុនស៊ូ ក្តាប់មាត់ ក្តាប់ដៃ រាប់មួយដល់មួយពាន់នៅក្នុងចិត្តជាការរម្ងាប់កំហឹង ខណៈនោះក៏រិះរកវិធីវាយបកមនុស្សប្រុសដែលចូលចិត្តចាក់ចុចជាងមនុស្សស្រីទៅទៀត ហើយពេលគេបត់ឡានចូលចម្ការ នាងក៏ធូរទ្រូង និងលួចញញឹមចុងមាត់ ព្រោះដល់ពេលដំណើរការផែនការ។

"អ៊ាៗ! លោក កាណៃត មានពស់ ពស់ៗវារនៅក្បែរកញ្ចក់ ខ្ញុំខ្លាចអ៊ា!"

នាងធ្វើជាស្រែក និងស្ទុះទៅតោងដៃរបស់គេ ដោយដៃញ័រទទ្រើត ដើម្បីឲ្យគេជឿ។

"ឯណាៗ?"

កាណៃត ក៏ភ្ញាក់ ប្រញាប់ចតឡានអែបផ្លូវ ហើយអើតមើល តែមិនឃើញអី ក្រៅពីភាពងងឹត។

"ខ្ញុំឃើញមិញនេះ វាតោងកញ្ចក់ឡាន លោកចុះទៅមើលឲ្យបន្តិច ខ្ញុំខ្លាច វានៅទេ បើវានៅ អីចឹងចុះយ៉ាងម៉េច ហ៊ឺៗ វាចូលមកក្នុងឡានទេ ខ្ញុំខ្លាច"

នាងធ្វើជាភ័យខ្លាចមែនទែន ថែមទាំងឱបគេមិនចង់លែងទៀត។

"ខ្លាចធ្វើអី អង្គុយឲ្យស្ងៀមក្នុងឡានទៅ ចាំចុះទៅមើលឲ្យ ឆ្កួតមែន!"

គេចងចិញ្ចើម បើកថតមុខឡាន យកពិល ចុះពីឡាន ដើរវាងខាងមុខរើសមែកឈើវែង ហើយបញ្ចាំងពិលមើលកញ្ចក់ខាង ស៊ុនស៊ូ តែមិនឃើញមានអី និងពេលងើយមើលអ្នកនៅក្នុងឡាននោះឯង ទើបដឹងថាចាញ់ល្បិចនាងហើយ ព្រោះត្រូវនាងគ្រវីដៃ និងលៀនអណ្តាតដាក់ បន្ទាប់មកនាងក៏បើកឡានចេញទៅ ទុកឲ្យគេឈរគ្រហឹមនៅត្រង់នោះម្នាក់ឯង ដោយកំហឹង។

"ស៊ុនស៊ូ នាងល្បិចណាស់ ស្រីឆ្កួត ស្រីល្បិច ស្រី..."

កាណៃត ស្រែកគំហកដោយកំហឹង តាមពីក្រោយឡានរបស់ខ្លួន ហើយពេលឃើញនាងចតឡានពីចម្ងាយ និងស្រែកដាក់ ក៏កាន់តែខឹង។



"សាកដើរទៅផ្ទះម្តងមើល៍ លោក កាណៃត ចាត់ទុកថារួចគ្នាកាលលោកបណ្ដេញខ្ញុំចុះពីឡាន ទុកខ្ញុំចោលកណ្ដាលផ្លូវយប់ស្ងាត់ បាយៗ ជួបគ្នានៅផ្ទះ

Scanned with CamScanner

សង្ស័យថាដើរបានលឿនជាងខ្ញុំ ឆាប់ដើរម៉ោ ងងឹតបែបនេះ គួរឲ្យខ្លាចចង់ងាប់"

នាងក្ដោបមាត់ ស្រែកប្រាប់ ដោយមានអារម្មណ៍ល្អ ហើយប្រញាប់បើកឡានចេញទៅ ពេលឃើញគេរត់តាម។

"ស៊ុនស៊ូ ស្រីជើងល្អ ស្រី..."

កាណែត ប្រឹងរត់ ហើយឈប់ ពេលនាងបើកឡានចេញទៅបាត់ ហើយគប់មែកឈើទៅលើផ្លូវ ដោយការមួម៉ៅ បន្ទាប់មកទើបដើរយឺតៗ ដោយមានញើសពេញថ្ងាស និងខ្លួន ព្រោះរត់ផង ដើរផងយូរគួរសម។

ងឹត!

ស៊ុនស៊ូ បើកឡានមកចតនៅមុខផ្ទះ ជាន់ហ្វ្រាំងឮសំឡេងទ្រហឹង ហើយប្រញាប់ទាញកូនសោ ចុះពីឡាន។

"អេាំ! អ្នកនាង ស៊ុនស៊ូ ឯណាលោក កាណែត?"

ជេមីន ដែលចេញមកចាំនៅមុខផ្ទះតាមបញ្ជាលោក អេដែន ក៏ញញឹមដើរមករក ស្មានថាអ្នកចុះពីឡានជាលោក កាណែត តែមានឯណា ជាអ្នកនាង ស៊ុនស៊ូ ទៅវិញ ទើបរកមើល។

"នុ៎ះ! នៅកណ្ដាលផ្លូវឯនោះ ទុកឲ្យដើរម្ដង នេះកូនសោឡានរបស់គេ បើគេម៉ោដល់ ជួយយកឲ្យគេផង"

នាងញញឹម ហុចកូនសោឡានឲ្យ ជេមីន ហើយដើរញញឹមដោយមានអារម្មណ៍ល្អ ចូលទៅក្នុងផ្ទះ ទុកឲ្យ ជេមីន ឈរមិងមាំង។

"ហើយបែបនេះត្រូវឲ្យខ្ញុំទៅយកទេ ចូលទៅសួរលោក អេដែន សិន"

"ស៊ុនស៊ូ ម៉ោហើយ ញាំបាយហើយនៅ?"

ស៊ូអា សួរនាំក្មួយស្រី ដោយការព្រួយបារម្ភ ប៉ុន្តែពេលឃើញទឹកមុខស្រស់ស្រាយ ក៏ធូរទ្រូង និងមើលទៅក្រោយខ្នង រកមើល កាណែត។

"រួចរាល់ហើយ ថ្ងៃនេះទៅជួបភ្ញៀវនៅក្នុងក្រុង លោក កាណែត ក៏នាំទៅញាំនៅទីនោះ ខ្ញុំឡើងបន្ទប់ហើយ មីង ងងុយដេកហើយ"

"អ្ហឹម! ងូតទឹក ចូលដេកទៅ ធ្វើការហត់ មីងបារម្ភ ទើបចាំមើលផ្លូវ"

"អរគុណច្រើន មីង ខ្ញុំឡើងទៅលើហើយ ពូថ្លៃ...ស្អូម ស្អែកព្រឹក បង ស៊ុនស៊ូ ចុះមកលេងជាមួយ ថ្ងៃនេះហត់ណាស់"

នាងឱបម្ដាយមីង ហើយងាកទៅប្រាប់ពូថ្លៃ និងចាប់ដៃប្អូនប្រុស ដែលហុចមកឲ្យ ថើបមួយខ្សឹត ទើបរត់ឡើងទៅជាន់លើ។

"ស្អីហ្នឹង អារម្មណ៍ល្អម្ល៉េះ ថ្ងៃនេះ"

ស៊ូអា តាមមើលអ្នកដែលរត់ឡើងជណ្ដើរ ទាល់តែបាត់ពីភ្នែក ហើយងាកមកនិយាយដាក់ស្វាមី ដោយការងឿងឆ្ងល់។

"ហ៊ឺៗ"

អេដែន សើចនៅដើម.កដាក់ភរិយា ព្រោះមានប្រផ្នូលល្អ។

"អឺ លោក អេដែន តើឲ្យខ្ញុំទៅយកលោក កាណែត ទេ អ្នកនាង ស៊ុនស៊ូ



Scanned with CamScanner

ប្រាប់ថាទុកលោក កាណែត ចោលនៅកណ្ដាលផ្លូវ"

ជេមីន ដើរមករាយការណ៍ប្រាប់ចៅហ្វាយ ទាំងអេះក្បាលមិងម៉ាំង។

"ស្លាប់ហើយ! អីចឹងតើ"

ស៊ូអា លើកដៃស្ទាបទ្រូង បើកភ្នែកធំៗ ងាកមកមើលស្វាមីដែលមិនក្ដៅក្រហាយអី មានតែញញឹមពេញចិត្ត។

"សមមុខវា មិនបាច់ទៅយកទេ យកឡានទុក ហើយចូលដេកទៅជេមីន តិចទៀត វាគង់តែដើរមកដល់ទេ"

"បាទ"

ជេមីន ញញឹមទទួលបញ្ជា ហើយដើរចេញទៅវិញ។

"ហេតុអីមិនឲ្យទៅយក ដើរងងឹតៗបែបនេះមិនល្អទេ"

ស៊ូអា ធ្វើមុខខ្វល់ដាក់ស្វាមី ព្រោះបារម្ភពីប្អូនថ្លៃ។

"មិនបាច់បារម្ភពីវាទេ តិចទៀតវាគង់តែមកដល់ ឲ្យវាដើរខ្លះទៅ ឲ្យវាដឹងថាហត់ប៉ុណ្ណា លើកក្រោយកុំឲ្យធ្វើដាក់ ស៊ុនស៊ូ ទៀត យើងឡើងទៅដេកទៅ មើលចុះ កូនស្ទាបហើយ ងងុយមែនទេ ស្អម ឲ្យម៉ាក់នាំចូលដេកមុនណ៎ះ កុំទៅខ្វល់ពីពូ កាណែត ចិត្តអាក្រក់"

អេដែន ពកូនដោយដៃម្ខាង ឱបស្មាប្រពន្ធដោយដៃម្ខាង។

"តែអូនខ្លាចពេលលោក កាណែត មកដល់ តាមទៅរករឿង ស៊ុនស៊ូ"

"អូនមិនបាច់បារម្ភទេ យកកូនទៅដេកមុនទៅ ចាំបងអង្គុយចាំវានៅមុខបន្ទប់ មិនឲ្យវាទៅរករឿង ស៊ុនស៊ូ បានទេ"

"ច្បាស់ហើយ ថាហាមបាន?"

"ជឿជាក់ស្វាមីម្នាក់នេះបាន ជានាថា កាណែត មិនហ៊ានឡូឡាទេ"

"អូនជឿជាក់បង"

នាងញញឹមស្រស់ដាក់ស្វាមី ទើបត្រូវថើបមាត់មួយខ្សឹត ហើយនាំគ្នាឡើងទៅបន្ទប់ដេក ដាក់កូនដែលដេកលក់លើគ្រែរបស់ក្មេង ដោយនាងអង្គុយលើកៅអីក្បែរនោះ មិនទាន់ចេញទៅបន្ទប់ដេកខ្លួនឯង ព្រោះខ្លាចកូនដេកមិនទាន់ស្ងប់។

"ចេញទៅចាំលោក កាណែត ទៅ"

អេដែន ញញឹមពព្រាយ ដើរមកថើបជញ្ជក់បបូរមាត់ប្រពន្ធ ហើយដើរចុះមកក្រោម ចូលផ្ទះបាយ យកទឹកក្រូចមកអង្គុយផឹកចាំប្អូនប្រុសពៅ យ៉ាងរំភើយ។

**កាណែត** លើកដៃជូតញើសដែលហូរដូចទឹក ចេញពីថ្ងាស ថ្ពាល់ដែលពុកមាត់ពុកចង្កាគ្របមិនដល់ក៏ក្រហម ដកដង្ហើមហត់គយូស ព្រោះហត់ និងប្រឡេះឡេវអាវទាំងអស់ និងដោះអាវមកពាក់ស្មា បង្អួតដើមទ្រូងហាប់ណែនដោយសាច់ដុំកង់ៗ។ គេព្រួសខ្យល់ដង្ហើមចេញមកតាមមាត់ សម្លឹងមើលផ្ទះដែលនៅមិនឆ្ងាយ ហើយប្រឹងដើរ ទាល់តែដល់មុខផ្ទះ ឈរច្រត់ជង្គង់មួយភ្លែត

ទើបដើរសំដៅក្បាលរ៉ូប៊ីណេ ដែលនៅមិនឆ្ងាយ បើកទឹកឲ្យស្រក់ដាក់ក្បាល លុបលាងមុខមាត់ ឲ្យត្រជាក់ រួចរាល់ទើបដើរចូលផ្ទះ ឡើងជណ្ដើរឆ្ពោម សំដៅបន្ទប់របស់ ស៊ុនស៊ូ។

"ដល់ផ្ទះហើយឬ កាណែត ហត់ទេ ហ៊ឺៗ"

សំឡេងបងប្រុសច្បងដែលបន្លឺឡើងនៅក្រោយខ្នង ធ្វើឲ្យអ្នកដែលយារដៃប្រុងគោះទ្វារបន្ទប់ ត្រូវទម្លាក់ដៃចុះ និងងាកយឺតៗ ទៅរក ដោយទឹកមុខក្រមូវ ព្រោះឃើញខ្លួនគេជោកញើសបែបនេះហើយ នៅសួរទៀត។

"មិនហត់ទេ ដើរតាំងពីមាត់ផ្លូវចូលចម្ការមកដល់ផ្ទះ ដឹងហើយម៉េចមិនឲ្យអ្នកណាទៅយកខ្ញុំ បងប្រុស"

កាណែត លើកដៃម្ខាងច្រត់ចង្កេះ ម្ខាងទៀតលើកជ្រងសក់ ដោយការមួម៉ៅដាក់អ្នកដែលកំពុងសើចចំអកខ្លួន។

"ហ៊ឺៗ ម៉េចដែរ ត្រូវម្ដងបែបនេះ សមមុខឯងហើយ"

"អុំ ព្រះ! នេះមិនកាន់ជើងខ្ញុំ ហើយនៅចំអកទៀត បែបនេះវាត្រឹមត្រូវត្រង់ណា"

"គឺឯងធ្វើដាក់គេមុន ម្ដងនេះត្រូវវិញម្ដង វារួចខ្លាហើយ ហើយឯងចង់មករករឿងគេទៀត"

"មិនបានរករឿងទេ!"

កាណែត ធ្វើភ្នែកឡេមឡាមមើលពិតាន ហើយមើលមកបងប្រុស។

*ឲញពួកដឹងច្រើនមែន នេះលោក អាហ្សា បែងភាគមែនទេ!*

"អ៊ីចឹងទៅងូតទឹក ចូលដេកទៅ ម៉ោពីហត់ ខ្លួនមើលមិនបានទេ ដូចកូនថ្លៃធ្លាក់ទឹកតែម្ដងឯង និងកុំឲ្យដឹង ថាឯងលួចចូលទៅធ្វើមិនល្អដាក់នាង មិនអ៊ីចឹង បងនឹងប្ដឹងលោក អាហ្សា ធានាថាឯងបានរៀបការបែបបន្ទាន់មិនខាន បើចង់រៀបការបែបបន្ទាន់តែលែងលះមិនបានដាច់ខាត ក៏សាកទៅបងតឿនឲ្យឯងបានដឹង"

អេដែន ញាក់ស្មា ពេបមាត់ញញឹមជាការបង្អាប់ប្អូនប្រុស។

"ហ៊ឺះ! ផ្ញើទុកសិនចុះ ងូតទឹក ចូលដេកក៏បាន ស្អិតខ្លួនណាស់"

កាណែត ធ្វើធឹះដាក់បងប្រុសច្បង ហើយអ៊ូរទាំ ដើរទៅបន្ទប់ដេករបស់ខ្លួន បិទទ្វារលាន់ក្អុងក្អាំង ពេលចូលទៅដល់ខាងក្នុង។

"សមមុខឯង កាណែត"

បងប្រុសគ្រវីក្បាលហួសចិត្ត ពេលតាមមើលពីក្រោយ មួយសន្ទុះ ទើបដើរទៅបន្ទប់ដេករបស់ខ្លួន ចូលទៅមើលកូនប្រុស ឃើញដេកលក់ស្រួល ក៏ដើរមកឡើងគ្រែ ដេកឱបប្រពន្ធ ដោយមានអារម្មណ៍ល្អ។

Scanned with CamScanner

# ៦

"ថ្ងៃនេះ បងនាំមីងក្អួយចូលក្រុង ទៅកាត់ខោអាវពាក់ក្នុងកម្មវិធីប៉ុន្តែបងសុំច្បាប់ឲ្យ ស៊ុនស៊ូ"

អេដែន ងើយមុខមកប្រាប់ បន្ទាប់ពីឃើញប្អូនប្រុសពៅដាក់ស្លាបព្រាចុះ និងលើកទឹកផឹក ចំណែក ស៊ុនស៊ូ ដាក់ស្លាបព្រាចុះ ងាកទៅមើលម្តាយមីង ទើបបានទទួលការគ្រវីក្បាលដាក់ ព្រោះ ស៊ូអា ក៏ទើបតែដឹងនៅពេលនេះដែរ ហើយពេលងាកទៅបុរសនៅក្បែរខ្លួន ឃើញគេដៀងមើលនាងដោយខ្សែភ្នែកកាចជាការដាក់ទោស។

"ទៅម៉ោងប៉ុន្មាន?"

កាណែត លើកចិញ្ចើម មើលមុខបងប្រុសបន្តិច ពេលសួរដោយសំឡេងធម្មតា។

"ពេលរសៀល ឯងមានអីឬអត់?"

អេដែន មើលមុខប្អូនប្រុស ហើយសួរ ព្រោះមើលទៅដូចមិនចង់ឲ្យ ស៊ុនស៊ូ ទៅជាមួយគេ សង្ស័យនៅខឹងរឿងកាលពីយប់មិញ។

"អីចឹង ចាំរសៀល ខ្ញុំនាំនាងទៅក៏បាន ពេលព្រឹកមានណាត់ លោក អាល់ប៊ីត ឲ្យនាងនៅជួយកត់ត្រា"

"អ៊ឹម! អីចឹងឬ"

បងប្រុសងក់ក្បាល មើលក្អួយប្រសាមួយភ្លែត ឃើញនាងធ្វើមុខក្រមូវ និងជកដង្ហើមធំ ដៀងមើល កាណែត ដោយកំហឹងហើយ គេក៏លួចញញឹម។

"ឲ្យលោក កាណែត នាំទៅក៏បាន កុំឲ្យខាតពេល"

នាងចេញមុខនិយាយ ព្រោះមិនចង់ឲ្យគេដៀមដាមថានាងធ្វើឲ្យខូចការខូចងារ ព្រោះការទៅកាត់ខោអាវ។

"អីចឹងក៏បាន" អេដែន ងក់ក្បាល។

"នាងគិតត្រូវហើយ ចាំរសៀល ខ្ញុំនាំទៅ ហាងផ្កាឈូកមែនទេ?"

កាណែត ងាកមកមើលអ្នកនៅក្បែរខ្លួន គ្រហឹមដាក់តិចៗ ហើយងាកទៅសួរបងប្រុស ព្រោះភាគច្រើននាំគ្នាទៅកាត់ខោអាវនៅហាងនោះ។

"អឺ ហាងហ្នឹង បងតេរទៅប្រាប់ម្ចាស់ហាងហើយ ថាទៅពេលរសៀលខាងគេក៏អូខេដែរ និងឲ្យជាងគេចាំវាស់ខ្លួនហើយ"

"បាទ ហើយត្រូវនាំប្រពន្ធរបស់បង អាជ្រេ ទៅដែរឬអត់?"

"បងសួរហើយ អាជ្រេ ប្រាប់ម្ចាស់ហាងរួចហើយ លឿនជាងយើងទៅទៀត"



"អ៊ូហ៊ូ! លឿនណាស់ណ៎ អីចឹងតើ បានជាមិនព្រមនាំប្រពន្ធមកផ្ទះធំ"

"គង់តែនាំមកទេ មួយរយៈនេះរវល់ការងារនៅកសិដ្ឋាន"

Scanned with CamScanner

"ហ៊ឺៗ រវល់ស្អី នេះខ្ញុំបានដំណឹងថាប្រើប្រពន្ធឲ្យទៅធ្វើការនៅកសិដ្ឋាន ឲ្យទៅសម្អាតរោមសេះ ការងារធ្ងន់ៗ ទាំងអស់"

"អ្ហឹម! ជេមីន ប្រាប់ហើយ តិចទៀតប្ដូរហើយ តែប្រើយូរប្រពន្ធឈឺល្មម"

អេដែន ប្រាប់ប្អូនប្រុស តាមអ្វីដែល ជេមីន យកមកប្រាប់ ពេលទៅកសិដ្ឋានសេះ មានកម្មករលួចខ្សឹបប្រាប់។

"ខ្ញុំប្រញាប់ ទៅសិនហើយ នេះជិតដល់ម៉ោងដែលភ្ញៀវមកដល់ចម្ការហើយ សុំទៅសិនហើយ"

កាណែត លើកដៃមើលនាឡិកា ហើយលាបងប្រុស និងញញឹមដាក់បងថ្លៃច្បងបន្តិច ចំណែក ស្ពម ឬ ពេលនេះកំពុងខាំផ្លែឈើលេងយ៉ាងរីករាយនៅលើកៅអីសម្រាប់ក្មេង ទាំងដែលមិនទាន់មានធ្មេញ។

"អ្ហឹម"

កាណែត ងើបចេញពីតុ ទើប ស៊ុនស៊ូ ប្រញាប់ងើបតាម ទៅឡើងឡានសំណាងដែលគេមិននិយាយដៀមដាមអី ទើបនាងធូរទ្រូង សង្ស័យប្រញាប់ទៅរកភ្ញៀវទេដឹង។

គេនាំនាងមកដល់ចម្ការតែមុនភ្ញៀវមកដល់មួយសន្ទុះប៉ុណ្ណោះ ហើយនាំក្រុមការងាររបស់ អាល់បឺត ដើរមើលការធ្វើការ ការបេះស្លឹកតែ ការហាលនិងវិធីនៃការផលិតតែ បន្ទាប់មកនាំទៅមើលចម្ការផ្លែឈើ ដែលជិតប្រមូលផលហើយ ព្រមទាំងអញ្ជើញភ្ញៀវទទួលទានអាហារថ្ងៃត្រង់ នៅអាហារដ្ឋានរបស់វីសត ដែលភ្ញៀវមានការពេញចិត្តជាខ្លាំង។

"រសៀលនេះ ខ្ញុំមិនចូលមកវិញទេ សុងចូ មើលការងារផង បើមានអីសំខាន់ តេរប្រាប់"

កាណែត មូរដៃអាវដល់កែងដៃ ខណៈដែលបញ្ជាការងារកូនចៅ មុនពេលគេចេញទៅខាងក្រៅ។

"បាទ អឺ! ហើយលោក កាណែត ទៅណា?"

"ចូលក្រុង ណាត់បង អេដែន នាំ ស៊ុនស៊ូ ទៅកាត់ខោអាវសម្រាប់កម្មវិធីប៉ូឡូ បង អេដែន នាំប្រពន្ធទៅកាត់ខោអាវដែរ ប្រហែលមិនម៉ោធ្វើការវិញទេ"

"បាទ"

សុងចូ ទទួលបញ្ជា និងញញឹមបង្អាប់ដាក់ ស៊ុនស៊ូ ទើបត្រូវនាងសម្លឹងដាក់វិញ។

"តោះ ទៅ ស៊ុនស៊ូ"

"ចាំ ទៅសិនហើយលេខា ហុង ស្អែកចាំខ្ញុំទិញនំម៉ោផ្ញើ"

នាងញញឹម ប្រាប់ សុងចូ និងគ្រវីដៃលា ព្រោះពេលចូលក្រុង នាងតែងតែទិញនំចំណីមកច្រើន។

"អរគុណច្រើន"

សុងចូ ញញឹម និងគ្រវីដៃដាក់ភាពរបិលរប៉ូចរបស់ ស៊ុនស៊ូ តែពេលងាកទៅឃើញមុខក្រមូវរបស់ចៅហ្វាយ ក៏ប្រញាប់បិទស្នាមញញឹមនិងអង្គុយធ្វើការ



Scanned with CamScanner

បន្ត ចំណែក ស៊ុនស៊ូ ក៏ធ្វើជាមិនដឹងមិនឮ ដើរតាម កាណែត ឡើងឡាន និង អង្គុយស្ងៀម ទាល់តែចេញផុតចម្ការ។

"កុំទៅលេងមុខលេងមាត់ដាក់ សុងចូ គេមានសង្សារហើយ បើមិនចង់ធ្វើជាជនទីបី ឲ្យគេបែកបាក់គ្នា"

"ខ្ញុំមិនបានលេងមុខលេងមាត់ដាក់ទេ គឺគ្រាន់តែប្រាប់ថាទិញនំម៉ោផ្លើ ប៉ុណ្ណឹង លោកគិតដោយខ្លួនឯងទៅវិញទេ!"

"កុំឲ្យដឹងឲ្យសោះ"

កាណែត គ្រហឹមដាក់ ហើយក៏លែងមាត់លែងកទៀត រហូតដល់ក្រុងចតឡាននៅមុខហាងកាត់ដេរល្បីឈ្មោះ ហើយនាំ ស៊ុនស៊ូ ដើរចូលទៅ។

"សួស្តីលោក កាណែត"

ម្ចាស់ហាងម្នីម្នាដើរមកស្វាគមន៍ដោយទឹកមុខញញឹមញញែម និងលួចដៀងមើល ស៊ុនស៊ូ ដោយការចង់ដឹង ព្រោះជាស្រីតូចច្រឡឹង គួរឲ្យស្រឡាញ់ ខុសពីស្រីមុនៗដែលលោក កាណែត ធ្លាប់បណ្ដើរ។

"សួស្តីអ្នកនាង យ៉ុង...ស៊ុនស៊ូ នេះអ្នកនាង យ៉ុង ម្ចាស់ហាង"

"សួស្តីអ្នកនាង យ៉ុង ខ្ញុំ កាំង ស៊ុនស៊ូ"

"សួស្តីៗ អ្នកនាង កាំង ទេអ្ហ៎ស"

ម្ចាស់ហាង ញញឹមទទួលយកការគោរពពីស្រីស្អាតស៊ិងតែមិនទាន់។

"នាងជាក្មួយរបស់អ្នកបង ស៊ូអា"

កាណែត ឃើញទឹកមុខមានសំណួររបស់ម្ចាស់ហាង ក៏អាចសន្និដ្ឋានបាន ទើបជួយបំភ្លឺឲ្យ កុំឲ្យពិបាកអង្គុយសង្ស័យ។

"អូ៎! ចាំ អ៊ីចឹងខាងក្នុង លោក អេដែន មិនទាន់ម៉ោដល់ទេ"

អ្នកនាង យ៉ុង អញ្ជើញភ្ញៀវចូលអង្គុយ បុគ្គលិកក៏លើកទឹកមកដាក់ឲ្យ។

"អ៊ីចឹងយកម៉ូតមកឲ្យនាងមើលមុនមក ឲ្យចម្នាក់ៗ"

កាណែត ដាក់បង្គុយចុះ និងងាកទៅមើលមុខ ស៊ុនស៊ូ ហើយប្រាប់ម្ចាស់ហាង។

"ចាំ បាន ចាំឲ្យជាងវាស់ខ្លួនតែម្ដង"

"មិនបាច់ក៏បាន ឃើញខោអាវមានស្រាប់ច្រើនឈុត ចាំខ្ញុំរើសអាដែលកាត់រួចក៏បាន"

ស៊ុនស៊ូ ប្រញាប់លូកមាត់ដោយការក្រែងអែងចិត្ត។

"ចង់បានអ៊ីចឹងឬ អូខេ តែសុំវាស់ខ្លួនបន្តិច ក្រែងលខោអាវត្រូវកែកុន"

"ចាំ"

នាងក្រមុំងក់ក្បាល និងងើបឈរភ្លាម គ្រដាងដៃឲ្យជាងវាស់ខ្លួន ដោយមិនងាកទៅមើល កាណែត ទើបមិនដឹងថាពេលនេះគេមើលមកដោយខ្សែភ្នែកកាច ពេលឃើញថាជាងជាមនុស្សប្រុស។

"រាងរៅស្តង់ដាណាស់ បែបនេះមានច្រើនឈុត ចាំឲ្យក្មេងៗ ដាក់ស្លមក ឲ្យរើស"

អ្នកនាង យ៉ុង សរសើរ ព្រោះ ស៊ុនស៊ូ មានរាងរៅល្អណាស់ គ្រាន់តែមិនសូវខ្ពស់ប៉ុណ្ណោះ តែត្រូវស្តង់ដាស្រីកូរ៉េ។

"ក្រុមការងារផ្ទៃមេឃ-ស"

អ្នកនាង យ៉ុង ប្រញាប់ប្រញាល់ទៅយកខោអាវដែលមានស្រាប់ដាក់ស្ទូមកឲ្យភ្ញៀវរើស។

"សុទ្ធតែស្អាតៗ អ្នកនាង យ៉ុង ខ្ញុំសុំមើលសិនបានទេ ?"

មនុស្សស្រីដែលទើបតែដើរចូលមកក្នុងហាង ចាប់ខោអាវដែលអ្នកនាង យ៉ុង ឲ្យកូនចៅយកមកដាក់ស្ទូបែបចល័ត ដោយកែវភ្នែកញ័រទទ្រើត ព្រោះវាសុទ្ធតែស្អាតៗ។

"អី សុំចាំមួយភ្លែត អ្នកនាង ចាង ជូនអីឈុតនេះឲ្យភ្ញៀវមើលសិន"

"អ្នកណា ?"

ចាង យូរ៉ា ដកដៃមកវិញ និងចងចិញ្ចើមដោយការមិនពេញចិត្ត។

"របស់អ្នកនាង កាំង ភ្ញៀវដែលអង្គុយចាំនៅសាឡុងខាងក្នុង"

"អ្នកណាគេ អ្នកនាង កាំង នោះនាងនោះ...លោក កាណែត"

យូរ៉ា ក្តាប់មាត់ មើលតាមចង្អុលដៃរបស់ម្ចាស់ហាង ហើយបើកភ្នែកធំៗពេលឃើញថាជាអ្នកណា។ នាងចាំបានច្បាស់តែម្តង មីស្រីសម្តីហំដែលជេរនាង និងធ្វើឫកពាក្រអឺតក្រទមនេះឯង ទើបដើរទៅរកភ្លាម។

"សួស្តីលោក កាណែត ថ្ងៃនេះមករើសឈុតឬ ខ្ញុំសុំអង្គុយផង ខែជន្យដល់ហើយដែលជួបលោក កាណែត នៅទីនេះ"

យូរ៉ា ញញឹមពព្រាយ និងដាក់បង្អុយបៀត កាណែត ធ្វើឲ្យជើងខោខ្លីសាច់រលាស់ពណ៌គ្រីម គូទខ្លីកន្ធើញឡើងលើ បង្ហាញជើងស្រឡូន អាវដៃមួយពណ៌សសមនឹងខោក៏ធ្លាក់ដៃ បង្ហាញដើមទ្រូងធំហួសមាឌ ទាក់ទាញខ្សែភ្នែកត្រេកកាមបុរសៗ បានល្អ តែធ្វើឲ្យ ស៊ុនស៊ូ លួចពេមាត់ ធ្វើភ្នែកឡៀមឡាម។

"អញ្ជើញអ្នកនាង ចាង ខ្ញុំមិនបានម៉ោរើសទេ របស់ម្នាក់នោះ"

កាណែត ញញឹមចុងមាត់ និងព្រមឲ្យស្រីស្អាតអង្គុយបៀត។

"អ៊ូហ៊ុំ! គួរឲ្យច្រណែនដល់ហើយ ជូនអីមានឈុតត្រូវចិត្ត តែអ្នកនាង យ៉ុង ប្រាប់ថាឲ្យភ្ញៀវមើលសិន មិនស្មានថាជានាង បើខ្ញុំចូលចិត្តឈុតណាក្នុងស្ទូ ខ្ញុំសុំមុនទៅចុះ រាងរៅខ្ញុំ ដឹងតែពាក់ទៅស្អាតហ្មង"

យូរ៉ា ម្មិកម៉្ញក់ដាក់អ្នកកំលោះ តែភ្នែកដៀងមើល ស៊ុនស៊ូ ហើយញញឹមឡូកឡឺយ មើលតាំងពីក្បាលដល់ចុងជើង ដោយមិនភ្លេចពើងដើមទ្រូងធំឲ្យឃើញ។

"ស្រេចតែនាង រើសបានតាមចិត្ត តែនាងពាក់បានឬអត់ក៏មិនដឹង ព្រោះដើមទ្រូងនាងធំពេកហើយ ឡើងចង់ចាក់មុខលោក កាណែត ទៅហើយ មិនដឹងថាធ្វើអស់ប៉ុន្មាន សង្ស័យបានកែកុនឈុត ទាល់តែទក់សាច់"

"នេះរបស់ពិត ម៉ែឲ្យម៉ោ មិនដូចរបស់ឯង មានដូចគេឬអត់ក៏មិនដឹង"

យូរ៉ា តវ៉ាដោយសំឡេងញ័រ ព្រោះកុហកនោះឯង តែរឿងអីដែលនាងត្រូវ

Scanned with CamScanner

ព្រមទទួលស្គាល់ការពិត។

"មាន ជានាពេលបិទភ្លើង គ្មានកាំរស្មី ប្របាច់ខ្លាំងៗ ក៏មិនបាច់ខ្លាចស៊ីលិខូនបែកដែរ ហើយពេលដេក វាក៏មិនចង្អុលពិតាន ឬសង្កត់ឲ្យថប់ដង្ហើម"

ស៊ុនស៊ូ ពើងទ្រូង ចាប់កអាវសំយេះ តែមិនឃើញដើមទ្រូង និងនិយាយបែបកំប្លែង ថែមទាំងលួចសើច និងអ្នកនាង យ៉ុង និងបុគ្គលិកលួចសើចដែរ។

"ឥឡូវនេះគេមានបែបចាក់ខ្លាញ់ចូលក៏បាន បើមិនដឹង កុំម៉ោនិយាយ"

យូរ៉ា ត្បកផ្ទុង តែពេលនិយាយចប់ក៏ក្រហមមុខ ព្រោះបានឃើញទឹកមុខសើចចំអករបស់ ស៊ុនស៊ូ។

"អ៊ូ! ក្រែងថាម៉ែឲ្យម៉ោនោះអី អីចឹងតើបានហើមស្អុរ"

"សម្ដីហំណាស់ឯង"

យូរ៉ា ខឹងញ័រខ្លួន តែធ្វើអីមិនបាន ព្រោះចាញ់ល្បិច ស៊ុនស៊ូ ឲ្យទាល់តែបាន។

ស៊ុនស៊ូ ញាក់ស្មា ពេបមាត់ដាក់ ធ្វើជាដកដង្ហើម ធុញទ្រាន់ ហើយមើលឈុតក្នុងស្ន ដែលបុគ្គលិករុញមកឲ្យ ដោយមិនត្រូវការជ្រលក់មាត់នឹងស្រីម្នាក់នោះទៀត។

"ឈុតនេះទើបតែចេញថ្មីចុងក្រោយរបស់ហាង វាលខ្នងជ្រៅ តែមានទ្រនាប់ក្នុងក្រាស់ សិចស៊ីណាស់"

"ខ្ញុំសុំឈុតនេះ អ្នកនាង យ៉ុង"



"ឲ្យនាងទៅ ឈុតនេះខ្ញុំមិនចូលចិត្តទេ"

ស៊ុនស៊ូ ប្រាប់ដោយទឹកមុខស្មើ ព្រោះនាងមិនចូលចិត្តម៉ូតបែបនេះទេ។

"អ៊ូ! ចាំ"

អ្នកនាង យ៉ុង សើចញឹមៗ ហើយបុគ្គលិកយកឈុតនោះចេញ ទុកឲ្យ យូរ៉ា និងឲ្យយកមកដាក់ថែម ដែលភាគច្រើនត្រូវស្រីស្អាតកាត់មុខរហូត ដែលវាធ្វើឲ្យ ស៊ុនស៊ូ ដកដង្ហើមធំ ធុញស្រីម្នាក់នេះមែនទែន ចំណែក កាណែត ឬអង្គុយញញឹមចុងមាត់ ដល់ថ្នាក់នាងចង់យកអីគប់ទៅហើយ។

"សង្ឃឹមថាឈុតចុងក្រោយ អ្នកនាង ចាង មិនដណ្ដើមខ្ញុំលទៀត មិនអីចឹង គេនឹងហៅថាគ្មានមារយាទ"

ពេលត្រូវនិយាយកាត់បែបនេះ យូរ៉ា ក៏ត្រូវបិទមាត់ មុខឡើងខ្មៅ។

"តាមចិត្តនាង"

"ខ្ញុំសុំលបន្តិច"

ស៊ុនស៊ូ ប្រាប់ ហើយយកឈុតចុងក្រោយ ដែលម៉ូតសាមញ្ញបែបនេះ សមនឹងខ្លួន ដើរចូលបន្ទប់ល។

"លោកចូលម៉ោធ្វើអី ?"

នាងក្រមុំប្រញាប់ងាកមកមើល ពេលឃើញថាអ្នកណាបើកវាំងននចូលមកដោយគ្មានមារយាទបែបនេះ។

"មកជួយមើល ថាអូខេទេ"

Scanned with CamScanner

កាណែត សម្លឹងមើលនាងដែលលើដងខ្លួនជាឈុតដែលត្រូវល ដោយខ្សែភ្នែកមានពន្លឺផ្លេកៗ និងញញឹមចុងមាត់។

"ពាក់បាន ចេញទៅបានហើយ គ្មានមារយាទ"

នាងហាមាត់បណ្តោញ និងមានអារម្មណ៍ប្លែកៗ ដោយសារខ្សែភ្នែករបស់កាណែត។

"គ្រាន់តែចូលមកមើលថាឈុតត្រូវកែកុនទេ ព្រោះមើលទៅដើមទ្រូងរបស់នាងមិនពេញល្អ តែបែបនេះប្រដាប់ខ្លាំងៗ ប្រហែលមិនបែកទេដឹង"

គេសម្លឹងមើលដើមទ្រូងរបស់នាង ដែលប្រាល់ចេញពីអាវឲ្យឃើញ តែធ្វើជានិយាយផ្សេង ធ្វើឲ្យនាងក្តៅមុខមួយរំពេច ប្រញាប់លើកដៃបាំង។

"វាជារឿងរបស់ខ្ញុំ ចេញទៅ មុនពេលខ្ញុំស្រែកឲ្យអ្នកនាង យ៉ុង ចូលមកជួយនៅក្នុងនេះ"

នាងខាំធ្មេញក្រតៗ ហើយហាមាត់បណ្តោញ ដោយទឹកមុខខឹងសម្បាលាយឡំអឹមអៀន។

"មិនបានចង់ឃើញអីទេ មានតែប៉ុណ្ណឹងឯង មិនចម្រើនភ្នែកសោះ"

គេញញឹមចុងមាត់ ហើយញាក់ស្មាបន្តិច បែរខ្នងដើរចេញទៅវិញ។

នាងក្រមុំក្តាប់មាត់ណែន និងតាមទៅបើកវាំងននមើលថា គេទៅមែនឬអត់ បន្ទាប់មកទើបប្រញាប់ដោះឈុតនោះមកឲ្យម្ចាស់ហាង។

"យកមួយនេះ"

នាងប្រាប់ ហើយដើរមកអង្គុយលើសាឡុងវិញ រង់ចាំឲ្យគេយកវាដាក់ថង់ គិតលុយ។

"ទៅញ៉ាំបាយជាមួយខ្ញុំណា៎ លោក កាណែត"

"ប្រហែលមិនបានទេ ជូនអីត្រូវរង់ចាំបង អេដែន ទៀត ចាំលើកក្រោយទៅ បើមានឱកាស"

"ស្តាយដល់ហើយ អីចឹងមិនអីទេ ខ្ញុំណាត់លើកក្រោយក៏បាន ថ្ងៃនេះយ៉ាងណាអរគុណដែលលោក កាណែត ជួយចេញលុយថ្លៃឈុតឲ្យទាំងអស់ អរគុណច្រើន"

និយាយហើយ យូរ៉ា ក៏ត្រសុលទៅរក ឲ្យដើមទ្រូងណែនក្បៀតនឹងដើមទ្រូងរបស់គេ ថែមទាំងបាញ់ខ្សែភ្នែកសិចស៊ីដាក់ បំណងឲ្យអ្នកខ្លះប្រណែន តែមានឬដែល ស៊ុនស៊ូ យកចិត្តទុកដាក់ ពេលយកថង់ឈុតដែលបុគ្គលិកយកមកឲ្យ ហើយលើកដៃឱបទ្រូង មើលនាឡិកាព្យួរជញ្ជាំងផង មើលទ្វារហាងផង ចាំមើលផ្លូវម្តាយមីង ដែលមិនយូរប៉ុន្មានក៏មកដល់។

"ម៉ោលឿនដល់ហើយ"

អេដែន ដាក់បង្គុយចុះ ដោយទាញភរិយាឲ្យអង្គុយក្បែរ ហើយប្អូនប្រុស និងក្មួយប្រសាដែលអង្គុយឆ្ងាយគ្នា។

"គឺមិនបានផ្អែមល្ហែមដូចអ្នកណាហ្នឹងណា៎ ទើបម៉ោយឺត"

កាណែត បង្អាប់បងប្រុសលេង។

Scanned with CamScanner

"ឲ្យ ស្នម ដេកសិន ទើបម៉ោបាន នេះត្រូវប្រញាប់ទៅវិញ ខ្លាចត្បាក់ឡើង យំរក ស៊ុនស៊ូ បានឈុតហើយនៅ ?"

"បានហើយ ពូថ្លៃ"

"អ៊ីចឹងជួយរើសឲ្យមីងផង យកឲ្យច្រើន ទុកកម្មវិធីផ្សេងផង"

"ចាំ ពូថ្លៃ"

ស៊ុនស៊ូ ញញឹមដាក់ពូថ្លៃ ហើយដើរមកដាក់បង្អួយក្បែរម្ដាយមីង មើលសៀវភៅម៉ូត ជួយរើសគ្នា បានច្រើនឈុតតាមតម្រូវការ ដោយមាន កាណែតលួចមើលគ្រប់ពេល សឹងតែមិនដាក់ភ្នែក ខណៈដែល អេដែន ក៏លួចសង្កេតនឹងញញឹម ពេលឃើញពន្លឺភ្នែករបស់ប្អូនប្រុសពៅ។

ច្រើនសប្ដាហ៍ក្រោយមក

កម្មវិធីប៉ុឡូត្រូវរៀបចំយ៉ាងអធិកអធម សមជាកម្មវិធីក្នុងសង្គមអភិជន ព្រោះនៅផ្នែកខាងក្រៅទីលានប្រណាំងសេះរបស់ចម្ការ ឈើរ៉សទិ ពេលនេះមានបណ្ដោសេឡេព្រីទី ដែលតែងខ្លួនតាមធីមផ្ទៃមេឃ-ស រ៉ូបខ្លី-វែង តែងខ្លួនមុខមាត់ ម៉ូតសក់អស់ពីថ្វីដៃ ហើយដែលស្អាតមិនចាញ់ម៉ូតសម្លៀកបំពាក់ គឺមួកហាមធំ លម្អដោយរោមបក្សី និងផ្កាស្អាតៗ ដើម្បីផ្ដល់កិត្តិយសឲ្យកម្មវិធីប្រណាំងប៉ុឡូ ដើម្បីសប្បុរស មានការសម្ដែងខ្សែហ្គីល ដែលតែងខ្លួនដោយឈុតស្រដៀងប៊ីតនី អង្គុយនៅលើខ្នងសេះ ទទួលបានសំឡេងហោកាំទ្រ។

កីឡាប៉ុឡូជាប្រភេទកីឡាប្រណាំងល្បឿន ដែលលឿនជាងគេនៅក្នុងលោក និងត្រូវអាស្រ័យភាពមាំមួននិងស្ទៀវក្លា ជាកីឡាកាចសាហាវ អ្នកលេងនិងសេះសុទ្ធតែរងការប៉ះទង្គិចខ្លាំង ព្រោះត្រូវប្រើដំបងវាយគ្រាប់បាល់ វាអាចមានថ្លោះធ្លោយខ្លះ តែមិនទាន់មានអ្នកណាមានគ្រោះថ្នាក់ទេ ព្រោះអ្នកលេងគោរពកត្តិកា ពេលចប់ការប្រណាំង អ្នកលេងទាំងពីរភាគីនឹងចាប់ដៃគ្នា។

អាចនិយាយបានថានេះជាកីឡាសម្រាប់សុភាពបុរស សម័យនេះមានកម្មវិធីខ្លះ ក៏មានអ្នកលេងស្រីចូលរួមដែរ បើរាងកាយអូខេ ម្យ៉ាងទៀតកីឡាប្រភេទនេះ គឺសម្រាប់អ្នកមានប៉ុណ្ណោះ បើមិនមែនជាសមាជិកគឺគ្មានសិទ្ធិចូលមកទស្សនាបានទេ ហើយសមាជិកទាំងឡាយ មិនមែនថាមានលុយហើយអាចចូលបានស្រួលៗ គឺត្រូវតែកក់ ត្រូវឆែកប្រវត្តិជាមុនយ៉ាងលម្អិត និងមានអ្នកខ្លះកក់ទុកមុនជិតមួយឆ្នាំ។

នៅជុំវិញទីលានប្រណាំង មានបញ្ជររបស់អ្នកឧបត្ថម្ភគាំទ្រ យកទំនិញលក់ឲ្យសមាជិកក្នុងតម្លៃទាបជាងពេលធម្មតា មានអ្នកកាសែត អ្នកថតមកផ្ដិតយករូបភាព ផ្ដិតយកបរិយាកាសដើម្បីយកទៅចុះផ្សាយក្នុងទំព័រសារព័ត៌មាន។

ស៊ុនស៊ូ អង្គុយជាមួយ យ៉ារីម ស៊ូអា និង ស្នម ដែលមើលទៅរីករាយពេលឃើញមនុស្សម្នាច្រើន ញញឹមផង សើចផង ស្រែកផង ដៃជើងនៅមិនសុខពេលឃើញឪពុកដឹកសេះចូលទីលាន។ អាល្អិតមានប្រជាប្រិយភាពណាស់ ហើយក៏មិនកំណាញ់ខ្លួនដែរ អ្នកណាឃើញក៏ក្ដាញ់ អ្នកណាឃើញក៏សុំបី ដែល

ថ្ងៃនេះលោក អាហ្សា ក៏មកចូលរួមដែរ ក្នុងឋានៈជាប្រធានកម្មវិធី។

នេះជាការប្រណាំងរបស់ក្រុមកូរ៉េខាងត្បូង និងអង់គ្លេស មានអ្នកគាំទ្រមកតាមច្រើន ធ្វើឲ្យបរិយាកាសកាន់តែអ៊ូអរ កំលោះក្រមុំដែលតែងខ្លួនមកអួតក៏កំពុងសង្កេតរកមើលគូ និងណែនាំកូនចៅរបស់ខ្លួនឲ្យសង្គមស្គាល់ ដូចជាការណែនាំខ្លួនដោយប្រយោល។

"សួស្តី អ្នកនាង កាំង"

ដុងវ៉ុក ដែលទើបមកដល់ ដើរលឿនស្លេវមករក ស៊ុនស៊ូ ភ្លាម ពេលរកមើលថានាងនៅត្រង់ណា។

"ម្ចាស់ចម្ការ សាន!"

នាងក្រមុំឧទានដោយការភ្ញាក់ផ្អើល ពេលគេលេងចូលមកជិតលឿនពេក ថែមទាំងលោមុខមកជិតទៀត។

"សប្បាយចិត្តដែលអ្នកនាងចាំខ្ញុំបាន ថ្ងៃនេះអ្នកនាងស្អាតណាស់ ខ្ញុំសឹងតែចាំមិនបាន"

គេញញឹមបាញ់មន្តស្នេហ៍ដាក់ និងសម្លឹងមើលនាងតាំងពីក្បាលដល់ចុងជើង ដែលធ្វើឲ្យនាងទាំងភ័យ ទាំងស្អប់គេ តែយ៉ាងណាក៏និយាយរកគេតាមមារយាទ។

"អរគុណដែលសរសើរ"

"អ៊ឹម! កម្មវិធីធំណាស់ថ្ងៃនេះ មនុស្សក៏ច្រើន ថែមទាំងរៀបចំស្អាតដូចអ្នកជំនាញទៀត បើមិនមែនជាការរំខាន សុំឲ្យអ្នកនាង កាំង នាំខ្ញុំដើរមើលក្នុងកម្មវិធីបានទេ?"

"អឺ...ប្រហែលមិនបានទេ តែមានបុគ្គលិកនៅខាងនោះ បើម្ចាស់ចម្ការ សាន ត្រូវការសួរនាំ ឬសុំការណែនាំអី គេជួយបាន ខ្ញុំមិនដឹងអីទេ ទើបតែបានចូលរួមកម្មវិធីនេះជាលើកដំបូង សុំទោសផង"

នាងញញឹមមិនសូវសមដាក់គេ និងងារដៃទៅរកបុគ្គលិកដែលចាំបម្រើសេវាកម្មដល់ភ្ញៀវ។

"មិនអីទេ បើអ្នកនាង កាំង មិនអូខេ តែបើទំនេរ ខ្ញុំអាចសុំបបួលនិយាយជាមួយបន្តិច"

ស្បែកមុខរបស់ ដុងវ៉ុក កន្ទ្រាក់តែម្តង ពេលត្រូវបដិសេធនៅកណ្តាលចំណោមបែបនេះ តែប្រឹងញញឹម។

"ប្រហែលមិនបានទេ ម្ចាស់ចម្ការ សាន មានតែធ្វើឲ្យលោកខាតពេលទទេៗ"

ស៊ុនស៊ូ ព្យាយាមបដិសេធយ៉ាងសុភាព តាមដែលអាចធ្វើបាន ពេលអ្នកនៅចំពោះមុខនៅតែតាមទាម។

"កុំអាលបដិសេធខ្ញុំអី សរុបទៅ ពេលនេះខ្ញុំថយសិនចុះ ខ្លាចមើលកីឡាមិនល្អមើល ចាំជួបគ្នាទៀត"

គេញញឹមចុងមាត់ ធ្វើជារីករាយដាក់ ដើម្បីបន្លប់អាការៈអាម៉ាស់មុខ

Scanned with CamScanner

របស់ខ្លួន ហើយត្រដាងដៃ ដើរថយក្រោយ បានបួនប្រាំជំហាន ទើបបែរខ្នងដើរចេញទៅ តែមិនបានទៅឆ្ងាយពេក ភ្នែករបស់គេតាមមើល ស៊ុនស៊ូ រហូត។

"ត្រៀមថ្នាំឲ្យហើយ ខ្ញុំរកសប្បាយជាមួយស្រីឆ្នាសនេះបន្តិច ពេលមានឱកាស នាំឡើងឡានភ្លាម មិនបាច់ឲ្យសន្លប់ទេ ខ្លាចមិនសប្បាយ"

ដុងវ៉ុក យកស្រាពីថាសដែលអ្នករត់តុដើរកាត់ មកផឹក ខណៈនោះក៏និយាយខ្សឹបៗ ដាក់កូនចៅដែលនៅក្បែរ ដោយខ្សែភ្នែករឹងកំព្រឹសតាមមើលនាងមិនព្រិច ដោយការឡកឡឺយ។ គេនឹងធ្វើឲ្យ ស៊ុនស៊ូ ថ្ងូចថ្ងូរនៅក្រោមរាងកាយរបស់គេ លុះក្រោមអំណាចរបស់គេឲ្យបាន។

ច្រើនថ្ងៃនេះ ឲ្យកូនចៅតាមឃ្លាំមើលសកម្មភាពរបស់នាងរហូត តែមិនសឹងមិនបានអ្វី ព្រោះនាងមិនសូវចេញពីចម្ការ ចំណែកគេមិនអាចចូលទៅក្នុងចម្ការនោះបាន។

"បាទ លោក ខ្ញុំនឹងរកឱកាសនាំឡើងឡាន តែប្រហែលចប់ការប្រណាំងសិន ពេលនោះមានពិធីជប់លៀង គិតថាគ្មានអ្នកណាចាប់អារម្មណ៍ប៉ុន្មានទេ ពេលចប់ការប្រណាំង លោកឡើងឡានចាំបាន"

"អ៊ឺម"

**ការប្រណាំងប្រព្រឹត្តទៅយ៉ាងក្តៅគគុក និងបញ្ចប់ដោយក្រុមរបស់**អាជ្រេ និងបងប្រុស រួមទាំងមិត្តភក្តិឈ្នះ ដោយពិន្ទុបួនទល់ពីរ។ ការប្រណាំងនៅថ្ងៃនេះប្រព្រឹត្តទៅដោយភាពសប្បាយរីករាយ ចំណែករង្វាន់ដែលទទួលបានត្រូវទូទាត់ថ្លៃចាយវាយ និងប្រគល់ឲ្យមូលនិធិសប្បុរសនានា ទាំងអស់។

ហៃឡៃត៍របស់កម្មវិធី គឺចន្លោះពេលសម្រាកនៃការប្រណាំង ពិធីករបានអញ្ជើញភ្ញៀវពន្លឺឲ្យមកដើរក្នុងទីលាន ដើម្បីបង្ហាប់ដី និងលុបដានជើងសេះ ឬចង់ហៅថាជាការអញ្ជើញឲ្យមកបង្អួតសម្រស់គ្នាលើវេទិកាក៏មិនខុស ជួបគ្នារាក់ទាក់គ្នា អ្នកស្គាល់គ្នាក៏និយាយគ្នាលេងតាមអធ្យាស្រ័យ។

ពេលទទួលមេដាយហើយ អាជ្រេ ក៏ដើរមករកភរិយានៅរបងឈើ ចាប់ដៃនាងថើបថ្នមៗ និងបាញ់ខ្សែភ្នែកព្រាននារីដាក់ ថែមទាំងយកមេដាយពាក់នឹងករបស់នាងទៀត ធ្វើឲ្យគ្រប់គ្នាងាកមើល យ៉ារីម ជាពិសេសស្រីៗ ដែលមើលដោយភាពឫស្យា រួមទាំង យូណា ដែលខាំមាត់ ក្តាប់កៃវសាំប៉ាញណែនដៃ។

អេដែន និង កាណែត ដើរមកតាមក្រោយ ហើយបងធំក៏យកកូនប្រុសមកពដៃម្ខាងទៀតឱបស្នាភរិយា ថើបថ្ពាសនាងថ្នមៗ មិនឲ្យចាញ់ប្អូនប្រុស ហើយនាំគ្នាអស់សំណើច ពេល ស្នូម លើកដៃទះមុខឪពុក ហាក់ដូចហួងហែងម្តាយ ចំណែក កាណែត មើល ស៊ុនស៊ូ មិនដាក់ភ្នែក ថែមទាំងវាយចិញ្ចើមដាក់ដោយការបេះបួយ ទើប ស៊ុនស៊ូ ខាំមាត់ ធ្វើឆើយដាក់។

"ក្មេងជើងល្អ ស្មានថាស្អាតគួរឲ្យមើលណាស់ក៏អី"

កាណែត និយាយរអ៊ូៗ តាមមើលអ្នកដែលដើរតាមម្តាយមីងចូលទៅក្នុងកម្មវិធីជប់លៀង។

Scanned with CamScanner

"លោក កាណែត មិញខ្ញុំឃើញម្ចាស់ចម្ការ សាន មកនិយាយជាមួយជំនួយការ កាំង"

សុងចូ ដែលឈរនៅមិនឆ្ងាយប៉ុន្មាន ម្នីម្នាដើរមករាយការណ៍។

"វាម៉ោដែរ?"

"បាទ តែពេលនេះដើរទៅកន្លែងផ្សេងហើយ ដូចទៅចំណតឡាន គួរតែត្រឡប់ទៅវិញទេដឹង"

"អ៊ីចឹងឬ ឲ្យមនុស្សរបស់យើងលួចទៅមើលឡានរបស់វាបន្តិច ក្រែងវាធ្វើអីមិនល្អនៅក្នុងកម្មវិធី"

កាណែត ចងចិញ្ចើម គិត ព្រោះមនុស្សដូច សាន ដុងវ៉ុក បើមកដល់ទឹកដីរបស់គេបែបនេះ មិនគួរណាប្រញាប់ត្រឡប់ទៅវិញ។

"បាទ" សុងចូ ទទួលបញ្ជា ហើយតេរទៅកូនចៅឲ្យធ្វើការភ្លាម។

កាណែត និង សុងចូ ដើរចូលក្នុងកម្មវិធីជប់លៀង ដែលកំពុងប្រកាសរង្វាន់តែងខ្លួនស្អាតផ្តាច់គេរបស់បុរសនារី។ គេឃើញបងប្រុសកណ្តាល និងភរិយា កំពុងត្រូវអ្នកកាសែតឃាត់ ដើម្បីសុំថតរូប ចំណែកបងប្រុសច្បងអង្គុយនៅតុអាហារជាមួយភរិយានិងកូនប្រុស ប៉ុន្តែមិនឃើញ ស៊ុនស៊ូ ក៏ចងចិញ្ចើមសង្ស័យ។

"សួស្តី លោក អេដែន អ្នកស្រី កាំង ឯណាជំនួយការ កាំង មិនឃើញ"

សុងចូ រាក់ទាក់ ហើយសួរនាំ ពេលឃើញមិន ស៊ុនស៊ូ ជំនួសចៅហ្វាយ

ដែលមើលមុខជាការឲ្យសញ្ញា។

"អូ្ន! សុំទៅនិយាយទូរសព្ទនៅខាងក្រៅ"

អេដែន ឆ្លើយប្រាប់ ព្រោះអម្បាញ់មិញមានទូរសព្ទ ស៊ុនស៊ូ ប្រាប់ថាមិត្តតេរមក។

"អូ្ន! បាទ"

សុងចូ ញញឹម ងក់ក្បាល ហើយផ្ទៀងខ្លួនទៅប្រាប់បុគ្គលិក ឲ្យយកអាហារមកដាក់។

"ហេឡូ ឌុងជូ ឬ បានឮច្បាស់ហើយនៅ មិញសំឡេងខ្លាំងបន្តិច មានកម្មវិធីនៅចម្ការ ចម្ការ ឈើរ៉សទិ មានប្រណាំងប៉ុឡូ ម៉ោៗ ហាសហា មិនម៉ោខ្មាសឬ ប្រុសសង្ហាៗច្រើនណាស់ ពេលនេះដើរចេញមកឆ្ងាយពីពិធី នៅមុំចំណតឡាន ទើបឮច្បាស់ កន្លែងយើងណាត់គ្នាទៅញ៉ាំបាយមែនទេ អ្ហឹម! ចាំចប់កម្មវិធី ខ្ញុំតេរទៅ ពេលនេះមិនទាន់ទំនេរ អូខេ ប៉ុណ្ណឹងសិនចុះ បាយៗ"

ស៊ុនស៊ូ ដើរមកនិយាយទូរសព្ទនៅខាងក្រៅ ដែលត្រង់នេះមានមនុស្សតិច សំឡេងមិនសូវខ្លាំង ទើបអាចនិយាយជាមួយមិត្តភក្តិបានស្រួល។

ឆឹត!

ឡានទំនើបពណ៌ខ្មៅបើកមកចតពីមុខ មានបុរសគ្រ័រហ្សេខ្មៅ វ៉ែនតាខ្មៅបើកទ្វារចុះមក ធ្វើឲ្យនាងឆ្ងល់។

៚

Scanned with CamScanner

"អ្នកនាង កាំង មែនទេ ?"

ពេលត្រូវសួរនៅនឹងមុខបែបនេះ ធ្វើឲ្យនាងមានអារម្មណ៍ដល់ស្ទើរនៃគ្រោះថ្នាក់ ទើបថយក្រោយ នៅឆ្ងាយពីគេ។

"មិនមែនទេ ច្រឡំហើយ"

នាងគ្រវីក្បាលជាការបដិសេធភ្លាម ហើយដើរចេញ តែលែងទាន់ទៅហើយ បុរសម្នាក់នោះញញឹមចុងមាត់ និងដើរមកកៀកភ្លាម។

"អី!"

នាងស្រែក តែសំឡេងឮក្នុងបំពង់.ក ព្រោះត្រូវបិទមាត់ បន្ទាប់មកនាងក៏ត្រូវគេលើកញាត់ឡាន ទ្វារក៏ត្រូវបិទភ្លាមៗ។

"លែងខ្ញុំ លែង ពួកឯងជាអ្នកណា លែងខ្ញុំ"

នាងប្រឹងរើបម្រះ តែមិនស្រួល ហើយឡានក៏ត្រូវបញ្ឆាចេញ បន្ទាប់មកដៃរបស់នាងក៏ត្រូវចងដោយក្រវាត់ក។

"កុំខ្លាចអី អ្នកនាង កាំង យើងកំពុងតែទៅសប្បាយជាមួយគ្នាប៉ុណ្ណោះ"

ហើយមនុស្សប្រុសដែលអង្គុយក្បែរអ្នកបើកបរក៏ងាកមករក ព្រមទាំងញញឹមចុងមាត់ដាក់ ដែលធ្វើឲ្យនាងបើកភ្នែកធំៗ ត្រជាក់ខ្លួន ញ័រមាត់ប៉ប៉ប់មិនស្មានថាជាគេ។

"ម្ចាស់ចម្ការ សាន លោកធ្វើបែបនេះធ្វើអី ?"

គេនៅតែញញឹមចុងមាត់ លូកដៃមករក បំណងចាប់ចង្កា តែនាងគ្រវីក្បាល ឲ្យចាប់បានតែអាកាសធាតុ ទើបគេសើចហ៊ឹៗ ជ្រឹមភ្នែកមើលស្រីស្អាតផ្កាសឆ្មើម ហើយងៀងមើលកូនចៅ ងក់ក្បាលដាក់។

"ចាប់ឲ្យនៅស្ងៀម ខ្ញុំបញ្ចុកនំឲ្យនាងបន្តិច"

"បាទ លោក"

កូនចៅទទួលបញ្ជា ហើយចាប់នាងសង្កត់ជាប់ ទោះរើយ៉ាងណាក៏គ្មានប្រយោជន៍។

"ជុំៗ គ្មានអីទេ គ្រាន់តែជានំដែលធ្វើឲ្យនាងមានសេចក្ដីសុខជាមួយខ្ញុំប៉ុណ្ណោះ ស៊ុនស៊ី"

គេទប់សំណើចនៅដើម.ក ជ្រឹមភ្នែកមើលអ្នកដែលកំពុងភ័យខ្លាច តែវាបែរជាធ្វើឲ្យឈាមក្នុងខ្លួនរបស់គេក្ដៅ ចង់ត្របាក់សត្វក្រមុំឆាប់ៗ។

"កុំ...កុំ...អី..."

នាងស្រែកប្រាប់ដោយសំឡេងញ័រៗ ហើយប្រឹងខ្ទប់មាត់ ពេលកូនចៅរបស់គេច្របាច់ថ្គាល់ខ្លាំងៗ ឲ្យហាមាត់ ហើយ ដុងរ៉ុក ក៏យកអ្វីម្យ៉ាងមកញាត់ចូលមាត់របស់នាង។ វាមានគ្រាប់តូចៗ ដែលនាងប្រឹងយកអណ្ដាតរុញចេញមកវិញ តែមិនបានសម្រេច ព្រោះត្រូវកូនចៅយកដៃខ្ទប់មាត់ជាប់ ទើបមិនអាចខ្ជាក់វាចោលបាន។

នាងរលីងរលោងទឹកភ្នែក ពេលថ្នាំគ្រាប់នោះរលាយក្នុងនោះ ហូរចូលបំពង់.ក ទោះមិនចង់លេបយ៉ាងណា ក៏វាហូរចូលដោយស្វ័យប្រវត្ត មួយសន្ទុះ

Scanned with CamScanner

កូនចៅក៏ដកដៃចេញ និងរុញនាងចេញតិចៗ។

"ខក់ៗ អ្នក"

នាងប្រឹងក្អួត មិនបានសម្រេច ប្រឹងឡើងមុខក្រហមអស់ទៅហើយ។

"គ្មានប្រយោជន៍ទេ នាងលេបវាបាត់ទៅហើយ មួយសន្ទុះទៀត នាងនិងក្ដៅខ្លួន អារម្មណ៍ហោះហើរ និងអង្វរករខ្ញុំឲ្យទៅរក ហ៊ឹៗ"

ដុងរ៉ៃក ញញឹមគួរឲ្យស្អប់ ដោយការពេញចិត្ត ពេលឃើញអាកប្បកិរិយារបស់ ស៊ុនិសូ ទម្រាំទៅដល់វីសេត ដែលកក់បន្ទប់រួចរាល់ហើយ នាងក៏មានប្រតិកម្មល្អម។

"អាចង្រៃ អាចោកទាប!"

នាងជេរប្រទេច ដោយការឈឺចិត្តដែលចាញ់ល្បិចវា ការភ័យខ្លាចកំពុងធ្វើការ ខួរក្បាលក៏គិត ចិត្តក៏អធិដ្ឋាន សុំឲ្យមានអ្នកណាឃើញគេចាប់នាងអូសឡើងឡានផងទៅចុះ។

"បន្តិចទៀត នាងនឹងមិននិយាយបែបនេះទេ នាងប្រមក់ ត្រៀមខ្លួនឲ្យបានល្អ ខ្ញុំប្រាប់ហើយតើថាគង់បានជួបគ្នា ហ៊ឹៗ ឯងមើលឲ្យហើយ ហើយកុំប៉ះពាល់របស់អញ"

គេអស់សំណើចតិចៗ មើល ស៊ុនស៊ូ ដោយខ្សែភ្នែកស្រេកឃ្លាន ហើយបញ្ជាកូនចៅនៅខាងមុខ។

"បាទ លោក"

"លែងខ្ញុំ លែង អាំ..."

"បិទមាត់ទៅ"

ស៊ុនស៊ូ ទាំងស្រែក ទាំងរើបម្រះ ទើបម្ចាស់ចម្ការ សាន បញ្ជាកូនចៅ ហើយមិនយូរប៉ុន្មាន ឡានក៏មកដល់គោលដៅ គេក៏ចូលតាមទ្វារក្រោយ ដោយកូនចៅជាអ្នកបីនាងចូលបន្ទប់។



Scanned with CamScanner

# ៧

"កុំ"

ស៊ុនស៊ូ ស្រែកឮខ្សាវៗ នៅដើម.ក ប្រឹងរើបម្រះ និងនាំរាងកាយខ្សោយកម្លាំងរបស់ខ្លួនចេញពីរង្វង់ដៃរបស់ម្ចាស់ចម្ការ សាន។

"មិនបាច់បង្ខំចិត្តទេ ស្រីស្អាត បណ្ដោយតាមធម្មជាតិទៅ នាងគង់តែចូលចិត្ត"

ដុងវ៉ៃ ញញឹមចុងមាត់ដោយការពេញចិត្ត កែវភ្នែកមានពន្លឺផ្លេកៗ ដៃក៏រឹតកាន់តែណែន នាំនាងចូលបន្ទប់ដេកនៅខាងក្នុង ដាក់ទៅលើគ្រែធំទូលាយ និងលោតអន្ទិល ព្រោះវាជាពូករ៉ឺស័រ ហើយសម្លឹងមើលរាងកាយរបស់អ្នកដែលដេកស្ប៉ាបនៅលើគ្រែ មុខក្រហមង៉ាំង ភ្នែកក៏ស្លឹ បបូរមាត់ក្រហមង៉ាំងក៏ប្រឹងស្រែកហាម តែសំឡេងឮនៅដើម.ក ខ្យល់ដង្ហើមក៏ដង្ហក់ ដៃជើងប្រឹងប្រវេប្រវាប្រឹងងើបអង្គុយ តែធ្វើមិនបាន ទើបវាធ្វើឲ្យគេអស់សំណើចហ៊ីៗ ញញឹមចុងមាត់ លើកដៃអង្អែលចង្កា បន្ទាប់មកដោះអាវគ្រ័រហ្សេគ្រវាត់ចោល តាមដោយការប្រឡេះឡេវអាវយឺតៗ ដោយខ្សែភ្នែកស្រេកឃ្លានសម្លឹងមើលអ្នកនៅលើគ្រែរហូត។

គេដើរទៅអង្គុយនៅគែមគ្រែ លូកដៃទៅប៉ះជើងរបស់នាង អង្អែលថ្នមៗដោយការចូលចិត្ត ព្រោះភាពរលោងរបស់វា ហាក់ដូចកាំម្ជី ដែលធ្វើឲ្យតម្រូវការនៅក្នុងខ្លួនរបស់គេក្ដៅមួយរំពេច។

"អឺ!"

ស៊ុនស៊ូ ភ្ញាក់កន្ត្រាក់ មិនត្រូវការឲ្យគេប៉ះពាក់រាងកាយ តែមើលទៅវាដូចផ្ទុយពីអាកប្បកិរិយារបស់រាងកាយ ដែលពេលដៃរបស់គេប៉ះពាល់ នាងក៏ក្ដៅខ្លួនប្លែកៗ ញ័រខ្លួនទទ្រើត សំឡេងថ្ងូរខ្សាវៗ បន្លឺឡើង ទើបខាំមាត់តតាំង និងប្រឹងទប់ខ្លួនឯងមិនឲ្យភ្លើតភ្លើន ព្រោះអំណាចថ្នាំដែលគេបង្អកឲ្យលេប។

"នាងត្រូវការខ្ញុំហើយមែនទេ ស្រីស្អាត ខ្ញុំបានសំឡេងនាងថ្ងូរ គួរឲ្យស្រឡាញ់ណាស់ នាងប្រមក់ ខ្ញុំនឹងធ្វើឲ្យនាងសេចក្ដីសុខបំផុត ស្បែកនាងរលោងណាស់ ខ្លួនក៏ក្រអូប បែបនេះទើបសមាមាត្រនឹងការប្រថុយបន្តិច បើនាងស្ដាប់បង្គាប់ ខ្ញុំនឹងផ្គងផ្គើមនាងឲ្យរស់ស្រួល មិនបាច់ធ្វើការត្រុកៗ នៅចម្ការនោះទៀតទេ"

"កុំ...កុំ..."

"ជុំៗ ខ្ញុំនឹងថ្នមដៃ ថ្នាក់ថ្នមនាង តែបើនាងពុះកញ្ជ្រោល ខ្ញុំនឹងពុះតាមមិនបាច់ខ្លាចទេ"

គេខ្សឹបខ្សៀវប្រាប់ មើលមុខក្រហមង៉ាំងរបស់នាងម្ដងទៀត ហើយសម្លឹងដើមទ្រូងទ្រលុកទ្រលន់ ក្រសោបមុខស្រស់ស្អាតឲ្យងើយ និងឱនទៅរក



Scanned with CamScanner

បំណាងបើប។

ផូស!

ទ្វារបន្ទប់ត្រូវរុញចូលមកមួយទំហឹង ធ្វើឲ្យ ដុងវ៉ុក ភ្ញាក់ និងគំហកដាក់ទាំងមិនបានងាកទៅមើលថាជាអ្នកណា។

"ពួកឯងចូលម៉ោធ្វើអី អញកំពុងជិតបានស៊ីបានចុកហើយ ចេញទៅវិញភ្លាម អញប្រាប់ថាឲ្យចេញ អុំ!"

គេខាំធ្មេញក្រតៗ ដោយកំហឹង និងងើបចេញពីការទ្រោបលើរាងកាយរបស់ ស៊ុនស៊ូ ងាកទៅមើលទ្វារ ហើយបើកភ្នែកធំៗ ចំហមាត់ឆ្លង ពេលឃើញថានរណាឈរជំទែងនៅត្រង់នោះ។

"កាណែត!"

"អឺ! អញហ្នឹង អាចង្រៃ!"

កាណែត មើលទៅគ្រែដែល ស៊ុនស៊ូ កំពុងដេករមួលខ្លួន ហើយស្ទុះមកដាល់ ដុងវ៉ុក ពីរដៃជាប់គ្នា ឲ្យជ្រមិល ឈាមហូរតាមចង្ហៃកមាត់និងច្រមុះ។

"អាំ! អាចង្រៃ កាណែត"

ដុងវ៉ុក ពង្រឹងជំហរបានក៏ការពារខ្លួនឯងនិងវាយបកវិញ ព្រមទាំងស្រែកជេរ កាណែត ដោយការចងអាឃាត ពេលឃើញឈាមរបស់ខ្លួនជាប់នឹងខ្នងដៃដែលលើកជូត ខ្លួនប្រាណឈឺចាប់ ព្រោះត្រូវដាល់ដោយដៃ ទាត់ដោយជើង។

"អឺ អញនេះឯង ឯងព្រហើនណាស់ ហ៊ានធ្វើដាក់មនុស្សរបស់អញ"

កាណែត ដកដង្ហើមព្ធគឃូស ព្រោះខឹងសម្បា។

"អញចូលចិត្ត ឯងចង់យ៉ាងម៉េច"

"គឺមិនយ៉ាងម៉េចទេ គ្រាន់តែប្រដៅឯងឲ្យងាប់លេង!"

កាណែត មិននិយាយមិនអីទៀត វាត់ជើងវែងស្ដង់ដាអឺរ៉ុបទៅលើ ដុងវ៉ុក ឲ្យដួលអុកគូទ និងតាមទៅវាត់លើមុខ ឲ្យផ្ងារក្រោយ ឲ្យសំឡេងសាច់ប៉ះសាច់ឮហើយ ញ័រខ្លួនជំនួស។

"អ៊ូយ! បានហើយ បានហើយ ឯងយកមនុស្សរបស់ឯងទៅ យកទៅ"

ម្ចាស់ចម្ការ សាន ថ្ងូរដូចព្រាបឈឺ ប្រឹងប្រវេប្រវាងើបឈរ តែជ្រមិលទៅតោងតុនៅជិតគ្រែ ព្រោះទប់ជំហរមិននឹងនិងប្រឹងដកដង្ហើមចូលឲ្យពេញពោះ។

"អញដឹងតែយកនាងទៅ តែអញលេងឯងឲ្យងាប់សិន"

មុខរបស់អ្នកកំលោះឡើងក្រហមងាំង កែវភ្នែកមុតស្រួចដែលជះពន្លឺលេងសើចបែរជាប្រាកដប្រជា មើលទៅគួរឲ្យខ្លាច ក្ដាប់ដៃណែន សរសៃឈាមឡើងរវាម សក់សើងមម៉ើង ខោអាវទក់ទី ស្បែកជើងសម្រាប់ជិះសេះ ពេលវាត់ទៅលើរាងកាយរបស់ ដុងវ៉ុក ម្ដងៗ គឺស្រែកមិនចង់ចេញ ញើសហូរតាំងពីថ្ងាសមកដល់ចុងចង្កា ខណៈដែល ដុងវ៉ុក ហូរឈាម។

"កុំៗ ព្រមហើយៗ"

"មនុស្សដូចឯងឬ ព្រមងាយៗ អញមិនជឿទេ អាចង្រៃ!"

កាណែត យារដៃម្ដងទៀត បំណងដាល់ តែ ដុងវ៉ុក លើកដៃម្ខាងហាម

Scanned with CamScanner

ចំណែកដៃម្ខាងទៀតក្ដោបផ្អឹងជំនិរ ដែលឈឺស្ទើរស្លាប់ហើយពេលនេះ។

"កុំវៃខ្ញុំ កាណែត ខ្ញុំស្បថថាមិនទៅរំខានឯង និង ស៊ុនស៊ូ ទៀតទេ មិនទៅចម្ការ ឈើរ៉សេទិ របស់ឯងទៀតទេ ខ្ញុំសន្យា"

ដុងវ៉ុក អង្វរករអស់សភាពតែម្ដង ប៉ុន្តែធ្វើភ្នែកក្រឡេបក្រឡាប់រកមើលកូនចៅ មិនដឹងថាថ្មើរណេះ វាបាត់ក្បាលទៅណា ទុកឲ្យគេឈឺខ្លួនម្នាក់ឯង។

"ឯងរកមើលអ្នកណា រកមើលកូនចៅអ្ហ៎! មិនឃើញទេ មនុស្សរបស់អញនៅខាងក្រៅជាមួយប៉ូលិស ឯងត្រៀមខ្លួនចូលគុកទៅ"

"ខ្ញុំសុំអង្វរ កុំឲ្យរឿងដល់ប៉ូលិសអី កាណែត ខ្ញុំស្បថហើយថាមិនទៅរំខានឯងទៀតដាច់ខាត មិនរំខានមែន"

"អឺ..."

ស៊ុនស៊ូ ដែលពេលនេះលែងមានភាពម្ចាស់ការទៅហើយ បប្រះពេញគ្រែ ដោយភាពវេទនា និងស្រែកថ្ងូររហូត។

"ឯងធ្វើអី ស៊ុនស៊ូ ឯងធ្វើអីនាង ហ៎ា!"

កាណែត ក្រឡេកមើល ឃើញភាពមិនប្រក្រតី ព្រោះមនុស្សវ៉ៃខ្លាយូរហើយ តែនាងមិនព្រមចុះពីគ្រែសោះ គិតតែស្រែកថ្ងូរ។

ផាច់! ផាច់!

"អ៊ូយ!"

សំឡេងដៃនិងជើងប៉ះរាងកាយរបស់ម្ចាស់ចម្ការ សាន ម្ដងទៀត ពេលមិនព្រមឆ្លើយសំណួររបស់ កាណែត។

"អ៊ូយ! ខ្ញុំ...ខ្ញុំយកថ្នាំសម្រើបឲ្យលេប ទើប...ទើបទៅជាបែបនេះ"

"អាចង្រៃ! ឯងទៅខាងក្រៅជាមួយអញ"

កាណែត ទះមួយកំផ្លៀងទៀត ហើយអូស ដុងវ៉ុក ចេញទៅខាងក្រៅដោយមិនភ្លេចបិទទ្វារបន្ទប់ដេក ពេលនេះឲ្យកូនចៅយាមកាមជាមួយប៉ូលិសស័ក្តិធំ ដែលជាមិត្តរបស់គេ។

"ថាក់គូ ឯងជួយចាត់ការបន្តិច"

"សុំអង្វរ កុំអី ខ្ញុំស្បថនៅចំពោះលោកប៉ូលិសក៏បានថា មិនទៅរំខានឯងស៊ុនស៊ូ ឬអ្នកចម្ការ ឈើរ៉សេទិ ទៀតជាដាច់ខាត មិនរំខានមែន រួមទាំងកូនចៅរបស់ខ្ញុំដែរ មិនមករំខានទីនេះទេ និងមិនតាមសងសឹកឯងទៀតដែរ ខ្ញុំស្បថ"

ត្រឹមឃើញលោកប៉ូលិស ដុងវ៉ុក ក៏ញ័រខ្លួនទៅហើយ ព្រោះមិនត្រឹមតែថាក់គូ មានស័ក្តិធំទេ ក៏ជាកូនលោកស្នងការទៀត។

"ឯងចង់យ៉ាងម៉េច កាណែត ខ្ញុំតាមឯង មិញថតវីដេអូទុកហើយ"

"សុំអង្វរ ខ្ញុំសុំអង្វរ កាណែត"

"បាន អញបន្ធូរដៃឲ្យឯងម្ដងទៅចុះ សាន ដុងវ៉ុក តែរឿងនេះអញត្រូវតែប្ដឹងប៉ូលិស ថាត្រូវឯងរំខាន ដើម្បីកុំឲ្យឯងម៉ោរំខាន ស៊ុនស៊ូ ឬរករឿងអ្នកណាទៀត នៅមានវីដេអូដែលថតបានទៀត អញឲ្យ ថាក់គូ ភ្ជាប់ជាភស្តុតាង បង្ការថ្ងៃក្រោយឯងលេងមិនស្មោះត្រង់ វីដេអូនេះវានឹងចាត់ការឯងឲ្យចូលគុកបាន

Scanned with CamScanner

ឬមិនអ៊ីចឹង អាច..."

"ខ្ញុំព្រមហើយៗ ធ្វើតាមឯងត្រូវការ"

"អ៊ីចឹងសម្រេចតាមហ្នឹង សុងចូ ដេមីន ដោះលែងកូនចៅវាឲ្យនាំមេវាទៅផ្ទះ កុំម៉ោឲ្យឃើញមុខទៀត" កាណែត ស្រែកប្រាប់កូនចៅទាំងពីរ។

"អរគុណ ខ្ញុំមិនម៉ោរំខានឯងទៀតទេ"

ដុងវ៉ុក ត្រូវឃ្លូរស្លាបសេកដោយកូនចៅទាំងពីរ ព្រោះឈរមិននឹង ចេញទៅឡើងឡាន ហើយបើកចេញទៅ។

"ដេមីន ត្រៀមឡាន ខ្ញុំយក ស៊ុនស៊ូ ទៅផ្ទះនៅចម្ការតែសិន ចំណែកឯង សុងចូ ជូន ថាក់គូ ទៅកន្លែងធ្វើការ បើមានអ្នកណាសួររកខ្ញុំ និង ស៊ុនស៊ូ ប្រាប់ថាខ្ញុំនាំនាងទៅជួបភ្ញៀវ ឬរកឯកសារស្អីក៏ដោយ ល្ងាចទើបត្រឡប់ទៅផ្ទះវិញ ដែលសំខាន់ បិទមាត់ឲ្យជិត ហាមចែកចាយរឿងនេះឲ្យអ្នកណាដឹងដាច់ខាត សូម្បីតែប៉ា ឬបងប្រុសទាំងពីររបស់ខ្ញុំ យល់ទេ"

កាណែត ប្រាប់កូនចៅដោយសំឡេងកាច និងបញ្ជាក់ម្តងទៀត ព្រោះមិនត្រូវការឲ្យមានមនុស្សច្រើនដឹងរឿងនេះ ដល់ពេល ចាំគេប្រាប់។

"បាទ"

កូនចៅទាំពីរទទួលបញ្ជា ហើយឡើងបញ្ឆេះឡាន បើកចូលមកចតមុខវិសេតភ្លាម។

"មានអីឬអត់ កាណែត?"

"មាន តែមិនមែនដូចឯងគិត មិនអ៊ីចឹងខ្ញុំមិនដោះលែងវាងាយៗទេ ឯងក៏ដឹង តែនេះវា..វាបង្កក ស៊ុនស៊ូ ឲ្យលេបថ្នាំសម្រើប"

អ្នកកំលោះលើកដៃជ្រងសក់ និងខាំធ្មេញក្រតៗ និយាយខ្សឹបៗ ប្រាប់មិត្តភក្តិ ដោយទឹកមុខខ្វល់ខ្វាយ ព្រោះខ្លាចកូនចៅទាំងពីរបានឮ។

"អ្ហឹម! អ៊ីចឹង ឯងឆាប់នាំនាងទៅ ទុកយូរអាចគាំង បើដូចដែលឯងប្រាប់ ខ្ញុំធ្លាប់ជួបករណីបែបនេះ"

ថាក់គូ ខ្សឹបប្រាប់មិត្តភក្តិ ដោយទឹកមុខខ្វល់ខ្វាយដូចគ្នា ទើប កាណែត ដើរចូលទៅក្នុងបន្ទប់ម្តងទៀត។

"អឺ...អឺ..."

ស៊ុនស៊ូ ពត់ពេនខ្លួន ព្រមទាំងថ្ងូចថ្ងូរ លើកដៃអង្អែលខ្លួនប្រាណ ដើម្បីកាត់បន្ថយអាការៈក្តៅស្រើបស្រាលដែលកើតឡើង ធ្វើឲ្យ កាណែត ដែលដើរចូលមក ត្រូវខ្ទឹបមាត់ណែន លូកដៃយឺតៗ ទៅលើកបីនាង ឱបជាប់ទ្រូង ដែលត្រឹមប៉ុណ្ណឹង នាងក៏ត្រសុលទៅរកគេទៅហើយ ថែមទាំងលើកដៃស្ទាបអង្អែល និងថាប់មុខរបស់គេ បំណងថើប។

"ស៊ុនស៊ូ!"

គេហៅនាងឲ្យមានស្មារតី ពេលបីចេញបន្ទប់ តែនាងមិនដឹងខ្លួន ហើយពេលមកដល់ក្រៅ មិត្តភក្តិក៏ញញឹមដាក់ និងជួយបើកទ្វារឡានបាំងក្រោយឲ្យ ចំណែក ដេមីន ក៏បញ្ជាឡានចេញទៅជាបន្ទាន់ សំដៅផ្ទះនៅចម្ការតែ។



Scanned with CamScanner

"ជំនួយការ កាំង កើតអី លោកប៉ូលិស សុង?"

សុងចូ ងាកមកសួរមិត្តភក្តិរបស់ចៅហ្វាយ ដែលអង្គុយក្បែរខ្លួន ព្រោះពេលមើលតាមកញ្ចក់ចំហៀង ឃើញនាងគ្មានភាពម្ចាស់ការចំពោះខ្លួនឯង។

"គ្មានអីទេ តិចទៀតលែងអីហើយ យើងទៅកន្លែងធ្វើការទៅ អ្ហ៎! ហើយជំនួយការ កាំង គ្មានគ្រោះថ្នាក់ពីម្ចាស់ចម្ការ សាន សប្បាយចិត្តចុះ វាមិនបានធ្វើអីនាងទេ"

ថាក់គូ ជួយស្រាយចម្ងល់ដោយទឹកមុខញញឹម ខ្លាច សុងចូ យល់ច្រឡំរឿងបែបនេះ និយាយផ្ដេសផ្ដាសមិនបានទេ ខ្លាចមនុស្សស្រីខូចខាត។

"បាទ" សុងចូ ងក់ក្បាលយល់ទាំងមិងមាំង។

ដេមីន បើកឡានមកដល់ផ្ទះនៅចម្ការតែ។ គេលួចឃើញ ស៊ុនស៊ូ មានកាយវិការប្លែកៗ ដូចគ្រុនក្ដៅ ដោយចៅហ្វាយចាប់ដៃនាងជាប់ ហើយពេលចតឡាន គេក៏រត់ទៅបើកទ្វារឲ្យ កាណែត បីនាងចុះពីឡាន។

"បើកទ្វារឲ្យបន្តិច ដេមីន កូនសោក្នុងហោប៉ៅខោ លូកយកម៉ោ"

"បាទ"

កូនចៅធ្វើតាមបញ្ជាជាបន្ទាន់ ហើយពេលចាក់សោរួច កាណែត ងាកមកប្រាប់។

"ឯងទៅវិញចុះ ដេមីន ហើយមិនបាច់ប្រាប់អ្នកណាទាំងអស់ បិទមាត់



ឲ្យជិត ល្ងាចខ្ញុំទៅវិញ"

"បាទ លោក កាណែត តែអ្នកនាង ស៊ុនស៊ូ មានសុវត្ថិភាពទេ មើលទៅនាងដូចគ្រុន នាងប្រហែលខ្លាចខ្លាំង ឲ្យហៅពេទ្យទេ?"

"មិនបាច់ទេ នៅទីនេះមានថ្នាំ ចាំខ្ញុំឲ្យនាងលេប បន្តិចទៀតប្រហែលលែងអីហើយ"

"បាទៗ អីចឹងខ្ញុំសុំទៅសិនហើយ"

ដេមីន សើចមិនសម ពេលឃើញទឹកមុខ និងសម្ដីកាចរបស់ចៅហ្វាយដែលបាញ់មករក ហើយប្រញាប់បែរខ្នងឡើងឡាន បើកចេញទៅភ្លាម។

កាណែត ប្រើជើងបិទទ្វារ ចុចគន្លឹះ នាំអ្នកដែលនៅមិនសុខ ដៃវើរវាមលើខ្លួនប្រាណរបស់គេរហូត សំដៅបន្ទប់ដេក ដាក់នៅលើពូកថ្នមៗ តែនាងមិនព្រមពន្លែងដៃពីគេ គិតតែពីប្រឹងឱបរឹត ត្រសុលមករក។

"ជួយខ្ញុំផង ខ្ញុំក្ដៅពេញខ្លួន"

ស៊ុនស៊ូ ទាញខោអាវចេញពីខ្លួន ពេលនេះវាកកិតនឹងសាច់ ឲ្យស្រៀវអស់ទៅហើយ។

"ហ៊ឺយ! ឆ្កួតមែន"

អ្នកកំលោះគ្រហឹមនៅដើម.ក ចាប់ដៃរបស់នាងជាប់ មិនឲ្យដោះខោអាវតែលែងទាន់ទៅហើយ នាងចាប់បោចអាវ កញ្ឆក់មួយទំហឹង ឲ្យដើមទ្រូងដែលក្ដោបដោយអាវក្នុងគ្មានខ្សែនៅកណ្ដាលវាល ដែលភាពទ្រលុកទ្រលន់នោះ វា





Scanned with CamScanner

ធ្វើឲ្យគេក្តៅខ្លួន តែប្រឹងទប់ចិត្ត។

"សុំអង្វរ ជួយខ្ញុំផង ខ្ញុំទ្រាំមិនបានទេ ហ៊ឺ!"

នាងស្រែកសុំជំនួយដោយសំឡេងញ័រ រលាស់ជើងពេញពូក និងមួលកដៃចេញពីដៃរបស់គេ ថែមទាំងប្រឹងស្ទុះទៅរកឲ្យបាន។

គេខាំធ្មេញក្រតៗ សង្កត់នាងទៅលើពូក និងទ្រោបពី ព្រលែងដៃរបស់នាងឲ្យមានសេរីភាព ហើយភ្ញាក់ក្រញាង ពេលនាងស្ទុះមករក លើកដៃឱប.ករបស់គេ ព្រមទាំងថើបមាត់ដោយភាពក្តៅគគុក ជើងស្រឡូនក៏លើកមកកៀរចង្កេះ សំពត់កង្វើញឡើងលើ ឲ្យឃើញខោក្នុង និងពោះរាបស្មើ។

"អឺ..."

កាណែត គ្រហឹមតិចៗនៅដើម.ក ដោយការចូលចិត្ត លង់នឹងការប៉ះពាល់របស់នាងដោយមិនដឹងខ្លួន ទើបថើបនាងវិញដោយភាពក្តៅគគុក តាំងពីមាត់មកដល់សាច់.ក រាលមកដល់គល់ដើមទ្រូង រុញអាវក្នុងចេញបានយ៉ាងងាយ ហើយប្រើអណ្តាត និងប្រអប់មាត់ទៅត្រវាស ទៅបឺតជញ្ជក់ ធ្វើឲ្យនាង ជូរពើងទ្រូងមករក ទើបបាតដៃម្ខាងច្របាច់ ប្រើម្រាមដៃកៀបដោយអារម្មណ៍ភ្លើតភ្លើន។

នាងមិនដឹងអ្វី ដឹងត្រឹមតែថាត្រូវការកាត់បន្ថយកម្តៅប្លែកៗរបស់ខ្លួនឲ្យជាធម្មតា ហើយពេលនេះវាកំពុងរត់សើបពេញខ្លួន ស្រៀបសព្វសាច់ ព្រឺសម្បុរមាត់ម្តងខាំ ម្តងស្រាយ តបស្នងគេ និងចូលទៅរកគេដោយមិនខ្លួន។

កាណែត ដោះខោអាវនាងចេញបានយ៉ាងស្រួល ព្រោះមាននាងជួយសហការ ចំណែកគេនៅទាំងអស់ តែតម្រូវការក្តៅតាយៗ ជ្រួលប្រាល់គ្រងប្រឡោះជើង ឈឺចាប់ស្ទើរស្លាប់ទៅហើយ ចង់ដោះលែងវា ឲ្យមកជ្រៀតជ្រែកក្នុងរាងកាយរបស់នាង របស់អ្នកដែលកំពុងរើបម្រះនៅក្រោមរាងកាយរបស់គេ ស្អាតដល់ថ្នាក់គេសឹងតែមិនចង់ដកខ្សែភ្នែកចេញ។

គេដកមាត់ចេញពីដើមទ្រូងអន្ទិល តែបាតដៃ និងម្រាមស្រឡូននៅតែជន្លជន្លេញ ហើយអូសបបូរមាត់សាច់រលោង អូសមកដល់ពោះរាបស្មើ ថើបខ្សឹតៗ ប្រើពុកមាត់ពុកចង្កាត្រដុសឲ្យសាច់សឡើងក្រហម ឲ្យនាងដង្ហក់ខ្យល់លើកដៃខ្វាំស្មារឹងមាំ ពេលខ្លះ ជ្រងសក់ ខ្វាំ ទាញខ្លាំងៗ និងពន្លែងដៃពេលមានអារម្មណ៍ប្លែកជ្រែកចូលមក។

បន្ទាប់មកគេក៏ទាញខោក្នុងរបស់នាងទម្លាក់យឺតៗ បបូរមាត់ក៏អូសតាមសាច់ភ្លៅ សង្កត់បបូរមាត់ខ្លាំងៗ ធ្វើឲ្យម្ចាស់វាភ្ញាក់កន្ត្រាក់ និងសម្លឹងមើលសម្រស់ផ្កាកុលាបនៅចំពោះមុខដោយការសរសើរ ហើយបឺតជញ្ជក់ ឲ្យនាងរ៉ែនត្រគាកមករក និងគ្រលែងដូចកំពុងរាំ ទើបគេចាប់ចង្កេះជាប់ ដែលធ្វើឲ្យនាងប្រឹងឡើងញ័រខ្លួន និងស្រែកឮខ្លាំងៗ។

អ្នកកំលោះត្រវាសអណ្តាតយកទឹកដមផ្អែមដូចទឹកឃ្មុំគ្រប់តំណក់ និងញញឹមចុងមាត់ ហើយដោលឡើងមកលើ មកឈប់ត្រង់ភាពអន្ទិលម្តងទៀត ចំណែកអ្នកដែលទទួលបានសេចក្តីសុខអម្បាញ់មិញ ក៏ស្រវាឱបគេម្តងទៀត

ទើបគេដឹងថានាងមិនរសាយពីអាការៈនោះ។ តើនាងមានដឹងទេថាវាធ្វើឲ្យគេវេទនា និងត្រូវគ្រប់គ្រងខ្លួនឯងឲ្យបានម្តងទៀត តែរាងកាយរបស់គេញ័រហើយពេលត្រូវនាងស្ទាបអង្អែលដោយប្រើបាតដៃ ទាញឲ្យគេដោលឡើងមកលើ ឲ្យរាងកាយនៃបនិត្យគ្នា គ្មានចន្លោះប្រហោងឲ្យខ្យល់ចេញចូល។

"ការអត់ធ្មត់របស់ខ្ញុំមានដែនកំណត់ ស៊ុនស៊ូ ឆាប់ដឹងខ្លួនទៅ មិនអីចឹងឈប់ចាប់ខ្លួនខ្ញុំទៅ"

កាណែត ខិនបើបថ្ពាល់រលោងមួយខ្សឹត និងសម្លឹងមើលមុខក្រហមដោយប្រឹងខាំធ្មេញក្រតៗ តែកែវភ្នែកមុតស្រួចទៅជាកន្ត្រាក់ ពេលឃើញបបូរមាត់ក្រពុំបង្អើបតិចៗ បញ្ចេញសំឡេងថ្ងូរ ទាមទារឲ្យគេជួយឲ្យនាងរសាយពីអារម្មណ៍វេទនានេះ។

"វេទនាណាស់ សូមមេត្តា អ្ហឹម..."

"កូនជ្រូក ពេលដឹងខ្លួន ខ្ញុំនឹងសងសឹក ចាំមើលទៅ"

គេខ្ទឹបមាត់បន្តិច ហើយខិនបើបបបូរមាត់ក្រពុំនោះ ដែលនាងក៏បើបគេវិញ ហើយអូសមកបើបចង្កា ឈ្មុលមុខនឹងប្រឡោះក ចំណែកបាតដៃក៏អូសលើសាច់សខ្ចី បំណងឲ្យនាងរសាយពីអារម្មណ៍វេទនានេះ តែត្រគាកដែលត្រលែងនៅមិនសុខ វាកំពុងត្រដុសប្រឡោះភ្លៅរបស់គេ ទើបសង្កត់ល្វែងក្រោម និងធ្វើសកម្មភាពដូចកំពុងគ្រប់គ្រងនាងបែបស៊ីជម្រៅ តែការពិតគ្រាន់តែជាការប៉ះពាល់ផ្នែកខាងក្រៅប៉ុណ្ណោះ ហើយមុនពេលភ្នំភ្លើងផ្ទុះ គេក៏បញ្ឈប់ ខណៈដែលនាងគិតតែពីស្រែក និងត្រលែងត្រគាកមិនឈប់ ទើបគេអូសបាតដៃតាមចង្កេះ ត្រគាក ភ្លៅដែលកៀវចង្កេះរបស់គេ កុលាបស្រស់ដែលទន់ល្មើយ និងក្តៅគគុក ប៉ះពាល់វាថ្នមៗ បន្ទាប់មកក៏ជ្រែកម្រាមដៃចូលទៅពិនិត្យ ដែលធ្វើឲ្យនាងភ្ញាក់ព្រើត ព្រោះមានរបស់ប្លែកៗ ចូលទៅក្នុងរាងកាយ ឲ្យអារម្មណ៍ឈឺតិចៗ តែក៏មានអារម្មណ៍ប្លែកតិចៗ លាយឡំ ហើយវាក៏ក្លាយជាអារម្មណ៍ដែលធ្វើឲ្យអារម្មណ៍ស្រៀវស្រើប។

កាណែត មានអារម្មណ៍ដល់ភាពតឹងណែនដែលរិត្បូតម្រាមដៃរបស់ខ្លួនវាធ្វើឲ្យបេះដូងលោតញាប់ប្រណាំងនឹងនាង បន្ទាប់មកភាពទន់ល្មើយក៏បង្កើតអារម្មណ៍ស្រើបស្រាលឲ្យនាងឱបរឹតគេកាន់តែណែន។ នាងខាំស្មារបស់គេដើម្បីកាត់បន្ថយអារម្មណ៍នោះ ពេលគេបន្ថែមចំនួនម្រាមដៃ ដែលដំបូងវាធ្វើឲ្យថប់ដង្ហើម តែពេលគេកម្រើកវា នាងក៏យោលត្រគាកតាម ទាល់តែរាងកាយកន្ត្រាក់ និងមានសេចក្តីសុខម្តងទៀត ដោយសារម្រាមដៃរបស់គេ។

"អ៊ំា !"

នាងស្រែកអស់សំឡេង រាងកាយញ័រទទ្រើត សុទ្ធតែញើស ដកដង្ហើមមិនដល់គ្នា តែបាតដៃក្តៅរបស់គេ នៅតែមិនបញ្ចប់បង្កើតអារម្មណ៍ ឲ្យនាងប្រឫកប្រពល់ម្តងទៀត ទាល់តែនាងស្រែកម្តងទៀត ស្ទើរតែសន្លប់តែម្តង ព្រោះអស់កម្លាំង បើកភ្នែកមិនចង់រួច ស្មារតីត្រឡប់មកវិញបន្តិចម្តងៗ និងមើលមកគេ ដោយប្រឹងគិតថា ហេតុអ្វីខ្លួនឯងមកនៅត្រង់នេះ។



Scanned with CamScanner

"លោក កាណែត"

នាងមើលគេឃើញព្រិលៗ នៅជិតបង្អើយ តែនាងខ្សោយពេកហើយ មិនអាចងើបមកតវ៉ាគេបាន បានត្រឹមតែហៅឈ្មោះគេដោយសំឡេងខ្សាវៗ ហើយសន្លប់ទៅ។

កាណែត ដោលខ្លួនឡើងមកលើ លើកដៃវាសសក់ចេញពីមុខក្រហមងាំងរបស់អ្នកដែលសន្លប់ទៅហើយ និងសម្លឹងមើលមុខស្រស់ស្អាត ដោយខ្សែភ្នែកស្រទន់ បន្ទាប់មកក៏ងើបអង្គុយ មើលរាងកាយននលគក ហើយទាញភួយដណ្តប់ឲ្យ ដើម្បីបិទបាំងសម្រស់ដ៏ស្រស់ស្អាតរួចរាល់ ទើបដើរចូលបន្ទប់ទឹក រលាស់ខោអាវចេញពីខ្លួន ឲ្យទឹកត្រជាក់ជួយកាត់បន្ថយកម្តៅនៅក្នុងខ្លួន តែដោយសារក្តៅពេក ទឹកក៏មិនអាចជួយបាន ទើបឲ្យបាតដៃធំក្រាស់ជួយដោយស្រមើស្រមៃថាជាបាតដៃរបស់ ស៊ុនស៊ូ ជាភាពទន់ល្មើរបស់នាងដែលគេបានប៉ះពាល់មុននេះ ដែលត្រឹមគិតក៏ធ្វើឲ្យគេផ្ទុះ ដកដង្ហើមមិនចង់ដល់គ្នា គ្រហឹមឮពេញបន្ទប់ទឹក។

មួយសន្ទុះក្រោយមក គេក៏ស្លៀកខោដដែល តែមិនទាន់ពាក់អាវ ដើរមកឈរក្បែរគ្រែ មើលអ្នកដែលកំពុងដេកលក់ស្រួល ហើយសើចញឹមៗ ដោយទឹកមុខមានល្បិចកល ហើយត្រសុលចូលភួយជាមួយ តែនាងបែរជាត្រសុលមករក និងស្រវាឱប ហាក់ដូចត្រូវការភាពកក់ក្តៅ ទើបគេបានត្រឹមដកដង្ហើមធំ និងប្រឹងបិទភ្នែកដេកឲ្យលក់ មិនស្រមើស្រមៃដល់រឿងនោះ រង់ចាំឲ្យនាងភ្ញាក់ពីដេក និងមានស្មារតីពេញលេញសិន សង្ឃឹមថាមិនលើសម៉ោងអាហារល្ងាច មិនអីចឹង គេត្រូវដាស់នាងហើយ ដាស់ដោយវិធីណានោះ ដល់ពេលនឹងដឹង។

គេនឹកដល់វេលាដែល ជេមីន តេរមកប្រាប់ ហើយក៏ក្តុកក្តួល បើគេមិនចុចទទួល មិនដឹងថាថ្មើរណេះ ស៊ុនស៊ូ យ៉ាងម៉េចយ៉ាងម៉ាទៅហើយ។

'លោក កាណែត ឆាប់តាមខ្ញុំម៉ោជាបន្ទាន់ ពេលនេះខ្ញុំកំពុងតាមឡានរបស់ សាន ដុងរ៉ុក មកជិតដល់រីសតព្រះអាទិត្យ នុះ ឡានវាបន្ថយល្បឿនហើយ'

'តាមធ្វើអី ជេមីន មានរឿងអី ?'

គេដើរចេញពីបញ្ជរអាហារ មករាក់ទាក់អ្នកស្គាល់គ្នា ហើយប្រុងដើរទៅវិញ តែទូរសព្ទរោទ៍ ពេលយកមកមើលឃើញថាជាលេខរបស់ ជេមីន។

'អ្នកនាង ស៊ុនស៊ូ ត្រូវវាចាប់ឡើងឡាន ខ្ញុំចេញមកជក់បារី ឃើញល្មមដំបូង ខ្ញុំឃើញឡានរបស់វាធ្វើដូចបើកចេញទៅហើយ តែមានឯណា វាមកស្ទាក់ចាប់អ្នកនាង ស៊ុនស៊ូ ឡើងឡាន ទើបខ្ញុំបើកតាមភ្លាម'

ដំបូង ជេមីន ភ័យពេក មិនដឹងថាធ្វើយ៉ាងណា ទើបបើកឡានតាម ហើយពេលពង្រឹងស្មារតីបាន ទើបទាញទូរសព្ទមកចុច ជូនអីលេខរបស់លោក កាណែត ដែលទើបតែតេរចេញនៅមុនគេល្មម ក៏តេរទៅរកភ្លាម។

'តាមទៅ ខ្ញុំនឹងស្រុតទៅ និងមិនបាច់ប្រាប់អ្នកណាទាំងអស់'

កាណែត ក្តាប់ទូរសព្ទណែនដៃ ប្រាប់អ្នកតេរមកដោយទឹកមុខកាច។



Scanned with CamScanner

'បាទ លោកឆាប់ម៉ោ ខ្ញុំខ្លាចមិនទាន់ការណ៍'

'អ៊ឺម! ខ្ញុំនឹងស្រួតទៅ'

ពេលដាក់ទូរសព្ទរបស់ ជេមីន ចុះហើយ គេក៏តេរទៅ សុងចូ ជូនអ៊ីជូប ថាក់គូ ដែលជាមិត្តភក្តិល្មម ទើបជួយដាក់ផែនការ ដែលពេលនៅលើឡាន គេ និង ជេមិន ទាក់ទងគ្នារហូត។

បេះដូងរបស់គេចង់ជ្រុះពីទងទៅហើយ ពេលឮថា សាន ដុងវ៉ុក ចាប់ ស៊ុនស៊ូ ឡើងឡាន តែពេលទៅដល់វិសតនោះ គេធូរចិត្តបានមួយប្រឡោះ ព្រោះអាចង្រៃនោះមានខោជើងវែងជាប់ចង្កេះ ដោះតែអាវ ហើយសំណាងល្អ ដែល ថាក់គូ ទៅជាមួយ មិនអ៊ីចឹង គេក្លាយជាឃាតកសម្រាប់អាចង្រៃនោះទៅ ហើយ ដែលហ៊ានប៉ះពាល់មនុស្សរបស់គេ។

**មិនយូរប៉ុន្មាន ស៊ុនស៊ូ ក៏ដឹងខ្លួន។ នាងបើកភ្នែក មើលទៅជុំវិញខ្លួន** និងស្ទះង៉េបភ្លាម ពេលនឹកឃើញថាមុនពេលសន្លប់ ដុងវ៉ុក កំពុងធ្វើអីនាង តែ ពេលនេះវាបាត់ទៅណា។

នាងរលីងរលោងទឹកភ្នែក ពេលមានអារម្មណ៍រងា ទើបឱនមើល ហើយ ប្រញាប់ស្រវាភួយមកឱបជាប់ទ្រូង និងយំស្ងាត់ៗ។

"ហ៊ឺៗ ហ៊ឹក!"

កាណែត ដែលចុះពីគ្រែ ទៅនិយាយទូរសព្ទជាមួយបងប្រុសថាឪពុក ហៅឲ្យទៅញ៉ាំអាហារជុំគ្នាល្ងាចនេះទើបតែចប់ ក៏ងាកមកឃើញសម្រស់ដែល ធ្វើឲ្យគេចង់យកមុខទៅឈ្មុល ភ្នែកបើកមិនទាន់ស្រឡះ សក់សើងមម៉ើង សាច់ ដែលលេចចេញពីភួយដែលបិទមិនជិត ក៏សខ្ចី ស្អាតមែនទែន ហើយមើលចុះ យំឡើងរង្គើខ្លួន ទើបដើរយឺតៗ ទៅរក លូកដៃទៅប៉ះស្មាតិចៗ។

"ចេញទៅ យកដៃស្មោកគ្រោករបស់ឯងចេញទៅ អា..."

នាងស្រែកបណ្ដេញ និងយកខ្នើយគប់ ព្រមទាំងគ្រវែងខ្លួនខ្លាំងៗ ដោយការខ្ញើមរអើម តែពេលងាកមកឃើញថាជាអ្នកណាក៏បើកភ្នែកធំៗ មើល គេដោយភាពស្រឡាំងកាំង។

"អាស្អី និយាយឲ្យពីរោះ ពេលនេះខ្លួននាងគ្មានខោអាវ ចំណែកខ្ញុំអាច ដោះគ្រវែងចោលបាន របស់ស្អាតៗ ល្អៗ ទាក់ទាញភ្នែកយ៉ាងនេះ"

គេវាយចិញ្ចើមដាក់ជាការបេះបួយ និងជ្រឹមភ្នែកមើលមិនព្រិចទៀត។

"ខ្ញុំមកនៅទីនេះដោយរបៀបណា ចុះអាចង្រៃនោះ វា..."

នាងអៀនឡើងក្ដៅមុខ ធ្វើភ្នែកឡេមឡាម មិនហ៊ានមើលគេចំ ព្រោះ ល្វែងលើរបស់គេស្អាតពេកហើយ សាច់ដុំទ្រូង សាច់ដុំពោះកង់ៗ ឃើញហើយ ពិបាកលេបទឹកមាត់ តែខួរក្បាលប្រឹងគិតដល់ហេតុការណ៍មុននេះ។ ពេលនេះ ខ្លួនប្រាណនាងនៅនលគក តើឲ្យគិតស្អីបានទៅ ក្រៅពីបង់ខ្លួនឲ្យវាទៅហើយ។

"វាធ្វើអីឬអត់ឬ មិនទាន់ទេ ខ្ញុំទៅទាន់ និងនាំនាងមកទីនេះ តែ..."

ព្រោះមិនចង់ឲ្យនាងគិតច្រើន ទើបគេប្រាប់តាមត្រង់ តែចុងប្រយោគ

Scanned with CamScanner

ឆៀតបង្ហូសសំឡេង ឲ្យនាងចង់ដឹង។

"តែអី ?"

នាងធូរចិត្តបាន តែប្រញាប់សួរ ពេលគេធ្វើចរិតបែបនេះ។

"តែនាងត្រសុលមករកខ្ញុំ ថើបខ្ញុំ ពើងមករក អញ្ជើញ បបួល ខ្ញុំរញចេញ នាងគិតតែពីស្រវាចាប់ ប្រាប់ឲ្យជួយផងៗ វេទនាណាស់ ជួយខ្ញុំបន្តិច ធ្វើឲ្យខ្ញុំទប់ចិត្តមិនបាន សំឡេងថ្ងូរនេះ ហ៊ឹម! ឡើងគ្រលួច"

គេលើកដៃឱបទ្រូង មើលនាងមិនដាក់ភ្នែក តែភ្នែកឡើងញ័រទង្រើត ហើយពេលនិយាយចប់ ក៏លួចសើច។

"មានន័យថាលោក..."

ស៊ុនស៊ូ ចំហមាត់ឆ្លង មើលគេ ខ្លួនប្រាណញ័រ និងស្លឹកទៅហើយ។

"មែន ខ្ញុំជួយឲ្យនាងបាត់វេទនានោះអី បែបនេះ ខ្ញុំសុំគិតថ្លៃខូចខាត ថ្លៃបង់ខ្លួនបង់ប្រាណពីនាងបន្តិចទៅចុះ ខ្ញុំមិនទារច្រើនទេ ដប់លានទៅចុះ អ្ហ៎! ខ្ញុំពិសោធរួចហើយថាដើមទ្រូងរបស់នាងជារបស់ពិត ធម្មជាតិ វាច្របាច់ហើយមិនបែកមែន ទន់ល្អណាស់"

"កាណែត អាមនុស្សឆ្កួត ខ្ញុំមិនជឿទេថាខ្ញុំធ្វើបែបនោះ ហើយខ្ញុំក៏មិនបានបង់ខ្លួនឲ្យលោកដែរ លោកកុហក!"

នាងប្រញាប់តវ៉ា ដោយមិនព្រមទទួលស្គាល់ការពិត ព្រោះវាជារឿងគួរឲ្យខ្មាសពេកហើយ។

"មិនជឿក៏មិនអីដែរ រកលុយបង់ថ្លៃខូចខ្លួនឲ្យម៉ោបានហើយ ថ្លៃខ្លួនខ្ញុំថ្លៃបន្តិច ប្រុសសង្ហា សាច់ដុំហាប់ណែនដូចខ្ញុំត្រូវនាងលូកលាន់ ឱប ថើប ច្របាច់សព្វសាច់ ខ្ញុំខូចខាតណាស់ ឲ្យតាមសម្រួលម៉ោ ដប់លានហាមតថ្លៃ"

"មនុស្សឆ្កួត មនុស្សមុខក្រាស់ និយាយបែបនេះ មិនចេះខ្មាសគេ ខ្ញុំទេដែលត្រូវខូចខាត ត្រូវទាមទារពីលោក មិនមែនលោកមកទាមទារពីខ្ញុំ ហើយខ្ញុំក៏មិនបង់ឲ្យដែរ ខ្ញុំមិនដឹងថាបានធ្វើមែនឬអត់ផង"

ស៊ុនស៊ូ សម្លក់សម្លឹងគេដោយការជិនឆ្អន់ចំពោះកាយវិការមានប្រៀបនិងក្អេងក្អាងរបស់បុរសនៅចំពោះមុខ។

"នេះអី ស្នាមដែលនាងក្រញៅខ្ញុំ ស្នាមខាំស្នា ត្រង់មាត់នេះ ហើយចង់ប្រាប់ថាមិនមែនម៉េចបាន កុំម៉ោធ្វើពុតជាមិនចង់ប៉ះពាល់ខ្លួន ស៊ុនស៊ូ ខ្ញុំដឹងថានាងចង់ធ្វើជាសមាជិក ឈើរសេទិ ម៉ែមិនបាន កូនបានក៏ល្អ បែបនេះហ្នឹងអី"

គេបង្ហាញស្លាកស្នាមដែលនាងបន្សល់ទុកលើខ្លួនប្រាណរបស់គេ និងមិនភ្លេចធ្វើជានិយាយឲ្យនាងឈឺ។

"ខ្ញុំមិនជឿ លោកអាចធ្វើដោយខ្លួនឯងក៏ថាបាន លោកកុហក ហើយខ្ញុំក៏មិនបានចង់ធ្វើជាសមាជិក ឈើរសេទិ ដែរ"

"ខ្ញុំមិនព្រម នាងត្រូវទទួលខុសត្រូវ"

"ខ្ញុំក៏មិនព្រម វាជាបញ្ហារបស់លោក ខ្ញុំមិនដឹង"

នាងធ្វើឆើយដាក់ មិនចង់មើលមុខចំ ប្រុសអីមុខក្រាស់ជាងដែកថែប





Scanned with CamScanner

មានពិអង្គាល់ មកទាមទារឲ្យមនុស្សស្រីទទួលខុសត្រូវ។

"និយាយបែបនេះ មិនបាច់ចុះពីគ្រែទេដឹង"

"លោកចង់ធ្វើអី!"

នាងងាកមកវិញចង់បាក់ក មើលគេទាំងបុកពោះ។

"មិនទទួលខុសត្រូវ អីចឹងខ្ញុំសុំរបស់ហ្វ្រីៗ ច្រើនដងទៅចុះ"

សំឡេងរបស់គេព្ញស្អកៗ ធ្វើនាងព្រឺសម្បុរខ្លាកៗ។

"កុំ អាមនុស្សឆ្កួត កុំធ្វើអីខ្ញុំ"

នាងអូសគូទថយក្រោយភ្លាម ពេលគេដាក់បង្អួយនៅគែមគ្រែ និងមើលមកដោយខ្សែភ្នែកកាច។

"បើមិនឲ្យធ្វើ អីចឹងទទួលខុសត្រូវម៉ោ"

"ខ្ញុំ...ខ្ញុំគ្មានលុយច្រើនយ៉ាងហ្នឹងទេ"

"គ្មានលុយហើយចង់យ៉ាងម៉េច អីចឹងបែបនេះទៅចុះ នាងត្រូវធ្វើការឲ្យខ្ញុំនៅទីនេះប្រាំឆ្នាំ ហាមទៅធ្វើការកន្លែងផ្សេងដាច់ខាត ទាល់តែខ្ញុំលុបចោលកិច្ចសន្យា ហាមល្មើសបញ្ជា ឬធ្វើអីដែលធ្វើឲ្យចម្ការខ្ញុំខូចខាត មិនអីចឹងនាងត្រូវមិនខាន ចាំកាត់ប្រាក់ខែ ដោះបំណុល សម្រេចតាមនេះ"

គេញញឹមចុងមាត់ ងើបឈរ ទាញទូរសព្ទមកថតរូបរបស់នាងពីរបីប៉ុស្តិ៍សេវទុក ដាក់លេខសម្ងាត់ត្រឹមត្រូវ ទោះវាមិនមែនជារូបអាក្រក់មើល តែគេមិនចង់ឲ្យអ្នកណា ក្រៅពីគេឃើញ។

"លោកធ្វើអី?"

នាងស្រៀវក្នុងទ្រូង តែគេញាក់ស្មាដាក់។

"បើសងលុយគ្រប់ហើយ ចាំខ្ញុំលុបរូបនេះឲ្យ"

គេដាក់ទូរសព្ទចូលហោប៉ៅខោ។

"លោកចង់គំរាមខ្ញុំ?"

"ទុកវា បង្ការនាងរត់"

"អាមនុស្សកំណាច"

នាងក្តាប់មាត់ដាក់ សម្លឹងគេចង់លៀនគ្រាប់ភ្នែកទៅហើយ តែគេមិនញញើត។

"ឆាប់តែងខ្លួនទៅ តិចទៅញ៉ាំបាយល្ងាចមិនទាន់ ក្រទៅ តិចត្រូវចាប់ពិរុទ្ធបាន ថានាំគ្នាទៅធ្វើអី ឬនាងប្តូរចិត្តសងជាស្អីផ្សេងក៏បាន ខ្ញុំមិនថា ខោអាវរបស់នាង ខ្ញុំដាក់ព្យួរ កុំឲ្យវាទក់ អាវក្នុងខោក្នុងនៅបន្ទប់តែងខ្លួន"

គេញញឹមមានប្រៀបដាក់ ពេលដេញនាងឲ្យទៅតែងខ្លួន ន្ទាលនាំទៅផ្ទះធំវិញ ព្រោះបើនៅនិយាយគ្នាយូរជាងនេះ គេខ្លាចខ្លួនឯងទប់ចិត្តមិនបាន ហក់សង្គ្រុបអ្នកអង្គុយសម្លក់សម្លឹងគេនៅលើគ្រែ ស៊ីជំនួសបាយល្ងាច។

ស៊ុនស៊ូ ឱបក្ងួយ ស្ទុះចុះពីគ្រែ ចូលបន្ទប់តែងខ្លួនភ្លាម ពេលឮសម្តីរបស់គេ ប្រញាប់ប្រញាល់តែងខ្លួន ដោយមិនបានពិនិត្យខ្លួនប្រាណច្រើន ថាមានស្នាមត្រង់ណាខ្លះទៀត ក្រៅពីដើមទ្រូង ដែលមានកន្ទួលក្រហម ហើយចេញ

Scanned with CamScanner

មកវិញ ពេលតែងខ្លួនរួច។

"រួចរាល់ហើយ តោះ អ៊ុំ! ខ្ញុំឲ្យគេប្រាប់ថាមកជាមួយនាង រកឯកសារឲ្យ ភ្ញៀវ ក្រែងលមានអ្នកសួរ ថាទៅណា ឲ្យឆ្លើយត្រូវគ្នា តែបើមិនខ្លាចអ្នកណាដឹងការពិត ក៏ប្រាប់ទៅថាត្រូវអូសឡើងឡាន ឲ្យគេល្បីកក្រើកពេញស្រុកភូមិ ថានាងត្រូវ សាន ដុងវ៉ុក បៀតបៀន"

ពេលនិយាយរួច ដែលម្តងនេះគ្មានការលេងសើច គេក៏ដើរចេញទៅមុន ទើបនាងដើរតាមពីក្រោយ ចេញមកមុខផ្ទះ ឃើញគេទៅយកម៉ូតូធំចេញពីរោងឡាន មកដល់ក៏ហុចមួកការពារឲ្យ និងបួញមាត់ឲ្យឡើង។

"ឡានក៏មាន ម៉េចយើងជិះអានេះ"

នាងដកដង្ហើមធំ ព្រម់យកមួកមកពាក់ ឡើងអង្គុយ ហើយឱបចង្កេះគេជាប់ ពេល កាណែត បន្ថែមល្បឿនជាការញ៉ោះ។

អ្នកកំលោះញញឹមពព្រាយ តែនាងមិនឃើញ ព្រោះរវល់តែខ្លាច និងមកដល់ផ្ទះធំដោយសុវត្ថិភាព។

នាងប្រញាប់ដោះមួកហុចឲ្យគេ ហើយម្នីម្នាដើរចូលទៅក្នុងផ្ទះ ដែលពេលនេះមិនទាន់មានអ្នកណាមកដល់ ទើបទៅឡើងទៅងូតទឹក តែពេលល្ងាចមានរឿងធំកើតឡើងចំពោះ អាជ្រេ យ៉ារីម និងស្រីម្នាក់ទៀតឈ្មោះ យូណា ឮថាជាបងស្រីម្តាយទីទៃរបស់ យ៉ារីម ដែលធ្វើឲ្យនាងអត់អាណិត យ៉ារីម មិនបានដែលគិតតែឈ្ងោកមុខ លាក់ទឹកភ្នែក មិនហ៊ានមាត់ក ដោយនាង ឬម្តាយមីង

ព្រមទាំងអ្នកឯទៀត មិនអាចជួយអ្វីបាន។



# ៨

ច្រើនថ្ងៃក្រោយមក

"ល្អហើយ ថ្ងៃនេះមិនបាច់ទៅធ្វើការទេ ចូលក្រុង ទៅរក ខុងជូ ល្អជាង"

បន្ទាប់ពីអាហារពេលព្រឹកជុំគ្នាហើយគ្រប់គ្នាក៏ទៅធ្វើការរៀងខ្លួន។ នាង ឃើញឡានរបស់លោក អាហ្សា ចេញទៅបានមួយសន្ទុះហើយ ប្រហែល អាជ្រេ ជាអ្នកជូនទៅអាកាសយានដ្ឋាន ចំណែក យ៉ារីម មិនបានទៅជាមួយ ព្រោះឡើងបន្ទប់ដេកដំណាលនាងនេះឯង។

នាងស្ទុះងើបពីគ្រែមកតែងខ្លួន ន្ទាលបានចូលក្រុង ខ្លាចថ្ងៃត្រង់ទាន់ តែ គិតថាទៅមួយភ្លែតប៉ុណ្ណោះ ដោយយកម៉ូតូកញ្ចាស់ជិះទៅមុខចម្ការ ហើយចាំ ឡើងឡានក្រុង។

ពេលពិនិត្យខ្លួនឯងនៅក្នុងកញ្ចក់រួចរាល់ ឃើញថាពេញចិត្តហើយ ក៏ចុះ មកខាងក្រោម រកមើលថាមានអ្នកណានៅផ្ទះខ្លះ តែមិនឃើញ ទើបដើរចេញ មកខាងក្រៅ ហើយឃើញ យ៉ារីម អង្គុយសោកសៅនៅត្រង់នោះ។

"អាំ! អ្នកស្រី ម៉ា មិនបានទៅជាមួយលោក អាជ្រេ ទេឬ?"

ស៊ុនស៊ូ ទប់ដំណើរ ហើយងាកមកញញឹម សួរនាំអ្នកដែលអង្គុយលេង



ម្នាក់ឯង ដោយព្យាយាមនិយាយដោយទឹកមុខ សម្ដីរីករាយ ព្រោះឃើញអ្នក នៅចំពោះមុខសោកសៅគួរសម។

"មិនបានទៅទេ ជូនអីមិនសូវស្រួលខ្លួន ទើបតែជួរ ក៏ចុះមកខាងក្រោម នេះឯង"

"អ៊ីចឹងចូលក្នុងក្រុងទេ ជូនអីខ្ញុំណាត់មិត្តភក្តិទៅទិញអីវ៉ាន់បន្តិច សុទ្ធតែ របស់ស្អាតៗ ច្រើនណាស់"

ពេលឃើញមុខសោកសៅរបស់ យ៉ារីម ហើយ ស៊ុនស៊ូ ក៏អាណិត ទើប ចង់បបួលទៅបើកភ្នែកបើកត្រចៀកនៅខាងក្រៅជាមួយខ្លួន ព្រោះនាងទើបតែ ដឹងរឿងទាំងអស់ ស៊ូអា ជាអ្នកខ្សឹបប្រាប់ ដើម្បីឲ្យនាងមកបបួលនិយាយលេង ព្រោះម្ដាយមីងពេលនេះមានទាំងកូនប្រុសតូច មានទាំងស្វាមីតោងស្អិត។

"ល្អដែរ" យ៉ារីម ញញឹម។

"តោះ ខ្លាចមិនទាន់ឡាន"

ស៊ុនស៊ូ ញញឹមពព្រាយ ព្រមទាំងដុកឲ្យឆាប់ចេញដំណើរ ដោយឡើង ម៉ូតូកញ្ចាស់មកជាមួយ ដោយទុកនៅមាត់ផ្លូវចូលចម្ការ ផ្ញើនឹងបញ្ជរសន្តិសុខ ហើយនាំគ្នាឡើងឡានក្រុង។

"អ្នកស្រី ម៉ា អឺ...តើខ្ញុំសុំសួរអីបានទេ តែបើអ្នកស្រីមិនឆ្លើយក៏បានដែរ"

ស៊ុនស៊ូ ញញឹមដាក់ ហើយសួរនាំជាការស្ទាបស្ទង់ ព្រោះមិនច្បាស់ទេ ថាសួរបានឬអត់ តែម្ដាយមីងប្រាប់ឲ្យមកសួរ ព្រោះសង្ស័យរឿងខ្លះ ដោយសារ



Scanned with CamScanner

លួចសង្កេតមួយរយៈហើយ។

"ចាំ បាន"

"អ្នកស្រីមានផ្ទៃពោះមែនទេ ?"

ស៊ុនស៊ូ ខ្ទឹបមាត់បន្តិច ហើយសួរទាំងក្រែងរអែងចិត្ត និងឃើញទឹកមុខរបស់ យ៉ារីម ហើយក៏អាណិត ដូចពេលម្ដាយមីងរបស់នាង ពេលនាំ សួម ដែលទើបកើតថ្មីៗ ទៅរកនាងនៅសេអ៊ូល ឃើញហើយក៏ខ្លោចចិត្ត។

"ខ្ញុំ..."

យ៉ារីម និយាយមិនចេញ តែលើកដៃប៉ះពោះរាបស្មើរបស់ខ្លួនឯង ហើយយំហ៊ឺ ធ្វើឲ្យអ្នកសួរភ្ញាក់ព្រើត ប្រញាប់ស្រវាចាប់ដៃ ប្របាច់តិចៗ លួងលោម។

"សម្រួលអារម្មណ៍ កុំយំអី គ្មានអីទេ"

នាងប្រញាប់លួងលោម អណ្ដាតចង់ព័ន្ធគ្នាទៅហើយ ព្រោះមិនស្មានថា យ៉ារីម យំបែបនេះទេ ប្រហែលប្រឹងអត់យូរហើយមើលទៅ។ បើនាងវិញយំតាំងពីដំបូងម្ល៉េះ មិនទុកយូរយ៉ាងនេះទេ នេះចាត់ទុកថា យ៉ារីម ពូកែហើយ អាចទ្រាំបានយូរយ៉ាងនេះ។

"អ្នកនាងនាំខ្ញុំចេញពីទីនេះបានទេ សូមអង្វរ ជួយនាំខ្ញុំចេញពីទីនេះ ខ្ញុំដឹងថាអ្នកនាងដឹងរឿងរបស់ខ្ញុំ"

យ៉ារីម លោមុខមកនិយាយទាំងទឹកភ្នែក ចាប់ដៃនាងអង្រួន សុំក្ដីមេត្តា។

"អ្នកស្រី!"

ស៊ុនស៊ូ ចងចិញ្ចើមហៅអ្នកនៅចំពោះមុខ ដែលចាប់ដៃខ្លួន យំយែក។

"សូមអង្វរ ខ្ញុំខ្លាច ខ្លាចថាពេលសម្រាលកូនរួច លោក អាជ្រេ បណ្ដេញខ្ញុំចេញ ខ្ញុំមិនចង់បានបែបហ្នឹងទេ ហ៊ឺៗ"

នាងនិយាយដោយសំឡេងញ័រៗ ទឹកភ្នែកហូររហាម។

"ខ្ញុំ..."

ស៊ុនស៊ូ និយាយមិនចេញ ព្រោះនាងក៏ខ្លាចដែរ បើនាំ យ៉ារីម រត់ ហើយអាជ្រេ ចាប់បាន ធានាថាអត់ដីកប់។

"សុំអង្វរ ឲ្យខ្ញុំក្រាបសំពះក៏បាន"

"មិនបាច់ទេៗ អឺ...ខ្ញុំសុំពិភាក្សាមីងសិន បានទេ"

"កុំអី ខ្ញុំខ្លាចលោក អាជ្រេ ដឹងហើយទៅតាម"

នាងហាមប្រាម ព្រោះខ្លាច បើ ស៊ូអា ដឹងរឿងនេះ អេដែន ក៏ត្រូវតែដឹងដល់ពេលនោះ នាងអាចរត់ទៅណាផុតទេ។

"មិនបាច់ខ្លាចទេ រឿងដែលខ្ញុំសួរអ្នកស្រី គឺមីងឲ្យមកសួរ"

"អីចឹងក៏បាន តែអ្នកនាងត្រូវជួយខ្ញុំណា៎"

ស៊ុនស៊ូ ងក់ក្បាល ហើយតេរទៅសួរម្ដាយមីងថាគួរធ្វើយ៉ាងណា ហើយពេលបានចម្លើយ ទើបនាំ យ៉ារីម ឡើងឡានចេញពីចម្ការ។



"ខុងជូ ឯងនៅឯណាពេលនេះ អ៊ុំ! ចេញម៉ោរកខ្ញុំបន្តិចបានទេ ពេលនេះ

Scanned with CamScanner

មានរឿងឲ្យជួយបន្តិច ខ្ញុំនៅហាងអាយស្ក្រីមនៅផ្សារ ហាងចាស់ ឆាប់ម៉ោៗ"

ពេលមកដល់ក្នុងក្រុង ញ៉ាំបាយរួចរាល់ នាំ យ៉ារីម មកអង្គុយនៅហាងអាយស្ក្រីមហើយ ស៊ុនស៊ូ ក៏តេររកមិត្តជិតស្និទ្ធ ដោយដុកឲ្យឆាប់មក ព្រោះខ្លាចមានអ្នកណាឃើញ ហើយមួយសន្ទុះក្រោយមកមិត្តភក្តិក៏មកដល់។

"ម៉ោហើយៗ"

ខុងជូ ដើរមករក ហើយពេលដាក់បង្អួយចុះ ក៏មើលមនុស្សស្រីដែលអង្គុយក្បែរមិត្តភក្តិ។

"នេះអ្នកស្រី ម៉ា ជាភរិយារបស់លោក អាជ្រេ...អ្នកស្រី ម៉ា នេះមិត្តរបស់ខ្ញុំ គីម ខុងជូ ជាអ្នកជួយអ្នកស្រី"

"រីករាយដែលបានស្គាល់ អ្នកនាង គីម"

"រីករាយដែលបានស្គាល់ដូចគ្នា អ្នកស្រី ម៉ា ហើយមានរឿងអី ដែលឲ្យមកជួយ កាំង ស៊ុនស៊ូ សុំច្បាប់កន្លះថ្ងៃនេះ"

ខុងជូ ញញឹមដាក់ យ៉ារីម ហើយងាកទៅសួរមិត្តរបស់ខ្លួន។

"មានរឿងសុំពឹងឲ្យធ្វើ និងមហាអាថ៌កំបាំង មីង ស៊ូអា សុំជាពិសេស"

ស៊ុនស៊ូ លោមុខទៅជិត លើកដៃក្តោបមាត់ ខ្សឹបខ្សៀវប្រាប់ ព្រោះខ្លាចអ្នកដទៃឮ ទាំងដែលត្រង់នេះនៅឆ្ងាយពីឯងគួរសម។

"បានៗ រឿងអី និយាយម៉ោ"

"ឱនឲ្យជិតៗម៉ោ"

បន្ទាប់ពីបានស្តាប់រឿងមហាអាថ៌កំបាំងហើយ ខុងជូ ក៏បើកភ្នែកធំៗ វិះភ្លាត់មាត់ស្រែកចាចទៅហើយ ចេះខ្ទប់មាត់ទាន់ ទឹកមុខក៏ស្លេកស្លាំង តែក៏មើលមុខ យ៉ារីម ដោយក្តីអាណិត។

"ធ្វើមែនទែនឬ ហើយលោក អី...មិនទៅឡូឡានៅផ្ទះខ្ញុំទេអី?"

"មីងជាអ្នកចេញមុខ កុំបារម្ភអី រឿងនេះមិនធ្វើឲ្យឯង និងម៉ាក់មានបញ្ហាទេ តែមិនចង់ឲ្យអ្នកមានពោះមានពុងទៅនៅកន្លែងផ្សេង ហោចណាស់ក៏មានអ្នកជួយមើលថែ"

"សុំទោសផង ដែលរំខានអ្នកនាង គីម"

"មិនអីទេ អ្នកស្រី ម៉ា អូខេ ខ្ញុំយល់ព្រម តែទៅថ្ងៃនេះ ឬថ្ងៃផ្សេង?"

"ថ្ងៃនេះតែម្តង ថ្ងៃផ្សេងម៉េចមានឱកាសទៅ"

"អីចឹងក៏បាន ភ័យដល់ហើយ"

ខុងជូ លើកដៃស្ទាបទ្រូង និយាយដោយទឹកមុខផ្អើលៗ។

"ពេលញ៉ាំអីរួចហើយ ឯងនាំអ្នកស្រី ម៉ា ទៅចុះ ឲ្យឡានមកយកនៅក្រោយផ្សារក៏បាន ត្រង់បន្ទប់ទឹក ខ្ញុំធ្វើជាចូលបន្ទប់ទឹក ហើយអ្នកស្រី ម៉ា ដើរចេញតាមនោះ ត្រង់នោះគ្មានកាមេរ៉ាសុវត្ថិភាពទេ ខ្ញុំពិនិត្យហើយ"

"អូខេ បាន"

ខុងជូ ងក់ក្បាល ហើយពួកនាងក៏អង្គុយញ៉ាំនេះញ៉ាំនោះមួយសន្ទុះទើប ខុងជូ ដើរចេញពីហាងមុន ធ្វើជាសុំលា បន្ទាប់មកតេរប្រាប់ ស៊ុនស៊ូ និង

Scanned with CamScanner

យ៉រិម ក៏ដើរទៅក្រោយផ្សារ។

"អរគុណច្រើន អ្នកនាង កាំង ផ្តាំអរគុណអ្នកស្រី កាំង ផង"

យ៉រិម និយាយដោយសំឡេងញ័រៗ ភ្នែកក៏ក្រហម មិនស្មានទេថាមានអ្នកជួយខ្លួនច្រើនយ៉ាងនេះសោះ។

"កុំយំ តិចមានគេសង្ស័យ នុ៎ះ ខុងជូ នៅមាត់ថ្នល់ ពេលខ្ញុំចូលបន្ទប់ទឹកហើយ អ្នកស្រីដើរចេញទៅចុះ ហាមងាកក្រោយ ក្រែងម្តុំនេះមានកាមេរ៉ា ហើយចាំខ្ញុំលួចទៅរកអ្នកស្រីនៅផ្ទះរបស់ ខុងជូ"

ស៊ុនស៊ូ ធ្វើជាបំបែកថង់អីវ៉ាន់មួយចំនួនឲ្យ យ៉រិម កាន់ ខណៈនោះក៏និយាយខ្សឹបៗ ព្រោះខ្លាចអ្នកដទៃបានឮ ហើយងើបមុខមកញញឹមដាក់ជាការលើកទឹកចិត្ត បន្ទាប់មកក៏បែរក្រោយ ដើរចូលបន្ទប់ទឹក ចំណែក យ៉រិម បែរខ្នងដើរចេញពីត្រង់នោះ ទៅរក ខុងជូ ដែលកំពុងឈរចាំ។

ពេលចូលមកក្នុងបន្ទប់ទឹកហើយ ស៊ុនស៊ូ ក៏ព្រួសខ្យល់ដង្ហើមតាមមាត់សម្រួលអារម្មណ៍ ធ្វើខ្លួនឲ្យធម្មតា ទាំងដែលពេលនេះខ្លួនញ័រអស់ទៅហើយ និងរង់ចាំជាងដប់នាទី ទើបដើរចេញមកវិញ ធ្វើជាតាមរក សួរអ្នកលក់នៅម្តុំៗនោះ បន្ទាប់មកក៏ដើរមករកកន្លែងដែលមានកាមេរ៉ាសុវត្ថិភាព ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនមួយភ្លែត ទើបដើរទៅអង្គុយនៅសួនសាធារណៈ តេរទៅម្តាយម៉ែង។

"រួចរាល់ហើយ ហើយចាំមួយសន្ទុះទៀត ចាំប្តឹងប៉ូលិស ខ្ញុំខ្លាចដល់



ហើយ មឹង មិនដែលខ្លាចអីក៏ខ្លាចបែបនេះទេ"

(មិនបាច់ខ្លាចទេ ធ្វើរួចហើយគឺត្រូវតែធ្វើឲ្យដល់ទីបំផុត យ៉ាងណានៅផ្ទះមិត្តរបស់ឯង មឹងមិនសូវបារម្ភ ធ្វើតាមផែនការ ពេលប្តឹងប៉ូលិសរួចហើយតេរទៅលោក អាជ្រៃ ចាំមឹងឲ្យលេខ នេះលួចម៉ោតេរក្នុងបន្ទប់ទឹកទេ ពូថ្លៃនាំសួម ទៅងូតទឹក ប៉ុណ្ណឹងសិនចុះ តិចគេសង្ស័យ)

"ចាំ"

នាងដាក់ទូរសព្ទចូលកាបូប ដកដង្ហើមចូលឲ្យជ្រៅៗ អង្គុយមួយសន្ទុះទើបហៅតាក់ស៊ី ទៅប៉ុស្តិ៍ប៉ូលិស ដើម្បីដាក់ពាក្យបណ្តឹង ដៃជើងញ័រអស់ទៅហើយពេលត្រូវធ្វើរឿងកុហក បានតែបន់ស្រន់ កុំឲ្យមានអ្នកណាចាប់បាន មិនអីចឹងច្បាស់ជាស្លាប់មិនខាន។

នាងក្តាប់សំណៅពាក្យបណ្តឹងណែនដៃ ពេលឡើងឡានមកផ្ទះជំរិញពេលជិតដល់ ទឹកភ្នែកក៏ហូរច្រោកៗ វាកើតឡើងដោយអារម្មណ៍ពិតប្រាកដមិនបានធ្វើពុត ការភ័យខ្លាចកំពុងធ្វើទុក្ខ ហើយពេលទុកម៉ូតូកញ្ចាស់នៅមុខផ្ទះហើយក៏រត់ចូលមកខាងក្នុងទាំងទឹកភ្នែក ធ្វើឲ្យពូថ្លៃ និងម្តាយមឹងដែលបី សួមមើលមកដោយការភ្ញាក់ផ្អើល។

"កើតអី ស៊ុនស៊ូ?"

ស៊ូអា ក៏ភ្ញាក់ផ្អើលដែរ មិនស្មានថាក្មួយស្រីមានអាការៈធ្ងន់ធ្ងរយ៉ាងនេះ ទាំងដែលដាក់ម៉ូត្សារួចហើយ ខ្លួនឡើងញ័រទទ្រើតតែម្តង ពេលដើរមកឱប។



Scanned with CamScanner

"ហ៊ិ្វ មិង"

"អ៊ុននិម អ៊ុននិម យក ស្វម ទៅមើលសិន ខ្ញុំមានការ"

អេដែន ស្រែកហៅអ្នកបម្រើឲ្យមកយកកូនរបស់ខ្លួន ព្រោះមើលទៅដូចមិនធម្មតា ក្មួយប្រសាយំយែកបែបនេះ ច្បាស់ជាមានរឿងធំហើយ ហើយពេលឲ្យកូនប្រុសទៅ អ៊ុននិម រួចរាល់ ទើបដើរមករកពីរនាក់មីងក្មួយ។

"ទៅបន្ទប់អង្គុយលេងសិនទៅ"

អេដែន ឱបស្មាភរិយា និងក្មួយស្រីចូលបន្ទប់អង្គុយលេង។

"មានរឿងអី និយាយឲ្យពូស្ដាប់ឲ្យអស់ម៉ោ ស៊ុនស៊ូ"

"ខ្ញុំ...ខ្ញុំបបួលអ្នកស្រី...ម៉ា ចូលក្រុង ឃើញនាងស្រពោនៗ នាំទៅញ៉ាំបាយ ទិញអីវ៉ាន់ ហើយខ្ញុំសុំចូលបន្ទប់ទឹក ឲ្យនាងចាំនៅខាងក្រៅ ពេលខ្ញុំចេញមកវិញ ក៏មិនឃើញនាងនៅចាំត្រង់នោះទៅហើយ ហ៊ឺៗ នាងបាត់ខ្លួន ខ្ញុំរកនាងមិនឃើញទេ សួរអ្នកនៅម្តុំនោះ ក៏គ្មានអ្នកណាឃើញដែរ ពូថ្លៃ ខ្ញុំធ្វើម៉េចទៅ ហ៊ឺៗ"

"យ៉ាមែ បាត់ខ្លួន រឿងធំហើយៗ អាជ្រេ នឹងថាម៉េចនេះ ឬប៉ាធ្វើរឿងនេះទៀតហើយ ដូចកាលអូននិងបង ប្រពន្ធសម្លាញ់"

អេដែន លើកដៃក្ដោបក្បាល និយាយដាក់ភរិយាដោយសំឡេងខ្សាវៗ។

"អូនមិនច្បាស់ទេ តែកាលពីព្រឹកលោកប៉ា ទើបតែទៅផ្ទះ គាត់ធ្វើឬ?"

"ថាមិនត្រូវដែរ ហើយ ស៊ុនស៊ូ រកសព្វហើយមែនទេ ថាមិនឃើញមែនមិនមែនវង្វេងគ្នា?"

"ច្បាស់ហើយ ខ្ញុំតាមរកច្រើនសាហើយ ទៅឈរកន្លែងចាស់ក៏មិនឃើញ ទើបខ្ញុំទៅប្ដឹងប៉ូលិស និងមករកនៅផ្សារម្ដងទៀត តែមិនឃើញ ទើបម៉ោផ្ទះ"

"ឆ្កួតមែន អីចឹងចុះ តេរទៅ អាជ្រេ សិន"

អេដែន មានទឹកមុខតានតឹងមួយរំពេច ទាញទូរសព្ទ តេរទៅប្អូនប្រុស ពេល អេដែន លើកហើយ ទើបហុចឲ្យក្មួយប្រសានិយាយទាំងទឹកភ្នែក រៀបរាប់តាមលំដាប់ហេតុការណ៍។

**បួនខែក្រោយមក...**

"ទៅណា ស៊ុនស៊ូ?"

កាណែត ដែលឈរឱបដៃ ផ្អែកនឹងឡានរបស់ខ្លួន ស្រែកសួរអ្នកដែលធ្វើឫកប្លែកៗ ដូចមានអាថ៌កំបាំង ងាកឆ្វេងងាកស្ដាំ ដើរចេញពីការិយាល័យហាក់ដូចខ្លាចមានអ្នកណាមកតាម ហើយមួយរយៈនេះគេសង្កេតឃើញថានាងមានអាការៈបែបនេះញឹកញាប់។

"ខ្ញុំមានការរវល់ ជូនអីមិត្តភក្ដិខ្ញុំ គេមកពី សេអ៊ូល មកលេងផ្ទះ ទើបខ្ញុំគិតថាទៅលេងបន្តិច"

ស៊ុនស៊ូ ភ្ញាក់ព្រើត ព្រិចភ្នែកញាប់ស្អេក ហើយដកដង្ហើមចូលឲ្យពេញពោះ ធ្វើឫកធ្វើពាធម្មតា មិនឲ្យគេសង្ស័យ តែពេលនិយាយលួចខ្វែងម្រាមដៃពីរ

Scanned with CamScanner

នៅក្រោយខ្នង។

"នៅឯណា ?"

កាណែត ដើរទៅរក ព្រមទាំងសម្លឹងមុខនាងមិនដាក់ភ្នែក ដែលត្រឹមប៉ុណ្ណឹងក៏ធ្វើឲ្យអ្នកដែលត្រូវសម្លឹងញ័រខ្លួនទៅហើយ។

"ជិតៗនេះឯង"

នាងប្រឹងលេបទឹកមាត់ ងើយមុខមកប្រសព្វភ្នែកជាមួយគេ ប៉ុន្តែក្លាហានបានតែមួយភ្លែតក៏ប្រញាប់ឈ្ងោកមុខឈ្ងោកមាត់ព្រោះខ្លាចគេចាប់បានថានាងកំពុងកុហក។

"អ្ហឹម! ចាំជូនទៅ"

គេជ្រឹមភ្នែក លួចពិនិត្យអាកប្បកិរិយារបស់នាងដោយការចាប់កំហុស។

"មិនបាច់ទេ ខ្ញុំទៅដោយខ្លួនឯងបាន"

នាងបដិសេធលឿនដូចព្យុះ ចង់ជាប់អណ្ដាតទៅហើយ ញើសគ្រាប់តូចៗផុសពេញថ្ងាស ដៃជើងក៏ត្រជាក់ស្រេង។

"ខ្ញុំប្រាប់ថាជូនទៅ បើនាងរឿងច្រើន អីចឹងមិនបាច់ទៅណាទេ"

គេញញឹមបុងមាត់ តែជាស្នាមញញឹមគួរឲ្យខ្លាចនិងមើលនាងមិនដាក់ភ្នែក ថែមទាំងលើកដៃឱបទ្រូង លើកចិញ្ចើមដាក់ដោយកាយវិការបេះបួយទៀតផង។

"លោក កាណែត!"

នាងហៅឈ្មោះគេដោយការមិនពេញចិត្ត ថែមទាំងខាំមាត់ សម្លក់សម្លឹងទៀតផង។

"ទៅឬមិនទៅ"

គេញាក់ស្មាបន្តិច ធ្វើជាមិនចាប់អារម្មណ៍ ជាការបង្គាប់បង្ខំដោយប្រយោល ដើម្បីឲ្យនាងធ្វើតាមបញ្ជា។

"ទៅក៏បាន"

នាងធ្វើងឺះ និងធ្វើមាត់ស្រួចដាក់ ថែមទាំងលួចសម្លក់សម្លឹងទៀត។

"ដើរតាមមក"

គេប្រាប់ ហើយដើរនាំមុខចេញទៅ ទើបនាងប្រញាប់ទាញទូរសព្ទមកចុច ទៅរកគោលដៅ។

"ខុងជូ បន្តិចទៀតខ្ញុំទៅចាំឯងនៅឯផ្ទះ ឆាប់មក អូ៎! មានអ្នកជូនខ្ញុំទៅលោក កាណែត កុំបារម្ភអី ឯងឆាប់មក តិចមេឃងងឹត បានៗ ប៉ុណ្ណឹងចុះ"

កាណែត ឈរប្រចត់ចង្កេះមើលមកមិនដាក់ភ្នែក ដែលខ្សែភ្នែករបស់គេនាងមើលមិនដឹងទេថាគេកំពុងគិតអី ប៉ុន្តែពេលនេះធ្វើឫកហំពើងទ្រូងដាក់សិនចុះ។

"ចៀសចេញខ្ញុំឡើងឡាន លោកចង់ជូនទៅក៏ឆាប់ជូនបន្តិចទៅ"

នាងដាក់ទូរសព្ទក្នុងហោប៉ៅខោ លេបទឹកមាត់ក្អឹកៗ ធ្វើឫកខ្លាំង ទាំងដែលមិនហ៊ានមើលមុខគេចំ បេះដូងក៏លោតញាប់ពេលដែលបើកទ្វារឡាន។

Scanned with CamScanner

"ទៅត្រង់ណា ប្រាប់មក"

កាណែត ងក់ក្បាល មិននិយាយអីច្រើន ដើរឡើងទៅខាងអ្នកបើកបញ្ចេះឡាន បញ្ចាចេញពីចម្ការតែ ពេលមកដល់មុខចម្ការទើបចត ហើយងាកទៅសួរអ្នកនៅក្បែរ ដែលធ្វើមុខផ្អើលៗ។

"ទៅខាងណា ឆ្វេងឬស្តាំ ?"

"ឆ្វេង"

ស៊ុនស៊ូ ដកដង្ហើមចូលឲ្យពេញសួត ហើយប្រាប់ទិសដៅដែលត្រូវទៅដល់អ្នកបើកបរ ដែលមើលទៅចិត្តត្រជាក់ដាក់នាងប្លែកៗ រហូតមកដល់ផ្ទះជំនំមួយ នៅក្នុងចម្ការប៉ោម ដែលពេលនេះស្ត្រីវ័យប្រហែលហាទៅហុកសិបឆ្នាំកំពុងតែវាសស្មីក៏មិនដឹងដែលត្រូវដាក់ហាល គិតថាគួរតែជាប៉ោមក្រៀម។

"ផ្ទះនេះហើយ អរគុណច្រើនដែលជូនមក"

នាងប្រាប់ឲ្យគេចតឡាន ហើយដោះខ្សែក្រវាត់ប្រុងចុះ ប៉ុន្តែត្រូវគេឃាត់ដោយសំណួរ។

"ឲ្យខ្ញុំមកយកទេ ?"

"មិនបាច់ទេ ចាំខ្ញុំទៅវិញខ្លួនឯង"

នាងគ្រវីក្បាល ហើយបុញមាត់ទៅចំណតឡានក្រុងដែលនៅមិនឆ្ងាយប៉ុន្មាន ម្តុំនេះមានផ្ទះច្រើន ប៉ុន្តែនៅឆ្ងាយពីគ្នា មិនស្ងាត់ គ្មានអ្វីគួរឲ្យខ្លាច។

"អ្ហឹម"

គេងក់ក្បាលដោយទឹកមុខស្មើ និងសម្លឹងមើលទៅក្នុងផ្ទះ ឃើញនាងដើរទៅរាក់ទាក់អ៊ំស្រីម្នាក់ ទើបគេបើកឡានចេញទៅ តែមិនប្រញាប់ប្រញាល់ប៉ុន្មាន ហើយពេលបើកបានឆ្ងាយបន្តិច ទើបបន្ថយល្បឿន ទាញទូរសព្ទ តេរទៅបងប្រុសកណ្តាលភ្លាម។

"បងប្រុស ឆាប់ម៉ោរកខ្ញុំជាបន្ទាន់ បើចង់ជួបប្រពន្ធរបស់បង ខ្ញុំចតឡានចាំនៅតាមផ្លូវ បើកឡានចេញពីចម្ការរបស់យើង ហើយបត់ឆ្វេង រួចជិះត្រង់ម៉ោដល់ផ្លូវបំបែក ត្រូវបត់ម៉ោស្តាំ និងបើកត្រង់ទៀត មិនឆ្ងាយទេនឹងឃើញឡានខ្ញុំហើយ ម៉ោដល់សិនម៉ោ ចាំប្រាប់ថាធ្វើយ៉ាងម៉េច នាំ ជេមិន ម៉ោផងក៏បាន ក្រែងត្រូវឲ្យគេបើកឡានឲ្យ រង់ចាំឱកាសសិន កុំអាលឆេវឆាវ បងមកឃ្លាំមើលសិន ព្រោះ ស៊ុនស៊ូ ប្រយ័ត្នខ្លួនណាស់"

កាណែត រៀបរាប់តាមទូរសព្ទ ពេលច្បាស់ហើយថា យ៉ារីម ភរិយារបស់បងប្រុសកណ្តាលមកនៅផ្ទះមួយនោះ ព្រោះបងប្រុសជំឲ្យគេតាមឃ្លាំមើលស៊ុនស៊ូ ព្រោះមានពិរុទ្ធ គិតថាមុខជាពាក់ព័ន្ធនឹងការបាត់ខ្លួនរបស់ យ៉ារីម និងប្រហែលមកលាក់ខ្លួនមិនឆ្ងាយពីចម្ការរបស់គ្រួសារគេប៉ុន្មានទេ។

អីចឹងតើ បានជាពួកគេតាមរកយ៉ាងណាក៏រកមិនឃើញ។

រង់ចាំមិនយូរប៉ុន្មាន អាជ្រេ និង ជេមិន ក៏បើកឡានមកដល់ ដំបូងឲ្យបើកឡានប៉ត្រុយកាត់មុខផ្ទះសិន មើលជើងការ ហើយមួយសន្ទុះក្រោយ ពេលឃើញ ស៊ុនស៊ូ ដើរចេញមកជាមួយស្រីម្នាក់ ទើបតេរប្រាប់បងប្រុស។

Scanned with CamScanner

"ស៊ុនស៊ូ ចេញម៉ោហើយ បងចូលទៅក្នុងផ្ទះនោះបាន"

(អរគុណ)

ពេលដាក់ទូរសព្ទបងប្រុសហើយ គេបើកឡាន តាម ស៊ុនស៊ូ ដែលកំពុងបណ្ដើរស្រីម្នាក់ទៅចំណតឡានក្រុង ចាំមួយសន្ទុះក៏បើកឡានមកចតពីមុខហើយចុចកញ្ចក់ចុះ ស្រែកហៅឲ្យនាងឡើងឡាន ក្រោមការភ្ញាក់ផ្អើលរបស់ស្រីម្នាក់ទៀតដែលមកជាមួយ។

"ឡើងមក ស៊ុនស៊ូ ជូនអីកំពុងត្រឡប់ទៅចម្ការវិញល្មម"

"លោក កាណែត"

នាងបើកភ្នែកធំៗ ព្រោះមិនស្មានថាជួបគេម្ដងទៀត មិនដឹងថាចៃដន្យឬគេមានចេតនា។

"ឲ្យឆាប់ឡើង មេឃជិតងងឹតហើយ"

គេតឿនដោយទឹកមុខកាច ទើបនាងងក់ក្បាលទាំងបង្ខំចិត្ត។

"ខ្ញុំទៅសិនហើយ ខុងជូ"

នាងងាកទៅប្រាប់មិត្តភក្តិ ហើយចាប់កាបូបស្ពាយជាប់ មើលទៅគេប្លែកៗ មើលទៅកាចយ៉ាងម៉េចក៏មិនដឹង នាងមិនសូវទុកចិត្តប៉ុន្មាន។

"បាយៗ ចាំជួបគ្នាលើកក្រោយ"

ខុងជូ ញញឹមគ្រវីដៃដាក់នាង និងតាមមើលទាល់តែឡានរបស់ កាណែតបើកចេញទៅបាត់។

នៅក្នុងឡាន ស៊ុនស៊ូ អង្គុយស្ងៀម តែភ្នែកដៀងមើល កាណែត ដោយការប្រុងប្រយ័ត្ន មុខមាត់ក៏ស្លេកស្លាំង ពេលមិនឮគេនិយាយអី គិតតែបញ្ជាឡានទៅខាងមុខ។

"លោកបើកហួសផ្លូវចូលផ្ទះហើយ"

"ខ្ញុំទៅចម្ការតែសិន"

គេឆ្លើយ ដោយមិនងាកមកមើល ឬដៀងមើលនាង នោះហើយដែលធ្វើឲ្យនាងកាន់តែខ្លាច ម្ដងក្ដាប់ ម្ដងលា ដៃដែលច្របាច់ដាក់លើភ្លៅក៏ត្រជាក់ តែពេលគេបើកចូលចម្ការតែ ក៏ធូរទ្រូង ព្រោះខ្លាចគេទៅកន្លែងផ្សេង។

កាណែត ញញឹមចុងមាត់ ពេលឮសំឡេងដកដង្ហើមធំរបស់អ្នកនៅក្បែរ ដោយនាងមិនដឹងទេថា ត្រូវគេនាំមកជម្រះក្ដី។

"តាមម៉ោ"

គេប្រាប់ ពេលពន្លត់ម៉ាស៊ីនឡាន ហើយចុះពីឡាន នាំចូលការិយាល័យដោយមិនរង់ចាំ ដូចជឿជាក់ថានាងត្រូវតែដើរតាម ហើយក៏ដូចការគិត ស៊ុនស៊ូដើរអូសជើងចូលមក ដែលពេលនេះគ្មានមនុស្ស មានតែផ្នែកសន្តិសុខដែលប្រចាំការនៅឆ្ងាយ។

នាងឈររេរា ពេលឃើញគេឈរជំទែងនៅមាត់បង្អួចបន្ទប់ធ្វើការ និងបាញ់ភ្នែកកាចមករក។

"លោកម៉ោធ្វើអីនៅការិយាល័យ គេចេញទៅផ្ទះអស់ហើយ ថ្មើរណេះ"



Scanned with CamScanner

"បើប្រញាប់ ម៉ោជួយរកបន្តិចម៉ោ ឲ្យឆាប់ឡើង"

គេញាក់ស្មាដាក់ ព្រមទាំងដើរចូលទៅខាងក្នុង ដែលពេលបែរខ្នងនោះ ក៏ចាំស្តាប់សម្រិបជើងថានាងដើរចូលមកទេ ហើយពេលឮ ក៏ញញឹមចុងមាត់ ធ្វើជារកមើលឯកសារក្នុងបន្ទប់ធ្វើការ ដែលពេលនេះបើកភ្លើងភ្លឺចិញ្ចាច តែមិនបើកវាំងនន។

"នាងទៅមើលនៅតុធ្វើការ ខ្ញុំមើលត្រង់នេះ សំណុំពណ៌ផ្ទៃមេឃ"

"ចាំ"

នាងខ្ចីបមាត់ណែន ដើរសំដៅតុធ្វើការរបស់គេ ទើបមើលមិនឃើញគេដែលដើរលឿនស្លេវមកតាម បន្ទាប់ពីចាំមើលនាងមួយសន្ទុះ។

"មិនឃើញមាន"

នាងរកមើលហើយ តែមិនឃើញមានអ្វី តុក៏ចាក់សោ នៅលើខាងក៏គ្មានអ្វីទាំងអស់។

"គឺវាគ្មានស្អីទេ"

កាណែត និយាយដោយសំឡេងកាច នៅជិតបង្កើយ ដែលធ្វើឲ្យនាងភ្ញាក់ព្រើត។

"ហើយលោកត្រូវការស្អី អ៊ុំ!"

នាងស្រែកខ្លាំងៗដាក់ បេះដូងធ្លាក់ទៅនៅនឹងតែ្នកគោ ពេលបែរមកវិញដើមទ្រូងណែនក្បែបុកនឹងដើមទ្រូងមាំមួនមួយទំហឹង ទើបប្រញាប់ថយក្រោយតែទៅបុកនឹងតុ ទើបស្រវាចាប់វា ទប់ជំហរ ខណៈនោះក៏គេក៏ស្ទុះមកតាមគ្រានដៃទាំងពីរនឹងតុ ឃុំឃាំងនាងជាប់។

"លោកធ្វើឆ្កួតស្អីហ្នឹង ថយចេញទៅ"

មុខរបស់នាងទៅជាស្លេកគ្មានពណ៌ឈាម លើកដៃរុញទ្រូងរបស់គេឲ្យថយចេញឆ្ងាយ ប៉ុន្តែគេកាន់តែត្រសុលចូលធ្វើឲ្យខ្លួននាងចង់សំប៉ែតនឹងតុទៅហើយ។

"ចាប់ជនទុច្ចរិតបាន គួរដាក់ទោសយ៉ាងណា"

"រឿងស្អី ជនទុច្ចរិតស្អី ខ្ញុំមិនដឹងរឿងអីទេ"

នាងគ្រវីក្បាលបដិសេធ និងប្រឹងរុញច្រានគេចេញដោយដៃញ័រៗ ព្រោះជិតអស់កម្លាំងហើយ។

"មាត់រឹងមែនទេ ល្អ ចាំខ្ញុំរកវិធីគាស់"

"កុំលោក កាណែត"

បេះដូងរបស់នាងលោតមិនត្រូវចង្វាក់ ជាពិសេសពេលគេបៀតចូលមកកាន់តែខ្លាំង ល្វែងក្រោមប៉ះនឹងស្អីក៏មិនដឹង ឯល្វែងលើ ដេកនៅលើតុ មានគេគ្រោមពីលើ ហើយញើសក៏បែកពេញថ្ងាស។

"ហ៊ានធ្វើខ្លួនជាជនទុច្ចរិត នាំមនុស្សទៅលាក់ផង ថែមទាំងធ្វើមុខមោឃលោកខ្ញុំនិងបងប្រុសទៀត"

"អត់មានទេ អឺ!"



Scanned with CamScanner

នាងបដិសេធ ហើយស្រែកឮតិចៗនៅដើម.ក ពេលត្រូវគេស្រវាចាប់ក្បាលជាប់ ឱនមកថើបមាត់ខ្លាំងៗ ឲ្យឈឺ ទើបងើបចេញឲ្យនាងដង្ហក់ខ្យល់។

"ហ៊ានបដិសេធទៀតឬ!"

គេខ្សឹបដោយសំឡេងស្អកៗដាក់បបូរមាត់ ឲ្យនាងព្រឺសម្បុរ។

"ខ្ញុំមិនបាន...អឺ!"

ពេលនាងចង់បដិសេធ កាណៃត ក៏ឱនមកបិទមាត់ដែលម្តងនេះ គេទាំងបឺត ទាំងខាំឲ្យហើម ហើយជ្រែកអណ្តាតចូលទៅក្នុងប្រអប់មាត់ ប្រដេញអណ្តាតរបស់នាងទាល់តែនាងឈ្លក់ខ្យល់ដង្ហើមខ្លួន។

"អាំ"

ស៊ិនស៊ី ខាំស្មារបស់គេខ្លាំងៗ បំណងឲ្យគេពន្លែង តែមិនបានសម្រេចទាល់តែងើបចេញដោយខ្លួនឯងនោះឯង ទើបនាងប្រឹងដកដង្ហើមចូលឲ្យពេញសួត ព្រោះពេលនេះមានអារម្មណ៍ហាក់ដូចកំពុងលង់ទឹក។

"នាងនាំអ្នកបងទិពីរទៅលាក់នៅផ្ទះមិត្តភក្តិរបស់នាងហើយសម្ងំស្ងៀមទុកឲ្យគេតាមរកឲ្យប្រវាត់ គិតថាខ្ញុំមិនដាក់ទោសនាងមែនទេ ស៊ិនស៊ី នាងគិតខុសហើយ ចាប់ពីពេលនេះទៅ នេះជាទណ្ឌកម្មរបស់នាង"

កាណៃត ទ្រោមទៅលើនាងម្តងទៀត ត្រសុលចូលប្រឡោះជើងចាប់កដៃទាំងពីរសង្កត់នឹងគុ ធ្វើឲ្យនាងអស់សេរីភាព។

"កុំអី លោក កាណៃត ខ្ញុំគ្មានចេតនាទេ ខ្ញុំគ្រាន់តែអាណិតបង យ៉ែម

សូមកុំធ្វើអីខ្ញុំ កុំ សុំអង្វរ"

នាងអង្វរករដោយការភ័យខ្លាច ព្រោះមិនសូវបានជួបភាពសាហាវព្រោះរបស់គេញឹកញាប់ទេ។ ពេលនេះគេមិនមែន កាណៃត ដែលចូលចិត្តលេងសើចបេះបួយ ឡេះឡោះ។

"ហ៊ឹ! ពេលនេះត្រូវអាណិតខ្លួនឯងហើយ ព្រោះខ្ញុំមិនដោះលែងនាងទេ"

អ្នកកំលោះជ្រឹមភ្នែកមើលអ្នកនៅក្រោមរាងកាយ និងនិយាយដោយសំឡេងកាច។

"កុំអី លែងខ្ញុំទៅ ខ្ញុំសុំទោស ខ្ញុំគ្មានចេតនាទេ"

"ខ្ញុំចូលចិត្តមនុស្សពូកែពេលខ្លាច វាធ្វើឲ្យខ្ញុំជ្រួលច្របល់ ជាពិសេសនាង ស៊ិនស៊ី"

គេពន្លែងកដៃរបស់នាងម្ខាង មកចាប់ចង្កា បង្គាប់ឲ្យនាងងាកមកប្រសព្វភ្នែកជាមួយ។

ស៊ិនស៊ី បណ្តោយឲ្យទឹកភ្នែកនៃការភ័យខ្លាចហូរតាមកន្ទុយភ្នែក។ នាងព្រមទទួលស្គាល់ថា ខ្លាចគេ មុខសង្ហាពេលខឹងគឺដូចបិសាច ដែលខាំនាងឲ្យខ្ទេច ហើយពេលពន្លែងដៃដែលចាប់ចង្កា មកអង្អែលក និងអូសចុះទៅក្រោមប្រឡេះឡេវអាវម្តងមួយៗ។

"កុំអី កុំ អាំ!"



Scanned with CamScanner

# ៩

"នាងធ្វើខុសសន្យា គឺត្រូវតែមានទោស ប៉ុន្តែខ្ញុំមិនដាក់ធ្ងន់ៗទេ ខ្ញុំនឹងថ្នមបំផុត កុំបារម្ភអី ជានាថានាងត្រូវតែចូលចិត្ត ព្រោះវាពុះកញ្ជ្រោលណាស់"

គេខ្សឹបប្រាប់ដោយសំឡេងស្អក ខណៈនោះ ក៏ទ្រាំនឹងភាពទាក់ទាញនៅចំពោះមុខស្ទើរតែមិនបាន ពេលប្រឡេះឡេវអាវរបស់នាងអស់រលីង ទាញជាវអាវចេញពីគ្នា ឲ្យដើមទ្រូងទ្រលុកទ្រលន់ សខ្ចី ផតផើតតាមការដកដង្ហើមស្ថិតនៅក្រោមខ្សែភ្នែក ត្រឹមប៉ុណ្ណឹង គេក៏ឈឺចាប់ត្រង់កន្លែងមួយទៅហើយ។

"កុំអី លោក កាណែត ខ្ញុំសុំទោស"

បេះដូងរបស់នាងលោតញាប់ដោយការភ័យខ្លាច រាងកាយដែលប៉ះគ្នាឲ្យអារម្មណ៍ស្រៀវស្រើប នាងទើបតែមានអារម្មណ៍បែបនេះ ជាលើកដំបូង មិនរាប់ពេលដែលត្រូវ សាន ដុងវ៉ុក ដាក់ថ្នាំ កាលណោះ នាងមិនដឹងខ្លួន ចាប់តាំងពីកើតរឿងថ្ងៃនោះមក អារម្មណ៍របស់នាងវាស្រពិចស្រពិល មិនដឹងថា ជាការពិតឬអត់ ប៉ុន្តែនាងត្រូវគេយករឿងដែលនាងលូកលាន់គេ បង្អាប់បង្ខំឲ្យនាងនៅក្នុងកណ្ដាប់ដៃ ហើយពេលដែលនាងប្រកែក ឬចង់តវ៉ា គេក៏ដៃដល់ បេះតែរករឿងថើបនាងគ្រប់ពេល ប៉ុន្តែលើកនេះ វាខុសគ្នា ដោយសារគេខឹងខ្លាំង និងប្រហែលជាមិនព្រមដោះលែងនាងនោះទេ។

នាងប្រឹងរើបម្រះយករួចខ្លួន ប៉ុន្តែគេបានបិទទ្វាររត់គេចរបស់នាងគ្រប់ច្រកទៅហើយ កាន់តែរើ រាងកាយកាន់តែប៉ះគ្នា។

កាណែត ថើបស្បែករលោងថ្នមៗ ដែលធ្វើឲ្យនាងស្រើបស្រាលសព្វសាច់ ខ្យល់ដង្ហើមដង្ហក់កាន់តែខ្លាំងទៅៗ ពេលគេប៉ះគល់ទ្រូង និងខ្ញាំខ្លាំងៗជាច្រើនដងបន្ទាប់មកក៏អូសទៅរកពោះរាបស្មើទើបនាងប្រឹងគ្រវែងត្រគាកដើម្បីគេច ប៉ុន្តែគ្រវែងទៅណាក៏ចៀសមិនផុត ត្រូវគេបេះបួយដោយការព្រួសខ្យល់ដង្ហើមដាក់ ដែលធ្វើឲ្យនាងរមួលក្នុងពោះ ហើយធ្លាក់ថ្លើមក្ដុកតែម្ដង ពេលគេប្រើអណ្ដាតនិងមាត់ប៉ះពាល់ ធ្វើឲ្យនាងព្រឺសម្បុរពេញខ្លួន និងប្រឹងអត់ដង្ហើមដោយការភិតភ័យ ខណៈនោះក៏លើកដៃញ័រទទ្រើត រុញក្បាលរបស់គេចេញ ប៉ុន្តែមិនបានសម្រេចដដែល គេនៅតែដំណើរការបន្ត។

"ឈប់...ឈប់ទៅ លោក កាណែត ឈប់ភ្លាម"

"ខ្ញុំថានាងមិនចង់ឲ្យខ្ញុំឈប់ទេ ស៊ុនស៊ូ ហ៊ឺៗ"

គេទប់សំណើចនៅដើមក ហើយថើបនាងបន្ត មកដល់ថ្ពាល់រលោង ដៃក៏ប្រឋាប់សព្វសាច់ ម្យ៉ាងទៀត ដៃរបស់គេដូចមឹកយ៉ាងអ៊ីចឹង វាសត្រង់ណាក៏មិនផុត ហើយគេក៏និយាយដាក់នាង នៅគម្លាតជិតបង្កើយ ខ្យល់ដង្ហើមក្ដៅស្រោចលើថ្ពាល់ ធ្វើឲ្យនាងប្រញាប់ងាកមុខចេញ ព្រោះវាធ្វើឲ្យព្រឺសម្បុរ ខ្លួនប្រាណក៏ក្ដៅភាយៗ។



Scanned with CamScanner

"លោកឯងឆ្កួតអំណាច"

"ខ្ញុំឬ អត់មានទេ តែនាងទេដែលរឹងក្បាល និងបោកប្រាស់ នាងធ្វើដោយខ្លួនឯងទេ ស៊ុនស៊ូ ហើយបែបនេះ តើឲ្យបន្ទោសអ្នកណាបានទៅ"

គេញញឹមចុងមាត់ ដោយការចូលចិត្តដាក់។

ផាច់!

ប៉ុន្តែ បន្ទាប់ពីនោះ គេក៏ស្ដីកមុខ ពេលត្រូវនាងទះមួយកំផ្លៀង ថែមទាំងខ្ទៅមុខដោយក្រចកទៀតផង ប៉ុន្តែគេប្រញាប់លើកដៃរង និងចាប់កដៃជាប់ក្រសោបទៅសង្កត់លើក្បាល។

"ហ៊ានទះខ្ញុំផង ស៊ុនស៊ូ ល្អ ចាំមើលមើល៍ ថានាងឬខ្ញុំដែលអាចចាត់ការអ្នកណាបានមុន"

"កុំ..."

នាងក្រមុំបើកភ្នែកធំៗ ពេលគេច្របាច់ដើមទ្រូង ប៉ុន្តែនៅតែបង្ខាប់ឲ្យនាងប្រសព្វភ្នែកនឹងគេដោយខ្សែភ្នែកកាច ធ្វើឲ្យនាងភ័យខ្លាច និងគិតថាមិនគួរណា ទះកំផ្លៀងគេ ហើយរមួលខ្លួន ពេលត្រូវគេលូកដៃចូលទៅអាវក្នុង ក្រសោបដើមទ្រូងដោយបាតដៃក្ដៅ ប្រើម្រាមដៃ គ្រវាសលើផ្លែឈើក្រហម ឲ្យនាងចំហមាត់ធ្លុង បន្ទាប់មកប្រឹងខាំមាត់ ព្រោះអារម្មណ៍ស្រៀវស្រើប វាត់រសើប ពេញខ្លួនប្រាណ ហើយមិនយូរប៉ុន្មាន គេក៏រុញអាវក្នុងរបស់នាងឡើងទៅលើ ហើយឈ្ងលមុខសង្ហា ត្រង់ជ្រលងទ្រូង ប្រើប្រអប់មាត់គ្រប់គ្រង បឺតជញ្ជក់ដើមទ្រូងរបស់នាងខ្លាំងៗ ឲ្យនាងថ្ងូចថ្ងូរនៅដើមក។

"អឺ..."

នាងស្រៀវសព្វសាច់ កម្លាំងនិងស្មារតី ស្ទើរតែខ្សោះអស់ពីខ្លួន ពេលនេះរាងកាយរបស់នាងតបស្នងការឈ្លានពានរបស់ កាណែត ដោយគ្មានអារម្មណ៍ជាខ្ពើមរអើម ថែមទាំងពើងទ្រូងទៅរក ឲ្យគេបើបានស្រួលទៀតផង។ នាងមិនដឹងទេថាខ្លួនឯងបានធ្វើរឿងគួរឲ្យអាម៉ាសទាំងដែលមុននេះប្រឹងក្រាញនៀល ប្រឹងរុញច្រានគេយកងាប់យករស់ ប៉ុន្តែពេលត្រូវគេប៉ះពាល់តែបន្តិចប៉ុណ្ណោះ នាងទៅជាទន់ល្មក ហាក់ដូចក្រមួនត្រូវភ្លើង ស្រៀវស្រើបសព្វសាច់ ចង់ឲ្យគេប៉ះពាល់លើសពីនេះ។

កាណែត ឈ្លក់វង្វេងនឹងភាពក្រអូបផ្អែមនៅចំពោះមុខ គេបឺតជញ្ជក់ដោយបបូរមាត់ គ្រវាសដោយអណ្ដាត ដោយការស្រេកឃ្លាន បាតដៃក៏ច្របាច់ភាពអន្ទិល បន្ទាប់មក ក៏អូសវាទៅរកចង្កេះ អង្អែលពោះរាបស្មើ ហើយប្រឡេះឡេវខោខូវប៊យរបស់នាង ទាញរ៉ូតទម្លាក់ យឺតៗ បន្ទាប់មក ប្រើបាតដៃក្ដៅលូកចូលទៅខាងក្នុង ប៉ះពាល់ ត្រគាកមូលក្លំ និងគូទងរបស់នាងដោយអារម្មណ៍ឈ្លក់វង្វេង។

ពេលនេះនាងដឹងខ្លួនពេលត្រូវគេច្របាច់តិចផង ខ្លាំងផង ទើបប្រឹងរមួលដៃ ឲ្យរបូតពីបាតដៃរបស់គេបានសម្រេចម្ខាង មកសង្គ្រុបចាប់ដៃរបស់គេដែលកំពុងបង្វៃទិសដៅ មករកល្វែងមុខ។

Scanned with CamScanner

"កុំ...កុំ លោក កាណែត"

នាងខាំធ្មេញក្រតៗ ពេលអារម្មណ៍ស្រើបស្រាលវារត់ឲ្យរសើបដោយសារបបូរមាត់និងបាតដៃរបស់គេ។

"កុំឈប់មែនទេ ស៊ុនស៊ូ"

អ្នកកំលោះញញឹមចុងមាត់ដោយការចូលចិត្ត ហើយងើបមុខ ចេញពីដើមទ្រូងទ្រលុកទ្រលន់ អូសមករកបបូរមាត់ ដែលប្រឹងខ្ទឹប ខ្សឹបប្រាប់ដោយសំឡេងស្អកៗ។

"អឺ...មិនមែនទេ មិនមែន ឈប់...ឈប់ភ្លាម"

នាងដកដង្ហើមដង្ហក់ ប្រឹងតឿតជើង ពេលត្រូវគេប៉ះពាល់ត្រង់ប្រឡោះភ្លៅ តែមិនបានសម្រេច ព្រោះគេឈរនៅត្រង់ប្រឡោះជើងរបស់នាង បាតដៃរបស់គេក៏ក្ដៅ ធ្វើឲ្យនាងស្រើបស្រាល ប្រឹងខាំដើមដៃរបស់គេខ្លាំងៗ ខាំបបូរមាត់ខ្លួនឯងឡើងជាំឈាមទៅហើយ ប្រឹងឡើងរឹងខ្លួន ពេលអារម្មណ៍ប្លែកថ្មី វាបោលសម្រុកចូលមកក្នុងរាងកាយ។

កាណែត ថើបដើមទ្រូងបរស់នាងម្ដងទៀត ដែលម្ដងនេះ នាងអត់ដង្ហើមទប់សំឡេងថ្ងូចថ្ងូរមិនបាន ទើបធ្វើឲ្យវាបន្លឺឡើងនៅដើមក ខ្លួនប្រាណក្ដៅភាយៗហាក់ដូចគ្រុនក្ដៅ ពេលដែលត្រូវគេដុត ធ្វើឲ្យនាងបាត់បង់ភាពម្ចាស់ការ។

ពេលនោះ កាណែត ក៏អូសដៃ ឡើងមកលើ ប្រុងស៊កចូលទៅក្នុងខោក្នុងរបស់នាង ដើម្បីបានប៉ះពាល់ សាច់ទន់ល្មើយនៅខាងក្នុង ប៉ុន្តែ...

គ្រឹត...គ្រឹត...

កម្លាំងញ័រនិងសំឡេងទូរសព្ទដៃ ធ្វើឲ្យគេអសកម្ម ព្រមទាំងដកដង្ហើមធំដោយការមួម៉ៅ ព្រោះកំពុងតែបានដាក់ទោសនាងទៅហើយ ដំបូងប្រុងមិនចាប់អារម្មណ៍សំឡេងនោះ ហើយដំណើរការបន្ត ប៉ុន្តែវានៅតែរោទ៍មិនឈប់។

"ថយចេញទៅ"

"ហ៊ឺយ!"

នាងក៏តាំង និងដឹងថាគេភាំងដូចគ្នា ទើបប្រមូលស្មារតីរុញច្រានគេចេញការខ្មាសអៀន ក៏កើតឡើង ពេលដែលនាងដឹងខ្លួន ប្រញាប់ប្រញាល់ ទាញអាវក្នុងទម្លាក់ បិទបាំងដើមទ្រូង។

"នៅឲ្យស្ងៀម ហាមទៅណា"

គេបញ្ជា ដោយសំឡេងនិងទឹកមុខកាច ពេលលូកដៃយកទូរសព្ទពីហោប៉ៅខោមកមើល ថាអ្នកណាគេរមកថ្មើរណេះ ហើយពេលឃើញថាជាបងប្រុសក៏ធ្វើមុខធុញទ្រាន់។

"តេរម៉ោធ្វើអីពេលនេះ ប្រពន្ធបានជួបហើយមិនអីចឹង ហ៊ឺយ!"

គេខាំធ្មេញក្រតៗ ប្រឹងរម្ងាប់តម្រូវការឲ្យវាស្ងប់។

"កុំ លែងខ្ញុំ អាំ! អឺ!"

ស៊ុនស៊ូ មិនខ្វល់ គិតតែពីប្រឹងរើបម្រះ និងស្រែក ដើម្បីឲ្យគេងើបចេញ ទើប កាណែត ប្រើដៃម្ខាងខ្ទប់មាត់របស់នាងមិនឲ្យស្រែក និងបាញ់ខ្សែភ្នែកកាច



Scanned with CamScanner

ដាក់។

"មានការអីបងប្រុស?"

គេគ្រហឹមសួរបងប្រុសទីពីរដែលគេរមក ដោយមិនមើលពេលមើលវេលា ទាំងដែលខ្លួនឯងបានជួបប្រពន្ធជាទីស្រឡាញ់ទៅហើយ ហើយក៏មិនខ្វីឈឺ ពេលដែលត្រូវនាងក្ដិចខ្លាំងដៃរបស់គេខ្លាំងៗដែរ។

(ស៊ុនស៊ូ នៅជាមួយឯងមែនទេ កាណែត ប្រពន្ធបងប្រាប់ថាហាមធ្វើអីនាង ឆាប់នាំនាងម៉ោផ្ទះវិញ កុំឲ្យមានស្នាមសូម្បីតែមួយចុងក្រចក)

អាជ្រេ ទូរសព្ទមកប្រាប់ប្អូនប្រុសតាមបំណងរបស់ភរិយាជាទីស្រឡាញ់ ព្រោះនាងបារម្ភពី ស៊ុនស៊ូ ខ្លាចត្រូវ កាណែត ដាក់ទោសធ្ងន់។

"មែន ពេលនេះនៅជាមួយខ្ញុំ អ៊ុ!...ស៊ុនស៊ូ"

កាណែត ឆ្លើយប្រាប់បងប្រុស ហើយក៏ស្រែកភ្លាត់មាត់ ពេលត្រូវនាងខាំដៃខ្លាំងៗ ធ្វើឲ្យគេឈឺ ប្រញាប់ដកដៃចេញ ហើយការងើបចេញរបស់គេនោះឯងធ្វើឲ្យនាងមានឱកាស ស្ទុះងើបឈរ និងរុញគេឲ្យជ្រមិលចេញ ហើយនាងក៏យកនាឡិកានៅលើតុ ដែលសង្កត់លើក្រដាស មកគប់គេដោយមិនប្រណី។

(អី បានហើយប៉ុណ្ណឹងចុះ ឆាប់ម៉ោផ្ទះវិញ)

ពេលបញ្ចាហើយ បងប្រុសកណ្ដាលក៏ដាក់ទូរសព្ទចុះ។

"នេះនែ៎ៗ!"

ពេលគប់ហើយ នាងក៏ស្ទុះរត់សំដៅទ្វារ ព្រមទាំងស្រវាយកអ្វីក៏ដោយ

ដែលអាចយកបានគប់គេ។

"ព្រហើនណាស់ ម៉ោណេះ!"

គេដើរតាម ពេលមកដល់ ក៏ស្រវាចាប់ដៃរបស់នាងជាប់ ទាញមកឱបរឹតហើយនាំទៅសង្កត់នឹងជញ្ជាំង។

"អ៊ូយ! កុំ លែងខ្ញុំ"

នាងប្រឹងរើបម្រះផង រុញស្មារបស់គេចេញផង ព្រមទាំងទះគប់ ដោយមិនប្រណី ដង្ហើមក៏ដង្ហក់ព្រោះហត់នឿយដោយសារការប្រើថាមពលអម្បាញ់មិញ ជាវអាវនៅតែបើកចំហ ព្រោះមិនបានដាក់ឡេវឲ្យមានរបៀប។

"ឆ្នាសណាស់ យករបស់ម៉ោគប់ ឡើងឈឺពេញខ្លួនទៅហើយ បែបនេះខ្ញុំគួរគប់នាងវិញទេ ឬខាំឲ្យមានស្នាម បែបនេះហ្នឹងអី"

មិនត្រឹមតែនិយាយទេ គេនៅឱនទៅខាំគល់ទ្រូងរបស់នាងតិចៗ មិនឲ្យឈឺ តែឲ្យភ្ញាក់កន្ត្រាក់ ហើយរឹតតែភ្ញាញ់ ពេលត្រូវនាងចាប់បោចសក់ ដោយការខាំពីរបីចង្កូមទៀត បន្ទាប់មក ក៏ងើយមកមើលមុខនាង ដោយទឹកមុខនិងខ្សែភ្នែកមានប្រៀបជាង។

"មនុស្សថោកទាប អី!"

នាងនៅតែខ្ទាំសក់របស់គេ ទាញខ្លាំងៗ និងជេរប្រទេច ទើប កាណែត ឱនថើបបបូរមាត់របស់នាង ថើបខ្លាំងៗ ថែមទាំងខាំតិចៗតាមទំនើងចិត្ត ឲ្យនាងទន់ខ្លួនល្អក គ្មានកម្លាំងកំហែងនឹងប្រឆាំង បន្ទាប់មក ក៏ជ្រែកអណ្ដាតទៅ



Scanned with CamScanner

កេរអណ្ដាតរបស់នាង ជាការជន្លជន្លេញ និងដូសដងយករសជាតិផ្អែមល្ហែម យូរគួរសម ទើបដកបបូរមាត់ចេញ ដើម្បីឲ្យនាងបានដកដង្ហើមចូលឲ្យពេញសួត ព្រោះពេលនេះនាងដង្ហក់ខ្យល់ និងទន់ខ្លួនល្ហុកទៅហើយ។

"ហុឺ! យ៉ាងម៉េចដែរ ថើបប៉ុណ្ណឹងដល់ថ្នាក់ចង់ដួល"

គេជ្រឹមភ្នែកមើល ព្រមទាំងសើចហ៊ីហ៊ីដាក់ដោយការពេញចិត្ត តែមមាត់ក៏មានស្នាមញញឹម ដោយសារកាយវិការរបស់អ្នកនៅក្នុងរង្វង់ដៃ មុខក្រហមង៉ាំង គួរឲ្យមើល ប៉ុន្តែមើលទៅមិនទាន់បាត់ឆ្ងាសទេ។

ស៊ុនស៊ូ ក្រហមមុខ ដោយសារការអាម៉ាស់ និងពុកមាត់ពុកចង្កាដែលត្រដុសពេញមុខរបស់នាង ប្រឹងលើកដៃរុញដើមទ្រូងរឹងមាំចេញខ្លាំងៗ ទឹកភ្នែកក៏ហូរកាត់ថ្ពាល់ ទើបលើកដៃជូតវាចេញហាក់ដូចកូនក្មេង។

"វ៉ូៗ យំធ្វើអី"

គេជញ្ជក់មាត់ និងជ្រឹមភ្នែកមើល ខ្សឹបដោយសំឡេងស្អកៗដាក់។

"ពេញចិត្តលោកហើយឬនៅ!"

នាងខាំមាត់ អត់ដង្ហើម ងើយមកប្រសព្វភ្នែកនឹងគេ ដោយមិនញញើតទៀត ជាការតវ៉ា ដែលធ្វើឲ្យអ្នកកំលោះដកដង្ហើមធំ។

"មិនទាន់ពេញចិត្តទេ តែពេលនេះប៉ុណ្ណឹងសិនក៏បានដែរ យើងគួរត្រឡប់ទៅផ្ទះវិញ ទៅអបអរបង អាជ្រេ ដែលបានជួបមុខប្រពន្ធកូនហើយ"

គេខាំធ្មេញក្រតៗ ព្រមដោះលែងនាងសិនទៅ ព្រោះគេនៅមានពេលច្រើនទៀត ជានាថា ស៊ុនស៊ូ គេចមិនផុតពីក្រញាំដៃរបស់គេងាយៗទេ។

"អ៊ីចឹងលែងខ្ញុំទៅ"

នាងរុញគេចេញ ក្រែងប្រាប់ថាអាចទៅផ្ទះវិញបានហើយនោះអី ម៉េចក៏មិនព្រមព្រលែងនាងពីរង្វង់ដៃបែបនេះ។

"តែងខ្លួនឲ្យមានរបៀបសិនទៅ ឬចង់ចេញទៅទាំងបែបនេះក៏ខ្ញុំមិនថាអីដែរ ឲ្យអ្នកនៅម្ដុំនេះបានឃើញថានាងចង់បង្ហាញស្អីខ្លះ"

គេងើបចេញ និងញញឹមចុងមាត់ដាក់ សម្លឹងមើលនាងតាំងពីក្បាលដល់ចុងជើង ឃើញនាងទាញរ៉ូត ដាក់ខ្សែរអាវទាំងញ័រដៃទទ្រើត ក៏អត់មិនបាននឹងចំអន់ឲ្យអៀនលេង។

"រួចរាល់ហើយក៏តាមម៉ោ កុំអែនអនឲ្យដៃខ្ញុំនៅក្នុងនេះ ឬចង់បន្តទៀត"

"លោកចេញទៅសិនទៅ"

នាងខាំមាត់ ដាក់ ហើយភ្ញាក់ព្រើត ពេលគេស្ទុះមករក ចាប់ដើមដៃរបស់នាងម្ខាង ឯម្ខាងទៀតចាប់ប្របាច់ចង្ការរបស់នាង មិនឲ្យគេចទៅណា។

"នៅសម្ដីហំទៀតមែនទេ បែបនេះវាគួរណាស់"

គេខាំធ្មេញក្រតៗដាក់ ហើយឱនថើបបបូរមាត់របស់នាងយ៉ាងយូរ ទើបបង្ខំចិត្តដកបបូរមាត់ចេញ និងសម្លឹងមើលអ្នកដែលញ័រខ្លួនទទ្រើត ប្រឹងខ្ទឹបមាត់លើកដៃត្រដុសខ្លាំងៗ តែមិនហ៊ានប្រសព្វនឹងខ្សែភ្នែកកាចរបស់គេ។

អ្នកកំលោះខាំធ្មេញក្រតៗ បែរខ្លួនដើរទៅបើកទ្វារបន្ទប់ធ្វើការ ចេញទៅ



Scanned with CamScanner

មុនភ្លាម ទើបនាងដើរយឺតៗតាមគេ ទៅឡើងឡាន ដោយមិននិយាយរកគ្នាទៀត ព្រោះពេលនេះ បបូរមាត់របស់នាងហើមជាំទៅហើយ ព្រោះគេគិតតែពីថើប។

"ហ៊ឺ! ស្ងាត់មាត់ធ្វើអី ម៉េចក៏មិនហំទៀតទៅ"

គេដៀងមើលអ្នកនៅក្បែរដែលគិតតែអង្គុយស្ងៀម តែដកដង្ហើមធំឲ្យឮ ទើបអត់ជ្រេញមិនបាន ដៀមដាមបន្តិចទៅ។

"ខ្ញុំនិយាយឬមិននិយាយវាជារឿងរបស់ខ្ញុំ លោកម៉ោចេះស្អីដែរ"

"កម្លាំងនៅសល់តើ ផៀងចូលព្រៃក្រូចបន្តិចទេ ក្រែងលោធ្វើឲ្យនាងអស់កម្លាំង"

"បញ្ឈប់គំនិតឆ្កួតៗរបស់លោកភ្លាម!"

ពេលគេបន្ថយល្បឿន ប្រុងចតនៅក្នុងព្រៃក្រូច នាងក៏ភ័យបុកពោះឌឹបៗ ស្ទើឲ្យភ្លាម។

"សាសងគ្នានៅក្នុងព្រៃក្រូចក៏ល្អ ផ្កាក្រូចក្រអូបចង់ងាប់ ធ្វើឲ្យរាងកាយស្រៀវស្រាញ ខ្ញុំឃើញកម្មករមកញ៉ែគ្នានៅក្នុងនេះច្រើនណាស់ ប៉ុន្តែស្ពាយ គេមិនឲ្យនៅយប់ងងឹត ប៉ុន្តែខ្ញុំជាប្អូនប្រុសរបស់ម្ចាស់ចម្ការ ប្រហែលបានណ៎ា អ៉ើ! ឬចង់ទៅសាកនៅម្តុំចម្ការតែមើលក៏បានដែរ"

គេនៅតែមិនព្រមបន្ថែមល្បឿនឡាន ព្រោះមិនទាន់ផុតចម្ការក្រូច។

"លោកចង់មុខក្រាស់ទៅសាសងជាមួយអ្នកណា វាជារឿងរបស់លោក ខ្ញុំមិនចាប់អារម្មណ៍ទេ"

នាងមើលមុខគេដោយការមិនទុកចិត្ត ព្រោះពេលនេះមេឃងងឹតហើយ អាកាសធាតុក៏ត្រជាក់ដែរ។

"ពេលនេះមិនទាន់មានស្រីណាជិះឡានជាមួយខ្ញុំទេ មានតែនាងម្នាក់ ខ្ញុំមានន័យដល់នាងហ្នឹងហើយ ស៊ុនស៊ូ សាកម្តងទេ ធានាថាអង្រួនចិត្ត"

គេនៅតែបេះបួយ ឲ្យនាងភ័យលេង។

"ឈប់និយាយស្តីគួរឲ្យស្អប់ទៅ!"

"មិនឃើញគួរឲ្យស្អប់ត្រង់ណា ត្រង់នៅក្នុងបន្ទប់ធ្វើការ នាងវិះតែក្លាយជារបស់ខ្ញុំទៅហើយ បើមិនត្រូវរំខាន ធានានាងនឹងព្រមដោយមិនជំទាស់"

"លោក កាណែត!"

"សង្ស័យជាប់ចិត្ត ហៅឈ្មោះខ្ញុំពីរោះដល់ហើយ ហ៊ឹៗ"

គេអស់សំណើចដោយការចូលចិត្ត ហើយបន្ថែមល្បឿនដោយមិនចង់ធ្វើឲ្យនាងភ័យទៀត សំដៅផ្ទះធំដែលនៅមិនឆ្ងាយប៉ុន្មាន ដោយមានអារម្មណ៍ល្អ។

*អាមនុស្សឆ្កួត អាមនុស្សមុខក្រាស់ អាមនុស្សមុខដែកថែប ហេតុអីនាងត្រូវមកជួបគេ បែបនេះ ស្អប់ណាស់!*

ស៊ុនស៊ូ ស្រែកជេរគេនៅក្នុងចិត្ត តែបេះដូងបែរជាលោតញាប់ដោយអារម្មណ៍ប្លែកៗដែលមានចំពោះគេ។ នាងមិនចង់ព្រមទទួលស្គាល់ មិនមែនទេ

Scanned with CamScanner

នាងគ្មានអារម្មណ៍ល្អចំពោះគេ គ្មានអារម្មណ៍ល្អចំពោះប្រុសម្នាក់នេះ។

នៅផ្ទះធំ...

អាជ្រេ នាំភរិយាចុះមកបន្ទប់អាហារ ដែលពេលនេះ បងប្រុសនិងភរិយារួមទាំងកូនប្រុស អង្គុយចាំទៅហើយ មានតែពីរនាក់ទៀតប៉ុណ្ណោះដែលមិនទាន់មក ទើបសួរនាំបងប្រុសធំ ពេលទាញកៅអីឲ្យភរិយានិងដាក់បង្គុយក្បែរនាងរួចរាល់។

"កាណែត និង ស៊ុនស៊ូ មិនទាន់ម៉ោទៀតឬ ?"

"បងតេរទៅហើយ ឮថាជិតដល់ហើយ"

អេដែន ញញឹមប្រាប់ប្អូនប្រុស និងមើលមុខប្អូនថ្លៃស្រី ដែលនៅស្លេកស្លាំង។

"មានអ្នកណានិយាយដើមខ្ញុំទេ មានអារម្មណ៍ថាកន្ត្រាក់ភ្នែក"

កាណែត ដើរយ៉ាងសង្ហាចូលមកក្នុងបន្ទប់អាហារ លើកដៃជ្រងសក់មើលបងប្រុសទាំងពីរ ដោយទឹកមុខញញឹម ចំណែក អេដែន និង អាជ្រេ ពេលសង្កេតឃើញស្នាមក្រហមត្រង់ក និងថ្ពាល់ដែលបិទបាំងដោយពុកមាត់ពុកចង្កាមិនជិតរបស់ប្អូនប្រុស ក៏ងាកទៅមើលមុខគ្នា យល់ន័យតែពីរនាក់ ចំណែក កាណែត ពេលដាក់បង្គុយចុះហើយ ក៏លើកដៃអង្អែលមាត់ខ្លួនឯងតិចៗ ខណៈនោះក៏លួចដៀងមើលអ្នកដែលដើរចូលតាមក្រោយ។

ស៊ុនស៊ូ ដើរចូលមក ដោយទឹកមុខញញើតញញើម ខណៈនោះក៏មើលអេដែន និង អាជ្រេ ដោយការដឹងកំហុស ហើយឱនគំនាប់ជាការសុំទោស។

"សុំទោសផងលោក អាជ្រេ ដែលខ្ញុំនាំបង យ៉ារីម ទៅនៅផ្ទះមិត្តភក្តិ សុំទោសផងពូថ្លៃ ដែលលាក់បាំង"

នាងឱនមុខជ្រប់ ព្រោះខ្លាចចាស់ទុំទាំងពីរមិនលើកលែងទោសឲ្យ។

"ខ្ញុំលើកលែងទោសឲ្យ ដែលនាងនាំ យ៉ារីម និងកូនទៅនៅផ្ទះមិត្តភក្តិល្អជាងបណ្ដោយឲ្យ យ៉ារីម បាត់ទៅណាក៏មិនដឹង ហើយខ្ញុំតាមរកមិនឃើញបែបហ្នឹងខ្ញុំអាចមានអារម្មណ៍វេទនាជាងនេះទៅទៀត និងត្រូវអរគុណនាងដែរកុំយំអី"

អាជ្រេ ញញឹមលួងលោម គេមិនខឹងនាងទេ ផ្ទុយទៅវិញ បែរជាសប្បាយចិត្ត ដែលនាងនាំប្រពន្ធរបស់គេទៅនៅផ្ទះមិត្តភក្តិ។

"អរគុណ"

នាងឱនគំនាប់ម្តងទៀត ដោយញញឹមទាំងទឹកភ្នែក ប៉ុណ្ណឹងក៏សប្បាយចិត្តទៅហើយមិនចាំបាច់មកស្ដាប់ប្រុសកំណាចថាឲ្យនាងទៀតថែមទាំងគេប្លន់ថើបនាងទៀតផង អាមនុស្សសាហាវ អាមនុស្សឃោរឃៅ នាងស្អប់គេណាស់។

"ពូក៏អភ័យទោសឲ្យដែរ ព្រោះពូយក ស្ទួម ទៅធ្វើញឹកញាប់ ចង់មានកូនភ្លោះដូច អាជ្រេ ដែរ"

អេដែន ញញឹមដាក់ក្ដួយប្រសា ហើយងាកទៅមិចភ្នែកដាក់ភរិយា ឲ្យ

នាងអៀនលេង។

"បងនេះ"

ស៊ូអា អៀនឡើងក្រហមមុខ ក្ដិចជើងរបស់គេនៅក្រោមតុ ខណៈដែលកូនប្រុសរវល់តែជាមួយនឹងរបស់លេង មិនខ្វល់ទេថាឪពុកម្ដាយផ្អែមល្ហែមដាក់គ្នាប៉ុណ្ណា។

"ថ្ងៃនេះ សុំបើកស៊ាំប៉ាញមួយដប អបអរដែល យ៉រឹម ត្រឡប់មកផ្ទះវិញ និង អបអរ អាជ្រេ ដែលមានកូនភ្លោះ ចំណែក យ៉រឹម និង ស៊ូអា បងចាក់ទឹកក្រូចឲ្យបុះ"

"អូខេ បងប្រុស"

ប្អូនប្រុសទាំងពីរញញឹមពព្រាយ ឲ្យបងប្រុសចាក់សាំប៉ាញឲ្យ ហើយក៏ជល់កែវគ្នា យ៉ាងរីករាយ ធ្វើឲ្យអាហារមួយពេលនេះកាន់តែឆ្ងាញ់ពិសា។

បន្ទាប់ពីជូនប្រពន្ធកូនចូលដេកបានមួយសន្ទុះ អេដែន ក៏ហៅប្អូនប្រុសពៅទៅជួបនៅក្នុងបន្ទប់អង្គុយលេង ដោយ កាណៃត កាន់ដបស្រា និងកែវពីរទៅជាមួយ ហើយពេលដាក់បង្គុយលើសាឡុង គេក៏ចាក់ស្រា ហុចឲ្យបងប្រុសមួយកែវ។

"ផឹកកំដរខ្ញុំបន្តិច ឲ្យខួរក្បាលរបស់ខ្ញុំធេងធោង ស្ដាប់បងដេរមិនសូវឈឺ"



"ដឹងដែរឬ ថាបងហៅឯងមកនេះដើម្បីដេរ"

អេដែន ញញឹមចុងមាត់ និងលើកស្រាដឹបបន្តិច ព្រោះមិនចង់ឲ្យប្រពន្ធកូនជុំក្លិនស្រារបស់ខ្លួន។

"ខ្ញុំជាប្អូនរបស់បងហ្នឹងណា អូខេ ចង់ដេរអីក៏អញ្ជើញ"

កាណៃត លូកដៃយកសណ្ដែកចម្រុះប្រភេទ ដែលចាក់ដាក់ចានតែមួយបោះចូលមាត់ ទំពាផ្ងាញៗ អែនខ្នងផ្អែកនឹងសាឡុង រង់ចាំបងប្រុសដេរ។

"ដឹងបែបនេះមិនបាច់ប្រាប់ច្រើនទេដឹង មែនទេ"

"ខ្ញុំម៉េចនឹងដឹងទៅថាបងចង់និយាយជាមួយខ្ញុំរឿងអី"

"មិនទំនងទេ កាណៃត អូខេ ក៏បាន បងនឹងនិយាយជាមួយឯងពីរឿងរបស់ស៊ុនស៊ូថ្ងៃនេះឯងធ្វើស្អីនាងក្រែងប្រាប់ថាមិនចូលចិត្តគ្មាននិស្ស័យនឹងគ្នា ហើយម៉េចក៏ធ្វើស្អីនាង កុំគិតថាបងមិនដឹង"

"គ្មានស្អីទេ គ្រាន់តែប្រដៅតិចតួច ថាកុំធ្វើបែបហ្នឹងទៀតតែប៉ុណ្ណោះ បងគិតច្រើនពេកឬអត់"

កាណៃត ញាក់ស្មាដាក់ បន្លប់ ដោយការលើកស្រាផឹក និងយកសណ្ដែកមកទំពា។

"អឺម ! បងប្រហែលគិតច្រើនដូចឯងថាទេដឹង កាណៃត ហើយប្រពន្ធបងក៏ជាអ្នកសុំឲ្យបងមកនិយាយជាមួយឯង ព្រោះនាងបារម្ភពីក្មួយស្រីរបស់នាង ថាត្រូវឯងធ្វើបាប"



Scanned with CamScanner

"សុំរឿងអី ?"

"នាងសុំឲ្យ ស៊ុនស៊ូ មកជួយមើលថៃ ស្នួម វិញ ហើយអាចឲ្យមកធ្វើការនៅចម្ការក្រូច មិនឲ្យទៅធ្វើការនៅចម្ការតែជាមួយឯង"

អេដែន និយាយមួយៗរង់ចាំមើលប្រតិកម្មរបស់ប្អូនប្រុសពៅថានឹងមានលក្ខណៈបែបណា និងដូចការស្មាន គឺ កាណែត មុខក្រមូវមួយរំពេច។

"ម៉េចនឹងបានទៅ លោក អាហ្សា បញ្ជាឲ្យនាងមកធ្វើការជាមួយខ្ញុំ ចង់ទាញទៅវិញស្រួលៗម៉េចនឹងបាន មិនបានដាច់ខាត!"

កាណែត ដាក់កែវស្រាលើតុ ប្រាប់បងប្រុសដោយទឹកមុខប្រាកដប្រជា។

"លោក អាហ្សា បញ្ជាឲ្យធ្វើបាន ក៏បញ្ជាឲ្យឈប់បានដូចគ្នា"

"មិនកំប្លែងទេ ខ្ញុំមិនឲ្យឈប់"

"តែឯងធ្វើបាបនាងបែបហ្នឹងមិនបានទេ"

"ខ្ញុំសុំគិតមើលសិន កំលុងពេលនេះ ឲ្យនាងធ្វើការតាមធម្មតាទៅ ហើយចាំមកសួរខ្ញុំសាថ្មី"

"សង្ឃឹមថារឿងវាមិនទៅដល់ដៃ លោក អាហ្សា ឯងក៏ដឹងដែរថា វានឹងមានអ្វីកើតឡើង"

"បើបងមិនប្រាប់ លោក អាហ្សា ក៏មិនដឹង"

"ហ៊ឺ! អ៊ូ! ហើយនៅមានរឿងថ្ងៃកម្មវិធីប៉ុឡូ ដែល សាន ដុងវ៉ុក ម៉ោបង្ករឿងទៀត ម៉េចក៏ឯងមិនប្រាប់ពួកបង"

អេដែន គ្រហឹមនៅដើម-កនឹងចរិតបេះបួយរបស់ប្អូនប្រុស មិនព្រមទទួលស្គាល់ការពិត ថ្នាក់យក លោកអាហ្សា មកគំរាមទៅហើយ ហើយនៅមានរឿងនេះទៀត ដែលគេទើបតែដឹងពី ថាក់គូ មិត្តភក្តិរបស់ កាណែត កាលពីពេលថ្មីៗនេះឯង។

"រឿងតូចតាចទេ គ្មានបញ្ហាអីទេខ្ញុំចាត់ការបាន ហើយអ្នកណាប្រាប់បងរឿងនេះ ?"

"ថាក់គូ ឯងមិនគួរប្រថុយយ៉ាងហ្នឹងទេ គួរតែឲ្យពួកបងទៅជាមួយ ឬមិនអីចឹង លើកទ័ពទៅឲ្យច្រើនបន្តិច តែសំណាងហើយដែលមានសុវត្ថិភាពត្រឡប់មកវិញ"

"ស្មានថាអ្នកណាប្រាប់ ទៅគ្នាច្រើនបានផ្អើលឆោឡោពេញមួយកម្មវិធីល្មម ឲ្យខ្ញុំចាត់ការម្នាក់ឯងក៏ល្អហើយ វាក៏សន្យាដែរថានឹងមិនម៉ោរញ៉េរញ៉ៃនឹងមនុស្សរបស់យើងទៀត ម្យ៉ាងទៀតយើងក៏មានភស្តុតាងគ្រប់យ៉ាងដែរ ថ្ងៃណាដែលវាលេងមិនស្មោះត្រង់ដាក់យើងទៀត យើងអាចចាត់ការវាបាន បងកុំបារម្ភអី ខ្ញុំនិង ថាក់គូ មានម្នាក់មួយច្បាប់ រក្សាទុករៀងខ្លួន"

"បងសប្បាយចិត្តដែលឯងទៅជួយ ស៊ុនស៊ូ បានទាន់ពេលវេលា រឿងនេះ ឲ្យ ស៊ូអា ដឹងមិនបានជាដាច់ខាត"

"សាកឲ្យអ្នកបងធំដឹងមើល៍ ច្បាស់ជាឡូឡាដាក់បងមិនខាន ធានាថាបានដេកក្រោមបន្ទប់បីថ្ងៃបីយប់ ហាសហា"

Scanned with CamScanner

កាណែត សើចក្អាកក្អាយ។

"គ្មានផ្លូវទេ មិនឲ្យចូលតាមទ្វារបងឡើងតាមបង្អួច រឿងស្អីព្រមដេកនៅក្រៅបន្ទប់"

"ហ៊ឺៗ ខ្ញុំក៏ថាអីចឹងដែរ"

"បងមានរឿងនិយាយជាមួយឯងតែប៉ុណ្ណឹងទេ កាណែត ទៅដេកវិញ ងងុយហើយ"

អេដែន ដាក់កែវស្រាចុះ មើលមុខប្អូនប្រុសបន្តិច និយាយដោយទឹកមុខស្មើ ហើយងើបដើរចេញពីបន្ទប់អង្គុយលេង ឡើងទៅដេកឱបប្រពន្ធ កក់ក្ដៅជាង។

"អញ្ជើញ"

កាណែត តាមមើលបងប្រុសច្បង ហើយលើកស្រាអកពីរកែវទៀត ទើបងើបឈរពត់ខ្លួនពត់ប្រាណ លើកដៃជ្រងសក់ ហើយឡើងទៅបន្ទប់ដេករបស់ខ្លួនដែរ។

**ស៊ុនស៊ូ សប្បាយចិត្ត ដែល អេដែន និង អាជ្រេ មិនរករឿង មានតែប្រុស**កំណាចម្នាក់នោះប៉ុណ្ណោះដែលនាងត្រូវប្រុងប្រយ័ត្នខ្លួន ព្រោះដឹងថាគេមុខជាមិនដោះលែងនាងទៀតទេ។

"មនុស្សឆ្កួត មនុស្សឡប់"



នាងត្រដុសមាត់ខ្លួនឯងខ្លាំងៗ មុខឡើងក្ដៅភាយៗ ព្យាយាមមិនគិតដល់គេ ហើយដើរចូលបន្ទប់ទឹក ដោះសម្លៀកបំពាក់ចេញអស់ពីខ្លួន ដោយមិនហ៊ានមើលកញ្ចក់ធំ ខ្លាចឃើញស្លាកស្នាមដែលគេបន្សល់ទុក លើកសក់បួងហើយដើរទៅឈរនៅក្រោមផ្កាឈូក បើកទឹកត្រជាក់ ឲ្យស្រោចស្រព្វរាងកាយដែលធ្វើឲ្យនាងមានអារម្មណ៍ធូរស្រាលហើយពេលងូតទឹករួចរាល់ក៏ពាក់អាវឃ្លុំងូតទឹកពណ៌ពងក្រសារ ដើរមកឈរនៅតុគ្រឿងសម្អាង លាបឡេខ្លួននិងឡេមុខបន្ទាប់មក ក៏ដើរទៅបន្ទប់តែងខ្លួន ដើម្បីស្លៀកឈុតដេក។

ពេលតែងខ្លួនរួចរាល់ហើយ នាងក៏បិទភ្លើងក្នុងបន្ទប់ ឲ្យភ្លើងមកពីខាងក្រៅ ចាំងចូលមកតាមបង្អួច ហើយក៏ផ្ដួលខ្លួនដេក ទាញភួយមកដណ្ដប់ដល់ចង្កា។

គ្រិត!

ទ្វារបន្ទប់ដេករបស់ ស៊ុនស៊ូ ត្រូវបើកថ្នមៗ ដោយដៃរបស់ កាណែត ដោយសោរសាគួដែលគេមាន បើកចូលមក គេដើរថ្នមៗចូលមកក្នុងបន្ទប់ មកឈរនៅក្បែរគ្រែមើលអ្នកដែលដេកនៅលើគ្រែ ដោយកែវភ្នែកក្ដៅគគុក បន្ទាប់មកក៏ដាក់បង្អុយនៅគែមគ្រែពីក្រោយខ្នងនាងដែលដេកបែរខ្នង។

គ្រែទ្រុឌ ធ្វើឲ្យនាងភ្ញាក់ព្រើត បើកភ្នែកធំៗ តែមិនហ៊ានកម្រើកទៅណា បានត្រឹមតែប្រឹងអត់ដង្ហើម ខ្លាចថា ការដកដង្ហើមញាប់ៗរបស់ខ្លួន ធ្វើឲ្យអ្នកដែលលួចចូលមក ដឹងថានាងភ្ញាក់។



Scanned with CamScanner

"ស្អែកទៅធ្វើការជាមួយខ្ញុំដដែល ហើយកុំរត់គេច ឬទៅធ្វើការនៅចម្ការក្រូចឬកសិដ្ឋានសេះរបស់អ្នកណាដាច់ខាត បើនាងហ៊ានល្មើសបញ្ជារបស់ខ្ញុំ ខ្ញុំនឹងទៅតាមអូសនាងដោយផ្ទាល់ ស៊ិនស៊ូ ខ្ញុំដឹងថានាងមិនទាន់ដេកលក់និងបានឮខ្ញុំនិយាយច្បាស់ ខ្ញុំម៉ោប្រាប់តែប៉ុណ្ណឹង"

គេទ្រានដៃនៅលើពូក លោមុខទៅជិតថ្ពាល់ ខ្សឹបដោយសំឡេងខ្សាវៗ ប៉ុន្តែកាច ព្រោះដឹងថានាងមិនទាន់ដេកលក់ និងឃើញនាងបើកភ្នែកធ្វើឡេមឡាម ហើយពេលនិយាយចប់ គេក៏នៅស្ងៀមមួយសន្ទុះ មិនព្រមងើបទៅណា មានចេតនាព្រួសខ្យល់ដង្ហើមក្តៅដែលលាយឡំដោយក្លិនស្រាលើថ្ពាល់រលោង បន្ទាប់មកក៏អស់សំណើចតិចៗ ងើបដើរចេញទៅវិញ ព្រោះមិនគិតថាមកធ្វើស្អីនាង ក្រៅពីមកប្រាប់តែប៉ុណ្ណឹង ទើប ស៊ិនស៊ូ ស្ទុះបុះពីគ្រែ រត់ទៅចាក់សោរទ្វារដោយបេះដូងលោតដុកដាក់។

"មនុស្សឆ្កួតធ្វើខ្លួនដូចចោរចូលមកក្នុងបន្ទប់អ្នកដទៃ ថែមទាំងមកបញ្ជានេះបញ្ជានោះទៀត ស្រវឹងហើយម៉េចក៏មិនទៅដេក ស្អប់ណាស់"

នាងនិយាយរអ៊ូៗ និងដើរមកផ្តួលខ្លួនដេកវិញ ម្តងនេះពិបាកនឹងសម្ងំដេក ចិត្តចេះតែគិតដល់រឿងរបស់ កាណែត។ គេចូលមកបញ្ជានាងដល់បន្ទប់ដេកបែបនេះ ប្រហែលខ្លាចនាងមិនទៅធ្វើការ ដែលនាងបានគិតរួចហើយ ប៉ុន្តែគេគំរាមបែបនេះហើយ នាងហ៊ានខ្លាំងឬ មនុស្សឆ្កួតនោះច្បាស់ជាទៅតាមឡូឡាឲ្យនាងខ្មាសគេគ្រប់កន្លែងមិនខាន។

# ១០

## ថ្ងៃបន្ទាប់ នៅការិយាល័យចម្ការតែ

"អត់ទោស ខ្ញុំមកជួបលោក កាណែត"

បារាំងស្រី សក់ទង់ដែង សម្បុរស មុខមាត់ស្រស់ស្អាត តែងខ្លួនថ្លៃថ្ន
ដោយរ៉ូបពណ៌ស សម្រុងត្រឹមក្បាលជង្គង់ មានកាបូបដៃម៉ាកល្បីពណ៌ផ្កាឈូក
ធ្វើពីស្បែកក្រពើពាក់នឹងកដៃ ដើរចូលក្នុងការិយាល័យ ដោះវ៉ែនតាចេញពីភ្នែក
ឈរមើល សុងចូ មិនដាក់ភ្នែក ព្រមទាំងពើងទ្រូង សួរជាភាសាអង់គ្លេស។

"អញ្ជើញអង្គុយ មិនជ្រាបថាបានណាត់ឬអត់?"

សុងចូ ងារដៃឲ្យអង្គុយ តែនាងមើលកៅអីនោះ ហើយពើងទ្រូង ធ្វើឫក
ក្រអឺតក្រទម ដាក់គេ។

"មិនបានណាត់ តែប្រាប់ទៅថា សានដ្រា ម៉ោរក"

ម្តងនេះ នាងនិយាយដោយសំឡេងគំរោះគំរើយ ព្រមទាំងបាញ់ខ្សែភ្នែក
ប្រមាថដាក់ទៀត។

"អូខេ អីចឹងចាំមួយភ្លែត ខ្ញុំសុំទៅរាយការណ៍ជូនលោក កាណែត សិន"

សុងចូ ងក់ក្បាល និងលួចធ្វើភ្នែកឡេមឡាម ហើយដើរចូលបន្ទប់ធ្វើការ

Scanned with CamScanner

របស់ចៅហ្វាយ។

"សូមអនុញ្ញាត លោក កាណែត មានភ្ញៀវមកសុំជួប នាងប្រាប់ថាឈ្មោះសានដ្រា"

សុងចូ ចូលមកក្នុងបន្ទប់ធ្វើការរបស់ចៅហ្វាយ ទាំងញញើតញញើម ហើយមើលទៅ ស៊ុនស៊ូ ដែលកំពុងមមាញឹកនឹងការធ្វើឯកសារ និងដើរយឺតៗទៅរកចៅហ្វាយ ដែលពេលនេះកំពុងមមាញឹកនឹងគំនរឯកសារនៅលើតុធំ។ ពេលទៅដល់ក៏ឈររាយការណ៍ ដោយទាំងក្រែងរអែង ខ្លាចចៅហ្វាយមួម៉ៅ។

"សានដ្រា ម៉ោធ្វើអី ?"

កាណែត ងើយមើលលេខាធិការមិនដាក់ភ្នែក ហើយចងចិញ្ចើមដោយការសង្ស័យថា សានដ្រា មកធ្វើអីទីនេះ។

"លោកឲ្យនាងចូលមកជួបទេ ?"

លេខាធិការលេបទឹកមាត់មិនចង់ចូលបំពង់.ក សួរដោយសំឡេងខ្សាវៗ ដោយមិនដឹងទេថាចៅហ្វាយ និងស្រីស្អាតឈ្មោះថា សានដ្រា ធ្លាប់ស្គាល់គ្នាឬអត់ តែមើលចៅហ្វាយរបស់គេស្គាល់ច្បាស់។

"អ្ហឹម ! ឲ្យចូលម៉ោបាន"

កាណែត ដៀងមើលជំនួយការលេខាធិការ ហើយញញឹមចុងមាត់ ទើបងាកមកប្រាប់ សុងចូ។

"បាទ ចាំខ្ញុំទៅអញ្ជើញនាងចូលមក"

សុងចូ ញញឹម ហើយដើរចេញទៅវិញភ្លាម ដើម្បីអញ្ជើញភ្ញៀវចូលមក។

"អ៊ីចឹង ខ្ញុំសុំទៅខាងក្រៅ ព្រោះលោកមានភ្ញៀវ"

ពេលឃើញឱកាសចេញពីបន្ទប់នេះបាន ស៊ុនស៊ូ ក៏ប្រញាប់ឆក់យកភ្លាម ប៉ុន្តែសំឡេងកាចរបស់គេឃាត់នាង ទាំងដែលមិនទាន់បានឱបឯកសារដើរចេញ។

"មិនបាច់ទៅណាទេ នៅក្នុងនេះហើយ ឬនាងហ៊ានមានបញ្ហាអីនឹងខ្ញុំ ស៊ុនស៊ូ"

កាណែត មិនអនុញ្ញាតឲ្យនាងចេញពីបន្ទប់ ព្រមទាំងបញ្ជាដោយសំឡេងកាច និងសម្លឹងមុខនាងមិនដាក់ភ្នែក។

"ហើយលោកឲ្យខ្ញុំនៅធ្វើអី បើមានភ្ញៀវចូលមកជួបលោកបែបនេះ ?"

នាងត្បុកសួរ ដោយសំឡេងគំរោះគំរើយ។

*ចេះបង្ខំគេទៅកើត ប្រុសឆ្កួតនេះ !*

អ្នកកំលោះងើបចេញពីតុ ដើរមករកដោយកាយវិការដាក់សម្ពាធ ទើបស៊ុនស៊ូ ឈានជើងថយក្រោយ ហើយទម្លាក់ខ្លួនលើសាឡុង បើកឯកសារមើលដើម្បីបន្លប់។

"ប៉ុណ្ណឹងធ្វើឯងរឿងច្រើន ឬចង់ប្ដូរការងារ ពីចម្ការតែទៅចម្ការក្រូច ឬកសិដ្ឋាន ដេកចាំទៅ បើខ្ញុំមិនអនុញ្ញាត កុំសង្ឃឹមថាបានទៅ"

កាណែត និយាយឡកឡឺយ សម្លឹងមើលនាងដែលងើបមុខមកមើល

Scanned with CamScanner

គេមិនដាក់ភ្នែក ហើយបែរខ្នង ដើរទៅតុធ្វើការវិញ។

"កាណែត"

សានជ្រា ដើរចូលមកក្នុងបន្ទប់ធ្វើការ ហើយរត់មកឱបចង្កេះ កាណែតពីក្រោយ និងស្រែកហៅគេដោយសំឡេងពីរោះ តែត្រូវគេចាប់បេះដៃចេញ និងបែរមករក ដែលធ្វើឲ្យនាងញញឹមពព្រាយ ស្រវាឱប.ករបស់កេ ព្រមទាំលោមកថើបមាត់លឿនដូចព្យុះ។

"សានជ្រា!" គេគំហកដាក់នាងដោយការមិនពេញចិត្ត។

គេនិងនាងធ្លាប់សេពគប់គ្នាមួយរយ: និងបែកគ្នាកាលពីបីឆ្នាំមុន។ នាងមិនធ្លាប់មកកូរ៉េខាងត្បូងទេ មានតែគេដែលទៅរកនាង ពេលទៅមើលការងារនៅបរទេស។ កាលមុនញឹកញាប់ ទៅម្តងៗ រាប់ខែ និងនាំនាងទៅគ្រប់ពេល រហូតដល់ចាប់បានថានាងលួចលាក់មានប្រុសផ្សេង ទើបគេបែកពីនាងភ្លាម ព្រោះធ្លាប់ព្រមព្រៀងគ្នាថាបើមានគេហើយ គឺហាមមានអ្នកផ្សេង តែនាងធ្វើខុសកិច្ចព្រមព្រៀង។ រឿងនេះ គេក៏មិនបានខូចចិត្ត ព្រោះមិនបានស្រឡាញ់អ្នកណាស្រាប់ហើយ គ្រាន់តែជាការព្រមព្រៀងគ្នាប៉ុណ្ណោះ ពេលនោះនាងក៏មិនខូចចិត្ត តែពេលនេះនាងមករកគេ ដើម្បីអ្វី។

"ស្អីគេ ហេតុអីមិនសប្បាយចិត្តដែលខ្ញុំមករកលោកដល់កូរ៉េខាងត្បូង"

ស្រីសក់ទង់ដែង ធ្វើជាងរង៉ក់ បំណងឲ្យគេលួង។

"ហើយហេតុអីខ្ញុំត្រូវសប្បាយចិត្ត បើយើងមិនត្រូវជាស្អីនឹងគ្នាផង"

គេញាក់ស្មាតិចៗ ដាក់ ព្រោះតែងតែសោះអង្គើយដាក់មនុស្សស្រីដែលទាត់ចោល ហើយកុំសង្ឃឹមថាបានចូលមកក្នុងជីវិតរបស់គេទៀត។

"ហេតុអីចិត្តអាក្រក់ដាក់គ្នាបែបនេះ ខ្ញុំខំមករកលោកដល់ទីនេះ ចម្ការលោកធំណាស់ ហើយស្អាតទៀត ខ្ញុំស្ញើចណាស់ មិនស្មានថាអ្នកជំនួញដូចលោកអាចរស់នៅទីនេះបាន តែពេលមកឃើញផ្ទាល់បែបនេះហើយ ជឿហើយថាដឹងតែរស់នៅបាន"

សានជ្រា អាម៉ាស់មុខគួរសមដែរ តែសម្របទឹកមុខឲ្យមានស្នាមញញឹម និងនាំនិយាយរឿងផ្សេងភ្លាម មិនចង់ជួញទុក្ខដាក់ខ្លួន។

"ទីនេះជាផ្ទះរបស់ខ្ញុំ ហើយហេតុអីខ្ញុំរស់នៅមិនបាន នាងមានការស្អីក៏និយាយម៉ោ ន្ទាលខ្ញុំធ្វើការបន្ត"

គេមើលស្រីស្អាតសិចស៊ីមិនដាក់ភ្នែក ហើយប្រាប់នាងដោយសំឡេងនឹងដូចទឹក។

"ខ្ញុំមករកព្រោះនឹក ហើយខ្ញុំក៏កក់បន្ទប់នៅកសិដ្ឋានសេះរបស់បងប្រុសលោកដែរ តាមពិតទៅ ចង់កក់នៅចម្ការតែ តែពេញអស់ ស្តាយណាស់ តែនៅកសិដ្ឋានសេះរបស់បងប្រុសក៏បាន"

"អ៊ីចឹងក៏អញ្ជើញទៅសម្រាកតាមសម្រួល"

"ខ្ញុំមករកព្រោះនឹក ខ្ញុំនៅស្រឡាញ់លោក កាណែត"

នាងធ្វើចរិតម៉ិកម៉ូក់ ព្រមទាំងលើកដៃឱប.ករបស់គេ ប្រឹងត្រសុលទៅកេ

Scanned with CamScanner

បំណាងឲ្យដើមទ្រូងធំហួសមាឌបៀតនឹងដើមទ្រូងរបស់គេ។

"សុំទោស សានជ្រា ខ្ញុំទៅរកនាងវិញមិនបានទេ ព្រោះពេលនេះខ្ញុំមានភរិយាហើយ ការដែលនាងមកប្រាប់ថាស្រឡាញ់ខ្ញុំ ខ្ញុំក៏រីករាយ តែទទួលយកមិនបានប៉ុណ្ណោះ"

កាណែត ធ្វើមុខធុញទ្រាន់ បេះដៃរបស់អតីតស្រីស្នេហ៍ចេញពីករបស់ខ្លួន ភ្នែកក៏ដៀងមើល ស៊ុនស៊ូ បន្តិច ហើយញញឹមចុងមាត់។

"លោកមានភរិយាហើយ? មិនពិតទេ មែនទេ ជារឿងអស្ចារ្យណាស់ ខ្ញុំមិនស្មានទេថាលោករៀបការរួចហើយ"

មុខរបស់ សានជ្រា ទៅជាស្លេកស្លាំងមួយរំពេច ក្រែងថាមិនទាន់មានភរិយា តែហេតុអី កាណែត ប្រាប់ថាគេមាន គេកំពុងកុហកនាងមែនទេ?

"មែន ហើយភរិយារបស់ខ្ញុំក៏នៅក្នុងនេះដែរ"

គេងក់ក្បាលបញ្ជាក់ ដោយទឹកមុខប្រាកដប្រជា ធ្វើឲ្យទំនុកចិត្តរបស់ស្រីស្អាតមានភាពរង្គោះរង្គើ។

"ឯណា កុំប្រាប់ណាថា..."

កាណែត ដើរទៅរក ស៊ុនស៊ូ ហើយស្រវាឱបចង្កេះនាងណែនដៃ ពេលឃើញនាងស្ទុះងើបឈរដោយការភ្ញាក់ផ្អើល ពេលឮគេប្រាប់ សានជ្រា ថាមានភរិយាហើយ ថែមទាំងមើលមកនាងទៀត ធ្វើឲ្យនាងញ័របេះដូង។

"នេះ ស៊ុនស៊ូ ភរិយារបស់ខ្ញុំ"

"មិនគួរឲ្យជឿ ខ្ញុំមិនចង់ជឿ"

"នាងត្រូវតែជឿ សានជ្រា"

"លោក កាណែត លោកធ្វើឆ្កួតស្អីលោកហ្នឹង!"

ស៊ុនស៊ូ ខាំធ្មេញក្រតៗ សួរគេខ្សឹបៗ ដោយការមិនពេញចិត្ត ដែលត្រូវគេយកធ្វើជាដំបងវាយឆ្កែបែបនេះ។

"នាងនៅឲ្យស្ងៀម និងធ្វើតាមខ្ញុំប្រាប់ ឬចង់មានបញ្ហានឹងខ្ញុំ ហ៊ឹម!"

គេមិនព្រមពន្លែងដៃ មានតែឱនកាន់តែណែន និងដាស់តឿនខ្សឹបៗ។

"ស្រីម្នាក់នេះជាភរិយារបស់លោក នាងមើលទៅដូចកម្មករជាង..."

ដំបូង សានជ្រា ចំហមាត់ឆ្ងង បន្ទាប់មកក៏ពេបមាត់ មើល ស៊ុនស៊ូ ដោយការប្រមាថ តែនិយាយមិនទាន់ចប់ផងប្រយោគស្រួលបួលផង ក៏ត្រូវកាណែត និយាយកាត់ឲ្យអាម៉ាស់មុខ។

"ជួយនិយាយពីភរិយារបស់ខ្ញុំឲ្យល្អបន្តិច សានជ្រា នាងអាចមើលទៅស្រមេកស្រមក តែយើងធ្វើការនៅចម្ការតែ វាត្រូវតែមានប្រឡាក់ដីប្រឡាក់ធូលីខ្លះហើយ តែខ្ញុំចូលចិត្ត មិនអីចឹង មិនយកធ្វើជាភរិយាទេ"

"ចាំ ខ្ញុំព្យាយាមជឿ រីករាយដែលបានស្គាល់ អ្នកស្រី...ឈើរសេទិ តើមានឈ្មោះអីដែរ សុំស្គាល់បានទេ?"

សានជ្រា និយាយរក ស៊ុនស៊ូ ជាភាសាអង់គ្លេស និងលូកដៃទៅសុំចាប់

ទាំងដែលមុននេះនាងនិយាយភាសាអង់គ្លេសផង កូរ៉េផងដាក់ កាណែត។

Scanned with CamScanner

"រីករាយដែលបានស្គាល់ អ្នកនាង សានជ្រា ខ្ញុំឈ្មោះ ស៊ុនស៊ូ សង្ឃឹមថាអ្នកនាងបញ្ចេញសំនៀងត្រូវ ព្រោះបានឮអ្នកនាងនិយាយភាសាកូរ៉េខ្លះដែរ សង្ឃឹមថាអ្នកនាងនិយាយជាមួយខ្ញុំជាភាសាកូរ៉េខ្លះដែរ បើអ្នកនាងមិនប្រកាន់ តែបើអ្នកនាងត្រូវការនិយាយជាមួយខ្ញុំជាភាសាអង់គ្លេស ខ្ញុំក៏មិនថា ខ្ញុំអាចនិយាយអង់គ្លេសបានតិចតួច បានឮថាអ្នកនាងមកស្នាក់នៅរីសតកសិដ្ឋានទីនោះស្អាតណាស់ មានកសិដ្ឋានសេះឲ្យទស្សនា និងជិះសេះលេង តែបើអ្នកនាងធុញទ្រាន់ អាចមកចម្ការតែបាន គយគន់បរិយាកាសធម្មជាតិ ចង់បេះស្លឹកតែមើលក៏បាន ទីនេះមានបង្រៀនផុងតែ ធ្វើនំពីតែ ដោយផលិតផលក្នុងចម្ការរបស់យើងនេះឯង សង្ឃឹមថាអ្នកនាងចាប់អារម្មណ៍ ដំណើរកម្សាន្តរបស់អ្នកនាងនឹងមិនសៅហ្មង ព្រោះមករក កាណែត តែគេមិនសូវទំនេរ អាចរវល់នៅជាមួយខ្ញុំរហូត ឲ្យសុំទោសផងដែលមិនអាចឲ្យស្វាមីទៅយកចិត្តយកថ្លើមស្រីផ្សេងបាន តែចង់បញ្ជាក់ថា អ្នកនាង សានជ្រា ហៅខ្ញុំអ្នកស្រី ឈើរ៉សទិ គឺត្រឹមត្រូវហើយ"

កាណែត មើលមុខអតីតស្រីស្នេហ៍ ហើយដកដង្ហើមធំ ប្រុងឆ្លើយជំនួស តែត្រូវចំហមាត់ផ្លុងតែម្តង ពេល ស៊ុនស៊ូ លេងរៀបរាប់ជាភាសាអង់គ្លេសដោយប្រយោគវែងអន្លាយ ប្រភេទនិយាយមិនដកដង្ហើមបែបនេះ និងនិយាយបានត្រូវសំនៀងទៀតផង ខណៈដែល សានជ្រា ទៅជាស្រឡាំងកាំង ព្រោះឃើញស្រមេកស្រមកបែបនេះ គិតថាមិនយល់ភាសាអង់គ្លេស។



ពេលនិយាយចប់ ស៊ុនស៊ូ ក៏ឱបចង្កេះរបស់អ្នកដែលមានឈ្មោះជាជាស្វាមី ដូចដែលគេកំពុងឱបនាង ធ្វើជាបង្ហាញក្តីស្រឡាញ់ដែលមានចំពោះគ្នាឲ្យជនទីបីបានឃើញ។

"អី ចាំ អ្នកស្រី ឈើរ៉សទិ ខ្ញុំអាចមករំខានម្តងម្កាល តែបើសុំឲ្យ កាណែត នាំដើរលេង អ្នកស្រីមិនថាអីទេ ណាំះ"

"មិនថាអីទេ ព្រោះខ្ញុំក៏ទៅជាមួយដែរ ស្វាមីរបស់ខ្ញុំជាបុរសសម្បូរស្នេហ៍ ខ្ញុំខ្លាចគេត្រូវស្រីស្អាតដូចអ្នកនាងល្បួងបាន ឬអ្នកនាងមិនអាចឲ្យខ្ញុំទៅជាមួយបាន ខ្ញុំនឹងបញ្ជូនកូនចៅឲ្យជូនអ្នកនាងដើរលេង"

ស៊ុនស៊ូ តាំងខ្លួនជាអ្នកស្រី ឈើរ៉សទិ និយាយស្តីសុភាពថ្លៃថ្នូរ តែអ្នកស្តាប់ទៅជាញ័រខ្លួន។

"អ៊ីចឹងខ្ញុំសុំទៅសម្រាកសិនហើយ មកពីហាត់ ស្អិតខ្លួនដែរ ធ្វើដំណើរផ្លូវឆ្ងាយ សម្រាកបន្តិចក៏ល្អ"

សានជ្រា មានអារម្មណ៍ស្លឹកមុខ ទើបប្រញាប់នាំខ្លួនឯងចេញពីត្រង់នេះជាបន្ទាន់ ទាំងដែលមកទីនេះ ដើម្បីវាយលុក តែបែរជាត្រូវបណ្តេញ ទាំងដែលមិនទាន់បញ្ចេញក្បួនបានមួយក្បាច់ផង។

"អញ្ជើញ ចាំឲ្យ លេខា ហុង ជូនទៅ"

ស៊ុនស៊ូ ងាវដៃ តែពើងទ្រូងដាក់ តែមមាត់មានស្នាមញញឹមតិចៗ ដែលត្រឹមប៉ុណ្ណឹងក៏ឈ្នះដាច់ទៅហើយ។



Scanned with CamScanner

"មិនបាច់ក៏បាន ខ្ញុំនាំអង្គរក្សមកជាមួយ និងអ្នកបើកឡានរបស់ចម្ការ គិតថានៅចាំខាងក្រៅ"

"តាមសម្រួល ធ្វើខ្លួនដូចនៅផ្ទះខ្លួនឯងបាន"

ស៊ិនស៊ុ ញញឹមដាក់ ពេលនិយាយ តែស្រីស្អាត ធ្វើមុខក្រមូវដាក់ មិនចង់និយាយរក តែពេលងាកទៅរក កាណែត បែរជាញញឹមដាក់ ទាស់ត្រង់គេធ្វើឫកជម្មតាៗ មិនញញឹមដាក់វិញ។

"ខ្ញុំទៅកន្លែងសម្រាកហើយ ចាំមករកលោកទៀត"

សានជ្រា ប្រុងដើរទៅជិត កាណែត ដើម្បីថើបលា តែត្រូវខ្សែភ្នែករបស់ស៊ិនស៊ុ បាញ់មករកមិនព្រិចតែម្តង ទើបមិនហ៊ាន បានត្រឹមតែប្រាប់គេ ហើយដើរចេញពីបន្ទប់ ដោយដំណើរស្រីស្អាត។

"ដកដៃចេញពីចង្កេះរបស់ខ្ញុំទៅ ដកចេញ!"

ស៊ិនស៊ុ ងាកមករុញដើមទ្រូងរបស់គេចេញឲ្យឆ្ងាយពីខ្លួនភ្លាម ដោយទឹកមុខក្រមូវ ព្រោះខឹងមនុស្សមុខក្រាស់ ដែលប្រើនាងឲ្យធ្វើការគ្រប់សព្វ តាំងពីរូមការងារ ដល់រឿងឯកជន។

"អេាំ! កំពុងស៊ីអារម្មណ៍ មិញឲ្យអារម្មណ៍ដូចប្រពន្ធហួងហែងប្តីយ៉ាងអីចឹង"

កាណែត សើចហ៊ឹៗ ចំអន់នាងឲ្យក្រហមមុខ។

"មនុស្សមុខក្រាស់ អ្នកណាចង់ធ្វើជាប្រពន្ធរបស់លោក និយាយមិនចេះ



ខ្មាសមាត់"

"មិនសាកធ្វើបន្តិចទេអី ក្រែងលនាងចូលចិត្ត ហ៊ឹៗ"

កាណែត ញញឹមចុងមាត់ ព្រមទាំងលើកចិញ្ចើមមើលនាងតាំងពីក្បាលដល់ចុងជើង ដោយខ្សែភ្នែកប្រឡឹម។

"ឈប់និយាយស្តីឈ្លើយៗ ទៅ"

"អូខេ បាន តែមិញខ្ញុំប្រាប់ សានជ្រា ហើយថានាងជាប្រពន្ធរបស់ខ្ញុំ នាងត្រូវតែធ្វើតាមហ្នឹង យល់ទេ បើ សានជ្រា ដឹងថាមិនមែន ខ្ញុំនិងនាងមិនមែនជាប្តីប្រពន្ធនឹងគ្នា ខ្ញុំនឹងចាត់ការនាង"

"ស្អីគេ!"

"ធ្វើ ឬមិនធ្វើតាមបញ្ជាខ្ញុំ?"

កាណែត ខិតមកជិត ដោយទឹកមុខកាច ឲ្យនាងថយក្រោយ គេច។

"ធ្វើក៏បាន!"

នាងឆ្លើយញាប់មាត់ ព្រោះខ្លាចគេខិតមកដល់ ហើយសម្លក់ថ្មៃ។

"តែប៉ុណ្ណឹង"

គេញញឹមពេញចិត្ត ហើយដើរចូលតុធ្វើការវិញ ទាញឯកសារមើលបន្តតែខណៈនោះក៏លួចមើលស្រីមុខខ្មួរ ដែលមាត់នៅតែអេចអូច រអ៊ូរទាំពីគេ តែគេមិនខ្វល់។



Scanned with CamScanner

ពេលរសៀល

"យើងត្រូវចេញទៅមើលចម្ការកាកាវ លោក ឬឲ្យខ្ញុំលើកពេល ?"

សុងចូ ចូលមករំឭក ព្រោះហួសពេលជាងដប់នាទីហើយ មិនឃើញចៅហ្វាយចេញពីបន្ទប់ធ្វើការ។

"កំពុងចាំឲ្យលោក ស៊ីន មកយកលុយ ដែលទិញដីរបស់គេជាប់ចម្ការរបស់យើង លុយមួយចំនួនទៀត ណាត់គេមកយកថ្ងៃនេះ ម៉េចក៏ក្រម៉ោម្លេះ"

"តិចទៀតគង់តែម៉ោទេ ឲ្យខ្ញុំតេរទៅប្រាប់មេការកម្មករទេ ថាលុបចោលការទៅចម្ការកាកាវថ្ងៃនេះ ?"

"មិនបាច់ យើងត្រូវចូលចម្ការកាកាវ រឿងលុយ ផ្ញើនឹង ស៊ុនស៊ូ ទុកឲ្យគេទៅចុះ ហៅនាងចូលមកបន្តិច"

"បាទ"

សុងចូ ចេញទៅហៅជំនួយការរបស់ខ្លួន ដែលកំពុងថតចម្លងឯកសារនៅខាងក្រៅ ហើយនាងក៏ដើរចូលមកដោយទឹកមុខស្មើ ព្រោះចៅហ្វាយបញ្ជាឲ្យទៅថតឯកសារ តែនេះមិនទាន់រួចរាល់ផង។

"មានការអី ?"

នាងសួរដោយទឹកមុខស្មើដដែល និងមើលគេដោយការមិនទុកចិត្ត។

"ខ្ញុំត្រូវចូលចម្ការកាកាវជាមួយ សុងចូ នាងមិនបាច់ទៅទេ នៅទីនេះហើយ"

"ល្អ"

"មិនបាច់សប្បាយចិត្តទេ ខ្ញុំឲ្យនាងយកលុយនេះឲ្យមនុស្សម្នាក់ ខ្ញុំចាំគេយូរហើយ មិនឃើញមកសោះ"

កាណែត បាញ់ខ្សែភ្នែកកាចដាក់អ្នកដែលញញឹមញញែម ពេលដឹងថាមិនចាំបាច់ទៅជាមួយគេ ដោយការជិនឆ្អន់។

"អ្នកណា ?"

"ម្នាក់នេះ ឈ្មោះ ស៊ីន គេពង់ ខ្ញុំទុកលុយក្នុងថតតុ នេះកូនសោ ផ្ញើនឹងនាង បើគេម៉ោ សុំអត្តសញ្ញាណប័ណ្ណគេមើលផងថាត្រូវគ្នាទេ បើត្រូវហើយ យកឯកសារនេះឲ្យគេស៊ីញ៉េ និងឲ្យលុយគេទៅ ខ្ញុំទៅមួយសន្ទុះទេ ម៉ោវិញហើយ"

កាណែត ហុចសំណៅអត្តសញ្ញាណប័ណ្ណ រូបថត ឯកសារពាក់ព័ន្ធនឹងការទទួលប្រាក់ឲ្យនាងមើល រួមទាំងប្រាក់ក្នុងស្រោមសំបុត្រពណ៌ត្នោត យកមកដាក់ម៉ាស៊ីនរាប់ បន្ទាប់មកទុកវាក្នុងស្រោមវិញ ដាក់ក្នុងថតតុ ចាក់សោ និងហុចកូនសោឲ្យនាង។

"ចាំ"

ស៊ុនស៊ូ យកកូនសោមកទុកដាក់ ព្រោះតាមរយៈចំនួនទឹកប្រាក់ ដែលម៉ាស៊ីនរាប់ឲ្យឃើញអម្បាញ់មិញ បើបាត់ ដឹងតែមានបញ្ហាធំហើយ។

"តោះ សុងចូ ប្រាប់មេការកម្មករឲ្យចាំបន្តិច យើងកំពុងទៅហើយ"

ពេលបញ្ជារួច អ្នកកំលោះក៏យកម្ហូកហាមធំមកកាន់ និងងាកទៅប្រាប់



សុងចូ ហើយបណ្ដើរគ្នាចេញទៅ ចំណែក ស៊ុនស៊ូ ដែលតាមមើលពីក្រោយក៏ដកដង្ហើមធំ ធូរទ្រូងតែម្ដង ព្រោះអាចធ្វើការបានស្រួល មិនចាំបាច់មានគេចាំសម្លឹងសម្លក់គ្រប់ពេល។

នាងយកឯកសារទៅថតចម្លងបន្ត ទាល់តែរួចរាល់ ហើយអង្គុយរៀបចំឲ្យមានរបៀប និងបែងចែក ព្រោះមួយចំនួនត្រូវយកទៅឲ្យបងប្រុសទាំងពីររបស់ កាណែត ប្រើប្រាស់ដែរ។

"អត់ទោស មានគេមកសុំជួបលោក កាណែត" បុគ្គលិកសន្តិសុខចូលមកប្រាប់។

"អ្នកណា ឈ្មោះអី?"

"ស៊ីន តេពង់"

"អ្ហូៗ អីចឹងឲ្យគាត់ចូលមក"

"បាទ"

ពេលបុគ្គលិកសន្តិសុខនាំភ្ញៀវចូលមក នាងក៏យកអត្តសញ្ញាណប័ណ្ណពីភ្ញៀវ មកផ្ទៀងផ្ទាត់នឹងឯកសារក្នុងដៃរបស់ខ្លួន ពេលឃើញថាត្រឹមត្រូវហើយទើបឲ្យស៊ីញ៉េ ទទួលយកប្រាក់។

គ្រិត...គ្រិត...

ពីរម៉ោងក្រោយមក ទូរសព្ទដៃរបស់នាងរោទ៍ ពេលយកមកមើល ឃើញឈ្មោះ កាណែត ទើបចុចទទួល។



"មានការអី លោក ស៊ីន មកយកលុយរួចហើយ"

(ស្អីគេ នាងថាម៉េច ស៊ុនស៊ូ លោក ស៊ីន មកយកលុយហើយឬ?)

កាណែត សួរបញ្ជាក់ដោយការភ្ញាក់ផ្អើល ពេលនាងប្រាប់បែបនេះ។

"ចាំ គេមកយកលុយកាលពីពីរម៉ោងមុន លោកចេញទៅបានមួយភ្លែតហ្នឹង គេក៏ម៉ោ"

(ឆ្កួតមែន គេទើបតែតេរមកប្រាប់ខ្ញុំមិញនេះឯង ថាគេមិនបានទៅយកលុយទេថ្ងៃនេះ គេមានគ្រោះថ្នាក់បាក់ជើង ទើបតែទៅរកពេទ្យ)

"ហ៊ឺ? លោកកុហកមែនទេ គឺមុននេះអ្នកមកយកលុយគឺគេ ឯកសារត្រឹមត្រូវទាំងអស់ មុខមាត់ដូចក្នុងរូបថត ហើយបែបនេះម៉េចអាចទៅ"

(ខ្ញុំដល់ការិយាល័យហើយ ចូលទៅឥឡូវហើយ)

នាងឈរកាន់ទូរសព្ទសំកាំង ពេល កាណែត ដាក់ទូរសព្ទចុះទៅហើយដោយស្មានមិនដល់ ទឹកមុខក៏ស្លេកស្លាំង បន្ទាប់មកទឹកភ្នែកក៏ហូរដោយមិនដឹងខ្លួន តែពេលដឹងខ្លួនក៏ប្រញាប់លើកដៃជូត ដាក់ទូរសព្ទចុះ ហើយគិតថាតើមានរឿងអីកើតឡើងចំពោះនាង។

"ឯណាឯកសារ លោក ស៊ីន"

កាណែត ដើរមកឈរនៅមុខតុធ្វើការរបស់នាង សួររកឯកសារដោយទឹកមុខកាច ដែលធ្វើឲ្យនាងខ្លាច។

"នៅតុលោក"





Scanned with CamScanner

"តាមខ្ញុំម៉ោ"

គេបញ្ជា ហើយដើរចូលបន្ទប់ធ្វើការ នាងក៏ហឹតសម្បោរ ដើរតាមភ្លាម ដោយមាន សុងចូ តាមមើលដោយការព្រួយបារម្ភ តែមិនបានដើរទៅតាម។

"អង្គុយចុះ"

គេបញ្ជានាងឲ្យអង្គុយ ចំណែកខ្លួនឯងពិនិត្យមើលឯកសារ ហើយបើកកាមេរ៉ាសុវត្ថិភាពមើល។

"ជាគេមែន មុខមាត់ដូចគ្នាទាំងអស់ មិនខុសទេ"

នាងលូកមាត់ ពេលឃើញគេចងចិញ្ចើម មើលទៅគួរឲ្យខ្លាច ព្រោះមិនធ្លាប់ឃើញគេមានទឹកមុខបែបនេះទេ តែគេមិននិយាយរក ក្រៅពីងាកមុខចេញពីកុំព្យូទ័រ មកមើលមុខនាង ហើយទាញទូរសព្ទចុចតេរ។

"សួស្តី លោក ស៊ីន ខ្ញុំសុំសួរនាំបន្តិច ថាមានអ្នកណា ឬសាច់ញាតិរបស់លោក មានមុខមាត់ស្រដៀងគ្នាទេ ឬលោកមានបងប្អូន អ្ហ៎! អ៊ីចឹងឬ បាទបាន លោក ស៊ីន គ្មានអីទេ"

គេនិយាយជាមួយអ្នកចុងខ្សែចប់ ក៏ដាក់ទូរសព្ទចុះ ហើយងាកមកបញ្ជានាង។

"ទៅហៅ សុងចូ ចូលម៉ោ"

"ចាំ ហើយលោក ស៊ីន គេថាម៉េច?"

"ទៅហៅ សុងចូ ចូលម៉ោ ហើយនាងចាំនៅខាងក្រៅ ទាល់តែខ្ញុំហៅ"

គេមិនឆ្លើយសំណួរ តែបញ្ជាដោយទឹកមុខនិងសំឡេងកាច។

នាងក្រមុំក្តាប់មាត់ មើលគេមួយភ្លែត ហើយដើរចេញទៅទាំងចង់យំ តែពេល សុងចូ ទៅចូលក្នុងបន្ទប់ នាងក៏យំ ដោយមិនចេញសំឡេង ទឹកភ្នែកហូរនិងរង់ចាំទាល់តែ សុងចូ ចេញមកវិញ ទើបនាងដើរទៅរកគេ។

"លេខា ហុង មានរឿងអី ខ្ញុំមិងមាំងអស់ហើយ"

"ឃើញថាអ្នកមកយកលុយ មិនមែនលោក ស៊ីន តែជាអ្នកផ្សេង ដែលមានមុខមាត់ស្រដៀងគ្នា គិតថាគួរតែជាសាច់ញាតិ មិនអ៊ីចឹង មិនអាចយកអត្តសញ្ញាណប័ណ្ណរបស់លោក ស៊ីន មកប្រើបានទេ លោក កាណែត ឲ្យខ្ញុំទៅតាមមើលគេនៅផ្ទះ ថាគេបាក់ជើងមែនឬអត់ ព្រោះអ្នកមកទីនេះដើរត្រុយ បើមានរបួសមែន គឺឲ្យយកលុយនៅសល់ទៅឲ្យគេដោយផ្ទាល់ និងយកឯកសារទៅឲ្យលោកប៉ូលិស សុង ជួយចាត់ការ"

សុងចូ មានទឹកមុខតានតឹង ពេលប្រាប់នាង។

"ម៉េចក៏ទៅជាបែបនេះ ហ៊ឹក!"

នាងយំ ទន់ជង្គង់ ចង់ដួល ព្រោះប្រាក់ច្រើនយ៉ាងហ្នឹង។

"អ៊ី...លោក កាណែត ប្រាប់ឲ្យជំនួយការ កាំង ចូលទៅក្នុងបន្ទប់"

"ចាំ"

នាងស្លេកមុខម្តងទៀត លើកដៃជូតទឹកភ្នែក ហើយប្រឹងលេបទឹកមាត់ មិនហ៊ានមើលមុខ សុងចូ ចំ ពេលដើរចូលបន្ទប់ធ្វើការរបស់ចៅហ្វាយ ដែល

Scanned with CamScanner

ពេលនេះបរិយាកាសស្ងប់ស្ងាត់ណាស់ មើលទៅគួរឲ្យខ្លាច ទើបដើរទ្រោនៗទៅអង្គុយនៅមុខតុធ្វើការរបស់គេ។

"ភាពធ្វេសប្រហែសដែលកើតឡើងនេះ ចាត់ទុកថាជាកំហុសរបស់ខ្ញុំដែរ និងត្រូវរកអ្នកជួយទទួលខុសត្រូវ បើចាប់ជនទុច្ចរិតមិនបាន គឺមានន័យថាមិនបានលុយមកវិញ ឬបើចាប់បាន តើបានលុយមកវិញទេ រឿងនេះគឺមិនច្បាស់អីចឹងហើយ នាងត្រូវទទួលខុសត្រូវលុយដែលបាត់បង់នោះពាក់កណ្ដាល ទម្រាំចាប់ជនទុច្ចរិតនោះបាន"

សម្ដីដែលនិយាយចេញមកដោយគ្មានក្ដីមេត្តា ធ្វើឲ្យនាងចំហមាត់ឆ្ងល់។

"តែខ្ញុំគ្មានលុយច្រើនយ៉ាងហ្នឹងទេ"

"កុំបារម្ភអី ខ្ញុំមិនទាររនៅពេលនេះទេ តែចន្លោះពេលនេះ ខ្ញុំចាត់ទុកថានាងជាកូនបំណុលរបស់ខ្ញុំ យល់ទេ"

"ចាំ"

នាងខាំមាត់ ឆ្លើយតប ដោយព្រមទទួលយកការពិតនេះ។

"ខ្ញុំឲ្យ សុងចូ ចាត់ការស្អែកនេះ បានការយ៉ាងណា ចាំគិតគ្នាទៀត"

នាងបានតែងក់ក្បាលទទួល និងលើកដៃជូតទឹកភ្នែកដោយមិនមាត់ក។

"កុំប្រាប់ម៉ីង"

ពេលពិចារណាមួយសន្ទុះហើយ នាងក៏ងើបមុខមកសុំចិត្តគេ ព្រោះមិនត្រូវការឲ្យម្ដាយមីងមកលំបាកចិត្តជាមួយខ្លួនពីរឿងនេះ។

"អ្ហឹម! ចេញទៅលុបលាងមុខមាត់ និងធ្វើខ្លួនឲ្យសមជានាងបន្ទិចទៅ ស៊ុនស៊ូ ឃើញបែបនេះហើយ ខ្ញុំមិនសុំភ្នែកទេ"

នាងងើបមុខមកសម្លក់សម្លឹង ពេលគេនិយាយបែបនេះ។

"អ្នកណាទៅមានដូចលោក លុយប៉ុណ្ណឹង លោកគ្មានអារម្មណ៍អីទេ តែខ្ញុំក្រ ឲ្យគ្មានអារម្មណ៍អី វាមិនបានទេ កុំឲ្យខ្ញុំមានម្ដងឲ្យសោះ"

នាងនិយាយស្ដីគំរោះគំរើយដាក់គេដោយការបញ្ឈឺដង ពេលងើបឈរសម្លឹងមុខគេ ហើយដើរចេញទៅ តែមិនទាន់បានបើកទ្វារផង កាណែត ក៏ដើរមកទ្រានដៃនឹងទ្វារ ទ្រាបពីក្រោយ។

"ធ្វើជាប្រពន្ធរបស់ខ្ញុំសាកមើលទេ ធានាថានាងនឹងមាន ឲ្យគេឯងច្រណែនលេង"

គេឈ្ងោកមកជិត មុខសឹងតែពិតគ្នាទៅហើយ ពេលខ្សឹបប្រាប់។

"ថយចេញទៅ មនុស្សឆ្កួត និយាយស្ដីគួរឲ្យស្អប់"

មុខរបស់នាងក្រហមង៉ាំង ព្រឺសម្បុរពេញខ្លួន ថយកែងដៃបុកពោះ តែគេដឹងទាន់ ទើបស្រវាឱបនាងណែនដៃ មិនឲ្យធ្វើអីរាងកាយរបស់គេបាន។

"ចង់ហិង្សារាងកាយរបស់ខ្ញុំបែបនេះ សង្ស័យគិតការថែមទេដឹង"

ពេលគេដាក់ចង្កាលើស្មា ក៏ធ្វើឲ្យនាងស្រៀវក្នុងទ្រូង ទើបគ្រវែងខ្លួនដើម្បីឲ្យរបូតពីរង្វង់ដៃរបស់គេ ប៉ុន្តែគេរឹតដៃកាន់តែណែន និងនិយាយទាំងអស់សំណើច។

Scanned with CamScanner

"ពន្លែងខ្ញុំភ្លាម មិនអីចឹង ខ្ញុំនឹងស្រែកខ្លាំងៗ"

"ខ្ញុំមិនទាន់បានធ្វើអីផង ឡូឡាធ្វើអី ហ៊ឺៗ"

គេញ៉ោះដោយការថើបថ្ពាល់នាងមួយខ្សឹត ទើបព្រមពន្លែងដៃ ទើបនាងប្រញាប់ថយចេញឲ្យឆ្ងាយភ្លាម ហើយលើកដៃក្តោបថ្ពាល់ ក្តាប់មាត់ និងសម្លឹងដោយខ្សែភ្នែកឆ្នាសឆ្នើម បន្ទាប់មកក៏ធ្វើធើយដាក់ ដោយការដើរចេញពីបន្ទប់ទៅរម្ងាប់អារម្មណ៍នៅតុធ្វើការរបស់ខ្លួន និងមិនហ៊ានមើលមុខ សុងចូ។

ដល់ម៉ោងចេញពីធ្វើការ នាងរៀបចំឯកសារទុកដាក់ ទាញកាបូបមកស្ពាយ ហើយដើរទៅរក សុងចូ ខ្សឹបខ្សៀវសួរគេ។

"លេខា ហុង ស្នែកលោកទៅរក លោក ស៊ីន ម៉ោងប៉ុន្មាន ឲ្យខ្ញុំទៅដែរបានទេ?"

"ជំនួយការ កាំង ចង់ទៅដែរ ប្រាប់លោក កាណែត ហើយនៅ ខ្ញុំថាកុំអីល្អជាង ក្រែងមានគ្រោះថ្នាក់ ស្អែកខ្ញុំទៅជាមួយលោកប៉ូលិស សុង និងមេធាវីរបស់លោក កាណែត"

សុងចូ និយាយទាំងញញឹមមិនសម បើប្រាប់ថាឲ្យនាងទៅជាមួយជានាថាលោក កាណែត លេងគេងាប់ ឲ្យអត់ដឹកប់មិនខាន។

"មិនបាច់ប្រាប់គេក៏បាន"

"តែខ្ញុំឮហើយ រឿងនេះខ្ញុំបញ្ឈប់ហើយ ហើយនាងមិនបាច់ទៅចេះដឹងទេ ទុកឲ្យមនុស្សរបស់ខ្ញុំចាត់ការទៅ រៀបចំអីវ៉ាន់ហើយ ទៅផ្ទះ ម៉ោរញ៉េរញ៉ៃនឹងការងាររបស់អ្នកដទៃ ឲ្យគេលំបាកចិត្តធ្វើអី"

ស៊ុនស៊ូ ភ្ញាក់ព្រើត ព្រោះសម្តីកាចរបស់ កាណែត បន្លឺឡើងនៅក្រោយខ្នងតែម្តង។ ការពិតទៅ គេមកតាំងពី សុងចូ សើចញឹមៗដាក់នាងម្លេះ ប៉ុន្តែ សុងចូ មិនហ៊ានប្រាប់។

"ជាខ្មោចឬយ៉ាងម៉េច ចូលចិត្តម៉ោស្ងាត់ៗ រហូត"

នាងងាកខ្ទាប់ទៅស្តីឲ្យ ហើយធ្វើធើយដាក់ដោយការងរង៉ក់ ដើរចេញពីត្រង់នោះ សំដៅឡានរបស់គេ ឈរពើងទ្រូងនៅក្បែរនោះ រង់ចាំឲ្យគេមកបើកទ្វារឲ្យ ដោយទឹកមុខក្រមូវ។

ពេលមកដល់ គេក៏សម្លឹងមុខមិនដាក់ភ្នែក ទាល់តែនាងផ្ទៀងខ្លួនចេញ ទើបដោះសោទ្វារឲ្យឡើង ហើយបើកឡានចេញទៅ ដោយមិនមាត់រកគ្នា។

ត្រឺត...ត្រឺត...

សំឡេងទូរសព្ទបន្លឺឡើង ស៊ុនស៊ូ ក៏រកមើលថាវានៅត្រង់ណា ព្រោះមិនច្បាស់ជារបស់ខ្លួនឯងឬអត់។

"របស់ខ្ញុំ"

កាណែត ប្រាប់ ហើយលើកវាដាក់ត្រចៀក។

"មានការអី សានដ្រា?"

(គ្មានអីទេ គ្រាន់តែស្អែកនេះ ខ្ញុំសុំណាត់លោកនិងភរិយាមកឱននន័រនៅបន្ទប់របស់ខ្ញុំ ខ្ញុំទើបមកដល់ ចង់អញ្ជើញលោកញាំបាយ តែបើអញ្ជើញលោក



Scanned with CamScanner

មកម្នាក់ឯង ភរិយារបស់លោកដឹងតែមិនព្រម សង្ស័យថាលោកមិនបដិសេធ)

"អ៊ឹម! ចាំសួរភរិយារបស់ខ្ញុំសិន ម៉េចដែរ អ្នកស្រី ឈើរ៉សេទិ សានត្រា អញ្ជើញញ៉ាំបាយស្អែកនេះ"

"ទៅក៏ទៅ"

ស៊ិនស៊ុ ធ្វើជាឆ្លើយដោយសំឡេងម្មិកម៉្ញក់ តែទឹកមុខសឹងតែសម្លាប់គេឲ្យបាន។

"អូខេ ស្អែកជួបគ្នា ភរិយារបស់ខ្ញុំអនុញ្ញាតហើយ បាយ"

កាណែត ញញឹមចុងមាត់ និងបន្ទាប់ពីប្រាប់ សានត្រា ហើយក៏ចុចផ្តាច់ទូរសព្ទ។

"ញញឹមរីកមុខដល់ហើយ"

នាងក្រមុំអត់មិនបាននឹងដៀមដាម ព្រោះគិតថាគេរីករាយដែលនឹងបានទៅខីននីជាមួយសង្សារចាស់។

"សប្បាយចិត្តដែលប្រពន្ធទៅជាមួយ"

"លោក កាណែត កុំនិយាយបែបនេះ ខ្ញុំមិនមែនប្រពន្ធរបស់លោកទេ"

"ហ្នឹកហាត់ទៅ ស្អែកនេះត្រូវសម្តែងទៀត បើត្រូវចាប់បាន ខ្ញុំនឹងចាត់ការនាងហើយ ចាំមើលទៅ"

"ពូកែតែគំរាមហ្នឹងហើយ ខ្លាចងាប់ហើយ"

នាងបែរមុខចេញ និយាយអ៊ែៗ ដាក់ខ្លួនឯង។

"បើធ្វើលើសគំរាម ខ្លាចអ្នកខ្លះយំ ម៉េចដែរ ឬចង់ឲ្យធ្វើ ក៏បាន មិនបាច់គំរាមក៏ល្អ កុំឲ្យខាតពេលនិយាយច្រើន"

"ឈប់និយាយភ្លាម"

សម្តីរបស់គេ ធ្វើឲ្យនាងក្តៅមុខភាយៗ ព្រោះយល់ន័យ។

"ហ៊ឹៗ"

គេសើច ហើយបើកចម្រៀងក្នុងឡានស្តាប់ រហូតដល់ផ្ទះធំ តែពេលចតឡានហើយ ប្រញាប់ងាកមកស្រវាចាប់ដៃនាងជាប់។

"ស្អែក រៀបចំខ្លួនទៅខីននីជាមួយខ្ញុំ មិនបាច់តែងខ្លួនស្អាតពេកទេ បែបនេះក៏បាន គ្រាន់តែទៅកសិដ្ឋានសេះប៉ុណ្ណោះ ឬចង់ស្អាតក៏តាមចិត្ត"

"ខ្ញុំក៏មិនចង់ទៅដែរ បែបនេះក៏បាន ប៉ុណ្ណឹងមែនទេដែលលោកត្រូវការប្រាប់ ពន្លែងបានហើយ ន្លាលទៅងូតទឹក មកញ៉ាំបាយ"

"ប៉ុណ្ណឹងឯង"

គេព្រមពន្លែងដៃ ញញឹមចុងមាត់ និងវាយចិញ្ចើមដាក់មួយខ្ទាច់ ធ្វើឲ្យនាងជ្រេញមហាជ្រេញ ប្រញាប់ដោះខ្សែក្រវាត់ ចុះពីឡាន ដើរចូលទៅក្នុងផ្ទះមិនរង់ចាំឲ្យគេចុះ មកដើរតាមទាន់ ប៉ុន្តែគេតាមទាន់ឲ្យទាល់តែបាន។

"ដើរតាមខ្ញុំធ្វើអី?"

"អត់មានទេ គឺឡើងទៅខាងលើដូចគ្នា ចង់ងូតទឹក ផ្លាស់ខោអាវ ចុះមកញ៉ាំបាយឲ្យស្រួលខ្លួន"

Scanned with CamScanner

គេនិយាយដោយទឹកមុខពព្រើម ព្រោះតាមពិតទៅមានចេតនាដើរតាមនោះឯង ទាំងដែលដើរវ៉ាក៏បាន។

"អ៊ីចឹងឡើងទៅមុនទៅ ឡើងទៅ"

ស៊ុនស៊ូ ឈានថយក្រោយមួយជំហាន ហើយប្រើដៃទាំងពីររុញខ្នងគេ ទើបគេព្រមដើរទៅមុន ថែមទាំងអស់សំណើចឲ្យឮទៀត និងទាល់តែគេចូលបន្ទប់បាត់នោះឯង ទើបនាងព្រមបើកទ្វារបន្ទប់ដេករបស់ខ្លួន។

ព្រឹកថ្ងៃបន្ទាប់

ស៊ុនស៊ូ មកដល់ការិយាល័យដំណាលចៅហ្វាយ ព្រោះជិះឡានជាមួយគេនោះឯង ហើយពេលមកដល់ នាងក៏ញញឹមពព្រាយដាក់ សុងចូ តែប្រញាប់បិទស្នាមញញឹមភ្លាម ពេល កាណែត ងាកមកសម្លឹងមុខ។

"សុងចូ ចូលបន្ទប់ខ្ញុំ"

ពេលបញ្ជារួច គេក៏ដើរចូលទៅមុន។

"បាទ"

"សុំលោក កាណែត ឲ្យខ្ញុំទៅផង"

នាងកេះ សុងចូ ដែលកំពុងបើកទ្វារបន្ទប់របស់ចៅហ្វាយ។

"អឺ...ខ្ញុំនឹងព្យាយាម"

សុងចូ សើចញឹមៗ ដើរចូលទៅ មួយសន្ទុះក៏កាន់ស្រោមសំបុត្រពណ៌ត្នោត ដើរចេញមកវិញ ទើបនាងស្ទុះមករក។

"យ៉ាងម៉េចដែរ ?"

"លោក កាណែត មិនអនុញ្ញាតទេ ខ្ញុំទៅធ្វើការសិន"

"អរគុណ"

នាងនិយាយទាំងទឹកមុខស្រពោន និងព្រមថយទៅតុធ្វើការរបស់ខ្លួន មើល សុងចូ ស្ពាយកាបូប ដើរចេញទៅ បន្ទាប់មកក៏ត្រូវ កាណែត ហៅចូលបន្ទប់ធ្វើការ និងធ្វើការក្នុងនោះជាមួយគ្នា រហូតដល់ជិតល្ងាច សុងចូ ត្រឡប់មកវិញ ដោយយកចម្លើយដែលនាងញញឹមមិនចេញមកឲ្យ។

សុងចូ ប្រាប់ថា សង តេពង់ មានបងភ្លោះម្នាក់ ធ្វើចម្ការជាមួយគ្នា ព្រោះចង់បានលុយដែលលក់ចម្ការទាំងអស់ ក៏ធ្វើឲ្យប្អូនប្រុសមានរបួសជើង ឆ្លៀតឱកាសនោះ បន្លំខ្លួនមកយកជំនួស ហើយរត់ទៅបាត់។ ពេលនេះ ប៉ាក់គូ កំពុងចាត់ការ តែមិនប្តឹង ព្រោះ សង តេពង់ សុំនិយាយជាមួយបងប្រុសសិន បើយ៉ាងម៉េចយ៉ាងម៉ា ចាំគិតទៀត។

នាងជួយធ្វើការ សុងចូ ដល់មេឃងងឹត ទាំងអារម្មណ៍សោកសៅ ទើបសុងចូ ត្រឡប់ទៅផ្ទះ ចំណែកនាងត្រូវ កាណែត នាំទៅវីសេតរបស់ អាជ្រៃ ព្រោះសានជ្រា តេរមកតាមនោះឯង ខ្លាចគេមិនទៅតាមការណាត់។

ស៊ុនស៊ូ មើលភ្លើងភ្លឺចិញ្ចែងចិញ្ចាច ចេញពីវីសេតរបស់ចម្ការតែ និងកសិដ្ឋាន ដោយអារម្មណ៍រំភើប ភ្លេចអស់ហ្មងសៅមួយខណៈ ព្រោះវាស្អាតពេក

Scanned with CamScanner

ហើយ ដោយសារធ្លាប់ឃើញតែពេលថ្ងៃ តែមិនធ្លាប់ឃើញពេលរាត្រី ហើយមួយសន្ទុះក៏មកដល់វីសេតដ៏ប្រណីត មានអង្គរក្សរបស់ សានជ្រា មកឈរចាំ និងនាំពួកនាងទៅផ្ទះវីអាយភី។

ខណៈនោះ កាណែត មានការងឿងឆ្ងល់ថា ហេតុអ្វីបានជា សានជ្រា កក់ផ្ទះវីអាយភីបាន ជម្មតាត្រូវកក់ឆ្លងឆ្នាំងណោះ ទម្រាំបាន តើមានអ្នកណាឲ្យសិទ្ធិពិសេសដល់នាងឬអត់។

# ១១

"ខ្ញុំសុំជប់លៀងអបអរឲ្យអ្នកទាំងពីរ អបអរសាទរផង ដែល កាណែត ជ្រើសរើសយកអ្នកស្រីជាភរិយា ប៉ីរ៉ស ចាក់វ៉ាញន៍បន្តិច"

ខ្សែភ្នែកផ្លេកៗ និងស្នាមញញឹមនៅចុងមាត់របស់ សានជ្រា បង្កប់ន័យពេលរុញកែវឲ្យអង្គរក្សចាក់វ៉ាញន៍ឲ្យភ្ញៀវទាំងពីរ តែពេលលើកកែវវ៉ាញន៍ដល់នឹង កាណែត និង ស៊ុនស៊ូ បែរជាញញឹមរួសរាយ។

ស៊ុនស៊ូ លើកកែវវ៉ាញន៍មកដាក់ជិតច្រមុះ ហិតបន្តិច ពេលធុំក្លិនរបស់វាមិនខ្លាំង ទើបជិប តាមតម្រូវការរបស់អ្នកអញ្ជើញ។

"រីករាយដែលនាងយល់ សានជ្រា"

កាណែត លើកកែវ៉ាញន៍ ជ្រឹមភ្នែកមើលមនុស្សស្រីនៅចំពោះមុខ ដោយមិនសូវទុកចិត្តប៉ុន្មាន មិនដឹងថាចង់លេងល្បៀតណាទៀត។

"អ៊ីចឹងយើងញ៉ាំអាហារទៅ សុទ្ធតែឆ្ងាញ់ៗ ចុងភៅវីសេតរបស់បងប្រុសលោក ធ្វើអាហារបានឆ្ងាញ់គ្រប់ពេល ថ្ងៃនេះ ខ្ញុំកុម្ម៉ង់ស្ទេកចៀម សង្ឃឹមថាអ្នកទាំងពីរញ៉ាំបាន ញ៉ាំជាមួយវ៉ាញន៍ក្រហម ឆ្ងាញ់ណាស់"

"ទីនេះ គេជួលចុងភៅជំនាញមកធ្វើ បើជាអាហារបន្ទប់វីអាយភី មិន

Scanned with CamScanner

បាច់ខ្លាចទេ ថាមិនឆ្ងាញ់"

ពេលប្រាប់ហើយ កាណែត ក៏លើកវ៉ាញន៍ដិប។

"ចាំ ញាំបាន"

ស៊ុនស៊ូ ប្រាប់ដោយទឹកមុខស្មើ ហើយទាញកាំបិតសមមកហាន់សាច់ចៀមនៅក្នុងចានរបស់ខ្លួន មួយដុំល្មមមាត់ ទទួលទានជាមួយវ៉ាញន៍ក្រហម ដែលរសជាតិរបស់វាឆ្ងាញ់ និងពេលអស់វ៉ាញន៍ អង្គរក្សក៏ចាក់ឲ្យ។

"អាហារមានរសជាតិឆ្ងាញ់ណាស់ ខ្ញុំចូលចិត្ត បែបនេះសុំនៅទីនេះឲ្យយូរ មួយរយៈហើយ"

សានជ្រា ដៀងមើលអតីតសង្សារ ពេលបុញមាត់បុញ.កនិយាយ និងបាញ់ខ្សែភ្នែកគឃ្លើនដាក់ទៀត ដោយមិនចាប់អារម្មណ៍ថា ស៊ុនស៊ូ នៅត្រង់នេះ ឬអត់។

"ស្រេចតែនាង សានជ្រា តែខ្ញុំមិនអញ្ជើញនាងទៅសម្រាកនៅផ្ទះទេ ព្រោះក្នុងផ្ទះមានតែមនុស្សក្នុងគ្រួសាររបស់ខ្ញុំ"

"លោកនិយាយដូចអ្នកឆ្ងាយគ្នាយ៉ាងអីចឹង តែមិនអីទេ ខ្ញុំមិនប្រកាន់ ខ្ញុំស្នាក់នៅទីនេះសិនក៏បាន សង្ឃឹមថាមិនយូរទេ ខ្ញុំនឹងបានទៅស្នាក់នៅក្នុងផ្ទះរបស់លោក"

ស្រីសក់ទង់ដែងនិយាយដោយពាក្យសម្ដីទាក់ទាញ និងមិចភ្នែកដាក់ ហើយលើកវ៉ាញន៍ដិប បន្ទាប់មកក៏ចាប់អារម្មណ៍អាហាររបស់ខ្លួន ចាក់ចំណិតដំឡូងបារាំង ដាក់ចូលមាត់ និងបឺតម្រាមដៃជាការទាក់ទាញ កាណែត តែគេមិនយកចិត្តទុកដាក់ នៅតែទទួលទានអាហារ មិនបានប៉ះវ៉ាញន៍ទៀត។

"ពេលញាំរួច ខ្ញុំសុំទៅវិញហើយ មិនបាននៅនិយាយជាមួយនាងទេ"

"តាមចិត្ត និងសង្ឃឹមថាលោកមកទទួលទានអាហារជាមួយខ្ញុំទៀត បើមានឱកាសក្រោយ"

សានជ្រា ធ្វើជាញញឹមញញែម ខណៈក៏លួចមើលប្រតិកម្មរបស់គេ។

"បើខ្ញុំមានឱកាស"

កាណែត ងក់ក្បាល និងឈ្ងោកមើលអាហាររបស់ខ្លួនដែលរលស់អស់ពាក់កណ្ដាល ដោយមានអារម្មណ៍ប្លែកៗចំពោះរាងកាយ។ គេក្ដាប់សមកាំបិតណែនដៃ ព្រោះពេលខ្លះក៏មានអារម្មណ៍ស្រៀវៗ ហើយពេលងើយមើលមុខសានជ្រា ឃើញនាងញញឹម ទើបខាំធ្មេញក្រតៗ យកទឹកត្រជាក់មកដិប ដឹងហើយថាត្រូវនាងធ្វើអីក្នុងស្រាក្រហម។

សានជ្រា ញញឹមសិចស៊ី លើកជើងឆ្កឹះជើងរបស់គេនៅក្រោមតុ ដែលកាណែត បានផឹកទឹកត្រជាក់អម្បាញ់មិញ ស្រួលខ្លួន ទៅញ័របន្តិច ដូចត្រូវខ្សែភ្លើងឆក់ ទើបសម្លឹងមុខនាងជាការព្រមាន តែនាងមិនញញើត។

"លោក កាណែត ខ្ញុំឆ្អែតហើយ ចង់ទៅផ្ទះវិញ"

ស៊ុនស៊ូ ដាក់កាំបិតចុះដោយដៃញ័រៗ និងដាក់ដៃនោះទៅលើភ្លៅរបស់កាណែត ហៅឈ្មោះគេខ្សឹបៗ។ ពេលនេះមុខរបស់នាងក្រហមង៉ាំងដូចស្រវឹង

Scanned with CamScanner

ស្រា តែរាងកាយបែរជាស្រៀវស្រាញ ដូចពេលត្រូវ ដុងរ៉ុក បញ្ច្រកថ្នាំសម្រើប។ នាងជឿថាអីចឹង ព្រោះអារម្មណ៍វាស្រដៀងគ្នា ហើយវាកំពុងតែធ្វើទុក្ខគ្រប់ពេលដែលកម្រើកខ្លួន។

"ហ៊ឹម!"

កាណែត ក៏ភ្ញាក់ព្រើតដែរ គ្រាន់តែត្រូវនាងប៉ះភ្លៅ តម្រូវការនៅក្នុងខ្លួនក៏មានប្រតិកម្មមួយរំពេច ធ្វើឲ្យគេឈឺចាប់ ហើយពេលងាកទៅមើលមុខនាង ក៏ភ្ញាក់ព្រើតតែម្តង ប្រឹងខាំថ្គាមណែន ប្រឹងរម្ងាប់តម្រូវការ និងកំហឹង។ គេដាក់ដៃលើខ្នងដៃរបស់នាង ច្របាច់ខ្លាំងៗ ឃើញទឹកមុខរបស់នាងហើយក៏យល់។

ស៊ុនស៊ូ គិតតែពីឈ្ងោកមុខ មិនហ៊ានប្រសព្វភ្នែកនឹងគេ ញើសគ្រាប់តូចផុសពេញថ្ងាស ដកដង្ហើមញ្ញាងខ្លាំង តែនាងប្រឹងទប់ និងប្រឹងខាំមាត់។

"ខ្ញុំសុំទៅសិនហើយ សានជ្រា មើលទៅភរិយារបស់ខ្ញុំមិនសូវស្រួលទេ"

កាណែត ងាកទៅប្រាប់ សានជ្រា និងមិនរង់ចាំចម្លើយ គេក៏ស្ទុះងើប និងចាប់ដៃរបស់ ស៊ុនស៊ូ ជាប់ ឱបចង្កេះរបស់នាងនាំចេញពីតុអាហារ។

"នេះស្អីហ្នឹង ប៊ីរ៉េស ខ្ញុំបញ្ជាឲ្យឯងដាក់ថ្នាំ កាណែត មិនមែនឲ្យដាក់ថ្នាំនាងនោះ ហើយមើលចុះ ចំណីរបុតពីដៃហើយ បែបនេះឯង សងយ៉ាងម៉េចឆ្កួតមែន"

សានជ្រា អង្គុយខាំមាត់ ក្តាប់ដៃណែន មើល កាណែត នាំប្រពន្ធរបស់គេចេញទៅ ហើយងើបឈរ វាសរបស់របរនៅលើតុអាហារ ឲ្យធ្លាក់ខ្ចាត់ខ្ចាយជាការកម្ចាយកំហឹង។

"លោក កាណែត អឹ!"

ស៊ុនស៊ូ សឹងតែទន់ជង្គង់ ពេលត្រូវគេនាំចេញពីផ្ទះរបស់ សានជ្រា មកដល់ឡានដែលចតនៅចំណត។ ពេលនេះខ្លួនប្រាណរបស់នាងញ័រ ម្តងក្តៅម្តងរងា មានអារម្មណ៍ប្លែកៗ ត្រឹមគេប៉ះខ្លួនបន្តិច។

"ស៊ុនស៊ូ នាងផឹកអាស្រានោះអស់ច្រើនមែនទេ?"

កាណែត គ្រហឹមនៅដើម.ក គេក៏មានអារម្មណ៍ប្លែកៗ ដែរ តែសំណាងដែលមិនបានផឹកអស់ច្រើន គិតថា ស៊ុនស៊ូ អាចផឹកអស់ច្រើនគួរសម មិនអីចឹងមុខជាគ្មានប្រតិកម្មខ្លាំងបែបនេះទេ។

"ពីរ...ពីរកែវ អឹ...ជួយខ្ញុំផង"

នាងឆ្លើយដោយសំឡេងរដាក់រដុប ពេលត្រូវគេរុញទៅផ្អឹបនឹងទ្វារឡានដើម្បីដោះសោ ទើបស្រវាឱប និងស្ទាបអង្អែលរាងកាយរបស់គេដោយទ្រាំមិនបាន និងចង់ឲ្យគេធ្វើបែបនេះដាក់នាងដែរ។

"ស៊ុនស៊ូ ឡើងឡាន កុំឆ្វេចឆ្វាចនៅមុំនេះ ខ្លាចគេឃើញ"

គេខាំធ្មេញក្រតៗ ទប់ចិត្ត ទប់ការឈឺចាប់ បេះដៃនាងចេញ ហើយរុញចូលឡាន ខ្លួនឯងក៏រត់ទៅឡើងទ្វារម្ខាងទៀត បើកចេញទៅយ៉ាងលឿន។

"ខ្ញុំក្តៅ លោកជួយខ្ញុំផង ខ្ញុំក្តៅ ខ្ញុំ...ខ្ញុំមានអារម្មណ៍ប្លែកៗ"

Scanned with CamScanner

នាងដកដង្ហើមដង្ហក់ មុខក្រហមង៉ាំង លើកដៃត្រដុលរាងកាយខ្លួនឯង ហើយដោះអាវគ្រវែងចោលក្នុងឡាន សល់តែឈុតក្នុងទាំងលើទាំងក្រោម។

"អត់ធ្មត់សិន ស៊ុនស៊ូ ជិតដល់ហើយ"

គេដៀងមើលនាងបន្តិច ហើយធ្វើចិត្តរឹង បើកឡានចេញពីកសិដ្ឋានរបស់បងប្រុស មកដល់ផ្ទះចម្ការតែរបស់ខ្លួន ដោយសុវត្ថិភាព។ គេនាំឡានចូលរោងឡាន បិទភ្លើងមុខ តែមិនពន្លត់ម៉ាស៊ីន ចុចកញ្ចក់ចុះបន្តិច មិនទាន់ដោះសោទ្វារ ហើយពេលងាកទៅមើលអ្នកនៅក្បែរខ្លួន ក៏ស្រឡាំងកាំងតែម្ដង ព្រោះពេលនេះ ស៊ុនស៊ូ ននលគកទៅហើយ ព្រមទាំងថ្ងូរឲ្យគ្រលួច ពត់ពេនខ្លួននៅមិនសុខ។

"ស៊ុនស៊ូ"

គេហៅនាង និងលូកដៃទៅប៉ះស្មាតិចៗ ត្រឹមប៉ុណ្ណឹង នាងក៏ភ្ញាក់ព្រើតហាក់ដូចត្រូវរបស់ក្ដៅ។

"ជួយខ្ញុំផង ខ្ញុំ...ខ្ញុំទ្រាំលែងបានហើយ អឺ"

នាងប្រឹងបើកភ្នែកគឃ្លើនដោយពិសប្រាថ្នាមើលមក អង្វរករដោយមិនខ្មាសអៀន ព្រោះតែអំណាចថ្នាំសម្រើប។

កាណែត ខាំធ្មេញក្រតៗ ឡើងប៉ោងថ្កាល់ត្រង់ថ្គាម មុខក៏ឡើងក្រហម ងាកទៅទ្រោបលើនាង ដាក់ជើងត្រង់ប្រឡោះជើង សម្រួលកៅអីឲ្យរាប ត្រឹមប៉ុណ្ណឹង នាងក៏ត្រូវលើកជើងកៀវចង្កេះ លើកដៃស្រវាឱប.កទៅហើយ។



"សម្រួលអារម្មណ៍ ស៊ុនស៊ូ ធ្វើចិត្តឲ្យត្រជាក់"

"និយាយឲ្យស្ដាប់គ្នាយល់មើល៍ ស៊ុនស៊ូ"

គេចងចិញ្ចើម មើលមុខនាងដោយការសង្ស័យ និងក្រសោបមុខរបស់នាងឲ្យមើលគេចំៗ ដើម្បីសួរនាំ។

"គឺរឿងលោក ស៊ុន...ស៊ុន គេពង់ លោកកុហកខ្ញុំធ្វើអី បោកឲ្យខ្ញុំជឿមកបោកថាខ្ញុំជំពាក់លុយ ទាំងដែលវាមិនមែនជាការពិត ហ៊ឹក!"

"ហ៊ឹៗ បើមិនធ្វើបែបហ្នឹង នាងគេចពីខ្ញុំល្មម ស៊ុនស៊ូ"

"លោកធ្វើដើម្បីអី ព្រោះអី ?"

"បើមិនធ្វើបែបហ្នឹង ហើយពេលណាទើបខ្ញុំបាននាងជាប្រពន្ធទៅ ទម្រាំយកបានមកដេកឱបបែបនេះ ខ្ញុំត្រូវចំណាយទាំងកម្លាំងកាយ កម្លាំងខួរក្បាលអស់គរគោក រឿងស្អីព្រមដោះលែងស្រួលៗ នោះ ហើយដឹងស្អីទេ ថ្ងៃដែលសានជ្រា ឲ្យដាក់ថ្នាំក្នុងស្រា ខ្ញុំដឹង តែនៅស្ងៀម ព្រោះត្រូវការឲ្យវាចេញមកបែបហ្នឹង មិនអ៊ីចឹង នាងមិនព្រមធ្វើជារបស់ខ្ញុំងាយៗ ទេ ថ្នាំនោះខ្ញុំមិនខ្លាចទេ តែខ្លាចវាមិនធ្វើឲ្យខ្ញុំសមបំណង"

គេសារភាពដោយទឹកមុខញញឹម ដោយមិនព្រឺខ្លួនអីបន្តិច។

"ហេតុអី ? ព្រោះលោកចង់យកឈ្នះខ្ញុំឬ លោក កាណែត ឬព្រោះខ្ញុំមិនដូចស្រីៗ ដែលភាគច្រើនចូលចិត្តរត់ដេញលោក ទើបលោកធ្វើបែបនេះដាក់ខ្ញុំ"

"មែន តែមិនទាំងអស់"

"ហើយព្រោះអី ហេតុអីលោក..."



បេះដូងរបស់នាងលោតញាប់ ពេលឃើញពន្លឺភ្នែកស្រទន់របស់គេ។ នាងចង់ដឹងថា ព្រោះអ្វីឲ្យប្រាកដទៅ ទើបគេដាក់ផែនការសាហាវបែបនេះមក



Scanned with CamScanner

លើនាង តែនិយាយមិនទាន់ចប់ផង ក៏ត្រូវគេឱនមកថើបបិទមាត់ ថើបថ្នមៗ ឲ្យនាងភ្លើតភ្លើន តបស្នងដោយមិនដឹងខ្លួន។

"បងស្រឡាញ់អូន ស៊ុនស៊ូ មិនដឹងថាវាចាប់ផ្តើមពីពេលណា ដឹងត្រឹមថាស្រឡាញ់រួចទៅហើយ ត្រូវធ្វើឲ្យអូនក្លាយជារបស់បងឲ្យបាន តែប៉ុណ្ណឹងយល់ទេ បងស្រឡាញ់អូន"

"លោក កាណែត"

នាងសម្លឹងមុខសង្ហារបស់គេ ដោយមិនចង់ជឿ ហាក់ដូចមនុស្សមមើ ទឹកភ្នែកក៏រលីងរលោង និងហូរកាត់ថ្ពាល់ ព្រោះមិនគិតថាគេស្រឡាញ់ ទាំងដែលតែងតែប្រាប់ថាស្អប់មុខ ចូលចិត្តនិយាយស្តីដៀមដាម កាច់កុង។

កាណែត ឱនថើប ផ្តិតទឹកភ្នែកចេញពីថ្ពាល់រលោងថ្នមៗ ទើបនាងស្រវាឱបគេណែនដៃ យំដាក់ដើមទ្រូងធំទូលាយដោយចិត្តរំភើប។

"លោកមិនបានកុហកទេ មែនទេ លោក កាណែត លោកមិនបានភរឲ្យខ្ញុំសប្បាយចិត្តលេងទេ មែនទេ ?"

"មិនភរទេ អូនសម្លាញ់ បងស្រឡាញ់អូនមែន ស៊ុនស៊ូ សូមជឿជាក់បុរសម្នាក់នេះ រឿងកុហកកន្លងមក គ្រាន់តែជាការល្បួងឲ្យអូនធ្លាក់មកនៅក្នុងរង្វង់ដៃបងប៉ុណ្ណោះ ចាប់ពីពេលនេះទៅ គ្មានការកុហកទៀតទេ កុំយំអី កុំយំ"

គេឱនថើបសក់ និងថ្ងាសរលោង ជាការលួងលោម អ្នកដែលកំពុងតែយំអណ្តឺតអណ្តក។

"អរគុណ ដែលបងស្រឡាញ់អូន កាណែត អូនស្រឡាញ់បង ស្រឡាញ់បុរសមាត់ដាចម្នាក់នេះ"

"ស៊ុនស៊ូ"

គេឱនថើបបបូរមាត់ និងថ្ពាល់របស់នាងខ្លាំងៗ ដោយការសប្បាយចិត្ត បេះដូងរីកមាឌណែនទ្រូង ពេលក្តីស្រឡាញ់របស់គេ ត្រូវបានតបស្នង។ ដំបូងគេគិតថានឹងធ្វើឲ្យនាងស្រឡាញ់គេបន្តិចម្តងៗ តែមិនស្មានថាត្រូវនាងប្រាប់ថាស្រឡាញ់បែបនេះសោះ ដឹងអ៊ីចឹង ប្រាប់តាំងពីយូរទៅហើយ មិនចាំបាច់ខាតពេលដាក់ផែនការបោកប្រាស់បែបនេះទេ។

"បងស្រឡាញ់អូន អូនជាមនុស្សស្រីតែម្នាក់គត់ដែលបងស្រឡាញ់ និងនៅក្បែរបង ស៊ុនស៊ូ បងមិនបោះបង់អូនទេ និងប្រាប់ឲ្យដឹងទៅ ថាប្តីម្នាក់នេះប្រចណ្ឌអាក្រក់អាក្រីណាស់"

"ប្រចណ្ឌ ឬព្រាននារី!"

នាងសម្លក់សម្លឹងមនុស្សកំហូច និងគក់ទ្រូងគេមួយដៃ។

"កាលមុនមិនទាន់មានប្រពន្ធ អាចព្រានបាន តែពេលនេះមានប្រពន្ធហើយ មិនព្រានទេ តែប្រចណ្ឌ ព្រោះស្រឡាញ់ប្រពន្ធ មានបញ្ហាអីទេ"

"ឆ្កួត"

"ឆ្កួត ហើយស្រឡាញ់ទេ ហ៊ឹម! ស្រឡាញ់ទេ ?"

គេលោមុខទៅជិត ខ្សឹបសួរដោយសំឡេងស្អកៗ។





Scanned with CamScanner

"ស្រឡាញ់"

នាងឆ្លើយ និងថើបមាត់គេយ៉ាងលឿន ហើយប្រញាប់ឈ្ងោកមុខដាក់។

"រំភើបណាស់"

កាណែត ខ្សឹបប្រាប់អ្នកនៅក្នុងរង្វង់ដៃ និងត្រសុលទៅបៀត នាំនាងទៅកាន់ដែនដីឋានសួគ៌ម្តងហើយម្តងទៀត អបអរបេះដូងពីរដួងដែលវេញក្លាយជាបេះដូងមួយ ពេញមួយរាត្រី។

# ១៥

ព្រឹកថ្ងៃបន្ទាប់

កាណែត ងើប បើកភ្នែកឃើតៗខិនថើបខ្នងរបស់នាងថ្នមៗ ក្រឡេកមើលម៉ោង ឃើញថាថ្ងៃខ្ពស់ទៅហើយ ហួសម៉ោងអាហារពេលព្រឹកជាងមួយម៉ោងទៅហើយ ទើបស្ទុះពីគ្រែចូលបន្ទប់ទឹក ងូតទឹកជម្រះខ្លួនឲ្យអារម្មណ៍ស្រស់ស្រាយ ពាក់អាវយឺតពណ៌ប្រផេះនិងខោកីឡា ដើរមកអង្គុយនៅគែមគ្រែខាង ស៊ុនស៊ូ ដេកនិងបែរមុខមករក លើកដៃវាសសក់ចេញពីមុខរបស់នាង តែធ្វើឲ្យនាងដឹងខ្លួនល្មម និងប្រឹងបើកភ្នែកមើលគេ បន្ទាប់មកក៏គេចហើយប្រញាប់បិទភ្នែកវិញដោយការអៀនអៀន។

"បងចុះទៅយកអាហារពេលព្រឹកមកឲ្យ អូនងើបងូតទឹករួចទេ"

"រួច"

នាងតបដោយសំឡេងខ្សាវៗ និងប្រឹងងើបព្រោះឈឺចុកចាប់ពេញរាងកាយ ប៉ុន្តែអាចទ្រាំបាន ធ្វើឲ្យគេញញឹមគ្រវីក្បាលហួសចិត្ត ហើយលើកនាងបី នាំចូលបន្ទប់ទឹកយកមកដាក់ក្នុងអាងធំ បើកទឹកក្តៅឲ្យដេកត្រាំ ដោយមានគេអង្គុយនៅមាត់អាង សម្លឹងមើលនាងដោយខ្សែភ្នែកស្រទន់ ទើបនាងប្រឹងបន្លឺប





Scanned with CamScanner

ខ្លួននឹងទឹកឲ្យផុតពីភ្នែករបស់គេ។

"ហ៊ឺៗ តិចទៀតឡើងមកវិញ មិនបាច់ប្រញាប់ទេ ដេកត្រាំឲ្យស្រួលខ្លួនសិនទៅ"

គេញញឹមពព្រាយដាក់ ធ្វើឲ្យនាងមើលឡើងភ្លឹកតែម្តង។

"ចាស"

នាងឆ្លើយតប ហើយខិនមុខជ្រប់ទើបត្រូវគេខិនថើបថ្ពាល់ខ្សឹតៗ និងដើរចេញទៅ ព្រមទាំងហួចដោយមានអារម្មណ៍ល្អទៀតផង ហើយពេលបានឮសំឡេងបិទទ្វារបន្ទប់ ទើបនាងស្ទុះងើបចេញពីអាង ងូតទឹកតែងខ្លួន ទៅអង្គុយចាំលើសាឡុងក្នុងបន្ទប់ដេក ដែលអាចមើលឃើញទេសភាពនៅខាងក្រៅបានច្បាស់។ សម្លៀកបំពាក់នៅក្នុងបន្ទប់តែងខ្លួនសុទ្ធតែជារបស់ថ្មី និងមកពីហាងល្បីៗ ធ្វើឲ្យនាងមិនចង់ទាញវាមកពាក់ ខ្លាចដាច់រហែកនាំឲ្យស្តាយ ប៉ុន្តែត្រូវបង្ខំចិត្តពាក់ ព្រោះទីនេះគ្មានសម្លៀកបំពាក់ចាស់របស់នាង ហើយពេលពាក់រួចវាក៏ឲ្យអារម្មណ៍ស្រួលខ្លួន សាច់ទន់ល្មើយ ហើយឈុតមួយនេះក៏សមនឹងដងខ្លួនរបស់នាងហាក់ដូចត្រូវកុម្ម៉ង់កាត់ដើម្បីនាងជាពិសេស ក្រៅពីនេះ នៅមានឈុតក្នុងជាច្រើនម៉ូតច្រើនម៉ាកទៀត ដែលគេកុម្ម៉ង់ឲ្យ។

"យប់មិញមិនបានយល់សប្តទេមែនទេដែលគេប្រាប់ថាស្រឡាញ់"

នាងលើកដៃចាប់មុខខ្លួនឯង ត្រឹមគិតក៏ក្តៅមុខទៅហើយ ពេលចាំបានថាគេប្រាប់ថាស្រឡាញ់នាង សារភាពរឿងដែលនាងសង្ស័យ។

កាណែត បើកទ្វារបន្ទប់ កាន់ថាសអាហារធំចូលមកជាមួយ ទើបនាងស្ទុះទៅជួយ។

"ចាំខ្ញុំជួយ"

"មិនបាច់ទេ ទៅអង្គុយចាំញ៉ាំនៅតុទៅ ថ្ងៃនេះប្តីបម្រើប្រពន្ធ"

កាណែត គ្រវីក្បាលបដិសេធ ហើយមិចវ៉ៃចិញ្ចើមដាក់ បណ្តេញនាងឲ្យទៅអង្គុយចាំ។

"ចាស"

នាងធ្វើតាមបង្គាប់ ដើរទៅអង្គុយនៅតុអាហារ វានៅឆ្ងាយពីសាឡុងដែលនាងអង្គុយអម្បាញ់មិញ។

កាណែត ញញឹមពព្រាយ យកថាសមកដាក់លើតុ ដួសបបរដាក់ចានដែលមានតែចានមួយ ស្លាបព្រាមួយប៉ុណ្ណោះ និងចាក់ទឹកក្រូចដាក់ឲ្យនាង ចំណែកខ្លួនឯងផឹកកាហ្វេខ្មៅ។

"ហេតុអីមានចានតែមួយ ចុះញ៉ាំខាងក្រោមឬ ម៉េចក៏លឿនម្លេះ ?"

"មិនទាន់ញ៉ាំទេមកញ៉ាំជាមួយប្រពន្ធញ៉ាំចានមួយស្លាបព្រាមួយជាមួយគ្នា"

"ចាស"



នាងដាក់កែវទឹកក្រូចចុះ ដោយទឹកមុខឆ្អើលៗ អៀនធ្វើខ្លួនមិនចង់ត្រូវ ទៅហើយ និងមិនហ៊ានមើលមុខគេចំ ហើយក៏មិនហ៊ានរើបម្រះ ពេលត្រូវគេ

ស្រវាចាប់ដៃទាញឲ្យទៅអង្គុយលើភ្លៅ។

"បញ្ចុកបន្តិច ប្រពន្ធមួយម៉ាត់ប្ដីមួយម៉ាត់ ឲ្យវាឆាប់អស់នឹងអាល អ៊ិននីម យកចានទៅលាង"

គេមិនត្រឹមតែនិយាយស្ដីផ្អែមល្ហែមទេ នៅថើបដើមដៃរបស់នាងខ្សឹតៗ ឲ្យព្រឺសម្បុរទៀតផង។

"ញ៉ាំរួចហើយទៅធ្វើការទេថ្ងៃនេះ មិនចង់នៅផ្ទះ"

នាងសួរនាំ ព្រោះបើនៅផ្ទះច្បាស់ជាត្រូវគេឃុំឃាំងនៅក្នុងបន្ទប់ដេក ពេញមួយថ្ងៃមិនខាន ដូច្នេះហើយចេញទៅខាងក្រៅល្អជាង។

"អូខេ ថ្ងៃនេះបាននាំប្រពន្ធទៅអួតកម្មករនៅក្នុងចម្ការបន្តិច ក្លាយជាអ្នកស្រីចម្ការតែទៅហើយ"

"មនុស្សឆ្កួតនេះ ចង់ធ្វើបាបគេឬ ញ៉ាំបាយទៅ"

នាងគក់ដើមទ្រូងរបស់គេតិចៗបន្លំការខ្មាសអៀន ហើយដួសបបរផ្ដើបញ្ចុកគេមុន ទើបទទួលទានដោយខ្លួនឯង។

"ឆ្ងាញ់ជាពិសេស ព្រោះប្រពន្ធបញ្ចុកនេះឯង"

ពេលត្រូវស្វាមីបាញ់ពាក្យផ្អែមល្ហែមដាក់បែបនេះ នាងក៏ប្រញាប់ដួសបបរបញ្ចុកគេ ធ្វើឲ្យអាហារពេលព្រឹកនាថ្ងៃនេះ ក្លាយជាអាហារដែលចំណាយពេលទទួលទានយូរមែនទែន ព្រោះពេលខ្លះញ៉ាំមួយម៉ាត់សុំថើបនាងមួយខ្សឹត បន្ទាប់មកទើបពិនិត្យមើលរបៀបរៀបរយរបស់ខ្លួនឯងនិងភរិយា មុនពេលចេញទៅចម្ការតែ។

"ដេមីន ទៅយកឡានឲ្យបន្តិច"

កាណែត ដើរមកបញ្ជាកូនចៅនៅមុខផ្ទះ ហើយយកថាសទៅឲ្យ អ៊ិននីម នៅក្នុងផ្ទះបាយ ទើប ស៊ុនស៊ូ ដើរចេញមកចាំគេនៅមុខផ្ទះ ឃើញឡានពីរគ្រឿងបើកតាមគ្នាចូលមក ដែលធ្វើឲ្យនាងញញឹមពព្រាយដោយការសប្បាយចិត្ត ម្ល៉ឹម្ល៉ាដើរទៅរក ព្រោះឡានដំបូងដែលមកដល់គឺ ខុងជូ ចំណែកឡានមួយគ្រឿងទៀត ក៏ជាអ្នកដែលនាងចង់ជួបដូចគ្នា។

ឆឹត!

"ស៊ុនស៊ូ នឹកខ្លាំងណាស់"

មនុស្សប្រុសដែលចុះពីឡាន រត់មកឱបនាងណែនដៃ ក្រោមការភ្ញាក់ផ្អើលរបស់ ដេមីន ចំណែក ខុងជូ ដែលទើបតែចតឡាន ក៏បើកទ្វារចុះមក មើលមិត្តភក្ដិរបស់ខ្លួនដោយការអរចិត្ត ប៉ុន្តែមានស្នាមញញឹមលម្អនៅលើមុខ និងឈរឱបដៃមើលអ្នកដែលកំពុងរាក់ទាក់គ្នា។

"តេយ៉ុង លែងសិន"

ស៊ុនស៊ូ ធ្វើមុខផ្អើលៗ ច្រានមិត្តភក្ដិចេញ ព្រោះនាងខ្លាច កាណែត មកឃើញ នាំឲ្យមានរឿង។



"ថី ខ្ញុំឱបនាងញឹកញាប់សឹងអី ឬមកពីមានប្ដីហើយ ទើបឱបមិនបាន

ស្អិតៗ ពេលមានប្តីហើយភ្លេចមិត្តភក្តិ មួយរយៈនេះស្អាតជាងមុន"

តេយ៉ុង ចាប់ដៃមិត្តភក្តិ សួរនាំដោយទឹកមុខប្រាកដប្រជា ព្រមទាំងពិនិត្យមើលតាំងពីក្បាលដល់ចុងជើងទៀតផង។

"គឺ កាណៃត គេ..."

"ព្រលែងប្រពន្ធអញ!"

កាណៃត ស្ទុះមកគ្រវាសដៃរបស់ តេយ៉ុង ចេញ ថែមទាំងប្រានដើមទ្រូងទៀតផង ឲ្យជ្រមិលទៅបុកនឹងទ្វារឡាន។

"កាណៃត កុំ គេជាមិត្តភក្តិរបស់អូនទេ"

នាងស្រែកហាមអស់សំឡេង មុខក៏ស្លេកស្លាំង មិនស្មានថា កាណៃត ប្រចណ្ឌដល់ថ្នាក់នេះ ខណៈដែល ខុងជូ លើកដៃបិទមាត់ ដោយការភិតភ័យ។

"មិត្តភក្តិស្អីឱបប្រពន្ធគេបែបនេះ គិតស្អីមកលើប្រពន្ធអញ!"

អ្នកដែលត្រូវស្ទុះគ្រវីក្បាលញាប់ស្អេក និយាយមិនចេញ បានត្រឹមលើកដៃខ្វែងបង្ការ កាណៃត ហក់មករក ប៉ុន្តែត្រូវ ស៊ុនស៊ូ ទាញទៅវិញ។

"ខ្ញុំជាមិត្តភក្តិរបស់ ស៊ុនស៊ូ យូរមកហើយ ហើយក៏ឱបគ្នាញឹកញាប់ដែរ"

ដំបូងខ្លាច ប៉ុន្តែពេលនឹកឃើញសម្តីរបស់ ខុងជូ ប្រាប់ថាឲ្យប្រយ័ត្នស្វាមីរបស់មិត្តភក្តិម្នាក់នេះ ក៏ចង់បេះបួយ។

"ឯងឱបប្រពន្ធអញឬ អាចង្រៃនេះ!"

កាណៃត ខាំធ្មេញក្រតៗ យារដៃ ស្ទុះទៅរកម្តងទៀត ប៉ុន្តែត្រូវ ស៊ុនស៊ូ ស្រវាចាប់ជាប់ និងទាញគេចេញឲ្យឆ្ងាយ។

"កាណៃត កុំអី គេមិនមែនជាប្រុសមួយរយភាគរយទេ"

"អា! កុំដាល់ កុំដាល់ ម៉ែអើយ ជួយផង ស៊ុនស៊ូ ប្រាប់ប្តីសង្ហារបស់ឯងបន្តិចទៅថាកុំដាល់ខ្ញុំ មុខខ្ញុំខ្ទេចតើគិតយ៉ាងម៉េច ខ្ញុំទៅស្ទូចអ្នកណាបានទៅ"

តេយ៉ុង ស្រែកចាច បង្ហាញជាតុពិតជាស្រីស្អាតក្នុងស្រោមបុរសសង្ហា។

"ជាហ្អែក៏ហាម ប្រចណ្ឌវើយ ហាមឱបហាមចាប់ដៃ យល់ទេ!"

កាណៃត ដកដង្ហើមចូលឲ្យជ្រៅៗ ព្រមដកថយពេលដឹងថាបុរសនៅចំពោះមុខមិនមែនជាបុរសពិត ប៉ុន្តែមុខមាត់របស់វាសង្ហាពេកហើយ ទោះយ៉ាងណាក៏ជាមនុស្សប្រុសដដែល គេត្រូវតែហាមប្រាម។

"យល់ លោក កាណៃត សង្ហា"

តេយ៉ុង ងក់ក្បាលជាចម្លើយ ថែមទាំងលួចបាញ់ភ្នែកដាក់ទៀតផង ប៉ុន្តែពេលត្រូវគេធ្វើមុខកាចដាក់វិញ ក៏ប្រញាប់លើកដៃបិទមាត់និយាយរអ៊ូៗ។

"អុំ! កាចដល់ហើយ"

"អឺ! ហើយចង់យ៉ាងម៉េច!"

គេខាំធ្មេញក្រតៗដាក់ជាការគំរាម។

"មិនយ៉ាងម៉េចទេ មិនហ៊ានធ្វើអីទៀតទេ"

តេយ៉ុង គ្រវីដៃ គ្រវីក្បាលជាការបដិសេធ ព្រោះបើហ៊ានធ្វើទៀត អាចនឹងត្រូវដាល់បែកមុខ។



"ហើយមកធ្វើអីទីនេះ ?"

"មករក ស៊ុនស៊ូ កាលពីម្សិលជាប់រវល់ការងារ មិនបានមកចូលរួមពិធីមង្គលការ ទើបថ្ងៃនេះប្រញាប់មក ខុងជូ តេរទៅប្រាប់"

តេយ៉ុង ចង្អុលទៅមិត្តភក្តិ និងសើចហេះៗដាក់ កាណែត បន្ទាប់មកបក់ដៃហៅ ខុងជូ ឲ្យមកជិត ដើម្បីយកមិត្តភក្តិធ្វើជាព្រោះការពារខ្លួនឯង។

"ល្អ អីចឹងចាំខ្ញុំនាំដើរមើលចម្ការ"

ស៊ុនស៊ូ ញញឹមប្រាប់មិត្តភក្តិ មិនចង់ឲ្យពួកគេខ្លាច កាណែត។

"ល្អឬ កាំង ស៊ុនស៊ូ ប្តី អើយលោក កាណែត បានសម្លាប់ខ្ញុំល្មម"

តេយ៉ុង ខ្សឹបខ្សៀវ ប៉ុន្តែ កាណែត នៅតែបានឮដដែល។

"មកដើរលេងមែនទេ ចាំនាំដើរលេង ស្នាក់នៅចម្ការណា ចម្ការតែឬកសិដ្ឋានសេះ ?"

"ស្នាក់នៅក្នុងក្រុង ចម្ការនេះបន្ទប់ពេញអស់ហើយ គិតថាមករកហើយនាំ ស៊ុនសូ ទៅដើរលេង"

"ដើរលេងនៅចម្ការនេះមួយថ្ងៃសិនទៅ ថ្ងៃក្រោយចង់ទៅណា ចាំនាំទៅខ្ញុំត្រូវទៅជាមួយ"

កាណែត ប្រាប់ដោយទឹកមុខដែលបង្ហាញឲ្យឃើញពីចិត្តប្រចណ្ឌដដែល។

"បាទ"

"អីចឹងឡើងឡាន កំពុងទៅចម្ការតែ ចាំនាំដើរមើលចម្ការតែ ហើយរសៀលនាំទៅកសិដ្ឋានសេះ មុនត្រឡប់ទៅវិញ ឲ្យគេយកក្រូចពីចម្ការក្រូចមកឲ្យ"

កាណែត ដើរទៅយកសោឡានពី ជេមីន និងស្រែកប្រាប់ ធ្វើឲ្យ តេយ៉ុង ភ្ញាក់ក្រញាង ខណៈដែល ខុងជូ នៅផ្អើលៗដដែល។

"បាទ ខ្ញុំប្រណែនឯងដល់ហើយ ស៊ុនស៊ូ ប្តីឯងគួរឲ្យស៊ីមែនទែន"

តេយ៉ុង ឆ្លើយប្រាប់ កាណែត ហើយងាកមកខ្សឹបខ្សៀវដាក់មិត្តភក្តិ ធ្វើឲ្យ ស៊ុនស៊ូ អស់សំណើច។

"ខ្សឹបខ្សៀវអី ឡើងឡាន ស៊ុនស៊ូ ស្ពឹកស្រពន់តិចមិនបានទៅ"

គេបាញ់ខ្សែភ្នែកកាចនិងមុខមាំដាក់ ពេលឃើញ តេយ៉ុង លោមុខសង្ហាទៅជិតប្រពន្ធរបស់គេ។

"ទៅៗ ឲ្យឆាប់ឡើង ប្តីនាងតឿនហើយ"

តេយ៉ុង ដើរនាំមុខ ព្រមទាំងបក់ដៃហៅមិត្តភក្តិឲ្យដើរតាម មិនហ៊ានអែនអន ខ្លាចអត់បានទៅ។

កាណែត នាំ ស៊ុនស៊ូ និងមិត្តភក្តិដើរមើលចម្ការតែកសិដ្ឋានសេះពេញមួយថ្ងៃ មើលទៅមិត្តភក្តិរបស់នាងសប្បាយរីករាយខ្លាំងណាស់ ហើយគេក៏អញ្ជើញឲ្យទទួលទានអាហារពេលល្ងាច នៅកសិដ្ឋានសេះមួយពេលផងដែរ បន្ទាប់មកឲ្យមនុស្សរបស់ខ្លួនជូនទៅផ្ទះធំដើម្បីយកឡានត្រឡប់ទៅវិញ ចំណែកគេនិង ស៊ុនស៊ូ មកផ្ទះក្នុងចម្ការ ដោយទូរសព្ទទៅប្រាប់អ្នកផ្ទះធំរួចហើយ សុំ



ហាន់និមុនជាមួយប្រពន្ធនៅទីនេះមួយយប់ពីរ។

"បើ អាន តេយ៉ុង មកទៀត ហាមទៅជាមួយគ្នាតែពីរនាក់ យល់ទេ ហាម ឲ្យវាឱប ហាមឲ្យវាចាប់ដៃ ប្ដីហួងហែង ទោះវាមិនស្រឡាញ់ស្រីក៏ដោយ គឺ ហាម"

កាណែត ឱបស្មាភរិយា ប្រាប់នាងដោយទឹកមុខម៉ាំ។

"ចាស លោកប្ដីមហាហួងហែង"

នាងក្រមុំងាកមកប្រាប់ ហើយប្រញាប់ងាកមុខចេញ ពេលជួបនឹងខ្សែភ្នែកក្ដៅគគុក។

"បែបនេះត្រូវតែដាក់ទោស ឲ្យវាឱបនិងចាប់ដៃ"

និយាយចប់ កាណែត ក៏រុញភរិយាចូលក្នុងផ្ទះ ដែលមិនទាន់បើកភ្លើងធំ តែអាចមើលឃើញ ព្រោះពន្លឺភ្លើងអំពូលតូចៗ ដែលបើកចោល និងចាំងមកពីខាងក្រៅ ឲ្យមើលឃើញព្រាលៗ។ គេចាក់សោទ្វារ នាំនាងឡើងទៅខាងលើសំដៅបន្ទប់ដេកជាបន្ទាន់ ហើយស្រវាទាញនាងមកឱបថើប ព្រមទាំងទាញសម្លៀកបំពាក់ចេញជាបន្ទាន់ ដោយ ស៊ុនស៊ូ ក៏ជួយសម្រួល ទោះនៅអឹមអៀន តែមិនយូរប៉ុន្មាន នាងនិងគេក៏ននកលគកដូចគ្នា។

កាណែត លើកបីភរិយា ដើរសំដៅសាឡុងធំ ជាប់ជញ្ជាំងកញ្ចក់ ដែលពេលនេះបិទវាំងននស្តើងឲ្យពន្លឺចន្ទចាំងចូលមក ដាក់នាងទៅលើនោះថ្នមៗ និងតាមទៅទ្រាបពីលើ ឈ្មុលមុខសង្កត់និងប្រឡោះកក្រអូបប្រហើរ ហើយអូសទៅរកដើមទ្រូង ដែលធំពេញបាតដៃធំក្រាស់តែម្ដង ខាំច្បិច បិតជញ្ជក់ ឲ្យនាងថ្ងូចថ្ងូរ ខណៈដែលបាតដៃក៏អូសលើស្បែករលោង ប្រចាច់ត្រគាកមូលក្លំ និងភ្លៅ បន្ទាប់មកគេក៏រុញវាចេញពីគ្នា ហើយទ្រាបបាតដៃចំកណ្ដាល ប៉ះពាល់ត្រង់នោះថ្នមៗ ឲ្យនាងស្រៀវខ្លាំង ពេលគេកម្រើកម្រាមដៃតិចៗ ឲ្យផ្កាកុលាបបញ្ចេញទឹកដម និងរឹតម្រាមដៃខ្លាំងៗ ឲ្យគេទ្រាំមិនបាន ទើបត្រូវជំនួសម្រាមដៃដោយភាពមហិមា។

គេសម្ងំនៅស្ងៀម បន្ទាប់ពីជ្រែកចូលទៅបាន ហើយកម្រើកខ្លួនយឺតៗ ដោយមិនប្រញាប់ប្រញាល់ បាតដៃក៏ប្រចាច់ដើមទ្រូង ដើម្បីជួយកាត់បន្ថយការឈឺចាប់ឲ្យភរិយា។

"អឺ..."

ស៊ុនស៊ូ ក្ដាប់មាត់ដោយភាពស្រៀវស្រើប ទប់សំឡេងថ្ងូចថ្ងូរនៅដើម.កប្រឹងតឿតជើង ដែលកៀវចង្កេះបាវសាក់ បិទភ្នែក ងើយក្បាលទៅក្រោយ ឲ្យសក់វែងរសាយពេញសាឡុង។ នាងដកដង្ហើមដង្ហក់ ដើមទ្រូងផឹតផតមុខឡើងក្រហមង៉ាំង មានអារម្មណ៍ដល់ភាពមហិមាក្ដៅគគុកដែលជ្រៀតជ្រែកក្នុងខ្លួនត្រង់ប្រឡោះភ្លៅ ពេលគេគ្រវែងត្រគាក អារម្មណ៍ប្លែកៗក៏លុកលុយចូលមកធ្វើឲ្យនាងចង់ឈ្លក់សេចក្ដីសុខ ត្រូវគ្រវែងត្រគាកទៅរកដើម្បីគេបន្ថែមល្បឿនដោយភ្លេចខ្លួន។

"ត្រូវការប្ដីមែនទេ ប្រពន្ធសម្លាញ់"



កាណែត ប្រឹងទប់ចិត្ត មិនឲ្យខ្លួនឯងត្រលែងត្រគាក ពេលឮបស្ទូរ នាងក៏បើកភ្នែកយឺតៗ មកមើល ដោយខ្សែភ្នែកគយ្លើន។

"សូមមេត្តា អូនត្រូវការបង កាណែត ប្ដីសម្លាញ់"

នាងប្រាប់គេដោយសំឡេងស្អកៗ បបូរមាត់ឡើងក្រៀម ដែលធ្វើឲ្យគេគ្រហឹមដូចមនុស្សមមើ ថែមទាំងត្រូវស្រវាឱបណែនដៃ និងត្រលែងត្រគាកនៅមិនសុខទៀត។

"អូខេ ប្រពន្ធសម្លាញ់"

គេញញឹមចុងមាត់ គ្រហឹមតិចៗ ដាក់នាង ហើយត្រលែងត្រគាកស្លាមជូនតាមតម្រូវរបស់ភរិយា ធ្វើឲ្យនាងរមួលខ្លួនដូចក្រពើ ស្រែកថ្ងូរដូចព្រាបជាការតបតគេគ្រប់កាយវិការ ទោះនៅអឹមអៀន តែក៏ធ្វើឲ្យគេចូលចិត្ត គេធ្វើឲ្យមេរៀនប្រាថ្នានៅលើសាឡុងធំ និងបន្ទប់ដេកទាំងមូលឆេះសន្ធោសន្ធៅ គ្មានអ្វីអាចពន្លត់បាន បើភ្លើងប្រាថ្នាក្នុងចិត្តរបស់គេមិនស្ងប់។

**ង៉ិត! គ្រាំង!**

សំឡេងជាន់ហ្វ្រាំង និងសំឡេងទង្គិចគ្នារបស់ឡានពីរគ្រឿង ដែលបុកបំបុិងឡានមួយចាំងកន្លះ ឲ្យរអិលធ្លាក់ពីផ្លូវទៅទើរនឹងផ្ទាំងថ្មនៅក្រោម ដែលឈរមើលពីលើ ឃើញសភាពរបស់ឡានហើយ ជានាថាអ្នកនៅក្នុងនោះដឹងតែស្លាប់មួយរយភាគ។ ពេលគិតដូច្នោះហើយ ទើបបុរសឈុតខ្មៅចេញពីឡានខ្មៅពីរគ្រឿង មិនដាក់ស្លាកលេខ ប្រញាប់ប្រញាល់ឡើងឡាន បើកចេញភ្លាម។

"ពួកវាទៅហើយ លោក កាណែត"

សុងចូ ដែលសម្ងំនៅស្ងៀមតាមចៅហ្វាយប្រាប់ មិនចេញទៅស៊ីគ្រាប់កាំភ្លើង ប្រថុយសម្ងំនៅក្នុងឡានដែលមិនដឹងជាផ្ទុះពេលណា ដោយបន់ស្រន់និងនឹកដល់មុខឪពុកម្ដាយនិងសង្សារនៅវិនាទីដែលគិតថាខ្លួនឯងជិតស្លាប់។

"អ៊ុម! ឆ្កួតមែន វាប្រុងខាំមិនលែងមែនទេ បែបនេះបានតើ"

កាណែត ពេបមាត់ដោយការឈឺចាប់ ស្មារបស់គេទង្គិចនឹងទ្វារឡាន រួមទាំងក្បាលដែរ សំណាងដែលគេដាក់ខ្សែក្រវាត់ការពារនិងមានពោងការពារសុវត្ថិភាពជួយ មិនដូច្នោះពួកគេអាចនឹងគ្មានជីវិតរស់ បាននៅមើលមុខប្រពន្ធកូន។

សុងចូ ដោះខ្សែក្រវាត់ការពារចេញ និងវារចេញពីឡានមុនចៅហ្វាយ ហើយជួយទាញគ្នា និងលូនតាមស្មៅដែលនៅមិនឆ្ងាយប៉ុន្មានពីឡាន ហើយបន្ទាប់ពីសម្រាកដកដង្ហើមបានស្រួលហើយ ទើបឡើងទៅលើផ្លូវ ព្រោះខ្លាចពួកវាត្រឡប់មកវិញ។

"លោកមានរបួស"

សុងចូ ឃើញអាវរបស់ចៅហ្វាយរហែក និងមានឈាម ទើបស្រែកប្រាប់ ហើយដោះអាវរបស់ខ្លួនមកជូតឈាមឲ្យ។

"តិចតួចទេ ខ្ញុំតែរទៅបង អេដែន សិន ចំណែកឯង ទូរសព្ទនៅក្នុងខ្លួនទេ



Scanned with CamScanner

បើនៅ តេរទៅ ថាក់គូ ប្រាប់ឲ្យទៅស្ទាក់ចាប់ពួកវានៅផ្ទះ សាន ដុងវ៉ុក ក្រែងលោពួកវាទៅទីនោះ ទៅស្ទាក់ចាប់កូនចៅរបស់វា ខ្ញុំជឿជាក់ថាជាមនុស្សរបស់វា"

កាណែត ពេបមាត់ព្រោះឈឺមុខរបួស ហើយបញ្ជាកូនចៅ។

"បាទ"

សុងចូ ស្រវេស្រវារកទូរសព្ទក្នុងហោប៉ៅខោ សំណាងល្អដែលវាមិនជ្រុះបាត់ទៅណា ហើយតេរទៅ ថាក់គូ ភ្លាម។

"បង អេដែន ឲ្យកូនចៅមកយកខ្ញុំបន្តិច ឡានធ្លាក់ពីផ្លូវ មុនចូលចម្ការនាំមនុស្សមកឲ្យច្រើនបន្តិចក៏ល្អ ខ្លាចមកតិចពេក ត្រូវស្ទាក់ធ្វើបាប កុំប្រាប់ស៊ុនស៊ី"

ពេលទាក់ទងទៅបងប្រុសច្បង ដែលពេលនេះនៅចម្ការក្រូច កំពុងមើលកម្មករជ្រើសរើសផ្លែក្រូចល្អៗរៀបចំតាមលំដាប់ ដែលត្រឹមប៉ុណ្ណឹង បងប្រុសក៏សួរនាំផ្ទួងផាំងភ្លាម ដោយការព្រួយបារម្ភ។

( ឯងកើតអីធ្ងន់ធ្ងរទេ កាណែត រង់ចាំបន្តិច បងតាម អាជ្រេ ទៅជាមួយ កុំបារម្ភអី បងមិនប្រាប់នាងទេ )

"មិនអីទេ របួសតិចតួចប៉ុណ្ណោះ រឺះធ្លាក់ចូលជ្រោះទៅហើយ ហាសហា"

កាណែត និយាយទាំងអស់សំណើច មិនចង់ឲ្យបងប្រុសព្រួយបារម្ភ ហើយពេលនិយាយទូរសព្ទជាមួយបងប្រុសរួច ក៏អង្គុយចាំ សុងចូ ដែលកំពុងនិយាយទូរសព្ទជាមួយ ថាក់គូ។

"លោក ប៉ូលិស សុង កំពុងតែទៅព័ទ្ធចាប់ សាន ដុងវ៉ុក ល្មម បណ្ដាញរាយការណ៍ថា មានការដឹកជញ្ជូនថ្នាំញៀនឈុតធំ ទៅលាក់នៅផ្ទះរបស់វា ហើយពេលនេះកំពុងតែធ្វើការក្រសោបចាប់ល្មម ខ្ញុំទៅយកកាំមេរ៉ានៅមុខឡានមកទុកសិន ក្រែងលោពេលយកឡានឡើងមកមានអ្នកណាទាញចេញ"

"អឺម យកមកទុកនឹងយើងល្អជាង តិចទៀតបងប្រុសនាំមនុស្សមកជួយហើយ រួចហើយមកអង្គុយចាំនៅត្រង់នេះ កុំទាន់អាលឡើងទៅ"

កាណែត ងក់ក្បាល និងបញ្ជាកូនចៅដោយទឹកមុខស្មើ មួយមកពីទ្រាំទប់ការឈឺចាប់ ហើយមើល សុងចូ ដែលដើរទៅយកកាំមេរ៉ាមុខឡាន បន្ទាប់មកក៏មកអង្គុយចាំនៅត្រង់នេះវិញ មួយសន្ទុះធំ ទើបឮសំឡេងឡានជាច្រើនគ្រឿងរត់មកចត និងមានសំឡេងស្រែកហៅ។

"កាណែត សុងចូ"

"នៅត្រង់នេះ លោក អេដែន លោក អាជ្រេ"

សុងចូ រត់ទៅគ្រវីដៃដាក់អ្នកដែលនៅខាងលើ ខណៈដែល កាណែត ឈឺមុខរបួសកាន់តែខ្លាំង របួសមិនជ្រៅប៉ុន្តែវាធំ ធ្វើឲ្យហូរឈាមអស់ច្រើន ទោះពេលនេះមុខរបួសក្រៀមក៏ដោយ ក៏វានៅតែឈឺខ្ទោកៗ។

អេដែន និង អាជ្រេ ចងខ្លួនឯងនឹងខ្សែ សម្រូតចុះមកក្រោមជាមួយកម្មករប្អូនប្រាំនាក់ ជួយនាំប្អូនប្រុសនិង សុងចូ ឡើងទៅខាងលើ។

"យ៉ាងម៉េចហើយ កាណែត អូខេទេ ឆាប់ទៅមន្ទីរពេទ្យសិនទៅ ខាង





Scanned with CamScanner

ណោះ ឲ្យកម្មករនិង សុងចូ រង់ចាំប៉ូលិសមកត្រួតពិនិត្យកន្លែងកើតហេតុ"

"មិនអីទេ ឈឺមុខរបួសតិចតួច មិនចាំបាច់ទៅដល់មន្ទីរពេទ្យទេ លាងរបួសតែបន្តិចលែងអីទៅហើយ មានប្រអប់ថ្នាំទេ បងលាងរបួសឲ្យខ្ញុំបន្តិច បើមិនស្រួល ស្អែកនេះចាំទៅរកពេទ្យ"

"ឯងកុំរឹងក្បាលពេក កាណែត របួសមិនមែនតូចតាចទេ ឲ្យពេទ្យដេរសិនទៅ តោះ មិនអីចឹងបងនឹងប្រាប់ ស៊ុនស៊ូ ថាមានអ្វីកើតឡើង សំណាងប៉ុណ្ណាហើយដែលមិនធ្លាក់ទៅក្នុងជ្រោះនោះ។

"ទៅក៏បាន តែកុំប្រាប់នាង"

កាណែត ព្រមចុះចាញ់បញ្ហារបស់បងប្រុសទាំងពីរ ដែលឈរឱបដៃធ្វើមុខក្រមូវដាក់ ដុកឲ្យទៅរកពេទ្យ ដោយយកប្រពន្ធរបស់គេមកគំរាម បែបនេះអ្នកណាមិនព្រមទៅ ព្រោះបើនាងដឹង នាងនឹងយំមិនខាន សំណាងល្អដែលថ្ងៃនេះគេឲ្យនាងនៅផ្ទះជាមួយម្តាយមីង មិនឲ្យមកជាមួយ បើសិនមកជាមួយ មិនចង់គិតទេថានឹងទៅជាយ៉ាងណា។

អេដែន និង អាជ្រេ នាំប្អូនប្រុសទៅរកពេទ្យលាងរបួសនិងដេររួចរាល់ ក៏នាំគ្នាទៅប៉ុស្តិ៍ប៉ូលិស ដោយយកភ័ស្តុតាងទាំងអស់ទៅឲ្យ ដោយមានមេធាវីរបស់ពួកគេជាអ្នកចាត់ចែង។

"ទៅប្រាប់ប្រពន្ធដោយខ្លួនឯងទៅ"

អាជ្រេ មើលប្អូនប្រុសដែលអង្គុយស្ងៀមតាំងពីចេញដំណើរមក ដែល

ពេលនេះដោះអាវឲ្យឃើញបង់របួសនៅលើខ្លួន បង្ហាញដើមទ្រូងសុទ្ធតែសាច់ដុំឲ្យគិលានុបដ្ឋាយិកាញ័របេះដូងលេងរួចមកហើយ។ ពួកគេជូន សុងចូ ទៅផ្ទះរួចរាល់ហើយ ដោយសង្ស័យរបស់ សុងចូ ចេញមកចាំនៅមុខផ្ទះដោយចិត្តអន្ទះសា ត្រឹមឃើញក៏ស្ទុះមកឱបដោយការព្រួយបារម្ភ ជារូបភាពដែលធ្វើឲ្យពួកគេមានអារម្មណ៍ល្អ ដែលកូនចៅជំនិតនៅមានជីវិតរស់រាន។

"ចាំប្រាប់"

កាណែត ងក់ក្បាលតាមសម្តីរបស់បងប្រុស ការពិតគេក៏លួចខ្វល់ខ្វាយដែរ ខ្លាច ស៊ុនស៊ូ បារម្ភ ព្រោះពួកគេត្រឡប់ទៅផ្ទះវិញនាពេលយប់ ប៉ុន្តែ អេដែនបានទូរសព្ទទៅប្រាប់អ្នកផ្ទះធំហើយ។

ឡានរត់មកចតនៅមុខផ្ទះ ពួកគេចុះពីឡាន ជេមីន ក៏រត់មករកដោយការព្រួយបារម្ភហើយប្រុងសួរនាំ ពេលឃើញចៅហ្វាយមានរបួស តែត្រូវកាណែត ធ្វើសញ្ញាហាមឡូឡា។

"មិនធ្ងន់ធ្ងរទេ ជេមីន អរគុណដែលបារម្ភ"

"បាទ"

ជេមីន តាមមើលចៅហ្វាយពីក្រោយ ហើយយកឡានទៅទុកនៅក្នុងរោងឡាន។

កាណែត ដើរចូលមកក្នុងផ្ទះហើយឈរស្ងៀម ពេលឃើញ ស៊ុនស៊ូ រត់មករក នាងយំឡើងហើមភ្នែក ពេលឃើញស្វាមីក៏ហូរទឹកភ្នែកសស្រាក់ តែមិន





Scanned with CamScanner

ហ៊ានដើរមកជិត បបូរមាត់ក៏ញ័រទទ្រើត លើកដៃខ្ទប់មាត់ ទាល់តែឃើញគេញញឹម និងត្រដាងដៃចាំនោះឯង ទើបនាងស្ទុះទៅឱបនិងយំដាក់ដើមទ្រូងរបស់គេ។

"ហ៊ឺៗ កាណៃត ចាប់ពីពេលនេះទៅអូនទៅជាមួយបង ហាមបញ្ជាមិនឲ្យអូនទៅជាដាច់ខាត"

នាងឱបគេណែនដៃ យំបណ្ដើរ ថើបដើមទ្រូងរបស់គេបណ្ដើរ ធ្វើឲ្យកាណៃតរលីងរលោងទឹកភ្នែក ឱបក្រសោបនាងជាប់ដើមទ្រូង និងឱនថើបសក់ថើបថ្ងាស ដោយអារម្មណ៍ក្ដុកក្ដួល ពេលគិតថាខ្លួនឯងត្រូវស្លាប់ និងមិនបានឃើញមុខមនុស្សស្រីជាទីស្រឡាញ់ទៀត ប៉ុន្តែគេនៅតែមានជីវិតរស់ត្រឡប់មកវិញដើម្បីប្រាប់ថាស្រឡាញ់នាង ហើយសន្យាចំពោះខ្លួនឯងថានឹងមិនធ្វើឲ្យខ្លួនឯងមានគ្រោះថ្នាក់ជាដាច់ខាត។

"អូខេ អូនសម្លាញ់ បងស្រឡាញ់អូនណាស់ មិនបាច់យំទេ បងមិនកើតអីធ្ងន់ធ្ងរទេ ពេលនេះមានសុវត្ថិភាពហើយ របួសតិចតួចប៉ុណ្ណោះ ប្រពន្ធត្រូវជួយលាងរបួសឲ្យប្ដីផង"

គេចាប់ស្មារបស់នាងរុញចេញបន្តិច ហើយផ្ញើយចង្កាឲ្យឃើញទឹកភ្នែកដែលហូររហាម និងមុខក្រហមង៉ាំង ទើបប្រើមេដៃជូតទឹកភ្នែកឲ្យ និងឱនទៅថើបបបូរមាត់ដែលនាងប្រឹងខ្ទឹបទាល់តែក្រហម ហើយថើបខ្លាំងៗជំនួសមេដៃដែលគេអង្អែលថ្នមៗអម្បាញ់មិញ ស៊ុនស៊ូ ក៏ជំទើតជើង លើកដៃឱប.ក និងថើបគេវិញទាំងអឹមអៀន។

"អូនស្រឡាញ់បង កាណៃត កុំធ្វើឲ្យអូនបារម្ភទៀត អូនខ្លាច"

"ស៊ូច! មិនបាច់ខ្លាចទេ ប្ដីមានសុវត្ថិភាព ពេលនេះដឹងហើយថាអ្នកណាមេខ្លោង ឲ្យប៉ូលិសចាត់ការហើយ នៅសល់ដំណាក់កាលតាមច្បាប់ប៉ុណ្ណោះ"

"អ្នកណាដែលហ៊ានធ្វើដាក់បងបែបនេះ?"

"សាន ដុងវ៉ុក ថ្ងៃនោះមិនគួរណាទុកជីវិតឲ្យវា ឲ្យវាបានមកលបខាំ!"

"សាន ដុងវ៉ុក អាចង្រៃនោះ!"

"កុំបារម្ភអី ពេលនេះវាត្រូវប៉ូលិសចាប់ហើយ ពីបទប៉ុនប៉ងមនុស្សឃាត និងជាឈ្មួញជួញដូរថ្នាំញៀនដ៏ធំ មិនអាចចេញពីគុកបានស្រួលៗទេ"

"មិនស្មានថាគេធ្វើរឿងបែបហ្នឹង ស្មានមិនដល់សោះ"

នាងនិយាយខ្សឹបៗ និងមើលមុខគេដោយការព្រួយបារម្ភ ហើយស្រវាឱបម្ដងទៀត សប្បាយចិត្តដែលរាងកាយរបស់គេនៅតែកក់ក្ដៅ បេះដូងនៅតែលោតឲ្យនាងបានឮ និងបានស្ដាប់គេតបត ប៉ុណ្ណឹងនាងសប្បាយចិត្តណាស់ទៅហើយ ត្រឹមគេមានសុវត្ថិភាពត្រឡប់មកវិញ។

ពេលបានឮ ជេមីន និយាយជាមួយមេផ្ទះ ជិន និង អ៊ុននីម ធ្វើឲ្យនាងធ្លាក់ថ្លើមក្ដុកតែម្ដង យំហ៊ុំភ្លាម បានម្ដាយមីងនិង យ៉ារីម មកជួយលួងលោមនិងសួរនាំ ជេមីន ឲ្យ ដឹងថានរណាកើតអី ព្រោះពេលនោះទាក់ទងមិនបាន មានតែ អេដែន ម្នាក់ប៉ុណ្ណោះដែលគេរមកប្រាប់ ហើយក៏ស្ងាត់បាត់ដំណឹងទៅ ទើបពួក





Scanned with CamScanner

នាងចេញមកចាំនៅបន្ទប់ទទួលភ្ញៀវ និងបានឮសំឡេងឡានមកចតនៅមុខផ្ទះ នាងក៏រត់ចេញទៅមុនគេមុនឯង បានឃើញស្វាមីដើរចូលមកដោយស្ពានភាព ដែលធ្វើឲ្យទឹកភ្នែករបស់នាងហូរសស្រាក់។

"មិនទាន់ញ៉ាំបាយទេមែនទេ ហ៊ឹម"

"នៅទេ បងឃ្លានទេ ?"

នាងងើយមុខទៅសួរគេ ថែមទាំងលើកដៃអង្អែលមុខរបួសថ្មមៗទៀតផង។

"ឃ្លានហើយ ទៅញ៉ាំទៅនឹងអាលឲ្យប្រពន្ធងូតទឹកឲ្យ នឹងបានលាងរបួសដែរ ធ្វើថ្មមៗ ពេលនេះឈឺខ្លាំងហើយនេះ"

គេងក់ក្បាល និងខ្សឹបខ្សៀវដាក់នាងឲ្យឮតែពីរនាក់ជាការចំអកចំអន់ ឲ្យនាងរសាយអារម្មណ៍ខ្វល់ខ្វាយ។

"មនុស្សឆ្កួតនេះ"

នាងក្ដាប់ដៃគក់ដើមទ្រូងគេតិចៗ ដោយការអឹមអៀន ព្រោះយល់ន័យរបស់គេ ហើយដើរតាមការឱបស្មារបស់ស្វាមី ចូលទៅក្នុងបន្ទប់ទទួលភ្ញៀវ បន្ទាប់មកក៏នាំគ្នាទៅទទួលទានអាហារពេលល្ងាច ដែលពេលនេះយប់ជ្រៅណាស់ទៅហើយ ដោយបរិយាកាសពោរពេញទៅដោយភាពកក់ក្ដៅ បន្ទាប់មកក៏ឡើងបន្ទប់ដេករៀងខ្លួន។

កាណែត ធ្វើម៉ិកម៉ូក់ឲ្យភរិយាជួយងូតទឹកឲ្យ ដែលនាងក៏ធ្វើដោយការពេញចិត្ត ដែលធ្វើឲ្យគេញញឹមញញែម ព្រោះបានឆ្មក់ថើបនាងញឹកញាប់ ប៉ុន្តែនាងមិនថាអី មានតែតបស្នងគេដោយការពេញចិត្ត និងនាំមកលាងរបួសឲ្យនៅលើគ្រែ។

"រួចរាល់ហើយ"

នាងបិទបង់របួស រៀបចំរបស់របរទុកដាក់ក្បែរគ្រែ ឲ្យឱនមកថើបស្មារបស់គេមួយខ្សឹត ទាំងអៀនប្រៀន។

"គួរឲ្យស្រឡាញ់បែបនេះ ទប់ចិត្តម៉េចបានទៅ"

កាណែត រុញនាងឲ្យដួលទៅលើពូក ហើយតាមទៅទ្រោបពីលើ និងឱនទៅជិត ខ្សឹបប្រាប់ដោយសំឡេងស្រទន់។

"មនុស្សឆ្កួតនេះ បងកំពុងឈឺរបួស"

"មិនអីទេ ឈឺដៃប៉ុណ្ណឹង សុំបន្តិចប៉ុណ្ណោះ"

មិនត្រឹមតែនិយាយទេ គេនៅឱនមកថើបបបូរមាត់ក្រពុំលឿនដូចព្យុះ និងចាប់ដោះខោអាវរបស់នាងជាបន្ទាន់ ហើយត្រសុលចូលកណ្ដាល ឲ្យជើងរបស់នាងកៀវចង្កេះរបស់ខ្លួន។ ភាពស្រៀវស្រើបរត់សើបពេញរាងកាយ ទើបគេជ្រែភាពមហិមាទៅរកនាងសន្សឹមៗ ដែលកុលាបស្រស់ត្រៀមខ្លួនបានលឿនណាស់ដើម្បីទទួល ទើបគេជ្រែកខ្លួនចូលទៅយ៉ាងលឿន ហើយបង្រៀនមេរៀនស្នេហាបែបថ្មី ឲ្យនាងស្វែងយល់តាមដោយភាពពុះកញ្ជ្រោល។

មុខមាត់ក្រហមឆ្អាំងជោកដោយញើសគ្រាប់តូចៗ រាងកាយញ័រទទ្រើត





Scanned with CamScanner

មិនយូរប៉ុន្មាន នាងក៏ស្រែកអស់សំឡេង រាងកាយកន្រ្ទាក់ខ្លាំងៗ ហើយក៏នៅស្ងៀម ពេលទៅដល់គោលដៅ ទើបគេបន្ថែមល្បឿន ដើម្បីតាមនាងឲ្យទាន់។

កាណែត ទម្លាក់ខ្លួនទៅលើរាងកាយរបស់ភរិយា បន្ទាប់ពីតាមនាងទាន់ហើយ ថៃថើបអ្នកដែលកំពុងដកដង្ហើមដង្ហក់ ដោយក្ដីស្រឡាញ់ ដើម្បីឲ្យនាងបានបន្ធូរអារម្មណ៍ បន្ទាប់មកក៏ចាប់ផ្ដើមមេរៀនក្ដៅគគុកថ្មីជាមួយនាង ឲ្យបន្ទប់ដេកអប់ទៅដោយភាពក្ដៅគគុក និងក្ដីស្រឡាញ់ដែលគេនិងនាងមានចំពោះគ្នា ដែលទម្រាំតែស្ងប់ លេងធ្វើឲ្យនាងទន់ខ្លួនលើទ្រូងរឹងមាំ ឲ្យគេឱបក្រសោប និងថើបថ្ងាស ហើយសម្លឹងមើលនាងដោយខ្សែភ្នែកស្រទន់។

"បងស្រឡាញ់អូន ស៊ុនស៊ូ កំពូលដួងចិត្តបង"

កាណែត ប្រាប់ថាស្រឡាញ់អ្នកដែលខ្លួនដេកឱបដោយក្ដីស្រឡាញ់។ គេនឹងនិយាយប្រយោគនេះដាក់នាងជារៀងរាល់ថ្ងៃ ហើយមិនបណ្ដោយឲ្យនាងបាត់ពីភ្នែកដាច់ខាត និងមិនធ្វើឲ្យនាងបារម្ភទៀតជាដាច់ខាត។

# ១៦

មួយខែក្រោយមក

"អ៊ុប! អួក!"

កាណែត ស្ទុះងើបពីគ្រែដេក ពេលភ្ញាក់ដឹងខ្លួនដោយសារអារម្មណ៍អន្ទីមអន្ទម ចង់ក្អួត ប្រញាប់រត់ចូលបន្ទប់ទឹក ទៅកម្ចាត់វាចេញពីពោះអស់រលីង។

"កាណែត កើតអី"

ស៊ុនស៊ូ ភ្ញាក់ពីដំណេក ស្រវាទាញអាវឃ្លុំមកពាក់ ហើយរត់តាមគេ ទៅជួយរឹតខ្នងឲ្យដោយចិត្តខ្វល់ខ្វាយ បារម្ភថាគេមិនស្រួលខ្លួនព្រោះពីរបីថ្ងៃមកនេះ គេមានអាការៈនេះនាពេលព្រឹករហូត។

"រាងធូរហើយ"

"ញ៉ាំអាហារពេលព្រឹកហើយ ទៅរកពេទ្យ អូនបារម្ភ ហាមរឹងទទឹង ឲ្យពេទ្យពិនិត្យបន្តិចទៅថាកើតអីទេ បើមិនទៅអូនខឹងហើយ"

នាងរលីងរលោងទឹកភ្នែក ពេលឃើញទឹកមុខស្លេកស្លាំងរបស់គេ យកកន្សែងមកជូតមុខជូតមាត់ឲ្យពេលដែលប្រាប់។



Scanned with CamScanner

"អូខេ ច្រើនថ្ងៃមកហើយ ត្រូវទៅរកពេទ្យពិនិត្យបន្តិច កុំយំអី ប្ដីមិនស្រួលចិត្តទេ"

គេផ្ញើយចង្ការបស់នាង ឱនទៅថើបបបូរមាត់ថ្នមៗ ហើយងក់ក្បាលញញឹមដាក់ ធ្វើតាមយោបល់ប្រពន្ធ ទៅពិនិត្យនៅមន្ទីរពេទ្យនាពេលព្រឹកសង្ឃឹមថាខ្លួនឯងគ្រាន់តែល្ងើយ មិនបានកើតរោគអីធ្ងន់ធ្ងរ ព្រោះគេចង់ផ្អែមល្ហែមជាមួយប្រពន្ធឲ្យបានយូរ។

"ចាស ទៅពិនិត្យជាមួយគ្នា អូនប្រាប់ឲ្យទៅតាំងពីដំបូងក៏មិនទៅ បែបនេះវាគួរតែធ្ងន់ធ្ងរ"

នាងគក់ដើមទ្រូងរបស់គេមួយដៃតិចៗ មុខឡើងខ្ញរ។

"អីចឹងងូតទឹកជាមួយគ្នា ព្រឹកល្មម"

គេដោះអាវឃ្លុំរបស់នាងចេញ និងបាញ់ខ្សែភ្នែកក្ដៅគគុកដាក់ ហើយនាំនាងចូលទៅឈរក្រោមផ្កាឈូក។

"ចាស"

នាងងក់ក្បាលទាំងអឹមអៀន ប៉ុន្តែព្រមងូតទឹកជាមួយគេដូចសព្វមួយដង ទាំងព្រឹកទាំងល្ងាចទម្រាំតែចេញពីបន្ទប់ទឹកបាន ជិតដល់ពេលអាហារពេលព្រឹកល្មម។

"ឈឺហើយនៅត្រេកកាមទៀត"

នាងប្រញាប់ប្រញាល់តែងខ្លួន ពេលរួចរាល់ក៏មិនភ្លេចសម្លក់សម្លឹងអ្នកដែលចេះតែកេងចំណេញលើនាងរហូត។

"ប្រពន្ធស្អាតហ្នឹងណា អ្នកណាទៅទប់ចិត្តបាន"

គេមិចភ្នែក ញាក់ចិញ្ចើមដាក់ ព្រមទាំងញញឹមពព្រាយឱបចង្កេះរបស់នាងនាំចុះមកបន្ទប់អាហារ ដែលពេលនេះបងប្រុសទាំងពីរនិងភរិយានៅជុំគ្នាហើយ រួមទាំង ស្នូម ដែលអង្គុយក្បែរឪពុក។

"អ៊ុៗ អ៊ុៗ"

ស្នូម ធ្វើភ្នែកព្រិចៗ ថ្ពាល់គ្រហាញឡើងក្រហម ញញឹមពព្រាយ មើលមក កាណែត មិនដាក់ភ្នែក ព្រមទាំងគ្រវីដៃដាក់ដោយការសប្បាយចិត្តទៀតផង ហើយពេលឪពុកមាលូកដៃទៅចាប់ថ្ពាល់និងដៃ អាល្អិតក៏សើចកក្អិច ធ្វើឲ្យគ្រប់គ្នានៅតុអាហារសើចតាមដែរ។

"បង្រៀនឲ្យ ស្នូម ហៅមែនទេ ស៊ុនស៊ូ"

គេងាកទៅសួរភរិយា ដោយសំឡេងកាច តែមិនប្រាកដប្រជា ព្រោះចាំបានថានាងធ្លាប់ហៅគេបែបនេះ។

"ពីរដងហ្នឹង គេចាំបានដោយខ្លួនឯងទេណ៎ា ស្នូម ណ៎ា"

នាងធ្វើមិនដឹងមិនឮមិនទទួលស្គាល់កំហុសនិងបុញមាត់ដាក់ប្អូនប្រុសជីដូនមួយ ដែលមិនទាន់ដឹងខ្យល់អី តែអាល្អិតក៏ញញឹមពព្រាយនិងធ្វើសើចកក្អិចដាក់។

"ច្បាស់ជាត្រូវមិនខាន"



កាណែត ខ្សឹបដាក់ត្រចៀកនាងជាការគំរាម ដែលធ្វើឲ្យនាងក្រហមមុខ ព្រោះយល់ន័យរបស់គេ។

"នេះពត៌មានរបស់ សាន ដុងវ៉ុក"

អេដែន ហុចកាសែតឲ្យប្អូនប្រុសពៅមើលពត៌មានទំព័រមុខ ដែលធ្វើឲ្យ កាណែត ញញឹមពេញចិត្ត។

"បើវាងាប់ក៏ល្អ កុំឲ្យខ្ញុំពិបាកប្រឡាក់ដៃ"

កាណែត ងៀងមើលបងប្រុសទាំងពីរ និងញាក់ស្មាបន្តិចដាក់ សាន ដុកវ៉ុក ត្រូវអ្នកទោសនៅក្នុងគុកវ៉ៃឲ្យមានរបួសធ្ងន់ធ្ងរ ត្រូវបានអនុញ្ញាតឲ្យមកសម្រាកព្យាបាលនៅមន្ទីរពេទ្យខាងក្រៅ។

"ហាមធ្វើដាច់ខាត"

ស៊ុនស៊ូ ស្រវាចាប់ដៃរបស់គេភ្លាម និងខ្សឹបប្រាប់ ប៉ុន្តែ កាណែត ធ្វើជាសើចញឹមៗដាក់ ជាការលួងចិត្ត ព្រោះគេមិនទុកវា បើដប់ឆ្នាំក្រោយពេលវាចេញពីគុកវាអាចនឹងតាមមកសងសឹក ដល់ពេលនោះគេអាចក្លាយជាឃាតករដោយផ្ទាល់ ឬមិនអីចឹងដោយប្រយោល ដោយពឹងពាក់ឥទ្ធិពលងងឹត ព្រោះឥទ្ធិពលងងឹតដែលគេមាន ក្រុមគ្រួសាររបស់គេជាម៉ាហ្វៀកាលជំនាន់មុខរបស់ រស្ស៊ីគ្រាន់តែប្រាប់បន្តិចកូនចៅក៏ចេញមុខចាត់ការឲ្យទៅហើយ។

"មិនធ្វើទេ ប៉ុន្តែបើវានៅតែមិនឈប់ ក៏មិនច្បាស់ដែរ អូនកុំបារម្ភ"

គេប្រាប់នាងនិងញញឹមដាក់វិញ ប៉ុន្តែបងប្រុសទាំងពីរដឹងថា កាណែត ច្បាស់ជាធ្វើ បើ សាន ដុងវ៉ុក នៅតែមិនព្រមឈប់ ចំណែកពួកគេក៏អីចឹងដែរ មិនត្រូវការឲ្យអ្នកណាមករំខានក្រុមគ្រួសារទៀត។

ពេលសមាជិកគ្រួសារមកជុំគ្នាអស់ហើយ អ៊ុននីម និងមេផ្ទះ ជិន ក៏លើកអាហារពេលព្រឹកមកដាក់ឲ្យ ចាក់កាហ្វេខ្មៅឲ្យ កាណែត ដែលចូលចិត្តផឹក ប៉ុន្តែក្លិនរបស់វា ធ្វើឲ្យអ្នកកំលោះអន្ទឹមអន្ទម រុញវាចេញឲ្យឆ្ងាយភ្លាម ទើប អេដែន សួរនាំដោយការងឿងឆ្ងល់។

"កើតអី កាណែត តាមធម្មតាឯងចូលចិត្តផឹកកាហ្វេខ្មៅតើ"

"មិនដឹងកើតអីទេ ពីរបីថ្ងៃមកនេះវាចេះតែស្អុយ វិលមុខ ពេងពោង អន្ទឹមអន្ទម ថ្ងៃនេះគិតថាទៅមន្ទីរពេទ្យ ឲ្យពេទ្យពិនិត្យបន្តិច"

"កើតច្រើនថ្ងៃហើយឬ មិនស្រួលខ្លួនម៉េចក៏មិនឆាប់ទៅពេទ្យ"

បងប្រុសកណ្តាលដាក់ស្លាបព្រាកាហ្វេចុះ សួរប្អូនប្រុសដោយការព្រួយបារម្ភ ចិញ្ចើមក៏ជ្រួញចូលគ្នា ចំណែកបងថ្លៃស្រីទាំងពីរក៏មើលមុខប្អូនថ្លៃដោយការព្រួយបារម្ភ។

"ខ្ញុំប្រាប់រួចហើយ ប៉ុន្តែគេថានៅទ្រាំបាន ថ្ងៃនេះធ្ងន់ធ្ងរ ងើបឡើងក្អួតទាំងព្រឹក ទើបខ្ញុំអង្វរករឲ្យទៅពេទ្យ វិងក្បាលណាស់"

"អ៎! បងថាអាការៈបែបនេះដូចប្រហែលៗ"

អេដែន ប្រឹងរកនឹក ព្រោះមានអារម្មណ៍ថាគេដូចធ្លាប់កើត។

"មែនហើយ ខ្ញុំគិតថាប្រហែលៗដែរ ដូចអាការៈមនុស្សចាញ់កូន ប៉ុន្តែ





Scanned with CamScanner

នេះជាលោក កាណែត ប្រហែលមិនមែនទេ អេំ! ឬចាញ់កូនជំនួសប្រពន្ធ ចាញ់កូនជំនួសអ្នកស្រីតូច"

មេផ្ទះ ជីន ដែលឈរស្តាប់ការសន្ទនាយូរមកហើយ ក៏និយាយផ្ទួងភ្លាម ព្រមទាំងទះភ្លៅខ្លួនឯងមួយដៃ ប្រាប់គ្រប់គ្នាដោយការជឿជាក់ថា កាណែត ត្រូវតែចាញ់កូនជំនួសប្រពន្ធ។

"មិន...មិនពិតទេដឹងអ៊ំ ជិន អាចទៅរួចឬ"

បេះដូងរបស់ ស៊ុនស៊ូ លោតញាប់ដោយការសប្បាយចិត្ត បើនេះគឺជារឿងពិត នាងធ្លាប់ឮខ្លះដែរ តែមិនធ្លាប់ដឹងថាមាន។

"ហ្នឹងហើយ អ៊ីចឹងតើបានជាប្រហែលៗ ឆាប់ទៅពិនិត្យទាំងពីរនាក់ទៅ បើ ស៊ុនស៊ូ មានផ្ទៃពោះ នឹងបានជប់លៀងថ្ងៃនេះ ចំណែកឯង កាណែត បើចាញ់កូនជំនួសប្រពន្ធ បងនេះឃើពីសមមុខឯង អបអរផង ស៊ុនស៊ូ ដែលមិនចាំបាច់ចាញ់កូន ហាសហា"

បងប្រុសធំអស់សំណើចដោយការចូលចិត្ត គេក៏មានអារម្មណ៍ថាវាច្បាស់ជាអ៊ីចឹងដែរព្រោះគេក៏ធ្លាប់មានអាការៈនេះប៉ុន្តែមានតែនៅថ្ងៃខ្លះប៉ុណ្ណោះ និងយូរៗម្តង បើថ្ងៃណាគេមានភរិយានឹងគ្មាន ចំណែក អាជ្រៃ ក៏អ៊ីចឹងដែរ វាធ្លាប់សួរគេ ប៉ុន្តែ កាណែត វាចាញ់ខ្លាំង ចាញ់ជំនួសប្រពន្ធតាំងពីមិនទាន់ដឹងថាមានផ្ទៃពោះ។

"អូ! អស្ចារ្យណាស់ កាណែត បងមិនប៉ុន្មានថ្ងៃក៏ចង់ងាប់ចង់រស់ទៅហើយ ឯងចាញ់តាំងពីដំបូងបែបនេះ សប្បាយចិត្តល្អទេនេះ តែល្អហើយដែល ស៊ុនស៊ូ មិនអី មិនអ៊ីចឹងលំបាកហើយ នេះ យ៉ាម ទើបតែរាងធូរហ្នឹងឯង ឃើញហើយអាណិតប្រពន្ធណាស់"

អាជ្រៃ អត់អាណិតប្អូនប្រុសមិនបាន គេដឹងថាវាវេទនាប៉ុណ្ណា ប៉ុន្តែគេរីករាយ បើធ្វើឲ្យប្រពន្ធស្រួលខ្លួន មិនចាប់បាច់ចាញ់ដោយខ្លួនឯង។

"មិនអីទេ បើចាញ់កូនជំនួសប្រពន្ធ តែមានផ្ទៃពោះមែនឬអត់ ត្រូវទៅឲ្យពេទ្យពិនិត្យសិន អ៊ីចឹងសុំទៅសិនហើយ ទៅរកពេទ្យសិន ឲ្យវាច្បាស់ រង់ចាំស្តាប់ដំណឹងល្អ តោះ ស៊ុនស៊ូ"

កាណែត ហ៊ឹងត្រចៀកអស់ទៅហើយ បេះដូងរីកមាឌណែនទ្រូង គិតតែពីញញឹមដោយការសប្បាយចិត្ត ពេលគិតថាខ្លួនឯងកំពុងមានកូន។

"យេស ជាការពិតមែនទេលោកគ្រូពេទ្យ ខ្ញុំកំពុងតែក្លាយជាប៉ាគេហើយមែនទេ ស៊ុនស៊ូ យើងមានកូនហើយ"

កាណែត ស្ទើរតែលោតកញ្ឆេង សប្បាយចិត្ត ញ័រខ្លួនទទ្រើត ទប់អាការៈមិនចង់បាន ពេលបានស្តាបចម្លើយពីគ្រូពេទ្យ។

"បាទ អបអរអ្នកទាំងពីរផង"

លោកគ្រូពេទ្យ ញញឹមតាមអ្នកជំងឺ មិនសូវឃើញ កាណែត គ្រប់គ្រងខ្លួនឯងមិនបានបែបនេះទេ ប្រហែលសប្បាយចិត្តខ្លាំងនេះឯង បន្ទាប់មកពួកគេ





Scanned with CamScanner

ក៏ស្តាប់ការណែនាំពីលោកគ្រូពេទ្យពីការប្រើប្រាស់ថ្នាំ ការជួយមើលថៃស្ត្រីមានផ្ទៃពោះ។

"ត្រៀមខ្លួនជប់លៀងទៅល្ងាចនេះ ខ្ញុំបានធ្វើជាប៉ាគេហើយ បងប្រុស"

គេទូរសព្ទទៅប្រាប់បងប្រុសដោយការសប្បាយចិត្ត។

(អបអរផង កាណែត ស្វម ជិតមានគ្នាលេងហើយ)

បងប្រុសធំជូនពរប្អូនប្រុសពៅតាមទូរសព្ទ ដោយមានភរិយាមកស្តាប់ក្បែរត្រចៀក។

"ខ្ញុំតេរទៅប្រាប់បង អាជ្រេ និងលោក អាហ្សា សិន លោក អាហ្សា ច្បាស់ជាសប្បាយចិត្ត មានចៅមកបន្តកន្ទុយគ្នាបែបនេះ លោក អាហ្សា លង់ស្លាប់ហើយ"

កាណែត ប្រាប់បងប្រុសធំ ហើយក៏តេរទៅបងប្រុសកណ្តាលនិងឪពុកភ្លាម ដោយដៃម្ខាងក្រសោបដៃរបស់ភរិយាជាប់ ភ្នែកក៏សម្លឹងមើលនាងមិនព្រិចហើយដូចការស្មាន លោក អាហ្សា សប្បាយចិត្តណាស់ គេបានឮគាត់ប្រាប់ តឹម បេ ដែលជាលេខាធិការឲ្យរកកាដូទទួលចៅថ្មី។

"អរគុណអូនសម្លាញ់ ដែលអូនធ្វើឲ្យបងមានសេចក្តីសុខបំផុត"

កាណែត បញ្ឆេះឡាន បន្ទាប់ពីនិយាយទូរសព្ទជាមួយបងប្រុសនិងឪពុករួច ប៉ុន្តែមិនទាន់បើកចេញទៅភ្លាមៗ ផ្អៀតងាកមកស្រវាទាញនាងទៅឱប ថើបថ្ពាស អូសមករកច្រមុះនិងបបូរមាត់ បញ្ចប់ដោយការលើកខ្នងដៃមកថើប បាញ់ខ្សែភ្នែកមុតស្រួច ដែលមានតំណក់ទឹកភ្នែកនៃការសប្បាយចិត្ត នៅក្នុងនោះមើលមក។

"អូនក៏សប្បាយចិត្ត ដែលកំពុងតែមានគេ គេកើតឡើងដោយក្តីស្រឡាញ់របស់យើងទាំងពីរ"

ស៊ុនស៊ូ ញញឹមទាំងទឹកភ្នែកដាក់ស្វាមីដោយការសប្បាយចិត្ត ចាប់ដៃរបស់គេមកដាក់លើពោះរាបស្មើរបស់ខ្លួន ដែលមិនប៉ុន្មានខែទៀត និងបានជួបកូនហើយ បន្ទាប់មក លោទៅថើបថ្ពាល់គ្រើម។

"អរគុណដែលស្រឡាញ់អូននិងកូនខ្លាំងដល់ថ្នាក់នេះ"

នាងនិយាយទាំងអឹមអៀនដាក់គេ និងលើកដៃជូតទឹកភ្នែកចេញពីថ្ពាល់។

"បងស្រឡាញ់អូន អូនសម្លាញ់ បងនឹងស្រឡាញ់ ការពារអូននិងកូនជារៀងរហូត"

កាណែត ប្រាប់ថាស្រឡាញ់ដោយមិនខ្មាសអៀន គេតែងតែប្រាប់ពាក្យនេះដល់នាងជារៀងរាល់ថ្ងៃ និងគ្រប់ពេលដែលមានឱកាស ដូចបងប្រុសទាំងពីរ ដែលចូលចិត្តបង្ហាញក្តីស្រឡាញ់ចំពោះប្រពន្ធគ្រប់ពេលវេលា បន្ទាប់មកគេក៏បើកឡានទៅការិយាល័យ ប្រកាសឲ្យបុគ្គលិកគ្រប់គ្នាបានដឹងឮរឿងដ៏គួរឲ្យរីករាយនេះ និងប្រាប់ឲ្យ សុងចូ នាំសង្សារទៅចូលរួមអបអរជាមួយក្រុមគ្រួសាររបស់គេនៅផ្ទះធំល្ងាចនេះ។





Scanned with CamScanner

...

កាណែត ដេកឱបភរិយាដោយទឹកមុខញញឹមនៃសេចក្ដីសុខ បាតដៃក៏អង្អែលពោះរាបស្មើរបស់នាងថ្នមៗ ខណៈដែល ស៊ុនស៊ូ លង់លក់ទៅហើយព្រោះហត់នឿយនឹងការជប់លៀងអបអរកាលពីល្ងាច ជាមួយក្រុមគ្រួសារធំ។

"កុំខូចដាក់ម៉ាក់ សាំម៉ី បើខូច ប៉ានឹងទះកំប៉េះគូទ"

គេឱនទៅខ្សឹបដាក់ពោះរបស់នាង និងថើបថ្នមៗហើយដេកឱបនាងវិញរហូតដល់ព្រឹក។

ច្រើនខែកន្លងផុតទៅ

"អេ...អេ...ហ៊ឹក!"

សំឡេងយំតិចៗរបស់កូនប្រុសដែលបន្លឺចេញពីបន្ទប់ដេកសម្រាប់ក្មេងធ្វើឲ្យ កាណែត ដែលកំពុងដេកឱបប្រពន្ធ ស្ទុះចុះពីគ្រែ ទាញកន្សែងពោះគោមករុំចង្កេះ ដើរទៅមើលកូនប្រុសថ្លោសទ្រលុកទ្រលន់ សម្បុរស កែវភ្នែកមូលក្លំដែលពេលនេះអាយុបានប្រាំបីខែហើយ កំពុងឈរតោងអគ្រឹងឈើ លើកជើងម្ខាងយោលយោក បបូរមាត់ក្រហម ពេបស្បែប យំអណ្ដឺតអណ្ដក ទឹកភ្នែករលីងរលោង ចិញ្ចើមក្រាស់ជ្រួញចូលគ្នា ប៉ុន្តែពេលឃើញឪពុកដើរមកឈរក្បែរក៏ឈប់យំ ព្រមទាំងទះអគ្រឹងហៅ និងញញឹមដាក់ទាំងទឹកភ្នែក ថែមទាំងលៀនអណ្ដាតតិចៗ ធ្វើភ្នែកព្រឹមៗដាក់ មើលទៅគួរឲ្យស្រឡាញ់ផង គួរឲ្យអាណិតផង



ធ្វើឲ្យ កាណែត អត់ញញឹមមិនបាន។

"ជើងល្អ"

"អេ...អេ..."

សាំម៉ី ងើយមុខធ្វើភ្នែកម៉ក់ៗ លើកជើងម្ខាងយោលដូចដំរី ហើយសើចកក្អិច ពេលត្រូវឪពុកលើកបី។

"យំធ្វើអី សាំម៉ី ឃ្លានឬ"

គេបីកូនដោយដៃម្ខាង ហើយដើរទៅបើកទូភ្លាស្សេទឹកដោះ យកមកដាក់កែវ ចាក់ទឹកក្ដៅចូលទាល់តែរលាយទឹកកក ទើបចាក់ដាក់ចូលដប ដោយមានអាល្អិត ស្រវេស្រវាដណ្ដើមយករហូត។

"ញ៉ាំច្រើនណាស់ មើលពោះចុះ ប៉ោងអស់ហើយ"

គេឱនថើបថ្ពាល់របស់កូនប្រុសខ្សឹតៗ ធ្វើឲ្យអាល្អិតសើចដោយការចូលចិត្តព្រោះរសើប ហើយដាក់ដបទឹកដោះគោឲ្យកូនបៅ។

សាំម៉ី បឺតទឹកដោះគោយកងាប់យករស់ ព្រមទាំងញញឹមមានសេចក្ដីសុខ ខណៈនោះ កាណែត ក៏ច្រកទឹកដោះគោចូលដបទីពីររង់ចាំ ព្រោះកូនប្រុសរបស់គេបៅច្រើនណាស់ មួយដបមិនឆ្អែតនោះទេ និងត្រូវតែមានដបទីពីរគ្រប់ពេលហើយពេលបានបឺតដបទីពីរភ្នែករបស់សាំម៉ីក៏ទន់ទើបគេទាញដបចេញពីមាត់របស់កូនយឺតៗហើយលើកកូនដាក់លើស្មា ទះខ្នងតិចៗ ឲ្យភើ ហើយពេលនោះ ប៉ះខោទឹកនោមឃើញទល់ ទើបដាក់កូនទៅលើតុសម្រាប់ប្ដូរខោទឹកនោម





Scanned with CamScanner

ដែលធ្វើឲ្យ សាំម៉ី ភ្ញាក់កន្ត្រាក់ តែមិនព្រមបើកភ្នែក។

កាណែត ញញឹម ពេលដេកលក់ កូនប្រុសរបស់គេស្លូតបូតណាស់ ទើបគេអាចប្ដូរខោទឹកនោមឲ្យកូនបានស្រួល ដោយមុនពេលស្លៀកខោទឹកនោមថ្មី គេត្រូវជូតសម្អាតខ្លួនប្រាណរបស់កូនដោយទឹកក្ដៅឧណ្ហៗ ហើយពេលជូតខ្លួនរួចរាល់ ក៏លាបម្សៅឲ្យ ទើបស្លៀកខោថ្មី បិកូនជាប់ទ្រូងម្ដងទៀត បំពេឲ្យលង់លក់ស្រួល ទើបយកទៅដាក់ក្នុងអង្រឹង ទាញភួយដណ្ដប់ឲ្យ រង់ចាំទាល់តែឃើញថាកូនដេកលក់ស្រួលនោះឯង ទើបដើរចូលមកក្នុងបន្ទប់ដេករបស់ខ្លួនដែលនៅជាប់គ្នា ផ្ដួលខ្លួនលើពូក ទាញប្រពន្ធឱប។

"អ្ហឹម...ទៅណា ?"

ស៊ិនស៊ី លើកដៃអង្អែលដើមទ្រូងរបស់ស្វាមី ប្រឹងបើកភ្នែកមើល ពេលត្រូវគេថើបបបូរមាត់ និងក្រឡាប់ខ្លួនឡើងមកទ្រោបពីលើ។

"សាំម៉ី ភ្ញាក់ ឃ្លាន ប្ដីបញ្ចុករួចរាល់ហើយ ដេកលក់ដល់ព្រឹកឯណោះ ពេលនេះប្ដីឃ្លានដែរ សុំញ៉ាំម្ដង"

កាណែត ខ្សឹបប្រាប់ដោយសំឡេងស្អកៗ និងឱនថើបមុខរបស់នាងថែមទាំងឱបរឹតនាងណែនដៃ ដើម្បីឲ្យដឹងថាគេក្ដៅប៉ុណ្ណានៅពេលនេះ។

"កាណែត ផ្ដេសផ្ដាសហើយ"

ស៊ិនស៊ី ក្ដៅមុខភាយៗ ពេលត្រូវស្វាមីគ្រប់គ្រងដើមទ្រូង បឺតជញ្ជក់ដូចទារក បាតដៃក៏ប្រចាច់រាងកាយ ឲ្យនាងថ្ងូចថ្ងូរ ក្ដាប់មាត់ជាប់ ទប់ភាពស្រៀវស្រើបដែលកើតឡើងនោះ ពត់ពេនរាងកាយដោយអារម្មណ៍រញ្ជួយ បន្ទាប់មកទើបគេជ្រែករាងកាយចូលមក ពេលដឹងថាអ្នកនៅក្រោមរាងកាយព្រមទទួលយកខ្លួនហើយ។

គេធ្វើសកម្មភាពយឺតៗ សន្សឹមៗ ដើម្បីឲ្យនាងសម្របខ្លួន ហើយនាំហោះហើរទៅរកអន្លង់ភ្លើងប្រាថ្នាក្ដៅគគុក ដែល ស៊ិនស៊ី ស្ទើរតែទ្រាំមិនបាន។ នាងឱបរឹតគេណែនដៃ ហើយដង្ហក់ខ្យល់ ពេលត្រូវគេក្រឡាស់ខ្លួនទៅនៅខាងក្រោម ដោយរាងកាយទាំងពីរនៅតែនៃបនិត្យគ្នា វាធ្វើឲ្យនាងញ័រខ្លួនទទ្រើត បន្ទាប់មកគេក៏ចាប់ចង្កេះតូចស្ដើង ឲ្យធ្វើសកម្មភាពយឺតៗ ឲ្យនាងតបស្នងចង្វាក់ស្នេហារបស់គេដោយភាពក្ដៅគគុក និងគួរឲ្យស្រឡាញ់ ដែលធ្វើឲ្យកាណែត ខាំធ្មេញក្រតៗ ងើបអង្គុយ ដោយនៅតែឱបក្រសោបនាងជាប់។

"អឺ..."

នាងគ្រលែងត្រគាកជាចង្វាក់តាមដែលស្វាមីបង្រៀន ភាពស្រៀវស្រើបលុកលុយរាងកាយ ធ្វើឲ្យនាងទ្រាំមិនបាន ឱបរឹតគេណែនដៃ និងសម្ងំនៅស្ងៀម ពេលរាងកាយកន្ត្រាក់ ដែល កាណែត តាមមកជាប់ប្រកិត។

គេឱបក្រសោបភរិយា ថើបជញ្ជក់បបូរមាត់ក្រពុំ បាតដៃក៏ស្ទាបអង្អែលលួងលោម ដើម្បីឲ្យនាងធូរស្រាលអារម្មណ៍។

"បងស្រឡាញ់អូន ស៊ិនស៊ី"



គេដកបបូរមាត់ចេញ លើកដៃវាសសក់ចេញពីមុខរបស់នាងថ្នមៗ និង



Scanned with CamScanner

ប្រាប់ថាស្រឡាញ់ដោយសំឡេងស្អកៗ កែវភ្នែកមានពន្លឺញញ័រទ្រេីត ដែលធ្វើឲ្យ ស៊ុនស៊ី មិនហ៊ានប្រសព្វភ្នែកជាមួយ។

"អូនក៏ស្រឡាញ់បង កាណែត"

នាងប្រាប់ថាស្រឡាញ់ដោយសំឡេងញ័រ ទើបត្រូវគេឱនមកថើបមាត់ និងផ្ដួលទៅលើគ្រែ គ្រតាកចាវសាក់ក៏គ្រលែងម្ដងទៀត ដែលម្ដងនេះព្រៃផ្សៃ ធ្វើឲ្យនាងសឹងតែឆេះទៅហើយ ហើយទម្រាំវារលត់ នាងក៏អស់កម្លាំង លង់លក់ស្របពេលដែលស្វាមី ផ្ដួលខ្លួនមកឱបរឹតរាងកាយតូចច្រឡឹង ហើយខ្សឹបប្រាប់ថាស្រឡាញ់ មុនពេលគេដេកលក់។

"បងស្រឡាញ់អូន ស៊ុនស៊ី"

ច្រើនឆ្នាំកន្លងផុតទៅ...

"ទើមកពីណាពីរនាក់ប៉ាកូន"

ស៊ុនស៊ី អង្គុយចាំនៅការិយាល័យ បន្ទាប់ពីឲ្យ ជេមីន ជូនមកទីនេះ ប៉ុន្តែបែរជាមិនជួបពីរនាក់ឪពុកកូន ដោយ សុងចូ មិនប្រាប់ទេថាទៅណា ប្រាប់ថាបន្តិចទៀតនឹងមកដល់។

"អុ! ម៉ាក់មក ប៉ា"

សាំម៉ី លើកដៃបិទមាត់ក្រហមរបស់គេ ងាកទៅប្រាប់ឪពុក ដែលដើរតាមក្រោយ ដោយសំឡេងខ្សឹបៗ។ ពេលនេះ សាំម៉ី មានអាយុជិតបួនឆ្នាំហើយ ប្រហាក់ប្រហែលនឹងឈ្មោះ ការីន កាវ៉ាន់ ជិតបួនឆ្នាំហើយ ប្អូនកូនឈ្មោះ ការីន កាវ៉ាន់ បួនប្រាំខែប៉ុណ្ណោះ និងមានអាយុតិចជាង សួម ជិតមួយឆ្នាំ។ ពេលនេះ អាល្អិតបង្ហាញឲ្យឃើញពីភាពសង្ហាមាំដូចឪពុក សក់ក្រាស់ខ្មៅព្រលាំឡោតតិចៗ ចិញ្ចើមក្រាស់ស្អាត ភ្នែកមូលភ្លុំពណ៌ត្នោត លំអដោយរោមភ្នែកវែងដូចផ្លិត ស្អាតដូចរោមភ្នែករបស់ម្ដាយ ច្រមុះស្រួចសមនឹងបបូរស្ដើងរហៀវ ក្រហមព្រឿងៗ ថ្ពាល់គ្រហាញៗ ដែលពេលនេះឡើងក្រហមដូចផ្លែប៉េងប៉ោះ ព្រោះរត់លេងហាលថ្ងៃ។

"មានអីឬ?"

ពេលឃើញអាកប្បកិរិយាកូនប្រុសហើយ នាងក៏ធ្វើជាស្ដីឲ្យ ដោយងៀងមើលស្វាមី ដែលញញឹមក្របួចមាត់ នៅក្រោយខ្នងកូនប្រុស។

"គ្មានអីទេម៉ាក់"

"កុហកម៉ាក់មែនទេ បើម៉ាក់ឃើញរបស់លេងនៅក្នុងឡានរបស់ប៉ា ម៉ាក់និងយកទៅឲ្យអ្នកដទៃ"

"ប្រាប់ក៏បាន"

សាំម៉ី ធ្វើមុខខ្ទួរ ដើរទៅរកម្ដាយភ្លាម លោតឡើងលើសាឡុង ចាប់ស្មារបស់ម្ដាយ លោទៅថើបថ្ពាល់ជាការយកចិត្ត។

"មិនបាច់មកម៉្មិកម៉្មក់ដាក់ម៉ាក់ទេ ទើបមកពីណាជាមួយប៉ា ប្រាប់ម៉ាក់ភ្លាម"



"ទៅផ្សារ ហើយទិញរបស់លេង យកមកចែកគ្នាលេងជាមួយពូ ស្ទួម បង ការ៉ែន បង ការ៉ាន់ និង ស្ទូ ម៉ាក់កុំស្តីឲ្យ ខ្ញុំឆ្លឹះកូនជ្រូកយកមកជួយផ្សំនឹងលុយប៉ាដល់ទៅមួយពាន់ ប៉ាប្រាប់ឲ្យជួយចេញ តែខ្ញុំមានតែប៉ុណ្ណឹង"

អាល្អិតធ្វើមុខខ្ទេវៗ យកបងប្អូនមកធ្វើជាលេស ហើយប្រាប់ដោយមានមោទនភាពពីរឿងលុយក្នុងកូនជ្រូក ដែលឆ្លឹះបានសុទ្ធតែកាក់យកមកជួយផ្សំនឹងលុយឪពុក ទិញរបស់លេងបានដល់ទៅមួយពាន់រៀល។

"ហ៊ឺៗ ដល់ទៅមួយពាន់ ហើយប៉ាចេញប៉ុន្មាន ហ៊ឹម"

នាងឱបកូនប្រុស ថើបថ្ពាល់ខ្សឹតៗ ហើយអង្អែលថ្ពាល់របស់គេថ្នមៗ។

"មិនច្រើនទេ យកមកចែកគ្នាលេង ស្អែកនេះមានជប់លៀងឲ្យលោកតាអបអរខួបកំណើតមនុស្សមិនព្រមចាស់ ទើបនាំទៅទិញកាដូ និងរបស់លេងឲ្យពូជាស្អែកនេះ ណាត់ហែលទឹកនៅអាង"

កាណែតដើរមកអង្គុយក្បែរភរិយា និងលើកកូនប្រុសពីដៃភរិយាមកដាក់លើភ្លៅរបស់ខ្លួន ដោយមិនភ្លេចថើបថ្ពាល់នាងមួយខ្សឹត។

"ខឹកៗ ប៉ាចង់ថើបថ្ពាល់ម៉ាក់មែនទេ ខ្ញុំឃើញ"

សាំម៉ី លើកដៃបិទមាត់សើចកក្អិចដោយការចូលចិត្ត ពេលឃើញឪពុកថើបថ្ពាល់ម្តាយ។

"អ្នកណាថើបមុន ហ៊ឹម!"

"ខ្ញុំថើបមុន"

អាល្អិតលើកដៃបញ្ជាក់ ព្រោះគេនិងឪពុកតែងតែដណ្តើមគ្នាថើបថ្ពាល់អ្នកម្តាយ។

"ពីរនាក់នេះ កាលពីម្សិលម៉្ងៃទៅរើសនៅកសិដ្ឋានសេះ អ៊ំ អាជ្រេ ក៏ទិញសេះក្រិនមកថែមទៀត ពេលនេះសង្ស័យបានបង្កាត់ពូជសេះក្រិនជំនួសសេះប្រណាំងហើយ"

"អ៊ំ អាជ្រេ ប្រាប់ថាទិញឲ្យប្អូនៗដែរ ចាំប្អូនកើត ខ្ញុំនឹងនាំប្អូនទៅជិះសេះលេង"

អាល្អិតរៀបរាប់ដោយទឹកមុខប្រាកដប្រជា ហើយឱនទៅថើបពោះខ្លាតធំរបស់ម្តាយ។

"ហ៊ឺៗ រង់ចាំឲ្យប្អូនកើតសិនទៅ ហើយចាំនាំប្អូនទៅជិះសេះ"

"បាទ ឲ្យដូច ស្ទូ ខ្ញុំចង់មានប្អូនស្រី ឲ្យ ស្ទូ មានគ្នាលេង"

"ប្រាកដហើយ ជានាថា សាំម៉ី នឹងបានជួយប៉ាហ្លួងហែងប្អូន"

កាណែត មិចភ្នែកដាក់កូនប្រុសដែលកំពុងធ្វើមាត់ស្រួច។

"ខ្ញុំមានប្អូនស្រីមែនទេប៉ា យេៗ សប្បាយចិត្តបំផុត យេៗ"

ស្ទួម លោតចុះពីភ្លៅឪពុក ទៅលោតកញ្ឆេងដោយការសប្បាយចិត្ត ហើយរត់ចេញពីបន្ទប់ធ្វើការ ទៅប្រាប់ សុងចូ បន្ទាប់មកក៏ដឹកដៃ សុងចូ ទៅប្រាប់អ្នកនៅក្រោមអហ្នឹស។

"បងនេះល្បិចមែន ប្រាប់កូនពេលនេះឲ្យកូនចេញពីបន្ទប់មែនទេ"





Scanned with CamScanner

នាងគក់ទ្រូងស្វាមីមួយដៃ រឿងល្បិចកលនេះត្រូវប្រគល់ឲ្យគេ ពូកែល្បួងកូនណាស់ ចំណែក សាំមុី ក៏ពូកែចាំណាស់ដែរ ទើបត្រូវរកវិធីទប់ទល់ថ្មីៗរហូតតែសំណាងល្អដែលកូនស្តាប់បង្គាប់និងធ្វើតាម ឆ្លាតក្នុងការគិត ពូកែក្នុងការនិយាយ។

"មិនប្រាប់ តិចមានងរង៉ក់ មានយំទៀតបើដឹងនៅពេលក្រោយ ម៉េចក៏មិនព្រមប្រាប់ឲ្យដឹងមុន មិនដឹងថាប៉ិនងរដូចអ្នកណា ថ្ងៃមុននៅចាំបានងរដែលមិនឲ្យចូលមកដេកជាមួយ អូសភួយមកឈរយំនៅមុខបន្ទប់ឡើងយូរ ស្មានថាខ្មោចក្មេងឯណាមកឈរយំខ្សឹកខ្សួលនៅមុខបន្ទប់តើ"

"នេះបងថាឲ្យកូន ចូលចិត្តធ្វើបាបកូន"

នាងចាំបាន កាណែត ធ្វើបាបកូនដោយដាក់ទោស ព្រោះធ្វើឲ្យ ស្នូ ដួលដោយផ្អាកមកដេកជាមួយ ព្រោះនោះជាថ្ងៃដែលត្រូវអនុញ្ញាតឲ្យដេកជាមួយតែម្តងនោះ សាំមុី មិនព្រម អូសភួយមកឈរយំខ្សឹកខ្សួលនៅមុខបន្ទប់ ធ្វើឲ្យឪពុកអស់សំណើច ទាល់តែត្រូវនាងងរងក់ដាក់ ទើបគេព្រមបើកទ្វារឲ្យកូនមកដេកជាមួយ ហើយបួននាក់ឪពុកម្តាយកូនក៏ដេកឱបគ្នាមានសេចក្តីសុខនៅលើគ្រែដ៏កក់ក្តៅ។

"តែប្តីស្រឡាញ់ប្រពន្ធកូនបំផុត"

"ចាំ អូនជឿ ហើយអូនស្រឡាញ់បងបំផុតដែរ"

នាងលើកដៃអង្អែលថ្ពាល់គ្រើមថ្មមៗ មើលគេដោយខ្សែភ្នែកស្រទន់ហើយលោទៅថើបផញ្ចក់បបូរមាត់ក្តៅ និងត្រូវគេថើបវិញ មិនឲ្យខាត និងមើលនាងវិញដោយខ្សែភ្នែកកក់ក្តៅ។ គេញញឹមពព្រាយ ដែលធ្វើឲ្យនាងព្រិលភ្នែកនឹងភាពសង្ហា និងភាពផ្អែមល្ហែមរបស់ស្វាមីដែលយូរៗទៅកាន់តែកើនឡើង។

"បងនឹងមើលថែអូនមួយជីវិតរបស់បង ស៊ុនស៊ូ ប្រពន្ធទីជាស្រឡាញ់របស់ប្តី"

នាងក្រមុំរលីងរលោងទឹកភ្នែកនឹងសម្តីរបស់គេ ក្រសោបមុខសង្ហា ថើបម្តងទៀត តបស្នងដែលគេស្រឡាញ់នាងមិនដែលប្រែប្រួល និងធ្វើខ្លួនជាស្វាមីល្អ ឪពុកល្អ ការពារនាងនិងកូនពីគ្រោះថ្នាក់។ នាងផ្ញើជីវិតក្នុងបាតដៃរបស់គេឲ្យគេមើលថែជារៀងរហូត និងស្រឡាញ់គេជារៀងរាល់ថ្ងៃមិនប្រែប្រួលដូចគ្នា។





Scanned with CamScanner

# សុភមង្គលស្នេហ៍

ពិធីចម្រើនជន្មាយុរបស់លោក អាហ្យា ប្រព្រឹត្តទៅយ៉ាងរីករាយ នៅកសិដ្ឋាន ដោយធ្វើជាកម្មវិធីធំ ឲ្យកម្មករទូទាំងចម្ការចូលរួមទទួលទានអាហារ មានតន្ត្រីប្រគុំ មានអ្នកចម្រៀងអម ឲ្យរាំលេងកម្សាន្ត មានទាំងអំណោយចែកឲ្យក្មេងៗ កូនរបស់បុគ្គលិក កម្មករ ហើយកម្មវិធីក៏បញ្ចប់នាពេលថ្ងៃត្រង់។

បន្ទាប់ពីចប់កម្មវិធីធំហើយ ក្រុមគ្រួសារ ឈើរ៉សទិ ក៏រៀបចំពិធីតូចតាចជាលក្ខណៈគ្រួសារនៅមាត់អាងទឹកក្នុងផ្ទះធំ ហើយពេលនេះនៅក្នុងអាងមានសុទ្ធតែរបស់លេងរបស់ក្មេងៗ និងសំឡេងសើចសប្បាយរបស់កំលោះតូចក្រមុំតូច ឈើរ៉សទិ ដែលកំពុងស្ថិតក្នុងវ័យលូតលាស់។

"បង ការីន បង ការ៉ាន់ ពូ ស្នួម ម៉ោះហែលទឹកប្រណាំងគ្នា"

សាំម៉ី ចាប់ក្តារសម្រាប់ហែលទឹកជាប់ដើមទ្រូង ខ្លួនទទឹកស្រកក់ ដូចគ្រប់គ្នាដែរ ស្រែកប្រាប់គ្រប់គ្នា ទើបកូនភ្លោះរបស់ អាជ្រេ រត់ចុះទឹកមុនគេតាមដោយ ស្នួម ដែលធំជាង ហើយពេលពេលគ្រប់ក្រុមហើយ ក៏នាំគ្នាលេងយ៉ាងរីករាយ មានតែសំណើចក្អាកក្អាយ ហែលទឹកប្រណាំងគ្នាជាច្រើនត្រឡប់ចំណែក ស្នូ នៅក្នុងពោង ពាក់មួកហាមធំការពារកម្ដៅថ្ងៃ មានអ្នកម្ដាយជួយចាប់ ឲ្យកូនស្រីបានដើរលេង និងស្រែកគ្រិតមានសេចក្ដីសុខតាមបងៗ សើចទាល់តែថ្ពាល់ក្រហមគួរឲ្យក្ដិចគួរឲ្យខ្ញាំអស់ទៅហើយ។

យ៉ារីម ក៏លេងទឹកជាមួយក្មួយស្រី បន្ទាប់ពីស្វាមីជូនចុះអាងទឹក ព្រោះពេលនេះនាងផ្ទៃពោះដូច ស៊ិនស៊ូ ដែរ អាយុគភ៌ស្រករគ្នា តែ ស៊ិនស៊ូ ដឹងភេទកូនហើយ។

"ក្មេងៗ យកកាដូអីជូនលោក អាហ្យា?"

អេដែន សួរឪពុក ព្រោះកូនប្រុសរបស់គេ និងក្មួយៗ នាំគ្នាលាក់ មិនព្រមប្រាប់ថាជូនអ្វីដល់លោកតា។

"ស្នួម ឲ្យកន្សែងបង់ក ប្រាប់ថាខ្លាចលោកតារងា កូនភ្លោះ ការីន ការ៉ាន់ ឲ្យអាវម្នាក់មួយ ចំណែក សាំម៉ី ឬ យកកូនជ្រូកសន្សំលុយរូបជ្រូកមកឲ្យ ប្រាប់ថា ឲ្យលោកតាដាក់លុយឲ្យច្រើនៗ ពេញហើយ នឹងយកទៅផ្ញើនៅធនាគារឲ្យមើលវាចុះ ជើងល្អប៉ុណ្ណា តម្រិះដូចឪវាកាលនៅតូចៗ យ៉ាងអីចឹង ហាសហា"

លោក អាហ្យា មានមោទនភាព ទោះជាកាដូ ដែលចៅៗទិញឲ្យ មានតម្លៃតិចតួច តែដឹងថាប្រាក់ទាំងនោះចៅៗ ប្រឹងសន្សំ។ លោកមានមោទនភាពដែលកូនប្រុសអប់រំកូនបានល្អ ឯកូនប្រសាស្រីទាំងបីក៏គួរឲ្យស្រឡាញ់ មើលថែកូនៗឲ្យក្លាយជាកូនល្អ ក្មេងល្អ អាចមានរពិស មានខូចខ្លះតាមវ័យរបស់ក្មេង តែមិនបណ្ដោយឲ្យទំនើង មិនទំយើ មិនទម្រើសហួសហេតុ មានស្ដីឲ្យខ្លះដែរពេលធ្វើខុស។





Scanned with CamScanner

"អូ! ប៉ា គឺ សាំមុី ប្រាប់ថាចូលចិត្តអានេះ ចង់ជូនអានេះដល់ប៉ា ទើបត្រូវតាមចិត្តហ្នឹងណា៎"

កាណែត និយាយដោយទឹកមុខញញឹម។ នៅចាំបានថា កាលពីម្សិលកូនប្រុសឲ្យជូនទៅទិញកាដូសម្រាប់ជូនលោកតា ព្រោះដេកទ្រមក់ មិនព្រមចុះពីគ្រែ បន្ទាប់ពីបានមកដេកឱបម៉ាក់និងប្អូន ងរង៉ក់ទាល់តែគេប្រាប់ឲ្យ អាជ្រៃនាំក្មេងៗ ទៅមុន ចាំគេនាំកូនប្រុសទៅតាមក្រោយ តែមិនបានប្រាប់ភរិយាថានាំទៅ ប្រាប់ត្រឹមថានាំទៅចម្ការប៉ុណ្ណោះ ទើបនាងឲ្យ ជេមីន ជូនទៅចម្ការតែនោះឯង ទើបដឹងថាពីរនាក់ឪពុកកូនលួចទៅទិញកាដូ និងរបស់លេង តែទៅមិនទាន់ អាជ្រៃ និងក្មួយៗ ព្រោះនាំគ្នាមកផ្ទះវិញទៅហើយ ជ្រួលគ្នាបន្តិច។

"មែនៗ ក្មេងៗ គេមានការតាំងចិត្តរបស់គេ កូនភ្លោះទាំងពីរក៏ដណ្ដើមគ្នាទិញអាវ ដណ្ដើមពណ៌គ្នា វ៉ៃតែបែកហាងទៅហើយ ស្ទម នេះឈរហ៊ោ ទើបខ្ញុំប្រាប់ថាទិញម្នាក់មួយពណ៌ជូនលោកតា ទើបឈប់ដណ្ដើមគ្នា ប៉ាមិនឃើញពេលដណ្ដើមគ្នាទេ ខ្ញុំនេះអត់សើចមិនបាន ចំណែក ស្ទម និយាយចេះស្ដាប់គ្នាទើបមិនដណ្ដើម មិនអឺចឹង ឈឺក្បាលវិញមុខបណ្ដោយ"

អាជ្រៃ និយាយបណ្ដើរ សើចបណ្ដើរ ព្រោះជាអ្នកនាំ ស្ទម និងកូនភ្លោះរបស់ខ្លួនដើរទិញកាដូ ដោយសារបងប្រុសយកកូនប្រុសច្បងមកផ្ញើ ចំណែកខ្លួនឯងនាំប្រពន្ធ និងកូនស្រីទៅផ្អែមល្ហែមនៅចម្ការក្រូច។ កាលនោះគេនឹកចង់តែចាប់កូនប្រុស ដែលដណ្ដើមគ្នាទិញអាវជូនលោកតា និងក្មួយប្រុសដែលជួយស្រែកហ៊ោ ទះកំប៉េះគូទទេ ដែលមិនចេះសាមគ្គីគ្នា ទើបត្រូវហៅទៅអប់រំនៅកៀនហាង និងមានការព្រមព្រៀងគ្នា ដោយទិញអាវម្នាក់មួយ ពណ៌ខុសគ្នាបន្ទាប់ក៏នាំទៅញ៉ាំអាយស្ក្រីម។

"ហុឺៗ ខូចគ្រប់គ្នា សង្ស័យត្រៀមរំពាត់ធំៗ ទុកសម្លុតហើយ"

អេដែន ញញឹម និងសើចតាម។ កូនប្រុសច្បងរបស់គេក៏ខូចណាស់ មិនចូលរួមដណ្ដើម តែចាំហ៊ោ គួរឲ្យទះគូទណាស់បែបហ្នឹង ជាបងធំមិនជួយហាមបែរជាជួយហ៊ោ គិតហើយឈឺក្បាល និងនឹកដល់អតីត កាលគេនិងប្អូនៗ នៅតូច ទៅណាមកណាជាមួយគ្នា ប្រជុំក្បាលគ្នាធ្វើនេះធ្វើនោះ ធ្វើរឿងខូចខិលជាមួយគ្នា។

"ប៉ាចូលចិត្តទាំងអស់ ប៉ានឹងប្រើរបស់ទាំងអស់ដែលចៅៗ ឲ្យ"

លោក អាហ្សា ទទួលទានអាហារជាមួយកូនចៅយ៉ាងរីករាយ។ បានប៉ុណ្ណឹងហើយ លោកមិនត្រូវការអ្វីទៀតទេ សុំត្រឹមបានឃើញចៅៗ ធំធាត់ជាបន្តបន្ទាប់ និងអស់បារម្ភហើយពេលនេះ ព្រោះបានទម្លាក់ការងារមុខជំនួញឲ្យកូនៗ អស់ហើយ សព្វថ្ងៃនេះលោករវល់តែលេងជាមួយចៅៗ ប៉ុណ្ណោះ។

កាណែត ដើរទៅឱបភរិយាដោយការព្រួយបារម្ភ ខ្លាចនាងរអិល ព្រោះកំពុងដើរចុះអាងក្មេង ដើម្បីទៅរក ស៊ីអា និង យ៉ារីម ដែលលេងជាមួយ ស្ទ។



"ប្រយ័ត្នរអិល ចាំជូនទៅ"

"ចាំ"



Scanned with CamScanner

ស៊ុនស៊ូ តោងដៃស្វាមីជាប់ ដើរចុះអាងយឺតៗ ហើយដាក់បង្គុយចុះ។ នាងមិនបានពាក់ឈុតហែលទឹក ស្លៀកតែខោខ្លីចង្កេះកៅស៊ូ និងពាក់អាវយឺតពណ៌ស ធំស៊ុលគយុលរបស់ស្វាមីប៉ុណ្ណោះ។

"ពេលឡើងម៉ោវិញ ត្រូវហៅ កុំឡើងដោយខ្លួនឯង"

"ចាំ"

ស៊ុនស៊ូ ងក់ក្បាលទទួលបញ្ជា ដោយមិនធុញទ្រាន់ ព្រោះដឹងថាគេបារម្ភ។ ពេលមានផ្ទៃពោះ សាំមុី គេក៏ចាញ់ជំនួស មកដល់ពោះកូនម្នាក់នេះ គេក៏ចាញ់ជំនួសទៀត តែមិនខ្លាំងដូចកូនដំបូង ដែលគេប្រាប់ថាព្រមចាញ់ជំនួស ដើម្បីកុំឲ្យប្រពន្ធលំបាក ដែលធ្វើឲ្យនាងស្រឡាញ់គេកាន់តែខ្លាំង។

ពេលប្រាប់រួច កាណែត ក៏ឱនថើបថ្ពាសរបស់ភរិយា ហើយដើរទៅរួមវង់ជាមួយឪពុក និងបងប្រុសទាំងពីរ អង្គុយជិបបៀរត្រជាក់ៗ មើលក្រមុំៗ និងក្មេងៗ លេងទឹកយ៉ាងមានសេចក្ដីសុខ៕

( ចប់ )